ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ចុងដៃជាង ឬ ចុងខេត្រោះ?
- សារជាតិនៃសេចក្តីព្រាងច្បាប់ខ្មែរក្រហម

[illegible]

លេខ១៣ ខែមករា ឆ្នាំ២០០១

- ទំព័រពិសេស : សភាជាតិអនុម័តសេចក្តីព្រាងច្បាប់ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម

# ស្វែងរកការពិត

លេខ១៣ ខែមករា ឆ្នាំ២០០១

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ សំបុត្រៈ ដើម្បីការចងចាំនិងយុត្តិធម៌..................................១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាពរបស់ ប៉ាន់ ស៊ីម ហៅ ស៊ែល.......................៤

◆ រណ្តៅសាកសពប្រល័យពូជសាសន៍នៅខេត្តបាត់ដំបង................៧

◆ ឯកសាររណសិរ្ស.........................................................៩

◆ លក្ខន្តិកៈបណ្តោះអាសន្ននៃសម្ព័ន្ធយុវជនកុម្មុយនិស្តកម្ពុជា.........១០

◆ ឯកសារសមមិត្ត ពីន....................................................១៤

◆ ច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម....................................១៦

◆ ជនជាតិចាមក្រោមរបបកម្ពុជាប្រជាធិបតេយ្យ.......................១៧

**ផ្នែកប្រវត្តិសាស្ត្រ និង ការស្រាវជ្រាវ**

◆ សម្លេងពីមន្ទីរស-២១.................................................២៤

◆ ជនដៃដល់ ឬ ជនរងគ្រោះ?.........................................២៨

◆ វង្វាស់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ............................៣២

**ផ្នែកច្បាប់**

◆ គំរូមួយនៃភ័ស្តុតាងឯកសារភ្ជាប់មេដឹកនាំជាន់ខ្ពស់...................៣៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ការសងសឹកមកពីជំនាន់ ប៉ុល ពត.................................៤០

◆ ការលើកលែងទោស....................................................៤៥

◆ សារជាតិនៃសេចក្តីព្រាងច្បាប់ខ្មែរក្រហម...........................៤៨

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ សៀវភៅកំណត់ហេតុជីវិត............................................ ៥៩

**ទំព័រពិសេស**

◆ សភាជាតិអនុម័តសេចក្តីព្រាងច្បាប់កាត់ទោស...................... ៦១

**ក្របក្រោយ**

◆ អំពីរូបថត......................................................................

◆ ទស្សនាវដ្តី ស្វែងរកការពិត ឆ្នាំ២០០០.................... ក្របក្រោ




ប៉ុល ពត



តាម៉ុក

# រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា


អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**វាគ្មិនលេខនេះ:** ដេវីត ឆេនដល័រ ស៊ីវ ហេឌ័រ អាឡិច ហ៊ីនតុន គ្រេក អេចឆេសាន់ យ៉ន វ៉ាន់ គ្រីនធិន អៀ ម៉េងទ្រី ទូច បូរ៉ា អ៊ីសា ឧស្មាន **អ្នកនិពន្ធនិងស្រាវជ្រាវ:** សាន់ កល្យាណ លី សុផល ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយក:** អែម សុខឃីម **និពន្ធនាយករងទី១:** ដាត កុសល **និពន្ធនាយករងទី២:** សឹម សុរិយ៉ា **អ្នកបកប្រែ:** សួ ប៊ុនស៊ួ **និពន្ធនាយកទូទៅ:** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ:** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយ:** ទ្រី សុភក្តិ

**សំបុត្រៈ**

# ដើម្បីការចងចាំនិងយុត្តិធម៌

មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលបំណងចម្បងពីរយ៉ាង ។ គោលបំណងទី១គឺចងក្រងនិងថែរក្សាប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមសម្រាប់ការសិក្សានិងអប់រំមនុស្សជំនាន់ក្រោយៗ ។ គោលបំណងទី២គឺប្រមែប្រមូលឯកសារសម្រាប់បម្រើឲ្យផ្នែកច្បាប់ ដើម្បីជាជំនួយដល់ប្រជាជនកម្ពុជាទាំងឡាយណាដែលមានបំណងស្វែងរកការទទួលខុសត្រូវចំពោះមុខច្បាប់ស្តីពីបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយមេដឹកនាំខ្មែរក្រហម ។ គោលគំនិតទាំងពីរនេះ (ការចងចាំនិងយុត្តិធម៌) ជួយបង្កើតនូវមូលដ្ឋានគ្រឹះសម្រាប់វិធាននៃច្បាប់ និងការបង្រួបបង្រួមជាតិពិតប្រាកដ ។ មិនតែប៉ុណ្ណោះសោត គម្រោងសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងធ្វើការវិភាគឯកសារដើមដែលត្រូវបានប្រមែប្រមូលតាមរយៈមធ្យោបាយផ្សេងៗ ដើម្បីអាចឲ្យយល់បានថាតើឯកសារទាំងនេះមានភាពស៊ីសង្វាក់គ្នាជាមួយនឹងរឿងរ៉ាវប្រវត្តិសាស្ត្រក្នុងជំនាន់ខ្មែរក្រហមដល់កម្រិតណា ។

តាំងពីឆ្នាំ១៩៩៥រហូតមកដល់ឆ្នាំ២០០០ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការចុះបញ្ជីរៀបចំឯកសារក្នុងប្រព័ន្ធកុំព្យូទ័របានប្រមាណមួយសែនប្រាំម៉ឺន និងរូបថតជាងប្រាំមួយពាន់សន្លឹក ។ កិច្ចខិតខំប្រឹងប្រែងយ៉ាងសស្រាក់សស្រាំនេះគ្រាន់តែជាកិច្ចការស៊ើៗមិនទាន់ស៊ីជម្រៅប៉ុន្មាននៅឡើយទេ ។ បណ្ណសារដ៏ច្រើនសន្លឹកសន្ធាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាមិនទាន់ត្រូវបានធ្វើការចុះបញ្ជីរៀបចំរួចរាល់នៅឡើយទេ រួមមានរូបថតជាងបីម៉ឺនសន្លឹកនិងឯកសារជាងបួនសែនទៀត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងរៀបចំការងារនេះសម្រាប់ផែនការប្រាំឆ្នាំបន្តទៅមុខ ។

ដើម្បីជាការគាំទ្រដល់គោលបំណងទី២ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែធ្វើការចុះបញ្ជីរៀបចំឯកសារបញ្ចូលទៅក្នុងទិន្នន័យតាមប្រព័ន្ធកុំព្យូទ័រដើម្បីបង្កើតជាអត្ថបទបំភ្លឺបន្ថែមទៅលើមាតិកានៃបណ្ណសារ ។ តាមរយៈដំណើរការនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាដោយមានកិច្ចសហការជាមួយនឹងដៃគូរបស់ខ្លួនបានប្រមូលព័ត៌មានយ៉ាងក្រាស់ក្រែលសម្រាប់ទិន្នន័យគន្ថនិទ្ទេសប្រវត្តិរូប រូបថត និងទិន្នន័យភូមិសាស្ត្រ ទាក់ទងទៅនឹងការរំលោភរបស់ខ្មែរក្រហម ។ កិច្ចការនេះនឹងផ្តល់ដល់អ្នកច្បាប់និងអ្នកស៊ើបអង្កេតជាន់ខ្ពស់ (ក្រៅពីអ្នកសិក្សាស្រាវជ្រាវ និងប្រវត្តិវិទូ) នូវឧបករណ៍ដ៏មានតម្លៃដើម្បីយល់ឲ្យបានច្បាស់ថាតើអ្នកណាធ្វើអ្វីខ្លះចំពោះអ្នកណា នៅពេលណា និងដោយមូលហេតុអ្វី ។ មិនតែប៉ុណ្ណោះទៀតសោតកិច្ចការនេះអាចធ្វើឲ្យប្រជាជនកម្ពុជាយល់ដឹងអំពីប្រវត្តិសាស្ត្រនៃប្រទេសខ្លួនឯងជាមួយនឹងគំនិតជឿជាក់និងយល់ស្របដោយឯករាជ្យទៀតផង ។ ដោយផ្អែកជាគោលការណ៍ទៅលើការពិនិត្យរបស់ខ្លួន កាលពីខែកុម្ភៈ ឆ្នាំ១៩៩៩ ក្រុមអ្នកជំនាញការច្បាប់អន្តរជាតិបានរកឃើញការទទួលខុសត្រូវចំពោះមុខច្បាប់ប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមស្តីពីអំពើឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងៗទៀត គ្រាន់តែតាមរយៈការពិនិត្យដ៏តូចមួយរបស់ខ្លួនទៅលើឯកសារចងក្រងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថានឹងជាប្រភពដ៏សំខាន់មួយសម្រាប់ផ្តល់ជាឯកសារភស្តុតាងដល់តុលាការគ្រប់ប្រភេទដែលអាចនឹងត្រូវបានរៀបចំឡើង ។ ព្រះរាជអាជ្ញានិងក្រុមប្រឹក្សាការពារក្តីដែលពាក់ព័ន្ធក្នុងរឿងក្តីមេដឹកនាំយោធាខ្មែរក្រហមឈ្មោះ តាម៉ុក និងប្រធានគុកទួលស្លែង (មន្ទីរស-២១) ឈ្មោះ ឌុច បានស្នើសុំរួចមកហើយនូវជំនួយការដ៏ពេញលេញពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ការសម្រេចនូវគោលបំណងទាំងពីរ (ការចងចាំនិងយុត្តិធម៌) នឹងជួយបង្កើតឡើងនូវមូលដ្ឋានគ្រឹះសម្រាប់វិធាននៃច្បាប់និងការបង្រួបបង្រួមជាតិនៅក្នុងប្រទេសកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគំនិតចង់សម្រេចគោលដៅនេះឲ្យបានតាមវិធីជា

ច្រើនដូចជា÷ ទី១ បន្តហើយបន្ថែមល្បឿនការចុះបញ្ជីរៀបចំឯកសារដើមទាក់ទងនឹងរបបខ្មែរក្រហម ។ ទី២ ពង្រីកទំហំនៃការវិភាគទៅលើឯកសារដោយផ្តោតសំខាន់ទៅលើប្រធានបទជាច្រើនពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះមុខច្បាប់និងការស្វែងរកការពិត ។ ទី៣ នៅក្នុងគន្លងប្រាំឆ្នាំទៅមុខទៀត មជ្ឈមណ្ឌលឯកសារកម្ពុជានឹងពង្រីកទិន្នន័យតាមប្រព័ន្ធកុំព្យូទ័រលើអ្វីដែលបានប្រមែប្រមូលក្នុងអំឡុងប្រាំមួយឆ្នាំដំបូង ។

ទន្ទឹមនឹងការចងក្រងឯកសារ មជ្ឈមណ្ឌលឯកសារកម្ពុជាមានការសិក្សាទៅលើប្រវត្តិសាស្ត្រជាច្រើនដែលប្រធានបទសិក្សារួមមានៈ ការសិក្សាទៅលើភូមិភាគបស្ចិម ភូមិភាគពាយ័ព្យ ភូមិភាគឦសាន ជនជាតិភាគតិច បញ្ហាស្ត្រីនិងព្រះសង្ឃក្រោមរបបខ្មែរក្រហម ។ ប្រធានបទលើសពីនេះទៀតដែលកំពុងតែដំណើរការទៅមុខរួមមានៈ ការសិក្សាអំពីភូមិភាគបូព៌ា ភូមិភាគនិរតី ជនជាតិវៀតណាម ជនជាតិចិន ក្រុមជនជាតិដែលរស់នៅតំបន់ភ្នំ និងកុមារ ។ ក្រៅពីនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងផ្តល់ទីកន្លែងនិងប្រភពឯកសារដល់អ្នកជំនាញការខាងសិក្សាស្រាវជ្រាវទៅលើប្រធានបទខ្មែរក្រហមដែលកំពុងតែរៀបចំសរសេរសៀវភៅ ដោយផ្អែកទៅលើឯកសារទាំងស្រុងឬដោយផ្អែកនៃបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថានឹងពង្រីកកិច្ចការស្រាវជ្រាវនៅពេលខាងមុខ ហើយក៏បានកំពុងរៀបចំឲ្យមានការសិក្សាស្រាវជ្រាវពីសំណាក់អ្នកស្រាវជ្រាវរដ្ឋាភិបាលទៅលើទាហានអាមេរិកាំងដែលបាត់ខ្លួននៅក្នុងអំឡុងពេលសង្គ្រាម ។ លើសពីនេះទៅទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងពង្រីកសកម្មភាពសិក្សាឲ្យឈានដល់កម្រិតអន្តរជាតិដោយធ្វើឲ្យមានការសិក្សានៅប្រទេសផ្សេងៗក្នុងតំបន់និងបង្ហាញអំពីលទ្ធផលសិក្សានៅក្នុងសន្និសីទអន្តរជាតិសម្រាប់អ្នកច្បាប់និងអ្នកសិក្សាជាន់ខ្ពស់នៅឯបរទេស ។

មជ្ឈមណ្ឌលឯកសារកម្ពុជាមានបុគ្គលិកទាំងអស់សុទ្ធតែជាជនជាតិខ្មែរ ។ ជាចាំបាច់ បុគ្គលិកម្នាក់ៗជាដំបូងគឺចូលបម្រើការជាបុគ្គលិកស្ម័គ្រចិត្ត ។ ក្រោយពីទទួលបានបទពិសោធន៍និងការជឿជាក់ក្នុងចិត្តមាំទាំហើយ បុគ្គលិកទាំងនេះនឹងក្លាយជាបុគ្គលិកពេញលេញ ។ ដូច្នេះសមាជិកថ្នាក់ដឹកនាំទាំងអស់សុទ្ធតែវិវត្តពីថ្នាក់ក្រោមតាមលំដាប់លំដោយ របៀបនេះគ្មានករណីលើកលែងឡើយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលការហ្វឹកហាត់ជំនាញពិសេសផ្សេងៗជាច្រើនដើម្បីឲ្យបុគ្គលិកអាចជួយបំពេញចំណេះទៅវិញទៅមកនៅពេលមានការចាំបាច់ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាពឹងផ្អែកសំខាន់ទៅលើបុគ្គលិកស្ម័គ្រចិត្ត និស្សិតទើបតែបញ្ចប់ការសិក្សា និងអ្នកមកធ្វើកម្មសិក្សា ។ បុគ្គលិកអចិន្ត្រៃយ៍ទាំងអស់សុទ្ធតែចាប់ផ្តើមពីបុគ្គលិកស្ម័គ្រចិត្ត ។ មកដល់ពេលបច្ចុប្បន្ននេះមានបុគ្គលិកស្ម័គ្រចិត្តប្រមាណមួយរយនាក់ដែលធ្វើការលើគម្រោងផ្សេងៗជាច្រើន ។ កិច្ចការនេះផ្តល់ជាឧបករណ៍បង្កើនសមត្ថភាពប្រកបដោយបទពិសោធន៍ដែលចេះតែកើនឡើងជាលំដាប់ នៅក្នុងវិធីសាស្ត្រចងក្រងឯកសារ ហើយតាមរយៈពិសោធន៍នេះយើងអាចជ្រើសរើសបុគ្គលិកធ្វើការនៅថ្ងៃអនាគតទៀត ។ ទន្ទឹមគ្នានេះដែរបុគ្គលិកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាផលិតនូវស្នាដៃជាច្រើនដែលស្នាដៃនេះពិតជាមិនអាចសម្រេចបានឡើយប្រសិនបើគ្មានបុគ្គលិកស្ម័គ្រចិត្តទាំងអស់នោះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានរៀបចំទទួលនិស្សិតទើបបញ្ចប់ការសិក្សាមកពីសាកលវិទ្យាល័យនានា ស្ថាប័នច្បាប់ និងគ្រឹះស្ថាននៅឯបរទេសមួយចំនួនទៀតឲ្យធ្វើការក្នុងគម្រោងពិសេសៗដាច់ដោយឡែកពីគ្នា ។ អ្នកសិក្សាជាន់ខ្ពស់និងមានជំនាញច្បាស់លាស់ទាំងនេះមកពីសហរដ្ឋអាមេរិក អូស្ត្រាលី អង់គ្លេស ហុល្លង់ ប្រទេសផ្សេងៗជាច្រើនទៀត និងព្រះរាជាណាចក្រកម្ពុជា ។ ក្រៅពីនេះទៀតក៏មានអ្នកសិក្សាជាន់ខ្ពស់កម្រិតពិភពលោកជំនាញលើបញ្ហាខ្មែរក្រហមបញ្ហាកម្ពុជាបច្ចុប្បន្ន និងសិក្សាអំពើប្រល័យពូជសាសន៍ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំទទួលមកធ្វើកម្មសិក្សានៅបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ចុងក្រោយនេះគឺថាដោយសារតែមានសកម្មភាពផ្នែកបច្ចេកទេសក្នុងការចងក្រងឯកសារមានកម្រិតខ្ពស់ម្តងម្កាលមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលសេវាពីអ្នកពិគ្រោះដែលមានជំនាញច្បាស់លាស់ដូចជាវិស័យច្បាប់ ប្រវត្តិវិទ្យាវិស្វកម្មផ្នែកសំណង់ជាដើម ។ល ។ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួមទាំងបុគ្គលិកស្ម័គ្រចិត្តផងបានរកឃើញការពិតជាច្រើនសន្ធឹកសន្ធាប់

ស្តីអំពីអ្វីដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ដើម្បីធ្វើឲ្យប្រជាជនកម្ពុជាយល់ដឹងអំពីគំហើញពត៌មានទាំងនេះនៅខែមករា ឆ្នាំ២០០០ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចាប់ផ្តើមការបោះពុម្ពផ្សាយនូវទស្សនាវដ្តីមួយជាភាសាខ្មែរដែលមានឈ្មោះថា "ស្វែងរកការពិត" ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកចាយជូនទស្សនាវដ្តីនេះដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងជួយអប់រំប្រជាជនកម្ពុជាឲ្យបានយល់ដឹងអំពីអ្វីដែលបានកើតឡើងពិតប្រាកដនៅក្នុង "របបខ្មែរក្រហម" និងបានយល់ដឹងបន្ថែមទៀតអំពីការរីកចម្រើនថ្មីៗ ឆ្ពោះទៅរកការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ទៅលើអំពើឃោរឃៅដែលកើតឡើងនៅក្នុងសម័យនោះ ។ ទស្សនាវដ្តី "ស្វែងរកការពិត" ត្រូវបានបោះផ្សាយជារៀងរាល់ខែ ហើយអត្ថបទនៅក្នុងទស្សនាវដ្តីផ្តោតសំខាន់ទៅលើ ១) ឯកសារដើម ២) ប្រវត្តិសាស្ត្រ និងការសិក្សាស្រាវជ្រាវទៅលើអំពើប្រល័យពូជសាសន៍ ៣) ការវិភាគផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាសាធារណៈ ៥) ទំព័រស្វែងរកគ្រួសារ និងរូបថតរបស់បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងដែលបង្ហាញពីមនុស្សនិងទីកន្លែងក្នុងរបបខ្មែរក្រហម ។ ទស្សនាវដ្តី "ស្វែងរកការពិត" គឺប្រហែលជាការបង្ហាញនូវការតាំងចិត្តដ៏បរិសុទ្ធជាទីបំផុតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ***ដើម្បីការចងចាំនិងយុត្តិធម៌*** ។

ទិសដៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺចង់បានការចងចាំនិងយុត្តិធម៌ ផ្តោតសំខាន់ទៅអនាគតកាលជាជាងបច្ចុប្បន្នកាល ស្តីអំពីការប្រយុទ្ធដើម្បីការពិតនៅចំពោះមុខអំណាចដ៏លើសលប់ដែលបានកម្ទេចសង្គមខ្មែរ និងជាអំណាចដែលចេះតែបន្តគំរាមកំហែងគ្រប់មធ្យោបាយការជំរុញទៅមុខដើម្បីសន្តិភាពនៅថ្ងៃអនាគត ។ អំពើឃោរឃៅនៃអំណាចបានធ្វើឲ្យសង្គមខ្មែររគាត់រគាយ និងធ្វើឲ្យប្រជាជនកម្ពុជារស់នៅរហេតរហូតពាសពេញពិភពលោក ដូចជាសហគមន៍ជនជាតិជ្វីហ្វដែលកំពុងរស់នៅក្រៅប្រទេសអ៊ីស្រាអែលយ៉ាងដូច្នេះដែរ ។ ប៉ុន្តែទោះជានៅឆ្ងាយឬជិតពីភូមិកំណើតយ៉ាងណាក្តី ហើយទោះបីអ្នករស់រានមានជីវិតឬក្មេងជំនាន់ក្រោយក៏ដោយ ក៏ប្រជាជនកម្ពុជានៅតែដក់ជាប់ក្នុងចិត្តនូវការឈឺចាប់ដោយការនិរាសព្រាត់ប្រាស ។ ការព្រាត់ប្រាសនេះបណ្តាលមកពីការបាត់បង់អ្វីម្យ៉ាងដែលធ្ងន់ធ្ងរជាងការឆក់យកនូវរបស់ផ្ទាល់ខ្លួនទៅទៀត ។ នេះគឺជាការបាត់បង់ព្រលឹងដែលជាវត្ថុសំខាន់នៅក្នុងចិត្តគំនិតខ្មែរ ។ នេះជាការបាត់បង់នូវអ្វីដែលមិនអាចស្រោចស្រង់ឡើងវិញបាន ហើយការព្យាបាលរបួសបង្កដោយអំពើប្រល័យពូជសាសន៍នឹងទាមទារអ្វីដែលថ្មីក្នុងការជំនួសអ្វីដែលបានបាត់បង់ទៅហើយ ។ ការកសាងនូវរឿងរ៉ាវជាប្រវត្តិសាស្ត្រស្តីអំពីអ្វីដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា និងការតស៊ូដើម្បីយុត្តិធម៌ដែលជាឱសថស័ក្តិសិទ្ធិដែលកំពុងត្រូវបានធ្វើឡើងនេះ នឹងនាំឲ្យយើងបង្កើតបាននូវមូលដ្ឋានគ្រឹះមួយដែលប្រជាជាតិកម្ពុជាអាចរកឃើញមូលដ្ឋានមាំទាំសម្រាប់ឈានទៅថ្ងៃអនាគតដ៏ភ្លឺស្វាងមួយ ។ ប្រទេសកម្ពុជានឹងសម្រេចចិត្តម្តងមួយជំហានៗ ហើយការបង្រួបបង្រួមជាតិនឹងកើតចេញពីទឹកចិត្តរបស់ប្រជាជនកម្ពុជាម្នាក់ៗ ។ ប្រជាជនកម្ពុជាមិនអាចលើកទោសឲ្យនរណាម្នាក់ដរាបណាខ្លួននៅមិនទាន់ដឹងច្បាស់ថាអ្នកណាជាអ្នកដែលខ្លួនលើកលែងទោសឲ្យ ហើយលើកលែងទោសដើម្បីអ្វីនោះ ។ ការផ្តោតសំខាន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាទៅលើការចងចាំនិងយុត្តិធម៌ ជួយជំរុញឲ្យប្រជាជនកម្ពុជានៅក្នុងការស្វែងរកការពិតដែលជាបង្អែកគោលយ៉ាងសំខាន់សម្រាប់ការផ្សះផ្សាជាតិយ៉ាងពិតប្រាកដ ។

**ឆាំង យុ**



ក្រុមអ្នកស្រាវជ្រាវនិងផលិតទស្សនាវដ្តីស្វែងរកការពិត ឆ្នាំ២០០០

# ចម្លើយសារភាពរបស់ ប៉ាន់ ស៊ីម ហៅ ស៊ែល

ប៉ាន់ ស៊ីម ឈ្មោះបដិវត្តន៍ ស៊ែល អាយុ២៨ឆ្នាំ (ឆ្នាំ១៩៧៧) ក្លាយជាអ្នកទោសនៅមន្ទីរស-២១ (គុកទួលស្លែង) នៅខែ៤ ឆ្នាំ១៩៧៧ ពីបទចោទប្រកាន់ថាបានរួមគំនិតធ្វើសកម្មភាពក្បត់បដិវត្តន៍ ។ ឯកសារចម្លើយសារភាពរបស់ ប៉ាន់ ស៊ីម ដែលបន្សល់ទុកនៅមន្ទីរស-២១បានឲ្យដឹងថា ប៉ាន់ ស៊ីម មានកំណើតនៅភូមិកន្ទែងបក សង្កាត់មៀន ស្រុកកោះសូទិន តំបន់២២ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ ប៉ាន់ សៀក ម្តាយឈ្មោះ ឡូញ ឃឹម ។ ប៉ាន់ ស៊ីម បានចូលជាសមាជិកបក្សពលករកម្ពុជា នៅខែ៤ ឆ្នាំ១៩៧០ ។ បន្ទាប់ពីឆ្លងកាត់ការប្រយុទ្ធជាច្រើនសមរភូមិ នៅទីបំផុត ប៉ាន់ ស៊ីម ក៏បានទទួលតំណែងជាលេខាកងអនុសេនាធំលេខ១៥២ និងធ្វើសកម្មភាពក្បត់នៅតាមសមរភូមិជាច្រើន ក៏ត្រូវអង្គការចាប់ខ្លួននៅខែ៤ ឆ្នាំ១៩៧៧ រួចបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែង ។

សេចក្តីទាំងស្រុងនៃចម្លើយសារភាពរបស់ ប៉ាន់ ស៊ីម បានបង្ហាញថា ប៉ាន់ ស៊ីម បានស្គាល់ឈ្មោះ ទុំ (លេខាតំបន់២២) កាលពីអាយុ១៩ឆ្នាំ (ឆ្នាំ១៩៦៧) ។ បន្ទាប់ពីព្រឹត្តិការណ៍រដ្ឋប្រហារដែលដឹកនាំដោយ លន់ ណុល នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ បាតុកម្មដ៏ធំ១ទៀតក៏ផ្ទុះឡើងនៅថ្ងៃទី២៣ ខែមីនា ។ ប៉ាន់ ស៊ីម ក៏ត្រូវបានឈ្មោះ ផុន និង ឌឹម ឃោសនាអូសទាញឲ្យចូលរួមក្នុងចលនាតស៊ូ ។ ក្នុងចម្លើយសារភាព ផុន និង ឌឹម បាននិយាយថាៈ "សង្គមនិយមគ្មានមនុស្សជិះជាន់មនុស្ស ទាំងអស់គ្នាធ្វើការ ទាំងអស់គ្នាទទួលផល...ទាំងអស់គ្នារស់នៅត្រូវមានវិន័យ ។ មិនមែនដូចសង្គមកន្លងមកទេ អ្នកធ្វើការធ្វើទាល់តែងាប់តែហូបមិនឆ្អែត...ឯអ្នកមិនធ្វើការនោះហូបចាក់ប្រាសទៅវិញ" ។ ប៉ាន់ ស៊ីម ត្រូវបាន ផុន បញ្ចូលក្នុងបក្សពលករកម្ពុជានៅខែ៤ ឆ្នាំដដែលៈ "...ទើបសមមិត្ត ឌឹម និងសមមិត្ត ផុន ហៅខ្ញុំទៅបញ្ចូលក្នុងអង្គការបក្សពលករកម្ពុជានៅក្នុងខែ៤ ឆ្នាំ៧០នោះ ហើយមានលើកទង់មានកណ្តៀវញញួរនិងរូបផ្កាយនៅពីក្រោម...រួចហើយទើបគេអានពាក្យសច្ចាឲ្យខ្ញុំថាតាមៈ ខ្ញុំសូមសច្ចាចំពោះទង់បក្សពលករកម្ពុជានិងវិញ្ញាណក្ខន្ធនៃវីរបុរស បើខ្ញុំមិនស្មោះត្រង់ចំពោះអង្គការឬក៏ក្បត់នោះសូមឲ្យវិញ្ញាណក្ខន្ធនៃវីរបុរសបក្សពលករប្រហារជីវិតខ្ញុំចុះ" ។ បន្ទាប់ពីក្លាយជាសមាជិកបក្សពលករកម្ពុជា ភារកិច្ចដំបូងរបស់ ប៉ាន់ ស៊ីម គឺធ្វើជានិរសារត់សំបុត្រពីមន្ទីរស្រុកទៅសង្កាត់ និងពីមន្ទីរស្រុកទៅចំណាតនិរសានៅតំបន់ ។

**មុនថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥÷**

នៅដើមឆ្នាំ១៩៧២ ប៉ាន់ ស៊ីម បានកាន់កងទ័ព១កងអនុសេនាតូចដែលមានឈ្មោះ ចៅ សឿង ដឹកនាំជាលេខាកងអនុសេនាធំ និងឈ្មោះ ឈូក សៅ ជាអនុលេខា ។ នៅខែ៥ ឆ្នាំ១៩៧១ កងអនុសេនាតូចរបស់ ប៉ាន់ ស៊ីម ត្រូវទៅបំពេញភារកិច្ចនៅជ្រោយអំពិល ។

ខែ៨ ឆ្នាំ១៩៧១ អង្គការចាត់តាំង ប៉ាន់ ស៊ីម ជាសមាជិកកងអនុសេនាធំស្រុកកោះសូទិន ជំនួសសមមិត្ត ឈូក សៅ ដែលត្រូវដកទៅភូមិភាគ ។ ឆ្លងកាត់ការប្រយុទ្ធអស់រយៈពេលដ៏យូរនៅលើសមរភូមិជាច្រើនដូចជានៅ កោះសូទិន ទន្លេបិទ កោះប៉ែន ខ្សាច់កណ្តាល កោះខកញ៉ែតី ព្រែកអំពិល មុខកំពូល អរិយក្សត្រ ។ល ។ ក្រោមការដឹកនាំរបស់ឈ្មោះ មុត ឌឹម និង ឈាន ប៉ាន់ ស៊ីម បានធ្វើនូវអំពើដែល ស៊ីម បានរៀបរាប់នៅក្នុងចម្លើយសារភាពរបស់ខ្លួនថាជាសកម្មភាពក្បត់ នោះគឺបំផុសយុទ្ធជនឲ្យភ័យបាក់ទឹកចិត្តប្រយុទ្ធ លួចបើកផ្លូវឲ្យខ្មាំងរត់ បំផ្លាញអាវុធគ្រាប់រំសេវ ធ្វើឲ្យបែកការណ៍សម្ងាត់ដឹងដល់ខ្មាំង លួចបញ្ចេញផលិតផលកសិកម្មលក់ទៅឲ្យខ្មាំង បំផ្លាញផែនការប្រយុទ្ធធ្វើឲ្យបាត់បង់ឱកាសយកជ័យជម្នះស្ទើរតែគ្រប់សមរភូមិ និងបង្កទំនាស់ជាមួយកងទ័ពវៀតណាមដែលបោះទីតាំងនៅជិតនោះធ្វើឲ្យមានបញ្ហាមិនចេះអស់មិនចេះហើយ ។

ខែ១២ ឆ្នាំ១៩៧៤ អង្គការបានចាត់តាំងវរសេនាធំថ្មីមួយទៀតគឺវរសេនាធំលេខ១២៤ ដែលមានឈ្មោះ មិត ជាលេខា (អតីតលេខាស្រុកខ្សាច់កណ្តាល) ប៉ាន់ ស៊ីម អនុលេខា និង គ្រី

ជាសមាជិក (គ្រី ពីមុនជាអនុលេខាស្រុកអូររាំងឪ) ។ កងទ័ពថ្មីនេះបានទទួលការអប់រំនយោបាយនិងបច្ចេកទេសរហូតដល់ចុងខែ១២ ឆ្នាំ១៩៧៤ ទើបចប់ ។ ខែ២ ឆ្នាំ១៩៧៥ អង្គការចាត់តាំងឲ្យអង្គភាព១២៤ទៅប្រយុទ្ធនៅសមរភូមិព្រែកតាសេកនិងព្រែកតាគង់ សហការជាមួយកងទ័ពភូមិភាគឧត្តរដែលវាយចុះពីពាមរាំងមក ។ ប៉ាន់ ស៊ីម សារភាពថាបានធ្វើសកម្មភាពក្បត់ដោយធ្វើឲ្យបរាជ័យមួយលើកជាពីរលើក ។

ខែ៤ ឆ្នាំ១៩៧៥ ដោយឃើញភាពកម្សោយរបស់អង្គភាពវរសេនាធំលេខ១២៤ ទុំ បានណែនាំឲ្យរកវិធីវាយខ្មាំងពីខាងក្រោយខ្នងវិញ គឺវាយកម្លាំងដែលខ្សោយៗបានហើយទុកកម្លាំងដែលខ្លាំងឲ្យនៅកន្លែងហ្នឹងចុះ ចាំទៅយកភ្នំពេញវិញ ។

## ក្រោយថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥

តាមចម្លើយសារភាពរបស់ ប៉ាន់ ស៊ីម ក្រោយពេលដែលខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ កម្លាំងកងពល១៥២ត្រូវដកថយពីភ្នំពេញមកបោះទីតាំងនៅជ្រោយចង្វា ការពារនិងបោសសម្អាតខ្មាំងនៅក្នុងតំបន់ និងគ្រប់គ្រងជយភណ្ឌទាំងអស់ ។ ចំពោះកម្លាំងកងពល១២៤ ត្រូវថយទៅបោះទីតាំងពីអរិយក្សត្រដល់ពុកឬស្សី មានភារកិច្ចការពារសន្តិសុខតាមតំបន់ទាំងនេះ និងបោសសម្អាតខ្មាំង ហើយត្រូវចាត់តាំងជម្លៀសប្រជាជនចេញពីភ្នំពេញឡើងទៅទន្លេបិទនិងជីហែ ។ ដូច្នេះអង្គភាព១៥២របស់ ប៉ាន់ ស៊ីម ក៏ថយមកបោះទីតាំងតាមការកំណត់និងរៀបចំជម្លៀសប្រជាជនចេញពីភ្នំពេញ ។ ពេលនោះ ប៉ាន់ ស៊ីម បានឲ្យឈ្មោះ ដាត បំផ្លាញផែនការជម្លៀសប្រជាជន គឺបានធ្វើឲ្យកើលកប៉ាល់ធំ២-៣គ្រឿងនៅទន្លេមេគង្គដែលនាំឲ្យស្ទះដល់ការដឹកជញ្ជូនប្រជាជនភៀសសឹក ។ ក្រៅពីនោះ ដាត បានបំផ្លាញម៉ាស៊ីនកាណូតចំហៀងដែលប្រមូលយកមកទុកនោះអស់ជាច្រើនគ្រឿង ។

ខែ៦ ឆ្នាំ១៩៧៥ ប៉ាន់ ស៊ីម បានរាយការណ៍ឲ្យ ទុំ អំពីសភាពការណ៍នៅស្រុកមួយចំនួនចាប់ពីកោះសូទិនមកដល់ល្វាឯមត្រូវខ្វះខាតស្បៀងនិងអំបិលច្រើនណាស់ ដូចជានៅពុកឬស្សីមានតែបបររាវៗឲ្យប្រជាជនហើយហូបមិនឆ្អែតទៀត ។

រហូតដល់ខែ៨ ឆ្នាំ១៩៧៥ ប៉ាន់ ស៊ីម ត្រូវអង្គការដកពីវរសេនាធំលេខ១២៤មកធ្វើជាលេខាវរសេនាធំ១៥២វិញ ។ នាទីជាលេខាវរសេនាធំ១២៤ ត្រូវធ្លាក់លើឈ្មោះ ពេជ ។

ខែ១១ ទុំ ប្រាប់ឲ្យ ប៉ាន់ ស៊ីម ត្រៀមកប៉ាល់ប្រយុទ្ធចំនួន១០គ្រឿង ត្រៀមអាវុធគ្រាប់រំសេវ ស្បៀងអាហារនិងកម្លាំងប្រយុទ្ធឲ្យបានស្រេចបាច់សម្រាប់ជួយធ្វើអន្តរាគមន៍រដ្ឋប្រហារនៅភ្នំពេញ ។ កម្លាំងនេះប្រយុទ្ធបានទាំងលើគោកផងក្នុងទឹកផង ដូច្នេះក្នុងរវាងខែ៤ឬខែ៥ ឆ្នាំ១៩៧៦នេះ ចេញ



ជនរងគ្រោះ ប៉ាន់ ស៊ីម?

បញ្ជាដល់កម្លាំងកុំដើរចោលកន្លែងឲ្យសោះប្រយ័ត្នថ្ងៃរះធ្លោយការ ពេលណាមានបញ្ជាឲ្យចេញប្រយុទ្ធគឺត្រូវតែចេញបានភ្លាម ។ ខែ១២ ទុំ បានប្រាប់ឲ្យ ប៉ាន់ ស៊ីម ធ្វើកាណូតឲ្យគាត់មួយគ្រឿងទៀត និងឲ្យត្រៀមកប៉ាល់ដឹកជញ្ជូនធុន១០០តោននិង៥០តោនសម្រាប់ដឹកជញ្ជូននាឆ្នាំ១៩៧៧ខាងមុខនេះ ព្រោះដឹកតាមផ្លូវទឹកចំណាយសោហ៊ុយតិចជាងតាមផ្លូវគោកច្រើនណាស់ ។

ចូលដល់ខែ១ ឆ្នាំ១៩៧៦ អង្គការតម្រូវឲ្យអង្គភាព១៥២របស់ ស៊ីម សង់កប៉ាល់ដឹកជញ្ជូនចំនួន៥០គ្រឿង ។ ស៊ីម

ក៏ចាត់តាំងឈ្មោះ ថែម និង យ៉េត ឲ្យទទួលខុសត្រូវរោងជាងដំឡើងកប៉ាល់នោះ ។ តាមចម្លើយសារភាពរបស់ ប៉ាន់ ស៊ឹម នៅក្នុងរោងជាងនេះអ្វីៗត្រូវបានបំផ្លាញតាំងពីការខ្វះខាតឈើ សម្ភារៈឧបករណ៍ត្រូវបានចោលពាសវាលពាសកាលបណ្តាលឲ្យបាត់បង់អស់ គោលបំណងនៃសកម្មភាពនេះគឺពន្យឺតពេលវេលាក្នុងការកសាងកប៉ាល់ ។ ក្រៅពីនោះ ឈ្មោះ ទុំ បានចាត់តាំងឲ្យ ប៉ាន់ ស៊ឹម រៀបចំមន្ទីរនិវេសាមួយនៅគល់ស្ពានជ្រោយចង្វារ ត្រៀមខាងលិចដើម្បីងាយស្រួលទាក់ទងជាមួយតំបន់២២ ។ ចំណតនេះប្រើរូបភាពជាកន្លែងចាំចម្លងកម្លាំងទៅមកខាងព្រៃស ។

ខែ៦ ឆ្នាំ១៩៧៦ ក្នុងខែនេះ ប៉ាន់ ស៊ឹម កាន់តែបង្កើនការគាបសង្កត់ទៅលើកម្លាំងពលកម្មខ្លាំងឡើងៗ ធ្វើឲ្យអ្នកទាំងនោះធ្លាក់ខ្លួនឈឺជាបន្តបន្ទាប់ ខាតកម្លាំងធ្វើការងារអស់ច្រើនសន្ធឹក ។ គាត់បានសារភាពថា "ខ្ញុំបានចាត់តាំងប្រើប្រាស់កម្លាំងនៅព្រៃសឲ្យកម្លាំងនេះប្រឹងហួសនៅក្នុងសភាពដែលហូបបាយមួយពេលបបរមួយពេលនោះ...ដូចជាកន្ទេលមកក្នុងវដ្ដវស្សុង ខ្ញុំចាត់តាំងកម្លាំង៣០នាក់ដាច់ខាតត្រូវស្ទូងឲ្យបាន៣ហិកតាដីក្នុង១ថ្ងៃ ដូច្នេះបងប្អូនត្រូវប្រឹងធ្វើការក្នុង១ថ្ងៃ១០ម៉ោងឯណោះ ។ ក្នុងសភាពហូបបាយមួយពេលបបរមួយពេលដូចនេះ កម្លាំង៤០០នាក់ត្រូវឈឺអស់២០០នាក់ទៅហើយក្នុងមួយថ្ងៃ" ។ ខែ៧ កប៉ាល់ត្រូវបានធ្វើរួច១គ្រឿងនិងត្រូវរុញចុះទឹក ។ ស៊ឹម បានរកវិធីធ្វើឲ្យដួចុះកប៉ាល់មានបញ្ហានាំឲ្យវៀចតួកប៉ាល់ ។

ខែ៨-៩ ទុំ បានមកប្រាប់ ស៊ឹម ឲ្យពិនិត្យឡើងវិញនូវអាវុធរំសេវ ស្បៀងអាហារ យានជំនិះ និងកម្លាំងប្រយុទ្ធដែលបានប្រាប់ឲ្យត្រៀមកាលពីលើកមុននោះពេលនេះត្រូវម្ចាស់ការឲ្យបាន ព្រោះសភាពការណ៍មិនប្រាកដថាពេលណាត្រូវផ្ទុះអាវុធទេ ដូច្នេះត្រូវតែត្រួតពិនិត្យអំពីបញ្ហាចាត់តាំងឡើងវិញដើម្បីឲ្យម្ចាស់ការលើសភាពការណ៍ជាមុនឲ្យហើយ ។ ខែ១១ ឆ្នាំ១៩៧៦ ឈ្មោះ ទុំ ប្រាប់ឲ្យ ប៉ាន់ ស៊ឹម ជួសជុលរថយន្តឲ្យគាត់មួយគ្រឿងឲ្យល្អដើម្បីយកទៅជូនបងភឹម ។ ខែ១២ ទុំ មកម្តងទៀតប្រាប់ឲ្យគូរប្លង់កប៉ាល់ប្រយុទ្ធមួយគ្រឿងធុន "វុលដែត" ធ្វើអំពីឈើដោយយកគំរូតាមកប៉ាល់របស់ចិន សម្រាប់ប្រើប្រាស់ក្នុងទឹកប្រៃ ។ ត្រូវសង់ឲ្យរួចមួយគ្រឿងនៅខែ១ ឆ្នាំ១៩៧៧នេះ ។

ខែ១ ឆ្នាំ១៩៧៧ កប៉ាល់ម៉ាក "វុលដែត" ចាប់ផ្តើមរៀបចំដំឡើង ។ ទុំ ខស្សព្រាហ៍ទៅទីនោះជាញឹកញាប់ដើម្បីពិនិត្យការងារនិងឆ្លៀតណែនាំ ប៉ាន់ ស៊ឹម ឲ្យខស្សព្រាហ៍ពិនិត្យកម្លាំងប្រយុទ្ធនិងសម្ភារសឹកទូទៅទាំងអស់ដើម្បីម្ចាស់ការជាមុននៅពេលដែលមានរដ្ឋប្រហារកុំធ្វើប្រហែសឲ្យសោះ ហើយឲ្យបំផ្លាញតួកប៉ាល់នេះកុំឲ្យយកប្រើក្នុងទឹកប្រៃបាន ព្រោះគាត់ចង់ទុក១គ្រឿងប្រើនៅទន្លេមេគង្គនេះ ចាំលើកក្រោយសឹមយកទៅសមុទ្រចុះ ។

នៅខែ៣ ឆ្នាំ១៩៧៧ ទុំ ឡើងទៅក្រចេះ ។ ការកសាងកប៉ាល់ក៏រួចរាល់ដែរគឺរត់បាន៤០គីឡូម៉ែត្រក្នុង១ម៉ោង បានជូនទៅឈ្មោះ ខៀវ សាកល្បងរួចរាល់ ។ បន្ទាប់ពីមានការកែតម្រូវតួកប៉ាល់ត្រង់ចំណុចខ្វះ កប៉ាល់ក៏ត្រូវបានយកទៅសមុទ្រដើម្បីសាកល្បងបើកកាត់រលកសមុទ្រ ។ រួចរាល់ការបញ្ជូនកប៉ាល់ទៅសមុទ្រហើយ ប៉ាន់ ស៊ឹម ត្រូវបានអង្គការចាត់តាំងឲ្យទៅសង់ស្ពានលូនៅប្រាំងចំរេះ កំណត់១៥ថ្ងៃឲ្យរួច គឺធ្វើយ៉ាងណាឲ្យរថយន្តអាចបើកលើលូនេះបាន ។ នៅខែ៤ត្រូវទៅធ្វើទ្វារទឹកនៅព្រែកព្នៅទៀត ។ ប៉ុន្តែមុនពេលដែលលូនៅប្រាំងចំរេះត្រូវបានធ្វើរួច ហើយទ្វារទឹកនៅព្រែកព្នៅទើបតែបុកគ្រឹះនោះ ប៉ាន់ ស៊ឹម ក៏ត្រូវអង្គការចាប់ខ្លួនបញ្ជូនមកគុកទួលស្លែង ។

នៅក្នុងគុកទួលស្លែង ប៉ាន់ ស៊ឹម ត្រូវបានសួរចម្លើយដោយឈ្មោះ ឈិន នៅក្នុង"ពួក១" ។ ឯកសារចម្លើយសារភាពរបស់ ប៉ាន់ ស៊ឹម មានកម្រាស់៩០ទំព័រ ត្រូវបានសរសេរដោយដៃ មានសភាពច្របូកច្របល់ មានចុះហត្ថលេខារបស់ ប៉ាន់ ស៊ឹម ចុះកាលបរិច្ឆេទថ្ងៃទី៧ ខែ៦ ឆ្នាំ១៩៧៧ ។ នៅទំព័រទី៣មានចំណារថា "រក្សាសម្ងាត់" ។ ភ្ជាប់ជាមួយចម្លើយសារភាពនេះមានបញ្ជីមួយដែលមានឈ្មោះមនុស្សចំនួន៧៤នាក់ សុទ្ធតែមានបញ្ជាក់តួនាទីនិងអង្គភាពច្បាស់លាស់ ។

តាមបញ្ជីឈ្មោះអ្នកទោសដែលត្រូវកម្ទេចបានឲ្យយើងដឹងថា ប៉ាន់ ស៊ឹម ត្រូវបានកម្ទេច (សម្លាប់) នៅថ្ងៃទី៩ ខែ១២ (ធ្នូ) ឆ្នាំ១៩៧៧ រួមជាមួយនឹងអ្នកទោសចំនួន៣០០នាក់ផ្សេងទៀត ។

**សាន់ កល្យាណ**

# រណ្តៅសាកសពប្រល័យពូជសាសន៍នៅខេត្តបាត់ដំបង

ការធ្វើផែនទីរណ្តៅសាកសពនៅខេត្តបាត់ដំបងសម្រាប់ឆ្នាំ ១៩៩៨ ប្រព្រឹត្តទៅពីថ្ងៃទី២១ ខែសីហា ដល់ថ្ងៃទី៣ ខែធ្នូ ទៅលើស្រុកចំនួន៤គឺ ស្រុកបវេល ស្រុកបាត់ដំបង ស្រុកសង្កែ និងស្រុករតនៈមណ្ឌល ។

## ស្រុកបវេល

ស្រុកបវេលមានចម្ងាយ៥០គីឡូម៉ែត្រពីទីរួមខេត្តបាត់ដំបង ប៉ែកខាងលិច ។ ស្រុកនេះមានព្រំប្រទល់ខាងកើតជាប់នឹងស្រុកបាត់ដំបង ខាងជើងជាប់នឹងស្រុកមង្គលបុរីខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងស្រុករតនៈមណ្ឌល និងខាងលិចជាប់នឹងស្រុកសំពៅលូន ស្រុកភ្នំព្រឹក និងស្រុកកំរៀង ។ មានទីតាំងសម្លាប់មនុស្សចំនួន២កន្លែង មន្ទីរសន្តិសុខមួយកន្លែង និងមន្ទីរពេទ្យរបស់ខ្មែរក្រហមមួយកន្លែងទៀត ស្ថិតនៅក្នុងទឹកដីស្រុកបវេល ខេត្តបាត់ដំបង ។ ទីតាំងទាំងប៉ុន្មានខាងលើនេះស្ថិតនៅក្នុងឃុំបវេល និងឃុំក្តុលតាហែន ស្រុកបវេលនាពេលបច្ចុប្បន្ន ដែលកាលពីសម័យខ្មែរក្រហមគឺជាស្រុក៧០ ក្នុងភូមិភាគពាយ័ព្យ ។

### ក) ទីតាំងមន្ទីរសន្តិសុខតំបន់៣

សាលាឃុំបវេលបច្ចុប្បន្នជាអតីតមន្ទីរសន្តិសុខតំបន់៣ របបខ្មែរក្រហម ។ ទីតាំងនេះមានចម្ងាយ៥២គីឡូម៉ែត្រពីសាលាខេត្តបាត់ដំបង និងប្រហែលជិត២គីឡូម៉ែត្រពីសាលាស្រុកបវេលប៉ែកខាងជើងឆៀងខាងកើត ។ អតីតមន្ទីរសន្តិសុខនេះស្ថិតនៅជាប់នឹងផ្លូវលំមួយខ្សែក្នុងភូមិបវេល១ ឃុំបវេល ស្រុកបវវេល ខេត្តបាត់ដំបង កាលពីជំនាន់ខ្មែរក្រហមគឺភូមិបវេល១ ឃុំបវេល ស្រុក៧០ តំបន់៣ ភូមិភាគពាយ័ព្យ ។ អតីតមន្ទីរសន្តិសុខនេះ (ដែលបច្ចុប្បន្នជាសាលាឃុំបវេល) មិនត្រូវបានរុះរើ ធ្វើថ្មីឬជួសជុលឲ្យខុសពីសភាពដើមឡើយ ។ មន្ទីរនេះធ្វើពីឈើយ៉ាងប្រណិត មានខណ្ឌជាបន្ទប់តូចៗដោយគ្រាន់តែទុកផ្លូវដើរដ៏តូចមួយនៅតាមចន្លោះបន្ទប់ទាំងនោះប៉ុណ្ណោះ ។ លោកមេឃុំបវេលឈ្មោះ គាប់ គោ បានឲ្យដឹងថា ជនរងគ្រោះដែលត្រូវបានបញ្ជូនមកដាក់មន្ទីរសន្តិសុខនេះគឺមានគ្រប់ប្រភេទប្រជាជន ។ ជនរងគ្រោះទាំងអស់ត្រូវបានយកមកសម្លាប់ចម្ងាយប្រហែលជាង១គីឡូម៉ែត្រពីមន្ទីរសន្តិសុខនោះ នៅក្នុងចម្ការក្រូចក្រោយផ្ទះលោកយាយ ថៃ ឡាត់ ប្រហែល ១៥០ ម៉ែត្រ ។ លោក គាប់ គោ បានបន្តថា មានមន្ទីរពេទ្យមួយទៀតរបស់ខ្មែរក្រហមស្ថិតនៅក្បែរសាលាឃុំបវេលដែរ ដែលទទួលព្យាបាលតែយុទ្ធជនខ្មែរក្រហមនៅសមរភូមិមុខប៉ុណ្ណោះ ។ មន្ទីរពេទ្យនេះបច្ចុប្បន្នជាវិទ្យាល័យបវេល ។ អតីតមន្ទីរពេទ្យនេះបានធ្វើឲ្យជនពិការខ្មែរក្រហមរាប់រយនាក់ស្លាប់ដោយការបាញ់រះពីពួកខ្មែរក្រហមដូចគ្នា នៅចុងឆ្នាំ១៩៧៨ ព្រោះតែទាហានពិការទាំងនោះមិនអាចធ្វើដំណើរឬផ្លាស់ប្តូរទីកន្លែងទៅណាបាន ។ សាកសពជនពិការទាំងអស់ត្រូវយកមកគរផុតចោលនៅប៉ែកខាងក្រោយនៃមន្ទីរពេទ្យនោះ ។


លោក គាប់ គោ

### ១) ទីតាំងសម្លាប់នៅចម្ការក្រូច (លេខកូដភូមិសាស្ត្រ ០២០៤០១)

ចម្ការក្រូចស្ថិតនៅឆ្ងាយពីទីប្រជុំជននិងឆ្ងាយពីផ្លូវធ្វើដំណើរ ស្ថិតនៅក្នុងភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ។ យោងតាមផែនទីរបបកម្ពុជាប្រជាធិបតេយ្យដែលបោះពុម្ពឆ្នាំ១៩៧៦ ទីតាំងពិឃាតនេះស្ថិតនៅក្នុងភូមិ


លោកយាយ ថៃ ឡាត់ ម្ចាស់ចម្ការក្រូច

បរវេល ឃុំបរវេល ស្រុក៧០ ភូមិភាគពាយ័ព្យ ។ ការធ្វើដំណើរទៅទីតាំងនេះប្រព្រឹត្តទៅបានតែនៅរដូវប្រាំងប៉ុណ្ណោះ ។ តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រពិភពលោក GPS ទីតាំងចម្ការក្រូចនេះស្ថិតនៅចន្លោះខ្សែស្រប ១៣° ១៥' ១០:៦២" និងខ្សែបណ្តោយ ១០២° ៥២' ២៤:៧៦" ។

ចម្ការក្រូចជាទីតាំងសម្លាប់ដ៏សាហាវមួយក្នុងរបបខ្មែរក្រហម ។ ប្រជាជនស្លូតត្រង់រាប់រយគ្រួសារត្រូវបានយកមកសម្លាប់ក្នុងបរិវេណចម្ការក្រូចនេះ ។ រហូតមកដល់សព្វថ្ងៃ ចម្ការក្រូចនេះនៅតែស្ថិតនៅក្នុងផ្នត់គំនិតរបស់ប្រជាជនគ្រប់រូប នៅស្រុកបរវេលថាជាទីតាំងសម្លាប់មនុស្សរបស់ខ្មែរក្រហម ។ ក្រោយថ្ងៃដួលរលំនៃរបបខ្មែរក្រហមរហូតមកដល់ដើមទសវត្សរ៍ឆ្នាំ៩០ ទីតាំងនេះបន្សល់ទុកស្លាកស្នាមយ៉ាងច្បាស់ៗជារណ្តៅតូចធំនៅក្នុងបរិវេណដីជាង១ហិកតារាងការេដែលជាចម្ការក្រូចរបស់លោកយាយ ថៃ ឡាត់ ។ ប៉ុន្តែនៅពេលក្រោយៗមកទៀត ស្លាកស្នាមទាំងនោះត្រូវរលុបបាត់បន្តិចម្តងៗ ដោយសំណឹកដី និងការឈូសឆាយលុបបំពេញ ។

លោកយាយ ថៃ ឡាត់ ដែលជាម្ចាស់ចម្ការក្រូច បានរៀបរាប់ថា ដើមក្រូចក្នុងចម្ការនេះទើបតែដាំថ្មីក្រោយឆ្នាំ១៩៧៩ប៉ុណ្ណោះ ប៉ុន្តែត្រូវដាំឃ្លាតពីគ្នាឆ្ងាយបន្តិច ព្រោះត្រូវចៀសរណ្តៅសាកសព ។ មានដើមក្រូចខ្លះឃ្លាតពីគ្នាចម្ងាយ ៥-៦ម៉ែត្រក៏មាន ។ ដុន ផត ដែលត្រូវជាកូនប្រុសរបស់លោកយាយ ថៃ ឡាត់ បាននិយាយថា កាលពីអំឡុងឆ្នាំ ១៩៩០ ខ្លួនមកជម្រះស្មៅនៅចម្ការក្រូចនេះបានឃើញរណ្តៅជាច្រើននៅពាសពេញក្នុងចម្ការ ប៉ុន្តែដល់ឆ្នាំក្រោយៗមក រណ្តៅទាំងនោះក៏រលុបបន្តិចម្តងៗរហូតស្ទើរតែរកចំណាំមិនបាន ។

តាមការឲ្យពត៌មានពីសាលាស្រុកក៏ដូចជាការនិយាយរបស់លោកយាយ ថៃ ឡាត់ ថា មានរណ្តៅសាកសពប្រហែលជាង ៣០រណ្តៅ និងមានសាកសពរួមទាំងអស់ប្រហែលជាង ៤៥០នាក់ ទាំងក្មេង ចាស់ ប្រុស ស្រី ។

### ក) ទីតាំងសម្លាប់នៅចំណុចស្ទឹងដាច់ ឃុំគុលតាហែន

ការសម្លាប់ប្រជាជននៅចំណុចស្ទឹងដាច់នេះប្រព្រឹត្តទៅនៅឆ្នាំ១៩៧៦ ។ តាមការបំភ្លឺរបស់ប្រជាជននៅក្នុងឃុំគុលតាហែន បានឲ្យដឹងថា នៅចំណុចស្ទឹងដាច់នេះមានការសម្លាប់មនុស្សច្រើន ប៉ុន្តែរូបភាពនៃការសម្លាប់នាពេលនោះគឺមានសភាពរាយប៉ាយ គ្មានរណ្តៅសម្រាប់កប់សាកសពទេ ។ លោកពូ ប៊ុយ រួម ជាប្រជាជនរស់នៅក្នុងឃុំគុលតាហែន បានរាយការណ៍ថា សាកសពជនរងគ្រោះដែលត្រូវខ្មែរក្រហមសម្លាប់ ត្រូវបានសត្វព្រៃដូចជា ចចក ខ្លា... ហែកស៊ីអស់តែក្នុងរយៈពេល២-៣ ថ្ងៃក្រោយការសម្លាប់ប៉ុណ្ណោះ ។ រហូតមកដល់សព្វថ្ងៃ ទីតាំងពិឃាតនេះគ្មានបន្សល់ទុកអ្វីទាំងអស់ក្រៅពីដីស្រែដ៏ធំល្វឹងល្វើយដាច់កន្ទុយភ្នែក ។

**ផេង ពង្សរ៉ាស៊ី**



ដុន ផត នៅក្នុងចម្ការក្រូចដែលជាអតីតទីតាំងសម្លាប់មនុស្ស

# ឯកសាររណសិរ្ស

ឯកសាររណសិរ្សទាំងអស់នេះត្រូវបានរកឃើញដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅចុងឆ្នាំ១៩៩៥ ។ ឯកសារនេះត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យឈ្មោះថា "ឯកសាររាប់លាន" មូលហេតុថាឯកសារនេះត្រូវបានសរសេររៀបចំចុះហត្ថលេខា និងផ្តិតមេដៃ ដោយប្រជាជនកម្ពុជាជាង១លាននាក់ ។ ឯកសាររណសិរ្សដែលមាននៅក្នុងបណ្ណសារសរុបទាំងអស់មានចំនួន១៧៣៨ច្បាប់ ។ នៅក្នុងនោះមានញត្តិចំនួន១២៥០ច្បាប់ដែលគាំទ្រចំពោះសេចក្តីសម្រេចចិត្តរបស់សភាជាតិនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងសម័យប្រជុំទី៥ មាតិកាទី១ ស្តីពីអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រព្រឹត្តឡើងដោយពួក ប៉ុល ពត អៀង សារី ខៀវ សំផនទៅលើប្រជាជនកម្ពុជាក្នុងចន្លោះឆ្នាំ១៩៧៥-៧៨ ។ ជាទូទៅញត្តិទាំងអស់ត្រូវបានសរសេរដោយដៃ ហើយមានហត្ថលេខានិង (ឬ) ស្នាមមេដៃធ្វើឡើងដោយបុគ្គលឬដោយប្រជាកសិករនៅក្នុងក្រុមសាមគ្គី និងតាមភូមិទូទាំងប្រទេសកម្ពុជា ។

ផ្អែកទៅលើញត្តិមួយផ្នែកដែលនៅសេសសល់ក្នុងដៃអាចជួយបង្ហាញឲ្យឃើញខ្លះថា មានប្រជាជនប្រមាណបីសែនប្រាំមួយម៉ឺនប្រាំមួយពាន់ប្រាំបីរយហុកសិបប្រាំបីនាក់ (៣៦៦៨៦៨) បានបាត់បង់ជីវិត ។ របាយការណ៍ជាផ្លូវការរបស់តុលាការប្រជាជនបដិវត្តន៍កម្ពុជាស្តីពី "ឧក្រិដ្ឋកម្មរបស់បនវាតទីនិយមចិនប៉េកាំងនិងបរិវារដាច់ថ្លៃ ប៉ុល ពត អៀង សារី ខៀវ សំផន ទៅលើប្រជាជនកម្ពុជាក្នុងអំឡុងពេលពីឆ្នាំ១៩៧៥-១៩៧៩" លេខ១០៥១-៨៣ ចុះកាលបរិច្ឆេទថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៨៣ ដោយក្រុមប្រឹក្សារណសិរ្សសាមគ្គីកសាងការពារជាតិ បានបញ្ជាក់ច្បាស់ថាមានប្រជាជនចំនួនមួយលានមួយសែនប្រាំមួយម៉ឺនប្រាំមួយពាន់បីរយប្រាំពីរនាក់ (១១៦៦៣០៧) ដែលបានធ្វើពាក្យបណ្តឹងឬញត្តិ ។ យោងតាមពាក្យបណ្តឹងនេះ មានប្រជាជនចំនួនបីលានបីសែនមួយម៉ឺនបួនពាន់ប្រាំពីររយហុកសិបប្រាំបីនាក់ (៣៣១៤៧៦៨) បានស្លាប់បាត់បង់ជីវិតដោយសារឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ តួលេខនេះរួមមានកសិករចំនួនមួយលានប្រាំបួនសែនពីរម៉ឺនប្រាំពីរពាន់ហុកសិបមួយនាក់(១៩២៧០៦១) ព្រះសង្ឃចំនួនពីរម៉ឺនប្រាំពាន់មួយរយហុកសិបប្រាំបីអង្គ (២៥១៦៨) ជនជាតិភាគតិចចំនួនបួនសែនប្រាំបីម៉ឺនប្រាំបីពាន់បីរយហាសិបប្រាំបួននាក់ (៤៨៨៣៥៩) កម្មករ បុគ្គលិករដ្ឋការ និងពាណិជ្ជករចំនួនបីសែនប្រាំពាន់ប្រាំរយដប់ប្រាំពីរនាក់ (៣០៥៥១៧) ហើយប្រជាជនចំនួនប្រាំសែនប្រាំមួយម៉ឺនប្រាំបីពាន់ប្រាំមួយរយហុកសិបបីនាក់(៥៦៨៦៦៣) ស្លាប់ក្នុងព្រៃដោយសារការធ្វើការបាក់កម្លាំងនិងអត់អាហារ ។

ញត្តិទាំងអស់សុទ្ធតែមានគំរូត្រឹមត្រូវ ហើយភាគច្រើនរៀបរាប់អំពីរឿងរ៉ាវផ្ទាល់ខ្លួននិងរៀបរាប់អំពីទីតាំងរណ្តៅសាកសព ឬឈ្មោះជនដៃដល់ ។ ញត្តិទាំងអស់ត្រូវបានបញ្ជូនមកសភាជាតិនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ធ្វើការគាំទ្រចំពោះសេចក្តីសម្រេចចិត្តរបស់សភាទៅលើអំពើឃោរឃៅប្រព្រឹត្តឡើងដោយខ្មែរក្រហម ហើយបានស្នើសុំឲ្យអង្គការសហប្រជាជាតិជួយស្វែងរកយុត្តិធម៌ឲ្យប្រជាជនកម្ពុជា និងបណ្តេញពួកប្រល័យពូជសាសន៍ឲ្យចេញពីអាសនៈកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ ។ មួយផ្នែកនៃឯកសាររណសិរ្សត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំធ្វើកាតាឡុក និងបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រទិន្នន័យគន្ធនិទ្ទេសនៅក្នុងឆ្នាំ១៩៩៦ ។ ដោយសារតែជម្រើសឯកសារនេះ ជាអាទិភាពទីពីររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមូលហេតុកាលបរិច្ឆេទហួសពីតម្រូវការនៃការសិក្សាស្រាវជ្រាវ ដូច្នេះឯកសារនេះមិនទាន់ត្រូវបានធ្វើកាតាឡុកទាំងស្រុងនៅឡើយទេ ប៉ុន្តែត្រូវបានចាត់ជាផ្នែកៗទៅតាមខេត្តផ្សេងៗ និងថែរក្សាត្រឹមត្រូវនៅក្នុងប្រអប់កាតុងនៃបន្ទប់បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ **ឆាំង យុ**

# លក្ខន្តិកៈបណ្តោះអាសន្ននៃសម្ព័ន្ធយុវជនកុម្មុយនិស្តកម្ពុជា

*លក្ខការណ៍និងគោលដំហរនយោបាយជាមូលដ្ឋានរបស់ "សម្ព័ន្ធយុវកក"*

១) អង្គការយុវជនបដិវត្តន៍កម្ពុជាយើងមានឈ្មោះថា "សម្ព័ន្ធយុវជនកុម្មុយនិស្តកម្ពុជា" ហៅកាត់ថា "សម្ព័ន្ធយុវកក" ។

២) "សម្ព័ន្ធយុវកក" ជាដៃស្តាំរបស់បក្សកុម្មុយនិស្តកម្ពុជា ជាកម្លាំងជំនួយដ៏សំខាន់ចំពោះគ្រប់កិច្ចការទាំងអស់របស់បក្សកុម្មុយនិស្តកម្ពុជា ។

ដូចនេះ "សម្ព័ន្ធយុវកក"ត្រូវជាអ្នកអនុវត្តយ៉ាងសកម្មនូវមាគ៌ានយោបាយ គោលនយោបាយ និងសេចក្តីសម្រេចចិត្តផ្សេងៗរបស់បក្សក្នុងយុវជនកម្ពុជាដ៏កុះករ ក្នុងប្រជាជនកម្ពុជាទូទៅ និងក្នុងគ្រប់កិច្ចការទាំងអស់" ។ (មាត្រាទី៣៥ នៃលក្ខន្តិកៈបក្ស) ។

៣) "សម្ព័ន្ធយុវកក" ស្ថិតនៅក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជា ។

៤) ធាតុពិតរបស់ "សម្ព័ន្ធយុវកក" មានពីរសំខាន់គឺៈ ធាតុវណ្ណៈនិងធាតុឈានមុខ ។

ក) ធាតុវណ្ណៈគឺជាធាតុវណ្ណៈកម្មកររបស់បក្ស ។ ដូចនេះក្នុងសកម្មភាពរបស់ខ្លួនដែលត្រូវធ្វើក្នុងយុវជនទូទៅ ត្រូវយកចិត្តទុកដាក់ទិសសកម្មភាពជាឃោសនា អប់រំ ចាត់តាំង ចលនាតស៊ូក្នុងស្រទាប់យុវជនកម្មករ យុវជនប្រជាពលករ យុវជនកសិករ និងយុវជនសិក្សាបដិវត្តជាមូលដ្ឋាន ។ ហើយឈរពីលើទិសសកម្មភាពនេះ ត្រូវចលនាស្រទាប់យុវជនផ្សេងទៀតឲ្យបានកុះករ ។

ខ) ធាតុឈានមុខគឺធាតុឈានមុខរបស់បក្ស អង់អាចក្លាហាន មោះមុត ស៊ូះស៊ាញ សកម្មប្រយុទ្ធជាងគេបំផុតក្នុងការអនុវត្តមាគ៌ានយោបាយ គោលនយោបាយ និងសេចក្តីសម្រេចចិត្តផ្សេងរបស់បក្សក្នុងគ្រប់ការងារ តស៊ូបដិវត្ត យោធា នយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច ការពារ និរសា ដឹកជញ្ជូន បច្ចេកទេសផ្សេងៗ ។ល ។ នៅគ្រប់សមរភូមិ ខាងមុខក្តី ខាងក្រោយក្តី ក្នុងគ្រាស្រួលក្តី ក្នុងគ្រាលំបាកក្តី គ្មានរាថយ តាមគោលជំហរវីរភាពបដិវត្តន៍ និងតាមស្មារតីវិន័យអង្គការដោយភ្ជាប់រលឹកខ្ពស់បំផុត ។ តាមធាតុទាំងពីររឹងមាំនេះ "សម្ព័ន្ធយុវកក" ជាកម្លាំងជំរុញចលនាតស៊ូបដិវត្តខ្លាំងក្លានាបច្ចុប្បន្ន និងជាអ្នកបន្តវេនកាន់កាប់វាសនាបដិវត្តន៍យ៉ាងរឹងមាំទៅអនាគត ។

៥) គោលបំណងយុទ្ធសាស្ត្រជាយុទ្ធសាស្ត្ររបស់ "សម្ព័ន្ធយុវកក" ស្របទៅតាមគោលបំណងជាយុទ្ធសាស្ត្ររបស់បក្ស គឺសម្រេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ហើយឈានទៅសម្រេចបដិវត្តន៍សង្គមនិយមនិងកុម្មុយនិស្តទៅអនាគតនៅប្រទេសកម្ពុជា ។

៦) "សម្ព័ន្ធយុវកក" រៀនសូត្រនិងប្រកាន់យកលទ្ធិម៉ាក្ស-ឡេនីន ធ្វើជាមូលដ្ឋាននៃទស្សនៈរបស់ខ្លួនតាមគោលការណ៍ទ្រឹស្តីជាប់និងជាក់ស្តែងនៃសភាពការណ៍បដិវត្តកម្ពុជា ។ សម្ព័ន្ធយុវកកបំពាក់និងប្រកាន់យកលោកទស្សនៈនិងជីវទស្សនៈបដិវត្តត្រឹមត្រូវនិងរឹងមាំ ហើយប្រឆាំងនឹងលោកទស្សនៈនិងជីវទស្សនៈមិនបដិវត្ត និងប្រឆាំងបដិវត្តន៍របស់អនុធន នាយទុនសក្តិភូមិ និងចក្រពត្តិ ។

៧) "សម្ព័ន្ធយុវកក" មានទស្សនៈមហាជនរឹងមាំ និងភ្ជាប់ជាប់នូវមាគ៌ាមហាជនគ្មានងាករេ ។ គឺជឿជាក់លើកម្លាំងមហាជន និងដើរជាប់នឹងចលនាតស៊ូបដិវត្តរបស់មហាជន ក្រោមការដឹកនាំរបស់បក្ស ។ "សម្ព័ន្ធយុវកក" ប្រឆាំងនឹងឯកកោនិយម នាមុឺននិយម ការិយាល័យនិយម អាជ្ញានិយម យោធានិយម ។ "សម្ព័ន្ធយុវកក" មិនត្រូវមានធាតុនិងអត្តចរិតនេះឡើយ ។

៨) "សម្ព័ន្ធយុវកក"គោរពនិងអនុវត្តប្រជាធិបតេយ្យប្រមូលផ្តុំដាច់ខាត ។ ត្រូវមានស្មារតីគោរពអង្គការវិន័យខ្ពស់ដោយភ្ជាប់រលឹក ។ ត្រូវមានស្មារតីប្រុងប្រយ័ត្នបដិវត្ត រក្សាការសម្ងាត់ ទប់ទល់ពីសកម្មភាពនិងកលខបាយខ្មាំងបំផ្លិចបំផ្លាញ ហើយការពារ "សម្ព័ន្ធយុវកក" បក្ស បដិវត្តន៍ ប្រជាជន ដាច់ខាត ។

៩) “សម្ព័ន្ធយុវកក” យករបបទិតៀនស័យទិតៀនធ្វើជាមធ្យោបាយកសាងផ្ទៃក្នុង កម្ចាត់គុណវិបត្តិ ជំរុញគុណសម្បត្តិ ធ្វើឲ្យ“សម្ព័ន្ធយុវកក”មានដំណើរទៅមុខមិនឈប់ឈរ ។

១០) “សម្ព័ន្ធយុវកក” ក្តាប់ជាប់និងអនុវត្តឲ្យបានល្អដាច់ខាតនូវស្នេហាជាតិនិយមបដិវត្ត និងអន្តរជាតិនិយមបដិវត្ត ។

## ស្នេហាជាតិនិយមបដិវត្ត

គឺជាស្នេហាជាតិឈរលើវណ្ណៈកម្មាជីព ឈរលើប្រជាជនតស៊ូកម្ចាត់ចក្រពត្តិឈ្លានពាននិងវណ្ណៈជិះជាន់សង្កត់សង្កិនរំដោះប្រជាជាតិប្រជាជន ប្រឆាំងនឹងជាតិនិយមចង្អៀតចង្អល់ជាតិនិយមរបស់វណ្ណៈជិះជាន់និងប្រកាន់សាសន៍ ។

## អន្តរជាតិនិយមបដិវត្ត

គឺអន្តរជាតិនិយមឈរលើវណ្ណៈកម្មាជីពអន្តរជាតិ ឈរលើបដិវត្តន៍អន្តរជាតិដែលខបត្ថម្ភទៅវិញទៅមក ប្រឆាំងចក្រពត្តិនិងប្រតិកិរិយា រំដោះនិងការពារប្រជាជាតិរៀងខ្លួន ឈរលើលក្ខការណ៍ស្មើភាព គោរពឯករាជ្យនិងអធិបតេយ្យភាពគ្នាទៅវិញទៅមក ។ ប្រឆាំងនឹងការរំលោភលើគ្នា ប្រឆាំងនឹងលទ្ធិប្រទេសធំមើលងាយមើលថោកប្រទេសតូច ។

លក្ខន្តិកៈ

១) អំពីសមាជិក

មាត្រា១ៈ គ្រប់យុវជនចំរើនជាជនជាតិកម្ពុជា ចាប់តាំងពីអាយុ១៧ឆ្នាំដល់៣០ឆ្នាំដែលទទួលគោរពអនុវត្តលក្ខន្តិកៈ លក្ខការណ៍និងគោលជំហរនយោបាយជាមូលដ្ឋានរបស់ “សម្ព័ន្ធយុវកក” យល់ព្រមឋិតនៅក្នុង“សម្ព័ន្ធយុវកក”មានជីវភាពក្នុង “សម្ព័ន្ធយុវកក” មានសកម្មភាពអង្គការ និងបង់វិភាគទានប្រចាំខែជូនអង្គការ “សម្ព័ន្ធយុវកក” សុទ្ធតែមានសិទ្ធិចូលធ្វើជាសមាជិកនៃ“សម្ព័ន្ធយុវកក”បានទាំងអស់ ។

មាត្រា២ៈ ចំពោះយុវជនចំរើនដែលមានវណ្ណៈភាពជាកម្មករពលករទីក្រុងនិងអនុធនទីក្រុងថ្នាក់ក្រោម ជាកសិករក្រនិងកសិករកណ្តាលថ្នាក់ក្រោម ត្រូវមានអ្នកខទ្ទេសនាមពីររូបដែលមានអាយុ“សម្ព័ន្ធយុវកក”ពី១ខែឡើងទៅ ហើយដោយមានអង្គការក្រុម“សម្ព័ន្ធយុវកក”អនុមតិ និងមានអង្គការបក្សដែលទទួលខុសត្រូវដឹកនាំមូលដ្ឋាននោះ (ដោយផ្ទាល់ឬដោយប្រយោល) យល់ព្រម ។

ក្នុងករណីមិនទាន់មានអង្គការ“សម្ព័ន្ធយុវកក” អង្គការបក្សចាត់ចែងការងារនេះផ្ទាល់តែម្តង ។

មាត្រា៣ៈ ចំពោះយុវជនចំរើនដែលមានវណ្ណៈភាពកសិករកណ្តាលថ្នាក់កណ្តាលនិងកណ្តាលថ្នាក់លើ ជាអនុធនទីក្រុងថ្នាក់កណ្តាលនិងថ្នាក់លើ ត្រូវមានអ្នកខទ្ទេសនាមពីររូបដែលមានអាយុ“សម្ព័ន្ធយុវកក”ពី៣ខែឡើងទៅ ហើយដោយមានអង្គការក្រុម“សម្ព័ន្ធយុវកក”អនុមតិ និងមានអង្គការបក្សដែលទទួលខុសត្រូវដឹកនាំមូលដ្ឋាននោះ (ដោយផ្ទាល់ឬដោយប្រយោល) យល់ព្រម ។

ក្នុងករណីមិនទាន់មានអង្គការ“សម្ព័ន្ធយុវកក” អង្គការបក្សចាត់ចែងការងារនេះតែម្តង ។

មាត្រា៤ៈ ចំពោះយុវជនចំរើនដែលមានវណ្ណៈភាពក្រៅពីវណ្ណៈខាងលើ មុននឹងឲ្យចូលត្រូវប្រយ័ត្នប្រយែងសាកល្បងចុះឡើងច្រើនលើកច្រើនគ្រា ត្រូវបំពេញលក្ខណៈសម្បត្តិម៉ត់ចត់ ហើយមានអ្នកខទ្ទេសនាមពីររូបមានអាយុអង្គការ“សម្ព័ន្ធយុវកក” ពី១ឆ្នាំឡើងទៅ ដោយមានក្រុម“សម្ព័ន្ធយុវកក”និងគណៈស្រុក “សម្ព័ន្ធយុវកក” អនុមតិ ព្រមទាំងសាខាបក្សនិងគណៈស្រុកបក្សយល់ព្រមផងទើបបាន ។

មាត្រា៥ៈ លក្ខណៈសម្បត្តិជាចាំបាច់ដែលត្រូវមានដើម្បីជ្រើសរើសបញ្ចូលជាសមាជិក“សម្ព័ន្ធយុវកក”គឺៈ

១) សកម្មភាពក្នុងការតស៊ូនិងធ្វើការងារបំពេញភារកិច្ចរបស់ខ្លួន ហើយដែលលេចចេញពីចលនានោះដោយមហាជនភាគច្រើនទទួលស្គាល់និងពេញចិត្ត ។

២) វណ្ណៈភាពល្អ សំខាន់ប្រភេទវណ្ណៈក្នុងមាត្រា២ ។ បន្ទាប់មកប្រភេទវណ្ណៈក្នុងមាត្រា៣ ។

៣) សីលធម៌រស់នៅល្អស្អាតស្អំ និងស្អាតស្អំខាងនយោបាយគ្មានអ៊ីស្មុគស្មាញ ។

មាត្រា៦ៈ ការបញ្ចូលសមាជិក“សម្ព័ន្ធយុវកក” ត្រូវមានពិធីគោរពទង់បក្ស ធ្វើសច្ចាប្រណិធានថា ខ្ញុំស្មោះត្រង់នឹងអង្គការ “សម្ព័ន្ធយុវកក” និងវណ្ណៈកម្មករ ស្មោះត្រង់និងបម្រើបដិវត្តន៍ ហើយប្តូរផ្តាច់តស៊ូបដិវត្តន៍បម្រើបក្ស បដិវត្តន៍ វណ្ណៈកម្មករ និងប្រជាជនអស់មួយជីវិត ។

អំពីភារកិច្ចរបស់សមាជិក"សម្ព័ន្ធយុវកក"

មាត្រា៧ៈ ១) ខិតខំអនុវត្តកម្មវិធីនយោបាយនិងលក្ខន្តិកៈរបស់ "សម្ព័ន្ធយុវកក" ។

២) ចលនាកៀងគរ យុវជន ទាំងខាងនយោបាយ ទាំងខាងចាត់តាំង ទាំងខាងតស៊ូ (តស៊ូកម្ចាត់និងតស៊ូកសាង) គ្រប់ផ្នែកជីវភាពនយោបាយ យោធា សេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច ។

៣) រក្សាការពារនិងពង្រឹងសាមគ្គីភាពឯកភាពផ្ទៃក្នុង "សម្ព័ន្ធយុវកក" តាមគោលជំហរ លក្ខន្តិកៈ និងកម្មវិធីនយោបាយរបស់"សម្ព័ន្ធយុវកក" ។

៤) រក្សាការសម្ងាត់គ្រប់បែបយ៉ាងរបស់"សម្ព័ន្ធយុវកក" ជាអង្គការចាត់តាំងក្ដីជាការងារក្ដី ។

៥) រក្សាការពារនិងពង្រីកឥទ្ធិពល"សម្ព័ន្ធយុវកក" ហើយពង្រឹងនិងពង្រីកជួរ "សម្ព័ន្ធយុវកក" ទាំងគុណភាពទាំងបរិមាណ ។

៦) មានជីវភាពអង្គការជាប្រក្រតី បង់វិភាគទានប្រចាំខែទៀងទាត់ ។

៧) ខិតខំរៀនសូត្រមាគ៌ានិងគោលនយោបាយរបស់បក្ស រៀនសូត្រវប្បធម៌ បច្ចេកទេស ដើម្បីមានសមត្ថភាពលើកអត្តភាពបដិវត្តន៍ខ្លួនជានិច្ច ។



អំពីសិទ្ធិរបស់សមាជិក"សម្ព័ន្ធយុវកក"

មាត្រា៨ៈ ១) បោះឆ្នោតឲ្យគេនិងឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យខ្លួនក្នុងការចាត់តាំងជ្រើសរើសចូលអង្គការដឹកនាំនៅបណ្ដាថ្នាក់ផ្សេងៗ ។

២) មានមតិស្មើពិភាក្សា ទិតៀន សាកសួរ អនុមតិគ្រប់បញ្ហាក្នុងការប្រជុំនិងក្នុងសន្និបាត ។ ក្រៅការប្រជុំនិងសន្និបាតក៏មានសិទ្ធិស្មើទិតៀនសាកសួរបានដោយផ្ញើតាមតែខ្សែរយៈអង្គការជាខ្សែសម្ងាត់ ។

៣) ត្រូវបាន"សម្ព័ន្ធយុវកក" យកចិត្តទុកដាក់ជួយឧបត្ថម្ភនិងកសាងខ្លួនគ្រប់បែបយ៉ាងឲ្យក្លាយទៅជាយុវជនបដិវត្តល្អ ។

២) អំពីការចាត់តាំង

មាត្រា៩ៈ លក្ខការណ៍ចាត់តាំងរបស់ "សម្ព័ន្ធយុវកក"ផ្អែកលើប្រជាធិបតេយ្យប្រមូលផ្ដុំគឺៈ

១) ម្នាក់ៗមានមតិពិគ្រោះពិភាក្សាគ្រប់បែបយ៉ាងមុនសមូហភាពសម្រេច ។

◆ ដល់សមូហភាពសម្រេចហើយបានទៅជាមតិអង្គការដែលគ្រប់ថ្នាក់ត្រូវគោរពជាដាច់ខាត ។

◆ គ្រប់អង្គការដឹកនាំជ្រើសរើសឡើងតាមបោះឆ្នោត ។ លើកលែងតែក្នុងសភាពលំបាកនោះថ្នាក់លើសម្រេចចាត់តាំងបាន ។

២) ការគោរពអង្គការចាត់តាំងទៅតាមគោលការណ៍បុគ្គលគោរពអង្គការ ថ្នាក់ក្រោមគោរពថ្នាក់លើ ភាគតិចគោរពភាគច្រើន សមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវដោយឡែក ។

◆ មានរបបរាយការណ៍ពីក្រោម ហើយពីលើទៅក្រោមវិញតាមគោលការណ៍ពីមហាជនទៅមហាជនវិញ ។

មាត្រា១០ៈ ខ្សែចាត់តាំងរបស់"សម្ព័ន្ធយុវកក"មានដូចតទៅៈ

◆ ភូមិ សង្កាត់ ជួរ រោងចក្រ ក្រសួង ធ្វើជាអង្គភាពមូលដ្ឋាន ។ ឃុំមានពី២ភូមិឡើងទៅ ស្រុក សង្កាត់ ក្រុង មានពី៣ឃុំ សង្កាត់ ជួរ រោងចក្រ ក្រសួង ឡើងទៅ ។ ខេត្តក្រុងមាន

ពី៣ស្រុក សង្កាត់ ក្រុង ឡើងទៅ ។ មជ្ឈិមមាន៣ខេត្តក្រុងឡើងទៅ ។

មាត្រា១១ៈ ការចាត់តាំងអង្គការមូលដ្ឋាន ក្នុងភូមិ សង្កាត់ ផ្លូវ រោងចក្រ ក្រសួង មានដូចតទៅៈ

◆ ៣នាក់ឡើងទៅចាត់តាំងជាក្រុមរបស់ "សម្ព័ន្ធយុវកក" ហៅកាត់ថា"ក្រុមសម្ព័ន្ធយុវកក" ។

◆ ៦នាក់ឡើងទៅចាត់តាំងជាក្រុម"សម្ព័ន្ធយុវកក"ដដែល តែបែកជា២អនុក្រុម មាន៣-៣នាក់ ។ មានប្រធាន១ អនុប្រធាន១ ។ ៩នាក់ឡើងទៅចាត់តាំងជា"ក្រុមសម្ព័ន្ធយុវកក" ដដែល តែបែកជា៣អនុក្រុម មាន៣-៣នាក់ ។ មានគណៈកម្មាធិការ "ក្រុមសម្ព័ន្ធយុវកក"មួយដឹកនាំ ។

មាត្រា១២ៈ ១) "សម្ព័ន្ធយុវកក" មានការប្រជុំជីវភាពនិង សន្និបាតតាមធម្មតាដូចតទៅៈ ក្រុមឬអនុក្រុម១៥ថ្ងៃម្តង គណៈឃុំ១ខែម្តង សន្និបាត៣ខែម្តង គណៈស្រុក សង្កាត់ ក្រុង ១ខែម្តង សន្និបាត៣ខែម្តង គណៈស្រុក សង្កាត់ ក្រុង ១ខែម្តង សន្និបាត៦ខែម្តង គណៈខេត្តក្រុង៣ខែម្តង សន្និបាត១២ខែម្តង គណៈមជ្ឈិម៦ខែម្តង មហាសន្និបាត២ឆ្នាំម្តង អាចមានការប្រជុំជីវភាពនិងសន្និបាតឬមហាសន្និបាតពិសេសក្នុងករណីជាចាំបាច់ សន្និបាតឬមហាសន្និបាតមានភារកិច្ចពិនិត្យសកម្មភាពកន្លងទៅ ពិនិត្យថវិកា ។

◆ អនុមតិកម្មវិធីការងារថ្មី

◆ ជ្រើសរើសគណៈកម្មាធិការថ្មី

◆ កែប្រែលក្ខន្តិកៈនិងកម្មវិធីនយោបាយ (ចំពោះមហាសន្និបាត)

៣) អំពីវិន័យ

មាត្រា១៣ៈ ១) វិន័យរបស់"សម្ព័ន្ធយុវកក"ជាវិន័យដែលគោរព និងអនុវត្តដោយភ្ញាក់រលឹករបស់សមាជិក ។ តាមរយៈនោះ វាជាវិន័យរឹងប៉ឹងគ្មានធូររលុងឡើយ ។ សមាជិកណា អង្គការថ្នាក់ណា អនុវត្តបានដោយសមត្រឹមត្រូវល្អនូវលក្ខន្តិកៈកម្មវិធីនយោបាយរបស់"សម្ព័ន្ធយុវកក" ហើយនិងភារកិច្ច សិទ្ធិ របស់សមាជិក"សម្ព័ន្ធយុវកក" ត្រូវបានសរសើរឬលើកស្ទួយតាមកម្រិតនិងតាមថ្នាក់ឲ្យសមតាមគុណសម្បត្តិរបស់ខ្លួន ។

◆ សមាជិកណា អង្គការថ្នាក់ណា ធ្វើឲ្យប៉ះពាល់ឬរំលោភ ធ្វើឲ្យខូចអន្តរាយដល់លក្ខន្តិកៈកម្មវិធីនយោបាយរបស់ "សម្ព័ន្ធយុវកក" ហើយនិងភារកិច្ច សិទ្ធិ របស់សមាជិក"សម្ព័ន្ធយុវកក" ត្រូវទិតៀន ព្រមាន ឬមានវិធានការធ្ងន់ស្រាលទៅតាមសភាពកំហុសរបស់ខ្លួន ។

៤) អំពីថវិកា

មាត្រា១៤ៈ ថវិកានិងទ្រព្យសម្បត្តិរបស់"សម្ព័ន្ធយុវកក"បានមកពីៈ

◆ វិភាគទានរបស់សមាជិកម្នាក់ៗ ។ កំណត់១រៀលក្នុង១ខែ ។ ចំពោះសមាជិកណាដែលក្រមែនទែននោះ អនុគ្រោះលើកលែងមិនឲ្យបង់ជារយៈកាលខ្លីវែងតាមដែលអង្គការកំណត់ ។ អំណោយផ្សេងៗជាប្រាក់កាសជាសម្ភាររបស់សមាជិក របស់មហាជន ឬរបស់អង្គការបដិវត្តន៍ផ្សេងៗ ។ ការទុកដាក់ចាត់ចែងចាយវាយប្រើប្រាស់ថវិកានិងទ្រព្យសម្បត្តិរបស់"សម្ព័ន្ធយុវកក" ត្រូវមានរបបសន្សំសំចៃថែរក្សាឲ្យបានល្អ ហើយមានបញ្ជីមួយត្រឹមត្រូវច្បាស់លាស់ជាប្រក្រតី ។

អំពីការអនុមតិនិងកែប្រែលក្ខន្តិកៈ

មាត្រា១៥ៈ លក្ខន្តិកៈនេះទុកជាបណ្តោះអាសន្ន និងអនុវត្តវាជាបណ្តោះអាសន្ន ។ មានតែមហាសន្និបាត"សម្ព័ន្ធយុវកក"ទេ ទើបមានសិទ្ធិអនុមតិឬកែប្រែលក្ខន្តិកៈរបស់"សម្ព័ន្ធយុវកក" ។

(ចម្លងតាមច្បាប់ដើមទាំងស្រុងពីសៀវភៅកត់ត្រា
របស់សមមិត្ត អ៊ីវ ប៊ុនឈឿន)

**ពន្យល់ពាក្យរបស់ខ្មែរក្រហម**

◆ **ទិតៀនៈ** ជួយយោបល់រំឭកកសាងដាស់តឿន កសាងមិត្តជុំវិញខ្លួនទាំងគុណសម្បត្តិនិងវិបត្តិដោយស្មារតីស្មោះសបរិសុទ្ធ ។

◆ **ស្វ័យទិតៀនៈ** លើកយកចំណុចខ្លាំងចំណុចខ្សោយរបស់ខ្លួនជូនមិត្តជុំវិញខ្លួនជ្រាប និងស្នើសុំបណ្តាមិត្តជុំវិញជួយជាយោបល់កសាងខ្លួនដោយទឹកចិត្តស្មោះត្រង់បំផុត មិនលាក់កំបាំងនូវការខុសឆ្គងណាមួយទាំងអស់ ។

◆ **សកម្មៈ** ញាប់ដៃញាប់ជើងនិងដោយយកចិត្តទុកដាក់ ។

◆ **សន្និបាតៈ** ការប្រជុំពិភាក្សាអំពីបញ្ហាអ្វីមួយតាមកាលកំណត់ ។

◆ **លក្ខការណ៍ៈ** ការកំណត់ ។ **វ៉ែម សុខឃីម**

# ឯកសារសមមិត្ត ពីន

សូមមើលរូបភាពនៅលើក្របខាងមុខនៃទស្សនាវដ្ដីលេខនេះ ឬរូបខាងក្រោមដែលចម្លងមកពីក្របខាងមុខ ។ បុរសម្នាក់ដែលឈរនៅខាងក្រោយនោះគឺជាសមមិត្ត ពីន អតីតលេខាកងពល៧០៣ មជ្ឈិម ប្រចាំការនៅភូមិភាគបូព៌ា និងជាសមាជិកគណៈភូមិភាគ បន្ទាប់ពី សោ ភឹម ត្រូវបានកម្ទេច ។ សមមិត្ត ពីន បានធ្វើការងារជាមួយសន្តិសុខនៅគុកទួលស្លែង ។ សមមិត្ត ពីន ធ្លាប់បានអមដំណើរអ្នកស្រី អេលីហ្សាប៊ែត ប៊ែកយ័រ (អ្នកនិពន្ធសៀវភៅ "នៅពេលដែលសង្គ្រាមបានរលត់ទៅ") ទៅតំបន់ក្រែក ខេត្តកំពង់ចាម នៅឆ្នាំ១៩៧៨ ។ សមមិត្ត ពីន ត្រូវបានអង្គការយកទៅសម្លាប់នៅដើមឆ្នាំ១៩៧៩ ដោយចោទថាក្បត់ ។

ខាងក្រោមនេះជាឯកសារមួយចំនួនដែលពាក់ព័ន្ធនឹងសមមិត្ត ពីន÷

**◆ឯកសារលេខ L ២៥៧៖ សេចក្ដីរាយការណ៍**

គោរពជូនសមមិត្ត សោម មន្ទីរ៦២ ជាទីគោរព ។

កម្មវត្ថុ៖ ស្ដីអំពីបាតុភាពនិងសកម្មភាពកងពល០៨ (ក្រុមសេរី) កន្លងមក ។

១) ឈ្មោះ ម៉េង ញឹល៖ ធ្វើពុតក្បួតឈឺច្រើន មិនធ្វើការ លួចដុះអាចម៍ដាក់កន្លែងដេកជាច្រើនលើកច្រើនសា ។ សកម្មភាពលួចមានជាបន្តបន្ទាប់ សមូហភាពកសាងពីព្រឹកល្ងាចលួចទៀត ។ បាយហូបមិនអស់ចាក់ចោល ហើយលួចបាយជ្រូកហូប ។ កន្លងមកបានរួមគ្នា៤នាក់មានឈ្មោះ អោ អេង ម៉េង ទ្រី យន រុន លួចកាប់មេមាន់ហូបអស់៣ដោយឯកជន ។

២) ឈ្មោះ យន រុន៖ សកម្មភាពលួចព្រ័ត្រស្បែកក្របី ដែលមិត្តយើងចងនឹមយកមកដុតហូប ស៊ីត្រីឆៅ ស្ងោរកូនជ្រូកស្អុយស៊ីទាំងរោម ។ បើហូបបាយហូបទាល់តែងើបអង្គុយលែងចង់រួច ហូបសម្លធំជាងបាយ សម្លមួយឆ្នាំងលេខ១០ហូប៨នាក់មិនគ្រាន់ទេ ។ ពេលកម្មាភិបាលប្រជុំលួចលូនចូលស្ដាប់ជាញឹកញាប់ ។

៣) ឈ្មោះ ម៉េង ទ្រី៖ សកម្មភាពលួចនេះលួចនោះជាបន្តបន្ទាប់ លួចនាឡិកា លួចពងមាន់ លួចបាយ+លួចស៊ីបាយជ្រូក យកកូនឆ្មាស្អុយស្ងោរស៊ីទាំងរោម ។ បញ្ហាហូបអាស្រ័យគ្រប់គ្រាន់ តែពេលហូបឆ្អែតហើយសល់ចាក់ចោល ពុតក្បួតឈឺច្រើន គេចអត់ទៅធ្វើការ លួចដេកក្រោមផ្ទះ ពេលមិត្តយើងជួប រត់ចេញពីក្រោមផ្ទះទៅដេកនៅតាមភ្លឺស្រែក្រោមដើមឈើ ។

៤) ឈ្មោះ អោ អេង៖ សកម្មភាពសេរី ខ្ជិលធ្វើការងារ លួចមាន់អស់៣ លួចបេះដូងកង់៣១រហូតដល់មិត្តយើងឃាត់ខ្លួន លួចជាបន្តបន្ទាប់ ទោះបីមានការណែនាំញឹកញាប់ ចេញពីប្រជុំហើយលួចទៀត ។

៥) ឈ្មោះ សំរិត បូ៖ សកម្មភាពលួចរាល់ថ្ងៃមិនចេះឈប់ឈរ លួចពងមាន់ លួចមាន់ លួចបាយ ។ សេរីក្នុងការដើរហើរគ្មានអង្គការវិន័យ ពេលកម្មាភិបាលហៅកសាងមុខញញឹមជាប់ហាក់ដូចជាគ្មានរឿងអី ។

-សេចក្ដីបញ្ជាក់៖ ចំពោះកង០៨ពិសោធន៍កន្លងមកបាយធ្លាប់ដាំ៣០គីឡូអង្ករ ហើយបើដាំដល់ទៅ៦០គីឡូអង្ករក៏នៅតែហូបអស់ដែរ ហូបៗទាល់តែងើបលែងចង់រួច ។ កន្លងមកក្នុងការអប់រំកសាង + ដោះស្រាយបាតុភាពផ្សេងៗ បានធ្វើជាបន្តបន្ទាប់តែមិនព្រមកែប្រែ ដូចនេះស្នើសុំដកចេញពីអង្គភាព ។ សេចក្ដីរាយការណ៍ខាងលើនេះសូមសមមិត្ត



សមមិត្ត ពីន

ជ្រាបនិងស្នើសុំយោបល់សំរេច ។

គោរពដោយស្មារតីប្រុងប្រយ័ត្នបដិវត្តខ្ពស់បំផុត ។

ផ្ញើនៅថ្ងៃទី២២-១២-៧៦ ជ.គណៈកងពល៧០៣, ពីន

**សេចក្តីសំរេចចិត្ត**

ឈ្មោះជនក្បត់មានដូចខាងក្រោម÷

១) អ៊ីង ប៊ុនឡាក់ សក្តិ៤នៅព្រៃស យោរយៅឡើងសក្តិរហ័ស ។

២) ខាំ ភួង សក្តិ៤កន្ទះ អតីតមេបញ្ជាការស៊ុបតាខ្មៅ គ្រួសារវាសុទ្ធតែក្បត់ទាំងអស់ អានេះធាតុកាចសាហាវណាស់ ។

៣) ឯម ថន គិញ

៤) កាំង គីមលាង សក្តិ១ទាហាន កងពិសេសរបស់អា អ៊ិត សួង ។

៥) ម៉ាញ់ ឈួន សក្តិ៤កន្ទះ មេទាហានបរិចារកិច្ចយោធា "ចាប់ទាហាន" ។

៦) អ៊ឺ លាងឆាង សក្តិ៤ទាហាន ធ្លាប់ច្បាំងនៅអាល្បឺម៉ង់ អ៊ីរ៉ុបតាំងពីកូនទាហានអានេះយោរយៅណាស់ ។

៧) ស៊ីសុវត្ថិ រិទ្ធិថាវ៉ាវង្ស សក្តិ៤កន្ទះ ពូជសក្តិភូមិក្បត់ប្រជាជន ។

៨) អាំ សាឆេន សក្តិ៥ទាហាន ដៃជើងផ្ទាល់អា សាក់ស៊ុតសាខន និងអា ហ៊ួ ហុង ។

៩) សំ សិន សក្តិ៤ទាហាន ធ្លាប់នៅកងពលតូចលេខ២០ ។

១០) ទេស សាអុន សក្តិ៤កន្ទះ ដៃជើងផ្ទាល់អា អំរ៉ុងរាយការណ៍ស្ថានការណ៍សឹករាល់ថ្ងៃ ។

១១) នួន យុច សក្តិ៤ប៉េអឹម គ្រួសារវាក្បត់ទាំងអស់ អានេះយោរយៅណាស់ ។

១២) ប្រាក់ វណ្ណារិន សក្តិ៤ទាហាន កងពលតូចលេខ២៨ ធាតុយោរយៅបំផុត អានេះសរសេរប្រវត្តិរូបគ្នះគិះដៀលយើងខ្លាំងណាស់ ធាតុដាច់ខាតប្រឆាំងនឹងបដិវត្តន៍ ។

១៣) ជ័រ យូហ៊ា ខ្មែរកាត់ចិន សក្តិ២គិញ ទាហានហ្វាស៊ីសយោរយៅបំផុត ។

១៤) អ៊ឹម សាយ សក្តិ២ទាហាន ពុករលួយពាលាអាវាសែយោរយៅវាជាអតីតគ្រូបង្រៀនក្បត់ ប្រវត្តិរូបវាគ្នះគិះដៀលយើងខ្លាំងណាស់ផ្នែកសង្គ្រាមចិត្តសាស្ត្រ ចំឡើយរបស់វាដាច់ខាតគាំទ្ររបបសាធារណរដ្ឋ ប្រឆាំងបដិវត្តន៍ ។

១៥) សោម សាខុម សក្តិ២ទាហានហ្វាស៊ីស នៅជាមួយអាឆួន លីយាង និន្នាការសង្គ្រាមនយោបាយ ។

១៦) ឡាញ មានស៊ីវ៉ាវុង ទាហានសក្តិ២ ព្រហើនកោងកាចជាមួយយើង ។

១៧) មាន មៀម សក្តិ៣ទាហាន គ្រួសារវាក្បត់ទាំងអស់ ។

ទាំង១៧នាក់នេះបក្សពិនិត្យនិងសំរេចកំទេច ។ ស្នើសមមិត្តអនុវត្តតាមគោលការណ៍របស់បក្ស ។ ថ្ងៃទី៤-៦-៧៥, ស.ម ពីនស្នើទុកពិនិត្យថែមឈ្មោះដូចខាងក្រោមនេះ÷

- ◆ ទូក ស៊ីវន្ថា វេជ្ជបណ្ឌិតសក្តិ២ "ពេទ្យទាហាន"
- ◆ សំ នឹមហេង សក្តិ១ទាហាន
- ◆ គឹម ទ្រី អតីតមេឃុំជ្រោយតាកែវ ។ ថ្ងៃ៤-៦-៧៥

**◆ឯកសារលេខ J ៣៦៨:** ចម្លើយសារភាពរបស់អ្នកទោសគុកទួលស្លែងឈ្មោះ ទី សារ៉េត អតីតនយោបាយកងធំវរសេនាតូច៧០៦ កងពល៧០៣ មានចំណារនៅខាងមុខថា "ជូនសមមិត្តពីន ១ច្បាប់ហើយ, ១៨/៨, ៧០៣" ។

**◆ឯកសារលេខ L ១៣៧៣: កំណត់ហេតុនៃការប្រជុំលេខានិងអនុលេខាកងពលលេខានិងអនុលេខាវរសេនាធំ ថ្ងៃទី២-៨-៧៦ ម៉ោង៧,៣០**

សមមិត្ត ពីន: -ការរៀនសូត្របានផ្សព្វផ្សាយតាំងពីបក្ខជនរហូតសម្ព័ន្ធយុវកក នៅសល់តែ២វរសេនាតូចទៀតពុំទាន់បានផ្សាយដល់មហាជន ។ លទ្ធផលរៀនសូត្រលើកនេះឃើញមានការរីកចំរើនល្អជាទូទៅ តែសមាសភាពមិនល្អខ្លះចេញប្រតិកម្មជំទាស់ ។ មាន២នាក់ចេញអាកប្បកិរិយាប្រឆាំងរករឿងហេតុវាយប្រហារកម្មាភិបាលខាងលើ ក្នុងជំហរទំនាស់ពីរឿងបុណ្យសក្តិ ។

-បញ្ហាស្រូវស្រាល ផែនការ៣០០ហិកតាធ្វើបាន១៩៣ហិកតា ។ សាប៤០០បាវតែខូចអស់១៥០បាវ ។ ការឃើតយ៉ាវមកពីខ្វះសំណាប ។ ដី៣០០ហិកតានិងច្បាស់ជាសំរេចបាន ។ សំណាងមាន៣០០បាវទៀត ។

-បញ្ហាស្រូវធ្ងន់ស្ទូងបាន១២៦ហិកតា ។ ពិសោធធ្វើដីមិនទាន់បានល្អ នៅមានស្មៅនិងដីទាបខ្ពស់ ស្ទូងញឹកបុរធ្មើលពុំស្របតាមសភាពការណ៍ដី ។

ចំណុចខ្វាំងក្រោយការរៀនសូត្រ**(តទៅទំព័រទី២៣)**

# ច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម

នៅថ្ងៃសុក្រ ទី២៩ ខែធ្នូ ឆ្នាំ២០០០ សភាជាតិនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើការពិភាក្សានិងអនុម័តលើសេចក្តីព្រាងច្បាប់ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

សេចក្តីព្រាងច្បាប់នេះមាន១៨ជំពូក ចែកចេញជា៤៧មាត្រា ។ នៅក្នុងជំពូកទី១ស្តីអំពីបទបញ្ញត្តិទូទៅ មានមួយមាត្រាហើយត្រូវបានអនុម័តនៅក្នុងថ្ងៃដដែល ។ មាត្រាទី១ចែងថា "ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា រំលោភទៅលើច្បាប់និងទម្លាប់អន្តរជាតិ ហើយនិងរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩» ។ ជំពូកនិងមាត្រាដទៃទៀតបានអនុម័តនៅថ្ងៃអង្គារ៍ ទី២ ខែមករា ឆ្នាំ២០០១ ។ នៅក្រោយពេលដែលសភាពិនិត្យនិងអនុម័តច្បាប់រួចហើយព្រឹទ្ធសភាជាតិនឹងពិនិត្យលើសេចក្តីព្រាងច្បាប់នេះដើម្បីអនុម័ត ។ បន្ទាប់មកត្រូវមានការអនុម័តពីក្រុមប្រឹក្សាធម្មនុញ្ញ ។ ចុងក្រោយបង្អស់តម្រូវឲ្យមានឡាយព្រះហស្តលេខារបស់ព្រះមហាក្សត្រខ្មែរ មុនពេលដែលអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាចុះកិច្ចព្រមព្រៀងជាផ្លូវការក្នុងការរៀបចំដំណើរការនៃតុលាការនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកម្ពុជាបានធ្វើកំណត់ហេតុទាំងស្រុងលើកិច្ចពិភាក្សានិងអនុម័តសេចក្តីព្រាងច្បាប់ ។

**ឆាំង យុ**

**(សូមអានទំព័រពិសេស ទំព័រលេខ៦១)**



# ជនជាតិចាមក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

ក្នុងចំណោមមនុស្សដែលត្រូវខ្មែរក្រហមសម្លាប់ និង សាសនាប្រពៃណីដែលត្រូវធ្វើឲ្យសូន្យសុង ជនជាតិចាមនិង សាសនាឥស្លាមក្នុងប្រទេសកម្ពុជាគឺជាជាតិសាសន៍មួយដែល បានទទួលរងគ្រោះថ្នាក់ក៏ធ្ងន់ធ្ងរដោយសាររបបខ្មែរក្រហម ។ ក្នុងចំណោមជនរងគ្រោះទាំងអស់ជិត២លាននាក់ មានជនជាតិ ចាមប្រមាណពី៤ទៅ៥សែននាក់ដែលបានស្លាប់បាត់បង់ជីវិត ។ តួលេខនៃការស្លាប់របស់ជនជាតិចាមទាំងនេះគឺយោងតាម លោក ហ្សាការីយ៉ា អាដាម ដែលធ្លាប់ឃើញស្ថិតិរបស់លោក រាជាធិបតី រ៉េស ឡោះ អតីតចាងហ្វាងសាសនាឥស្លាមកម្ពុជា ក្នុងសម័យសង្គមរាស្ត្រនិយមនិងសាធារណរដ្ឋខ្មែរ ។ យោងតាម លោក វ៉ាន ម៉ាត់ ដែលធ្លាប់ឃើញស្ថិតិរបស់ឧត្តមសេនីយ៍ ឡេស កសឹម ជាអ្នកស្រាវជ្រាវអំពីជនជាតិចាមនៅមុនឆ្នាំ១៩៧៥ អំពីចំនួនជនជាតិចាមក្នុងប្រទេសកម្ពុជា និងយោងតាមការចងចាំ ភាគច្រើនរបស់អ្នកដឹកនាំសហគមន៍ចាមបានឲ្យដឹងពីចំនួនសរុប របស់ប្រជាជនចាមនៅមុនឆ្នាំ១៩៧៥ មានចំនួនប្រហែល៧ សែននាក់ នៅក្នុងប្រទេសកម្ពុជាដែលមានប្រជាជនសរុបជាង៧ លាននាក់ ។ ក្រោយរបបខ្មែរក្រហមត្រូវបានដួលរលំនៅឆ្នាំ១៩៧៩ តាមតំណាងសហគមន៍ជនជាតិចាម និងលោក នៃ ប៉េណា អ្នកនិពន្ធសៀវភៅ "ការដួលរលំរបបប្រល័យពូជសាសន៍ ប៉ុល ពត" បោះពុម្ពឆ្នាំ១៩៩១ បញ្ជាក់ថា វត្តមាននៃជនជាតិចាម រាប់ទៅឃើញនៅសល់តែ២សែននាក់ប៉ុណ្ណោះ ។ ក្នុងចំណោម ប្រជាជនចាម៧នាក់មាន៤ឬ៥នាក់ដែលត្រូវស្លាប់ ។ ប៉ុន្តែនៅក្នុង សៀវភៅ "របប ប៉ុល ពត" របស់ប្រវត្តិវិទូ ប៊ែន គៀរនិន បោះពុម្ពឆ្នាំ១៩៩៦ បានរាយការណ៍ថា នៅឆ្នាំ១៩៧៥ប្រជាជន ចាមមានចំនួន២សែន ៥ម៉ឺននាក់ ហើយមកដល់ឆ្នាំ១៩៧៩ ប្រជាជនចាមនៅសល់១សែន៧ម៉ឺន ៣ពាន់នាក់ ដូច្នេះតួលេខ នៃការស្លាប់គិតបញ្ចូលទាំងអត្រាកើតយ៉ាងខ្ពស់បំផុត១ម៉ឺន៣ ពាន់នាក់ផងនោះ ឃើញថាមានជនជាតិចាមចំនួន៩ម៉ឺននាក់ដែល បានស្លាប់ក្នុងជំនាន់ប៉ុលពត ។

តាមការស្រាវជ្រាវរបស់ខ្ញុំមានលក្ខណៈស្របគ្នាជាមួយ ប្រវត្តិវិទូ ប៊ែន គៀរនិន នៅលើចំណុចថា ប្រជាជនចាមនៅ ឆ្នាំ១៩៧៩នៅសល់ប្រមាណ២សែននាក់ ប៉ុន្តែឃើញមានការ ខុសគ្នាឆ្ងាយដាច់ស្រឡះអំពីចំនួននៃប្រជាជនចាមនៅមុនឆ្នាំ ១៩៧៥ ។ តាមទូរលេខរបស់ខ្មែរក្រហម លេខ១៥ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ក៏បានបញ្ជាក់អំពីចំនួនប្រជាជនចាម ក្នុងភូមិភាគបូព៌ានៅសល់ជាង១សែននាក់ទៀតបន្ទាប់ពីការ ជម្លៀសទៅភូមិភាគឧត្តរ៥ម៉ឺននាក់ ។ ដូច្នេះមានន័យថាត្រឹមតែ មួយផ្នែកនៃខេត្តកំពង់ចាមតែប៉ុណ្ណោះមានប្រជាជនចាមចំនួន១ សែន៥ម៉ឺននាក់ ។ ប្រសិនបើបូកសរុបចំនួនជនជាតិចាមនៅ តាមស្រុកផ្សេងៗទៀតក្នុងខេត្តកំពង់ចាមនិងខេត្តក្រុងដទៃទៀត លើចំនួន១សែន៥ម៉ឺននាក់នោះ ធ្វើឲ្យចំនួនជនជាតិចាមទូទាំង ប្រទេសពិតជាកើនឡើងលើសពីចំនួនដែលអ្នកស្រាវជ្រាវ បរទេសបានរកឃើញ ហើយតួលេខនោះអាចប្រហាក់ប្រហែល ទៅនឹងតួលេខរបស់លោករាជាធិបតី រ៉េស ឡោះ និង ឡេស កសឹម ក៏ដូចជាការចងចាំរបស់ជនជាតិចាមស្ទើរគ្រប់ៗគ្នាដែល ថាមានប្រជាជនចាម៧សែននាក់នៅឆ្នាំ១៩៧៥ ។

ខាងក្រោមនេះជាតួលេខនៃការបាត់បង់ជនជាតិចាមនៅ តាមភូមិខ្លះ÷

◆ ភូមិស្វាយឃ្លាំង មុនឆ្នាំ១៩៧៥មានប្រជាជន១២៤០ គ្រួសារ ក្រោយឆ្នាំ១៩៧៩មានតែ១២០គ្រួសារ ។

◆ ភូមិអកមោក មុនឆ្នាំ១៩៧៥មានប្រជាជន១១០០ គ្រួសារ ក្រោយឆ្នាំ១៩៧៩មានតែ១០០គ្រួសារ ។

◆ ភូមិជ្រោយចង្វារក្រោម (វិហារឯករង្សី) មុនឆ្នាំ១៩៧៥ មានប្រជាជនច្រើនជាង ១ ០០០ គ្រួសារ តែក្រោយឆ្នាំ១៩៧៩ មានតែ៣០គ្រួសារប៉ុណ្ណោះ ។

◆ ភូមិសំរោង មុនឆ្នាំ១៩៧៥មានប្រជាជន៤០គ្រួសារ ក្រោយឆ្នាំ១៩៧៩មានតែ៦គ្រួសារ ។

◆ ភូមិត្រពាំងឈូក មុនឆ្នាំ១៩៧៥មានប្រជាជន២៥០

គ្រួសារ ក្រោយឆ្នាំ១៩៧៩មានតែ២០០គ្រួសារ ។

◆ ភូមិដូនប៉ែន មុនឆ្នាំ១៩៧៥មានប្រជាជន១៥០គ្រួសារ ក្រោយឆ្នាំ១៩៧៩មានតែ១០០គ្រួសារ ។

◆ ភូមិកោះដល មុនឆ្នាំ១៩៧៥មានប្រជាជន១៨៦៤នាក់ ក្រោយឆ្នាំ១៩៧៩មានតែ១៨០នាក់(**គ្មានគូលេខជាគ្រួសារទេ**) ។

ជាងនេះទៅទៀត ភូមិចាមចំនួន៩ត្រូវពួកខ្មែរក្រហមសម្លាប់អ្នកភូមិស្ទើរតែទាំងអស់ ។ សមាជិកភូមិនោះនៅសល់តិចបំផុតត្រឹមតែ៤-៥នាក់ ហើយមិនអាចរស់នៅឯកោក្នុងភូមិនោះបានក៏សម្រេចចិត្តបោះបង់ចោលផ្ទះសម្បែងភូមិកំណើតរបស់ខ្លួនរត់ទៅជ្រកកោនក្នុងភូមិផ្សេងៗទៅវិញ ។ អតីតភូមិចាមទាំងនោះបច្ចុប្បន្នខ្លះក្លាយជាដីស្រែចម្ការ ។ ភូមិទាំងនោះគឺភូមិបាយកាយក្នុងស្រុកល្វាឯម ភូមិពោធិ៍ទន្លេក្នុងស្រុកកោះធំ ខេត្តកណ្តាល ។ ភូមិកោះប្រាក់ ភូមិចម្ការសាមសិប ភូមិក្រគរ ភូមិកោះរកា ភូមិល្អាង ភូមិទាំង៥នេះនៅក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ ភូមិខ្វាវក្នុងស្រុក ព្រៃឈរ ខេត្តកំពង់ចាម ។ ភូមិទួលល្វាងក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

រាល់ការអនុវត្តនយោបាយកម្ទេចសាសនា ទំនៀមទម្លាប់ប្រពៃណីរបស់ជនជាតិចាម ពួកខ្មែរក្រហមជ្រើសរើសជនជាតិចាមណាដែលមានជីវភាពឬវណ្ណៈទាបបំផុតក្នុងភូមិឲ្យធ្វើជាអ្នកដឹកនាំ ។ គោលបំណងរបស់ខ្មែរក្រហមសំដៅចង់ឲ្យចាមសម្លាប់ចាម ចាមតាមដាននិងរាយការណ៍ពីចាមគ្នាឯង ចាមបំបិទសាសនានិងលុបបំបាត់ប្រពៃណីទំនៀមទម្លាប់ខ្លួនឯង ដូចជាការបិទទ្វារម៉ាស្ជិត (វិហារ) ហាមប្រាមមិនឲ្យសំបះយ៉ាង (ថ្វាយបង្គំ) មិនឲ្យសោម (បួស) ហ្សាកាត់ (បរិច្ចាគ) និងធ្វើពិធីបុណ្យសាសនាផ្សេងៗ ។ ការប្រមូលគម្ពីគូរអាន-កីតាប ការប្រមូលសារុង កន្ទប ម៉ាខ្នា (អាវវែងសម្រាប់សំយ៉ាង) ការចាប់បង្ខំឲ្យទទួលទានសាច់ជ្រូក ការចាប់បង្ខំឲ្យស្ត្រីកាត់សក់ខ្លី និងការមិនឲ្យទទូក្បាលតាមប្រពៃណី ។ ក្នុងកិច្ចការនេះខាងលើបើគ្មានជនជាតិចាមខ្លួនឯងបម្រើនយោបាយនិងចង្អុលប្រាប់គ្រឹះសំខាន់ៗរបស់សាសនាខ្លួនទេនោះ ក៏ពួកខ្មែរក្រហមមិនអាចដឹងថាតើធ្វើអ្វីខ្លះទើបប៉ះពាល់ដល់ ជំនឿ សាសនា ទំនៀមទម្លាប់ប្រពៃណីពីបុរាណកាលរបស់ក្រុមជនជាតិចាមដែរ ។ តាមទិសដៅនេះ ពួកខ្មែរក្រហមមិនអាចសម្រេចបានជោគជ័យទាំងស្រុងឡើយ ។ ហ៊ីម ឡេស ជាប្រធានភូមិពោធិ៍ទន្លេដែលខ្មែរក្រហមចាត់តាំងបានស៊ុំមគ្រលុំឲ្យប្រជាជនចាមរត់គៀសខ្លួនទៅប្រទេសវៀតណាមរហូតដល់ ខ្លួនគាត់ជាប់ឃុំឃាំងជាង១ឆ្នាំដោយសាររឿងនេះ ។ ម៉ាត់ លី ជាគណៈស្រុកត្បូងឃ្មុំ សុខចិត្តរត់ចូលព្រៃដោយមិនអាចស៊ូទ្រាំនឹងការមើលឃើញពួកខ្មែរក្រហមធ្វើបាបជនជាតិចាមគ្នាឯង ។ ស្មាន កាជិ ជាអ្នកដឹកនាំភូមិស្វាយឃ្លាំងរបស់ខ្មែរក្រហម និង រើស ទត ជាប្រធានភូមិកោះដលរបស់ខ្មែរក្រហមបានបំផុសឲ្យប្រជាជនងើបបះបោរនៅពេលដែលអង្គការថ្នាក់លើបញ្ជាឲ្យគាត់ទាំងពីរបិទទ្វារ ម៉ាស្ជិទ (វិហារ) ។

ថ្នាក់ដឹកនាំសាសនាឥស្លាមសំខាន់ៗដែលបានស្លាប់ក្នុងរបបខ្មែរក្រហមរួមមានដូចខាងក្រោម÷


រើស ឡោះ


ស្លៃម៉ាន សុគ្រី


ម៉ាត់ស្មេះ ស្លៃម៉ាន

១) ហាជ្ជីរាជាធិបតី រើស ឡោះ ចាងហ្វាងឥស្លាមកម្ពុជា ត្រូវចាប់ខ្លួននៅឆ្នាំ ១៩៧៥ នៅភូមិមេសប្រចណ្ឌ ឃុំមេសប្រចណ្ឌ ស្រុកពារាំង ខេត្តព្រៃវែង ។

២) ហាជ្ជី ស្លៃម៉ាន សុគ្រី ចាងហ្វាងឥស្លាមរងទី១ ត្រូវចាប់ខ្លួននៅឆ្នាំ១៩៧៥ នៅភូមិគោហេ ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល ។

៣) ហាជ្ជី ម៉ាត់ស្មេះ ស្លៃម៉ាន ចាងហ្វាងឥស្លាមរងទី២ ត្រូវចាប់ខ្លួននិងសម្លាប់នៅឆ្នាំ១៩៧៦ នៅភូមិបាក់រទេះ ឃុំព្រែកហ្លួង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

៤) ហាជ្ជី ម៉ាត់ លីហារូន ប្រធានសមាគមឥស្លាមកម្ពុជា ត្រូវចាប់ខ្លួននៅឆ្នាំ១៩៧៥ នៅភូមិចាមលើ ឃុំព្រែកថ្មី ស្រុកពារាំង ខេត្តកណ្តាល ។

៥) ហាជ្ជី ស្រង យូសុះ អ្នកដឹកនាំសាសនាឥស្លាមដែល



ហាជ្ជី ស្រង់ យូសុះ

បានទៅសិក្សានៅប្រទេសអេហ្ស៊ីប ត្រូវចាប់ខ្លួននិងសម្លាប់នៅឆ្នាំ ១៩៧៥ នៅភូមិមេស ប្របណ្ឌ ឃុំមេសប្របណ្ឌ ស្រុកពារាំង ខេត្តព្រៃវែង ។

៦) តួនហាជ្ជី លី មូសា សាស្ត្រាចារ្យមកពីប្រទេសម៉ាឡេស៊ី ត្រូវសម្លាប់នៅឆ្នាំ ១៩៧៥ នៅគុកស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។



ម៉ាន សេត

៧) ម៉ាន សេត ប្រធានសមាគមយុវជនឥស្លាម (មិនដឹងទីកន្លែង និងពេលវេលាដែលត្រូវចាប់ខ្លួន និងសម្លាប់) ។

៨) តួនហាជ្ជី យូសុះ អាវនី សាស្ត្រាចារ្យមកពីអារ៉ាប៊ីសាអ៊ូឌីត ត្រូវចាប់ខ្លួននៅឆ្នាំ១៩៧៧ នៅភូមិពង្រលីង ឃុំបាក់ស្នា ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

៩) តួនហាជ្ជី ម៉ូហាម៉ាត់ កាដិ ពិន មូសា ទីប្រឹក្សាចាងហ្វាងឥស្លាមត្រូវចាប់ខ្លួនដើមឆ្នាំ១៩៧៤ និងត្រូវសម្លាប់នៅឆ្នាំ១៩៧៥ នៅគុកស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។

១០) តួន ស្លៃម៉ាន ពិន យូសុះ សាស្ត្រាចារ្យមកពីប្រទេសអេហ្ស៊ីប ត្រូវចាប់ខ្លួនដើមឆ្នាំ១៩៧៤ និងត្រូវសម្លាប់នៅឆ្នាំ ១៩៧៥ នៅគុកស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។

១១) តួន យាក់កូប សាស្ត្រាចារ្យ ត្រូវចាប់ខ្លួនដើមឆ្នាំ ១៩៧៤ និងត្រូវសម្លាប់នៅឆ្នាំ១៩៧៥ នៅគុកស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។

១២) តួន អ៊ីស្មាអែល ហ្វាហ៊ី សាស្ត្រាចារ្យ ត្រូវចាប់ខ្លួននៅឆ្នាំ១៩៧៨ នៅភូមិពប្រេង ឃុំពប្រេង ស្រុកចំការលើ ខេត្តកំពង់ចាម ។

១៣) តួន សេស នោ សាស្ត្រាចារ្យ ត្រូវចាប់ខ្លួននៅឆ្នាំ ១៩៧៨ នៅភូមិស្វាយទាប ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ។

១៤) តួន អះម៉ាត់ សាស្ត្រាចារ្យមកពីប្រទេសម៉ាឡេស៊ី ត្រូវចាប់ខ្លួននៅឆ្នាំ១៩៧៥ នៅភូមិពប្រេង ឃុំពប្រេង ស្រុកចំការលើ ខេត្តកំពង់ចាម ។

១៥) តួនហាជ្ជី ម៉ូហាម៉ាត់ អាលី សាស្ត្រាចារ្យមកពីអារ៉ាប៊ីសាអ៊ូឌីត ត្រូវចាប់ខ្លួននៅឆ្នាំ១៩៧៤ នៅភូមិអកមោក ឃុំជយោ ស្រុកចំការលើ ខេត្តកំពង់ចាម ។

១៦) តួនហាជ្ជី ម៉ូហាម៉ាត់ ទត ទីប្រឹក្សាចាងហ្វាងឥស្លាម (មិនដឹងទីកន្លែងនិងពេលវេលាដែលត្រូវចាប់ខ្លួននិងសម្លាប់) ។

១៧) តួនហាជ្ជី អ៊ីទ្រេស ទីប្រឹក្សាចាងហ្វាងឥស្លាម (មិនដឹងទីកន្លែងនិងពេលវេលាដែលត្រូវចាប់ខ្លួននិងសម្លាប់) ។

១៨) ហាជ្ជី ម៉ាត់សើន សាស្ត្រាចារ្យ (មិនដឹងទីកន្លែងនិងពេលវេលាដែលត្រូវចាប់ខ្លួននិងសម្លាប់) ។

អ្នករដ្ឋការជាន់ខ្ពស់និងវរជនចាមដែលបានស្លាប់ក្នុងរបបខ្មែរក្រហមរួមមាន÷



អេល ព្រហ៊ីម

១) អេល ព្រហ៊ីម វរសេនីយ៍ឯក កងរាជអាវុធហត្ថស្រុកមុខកំពូល ស្លាប់នៅខេត្តកណ្ដាល ។

២) ម៉ាត់ ស្លៃម៉ាន វរសេនីយ៍ឯក មេបញ្ជាការកងពលតូចលេខ៥ (មិនដឹងទីកន្លែងស្លាប់) ។

៣) ចិក ប្រាហ៊ីម វរសេនីយ៍ទោ មេបញ្ជាការកងវរសេនាតូច១៨២ ស្លាប់នៅមន្ទីរស-២១(ទួលស្លែង) ។

៤) អ៊ុសការី ដូម៉ាន វរសេនីយ៍ទោ ការិយាល័យទី៣អគ្គសេនាធិការ (មិនដឹងទីកន្លែងស្លាប់) ។

៥) អូស ស្លៃម៉ាន តំណាងរាស្ត្រ (មិនដឹងទីកន្លែងស្លាប់) ។

៦) ហាជ្ជី សាឡេះ យ៉ាស់យ៉ា សមាជិកព្រឹទ្ធសភា ស្លាប់នៅទួលស្លែងមន្ទីរស-២១(ទួលស្លែង) ។

៧) អ៊ីបាហាំ អេញូល មេដឹកនាំចលនាហ្វុលរ៉ូ (មិនដឹងទីកន្លែងស្លាប់) ។

៨) សុះ ម៉ាន ប្រធានចលនាជនជាតិចាម ស្លាប់នៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

លើសពីនេះទៀត ពួកខ្មែរក្រហមបានហាមប្រាមដាច់ខាត

ក្នុងការនិយាយភាសាចាមនិងហៅឈ្មោះតាមភាសាចាម ។ ចាមគ្រប់រូបទាំងក្មេងទាំងចាស់ត្រូវបង្ខំឲ្យប្តូរឈ្មោះ ។ ខ្មែរក្រហមបានសម្រេចជោគជ័យលើចំណុចនេះ ។ ក្រោយពីឆ្នាំ១៩៧៩ ក្មេងៗជនជាតិចាមទាំងអស់ដែលមិនចេះនិយាយភាសាចាម ត្រូវបានឪពុកម្តាយឬគ្រូនក្នុងភូមិបង្រៀនក្មេងៗឲ្យចេះនិយាយភាសាខ្លួនឯងឡើងវិញ ។ ប៉ុន្តែរហូតមកដល់ពេលនេះ ប្រជាជនចាមនៅខេត្តកំពត ក្រុងព្រះសីហនុ នៅកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល និងនៅភូមិប្រាំងចំរេះក្បែរទីក្រុងភ្នំពេញ នៅតែមិនចេះនិយាយភាសាចាមដដែល ។ មុនឆ្នាំ១៩៧៥ អ្នកភូមិទាំងនេះនិយមនិយាយភាសាខ្មែរផងនិងភាសាចាមផង ។ ឆ្លងកាត់របបខ្មែរក្រហមដែលមានការហាមប្រាមនិយាយភាសាកំណើត និងការកាប់សម្លាប់ ហាកឹម គួន និងអ្នកភូមិចាស់ៗដែលចេះនិយាយភាសាចាមអស់ ។ ដូច្នេះក្រោយឆ្នាំ១៩៧៩មកគ្មានអ្នកភូមិដែលនៅរស់អាចចេះនិយាយភាសាកំណើតសម្រាប់បង្រៀនក្មេងៗ ។ ចំណែកឈ្មោះរបស់ជនជាតិចាម ពួកខ្មែរក្រហមគ្មានលទ្ធភាពធ្វើឲ្យមានការផ្លាស់ប្តូរបានមួយរយភាគរយទេ ព្រោះក្នុងជំនាន់នោះ នៅពេលដែលបងប្អូន ឬក្រុមគ្រួសារបានជួបគ្នានៅក្នុងទីដែលមិនមានមនុស្សច្រើន ការប្រាស្រ័យទាក់ទងគ្នានៅតែលួចលាក់ហៅឈ្មោះកំណើតគ្នាទៅវិញទៅមក ។ ក្មេងតូចៗរឹតតែធ្វើឲ្យពិបាកក្នុងការកែប្រែឈ្មោះជាងមនុស្សចាស់ទៅទៀត ពីព្រោះក្មេងៗទាំងនោះមិនអាចចងចាំឈ្មោះថ្មីបាន ។

ប្រជាជនចាមគ្រប់ទីកន្លែងត្រូវបានជម្លៀសចេញពីភូមិឋាន ហើយបំបែកជាហ្វូងតូចៗមាន៤-៥គ្រួសារ ខ្លះឲ្យទៅរស់នៅតាមខ្ទមឆ្ងាយពីភូមិ និងខ្លះទៀតឲ្យទៅរស់នៅក្នុងភូមិជាមួយជនជាតិខ្មែរ ។ ការបែងចែកប្រភេទប្រជាជនចាមជាក្រុមៗនិងឲ្យទៅរស់នៅតាមទីកន្លែងខុសគ្នាយ៉ាងនេះគឺអាស្រ័យទៅតាមទោសកំហុសដែលអង្គការមើលឃើញ ។ មានក្រុមខ្លះហៅថា «ប្រភេទខ្មាំងទី១» ជាអ្នកដែលបង្កកម្លាំងប្រឆាំងបដិវត្តន៍ ។ ក្រុមខ្លះហៅថា «ប្រភេទខ្មាំងទី២» ជាអ្នកដែលគាំទ្រកម្លាំងក្បត់ និងក្រុមខ្លះត្រូវបានចាត់ចូលជា «ប្រភេទខ្មាំងទី៣» ជាអ្នកដែលមានវណ្ណៈទាបក្នុងភូមិ ។ តាមរចនាសម្ព័ន្ធរបស់ខ្លួន ខ្មែរក្រហមបានចាត់ប្រភេទខ្មាំងទី១ ទី២ និងទី៣ ទៅក្នុងប្រភេទ «ប្រជាជនថ្មី» ប៉ុន្តែ



ខុកញ្ញា សុះ គីរី

ហាជ្ជី សុះ សោត ជាមនុស្សម្នាក់ដែលរួចជីវិតក្នុងចំណោមអ្នកទោស៣០០នាក់ដែលត្រូវពួកខ្មែរក្រហមសម្លាប់

កម្រិតនៃទោសពៃរ៍មានធ្ងន់ជាងប្រជាជនថ្មីដែលជាជនជាតិខ្មែរ ។ ការជម្លៀសជនជាតិចាមបំបែកជាហ្វូងតូចៗ នេះគឺជានយោបាយមួយរបស់ខ្មែរក្រហមក្នុងការទប់ស្កាត់មិនឲ្យប្រជាជនចាមមានការរើបម្រះ ដោយមូលហេតុថាមានភូមិ២ជាគំរូស្រាប់ហើយ គឺភូមិស្វាយឃ្លាំងនិងភូមិកោះផលធ្លាប់បានក្រោកឈរប្រឆាំងជាមួយពួកខ្មែរក្រហមជាបន្តបន្ទាប់គ្នាក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ។

ពួកខ្មែរក្រហមមិនមែនសំដៅលុបបំបាត់សាសនាឥស្លាមតែមួយមុខប៉ុណ្ណោះទេ សាសនាអ្វីក៏ដោយក៏សុទ្ធតែចាត់ទុកថាជាសាសនាប្រតិកិរិយាទាំងអស់ ។ ប៉ុន្តែការអនុវត្តវិធានការបោសសម្អាតជនជាតិចាមនិងលុបបំបាត់សាសនាឥស្លាមត្រូវពួកខ្មែរក្រហមចាត់ជាទិសដៅចម្បង ។ លោក សុះ កំរី ត្រូវអង្គការចាត់តាំងឲ្យមើលខុសត្រូវក្មេង១៤០០នាក់ក្នុងឃុំដយោ ស្រុកចំការលើ ខេត្តកំពង់ចាម ពីព្រោះអង្គការមិនបានដឹងថាគាត់ជាជនជាតិចាម ។ មានថ្ងៃមួយ នៅក្នុងឆ្នាំ១៩៧៧ លោក សុះ កំរី ត្រូវបានអង្គការហៅទៅប្រជុំសម្ងាត់នៅភូមិបុសខ្នុរ ឃុំមួយ ស្រុកចំការលើ ខេត្តកំពង់ចាម ។ អង្គប្រជុំមានសមាជិកដែលអង្គការទុកចិត្តចំនួន៤០នាក់ចូលរួម ។ ការប្រជុំនោះនិយាយអំពីផែនការកម្ទេចខ្មាំង ។ លោក សុះ កំរី បានឮអង្គប្រជុំលើកឡើងថា "ខ្មាំងរបស់បដិវត្តន៍មានច្រើនប្រភេទណាស់ ប៉ុន្តែខ្មាំងដែលធំបំផុតនោះគឺចាម ដូច្នេះតាមផែនការត្រូវកម្ទេចចាមឲ្យអស់នៅមុនឆ្នាំ១៩៨០" ។ ថ្ងៃក្រោយមកទៀតលោក សុះ កំរី បានអានសៀវភៅមួយមានចំណងជើងថា "ផែនការសហករណ៍ជឿនលឿន" មានឃ្លាមួយក្នុងសៀវភៅនោះសរសេរថា "ខ្មាំងចំពោះមុខគឺចាម ដូច្នេះត្រូវតែកម្ទេចចាមឲ្យអស់នៅមុនឆ្នាំ១៩៨០" ។ នៅតាមកន្លែងខ្លះមានភស្តុតាងបង្ហាញថាខ្មែរក្រហមពិតជាមានចេតនាក្នុងការរើសអើងចំពោះជនជាតិចាម(ករណីនៅភូមិទ្រា ក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម) ។ នៅដើមឆ្នាំ១៩៧៦ ពួកខ្មែរក្រហមបានប្រមូលអ្នកដែលមានទោសពៃរ៍ផ្តុំគ្នានៅក្នុងផ្ទះមួយដែលមានជនជាតិចាមនិងខ្មែរលាយឡំគ្នា ។ អ្នកទោសទាំងអស់ត្រូវបានសួរចម្លើយតែមួយម៉ាត់គឺ "តើអ្ហែងចាមឬខ្មែរ?" បើអ្នកទោសណាឆ្លើយថាចាមឲ្យនៅម្ខាង បើឆ្លើយថាខ្មែរឲ្យនៅម្ខាង ។ ក្រោយមកអ្នកទោសចាមទាំងអស់ដែលមានចំនួនប្រមាណ១០០នាក់ត្រូវបានបាត់ខ្លួនទាំងអស់ ។ មានបងស្រីជនជាតិចាមម្នាក់ឈ្មោះ នោ សាតាស់ ដែលបានរួចជីវិត ព្រោះគាត់កុហកខ្មែរក្រហមថាខ្លួនគាត់ជាជនជាតិខ្មែរ ។

ជនជាតិចាមត្រូវបានសម្លាប់គ្រប់ទីកន្លែងទាំងអស់ក្នុងប្រទេសកម្ពុជា ភាគច្រើននៃជនជាតិចាមក្នុងខេត្តកំពង់ចាមត្រូវបានជម្លៀសឲ្យទៅរស់នៅក្នុងតំបន់ក្រុងចាញ់ក្នុងខេត្តកំពង់ចាមដដែលនិងខេត្តកំពង់ធំ ។ ជនជាតិចាមនិងជនជាតិខ្មែរដែលរស់នៅក្នុងនិងជិតខាងក្រុងភ្នំពេញមួយចំនួនត្រូវបានជម្លៀស២លើក គឺនៅថ្ងៃទី១៦-១៨ ខែមេសា ឆ្នាំ១៩៧៥ ចេញពីភ្នំពេញទៅស្រុកស្អាងកោះធំ និងមុខកំពូល ក្នុងខេត្តកណ្តាល ហើយក្រោយពីរស់នៅទីនោះបាន៣ឬ៤ខែក៏ត្រូវជម្លៀសទៅបន្តខេត្តព្រះវិហារ និងបាត់ដំបងវិញ ។ ភាគច្រើនជនជាតិចាមក្នុងស្រុកព្រៃនប់ ខេត្តកំពត (បច្ចុប្បន្នខណ្ឌព្រៃនប់ក្រុងព្រះសីហនុ) ត្រូវបានជម្លៀសទៅខេត្តកំពង់ស្ពឺនិងកំពង់ឆ្នាំង ។ ជនជាតិចាមនៅជុំវិញទីរួមខេត្តកំពតត្រូវបានជម្លៀសឲ្យទៅនៅក្នុងស្រុកទូកមាសនិងស្រុកឈូកខេត្តកំពត ។ គ្រប់ខេត្តទាំងអស់នៃប្រទេសកម្ពុជាសុទ្ធតែមានជនជាតិចាមត្រូវបានជម្លៀសទៅដល់ គ្រាន់តែមានចំនួនច្រើនឬតិចតែប៉ុណ្ណោះ ។ ជនជាតិចាមដែលបានស្លាប់ពី៤ទៅ៥សែននាក់នោះ គឺស្លាប់រាយប៉ាយគ្រប់ទីកន្លែង ។ ទីណាមានរណ្តៅសាកសពរួម ទីនោះក៏អាចប្រហែលមានសាកសពជនជាតិចាមរួមជាមួយដែរ ។

**អ៊ីសា ឧស្មាន**

◆ **ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិជឿជំនឿឬសាសនាណាក៏បាន ហើយក៏មានសិទ្ធិមិនមានជំនឿអ្វីឬក៏មិនជឿសាសនាណាក៏បាន។ មិនអនុញ្ញាតឱ្យមានសាសនាប្រតិកិរិយាដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យនិងប្រជាជនកម្ពុជាជាដាច់ខាត។**

(មាត្រា២០ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ)

◆ **ធ្វើការងារច្រើន ទទួលផលច្រើន តែចំណាយធុនតិច។**

(យុវជននិងយុវនារីបដិវត្តន៍ លេខ៣ ខែមីនា ឆ្នាំ១៩៧៦)

# បញ្ជីឈ្មោះជនជាតិចាមដែលជាប់គុកទួលស្លែង (មន្ទីរស-២១) ឆ្នាំ១៩៧៥-៧៩

| ល.រ | ឈ្មោះ | ចាប់មកពី | ថ្ងៃចូលគុក | ថ្ងៃកម្ទេច | ប្រភពឯកសារ |
|---|---|---|---|---|---|
| ១ | ម៉ាត់ អេល | បាត់ដំបង | ១៣-២-៧៦ | ១០-៦-៧៦ | I ០៩១៩៧ |
| ២ | តិប យូណុះ | កំពង់សោម | ២០-៥-៧៦ | ១០-៦-៧៦ | D ០២៦៧៧ |
| ៣ | ម៉ាន សឹម | កងពល៣១០ | ៤-១២-៧៦ | ១៧-៣-៧៧ | បញ្ជីអ្នកទោស |
| ៤ | យ៉ា ម៉ាន | ស-២១យ | ២០-១០-៧៦ | ២៨-១-៧៧ | បញ្ជីអ្នកទោស |
| ៥ | ម៉ាត់ ទាំ | ស-២១ | (ឥតមាន) | ២៧-៨-៧៧ | K ០០៨៥៩ |
| ៦ | សា ល័ស | ពេទ្យ ២៦០ | (ឥតមាន) | ៣-៨-៧៧ | បញ្ជីអ្នកទោស |
| ៧ | យើ ម៉ាត់ | ស-២១ | ២២-២-៧៧ | ១២-៥-៧៧ | D ០២៦៨០ |
| ៨ | ម៉េ ម៉ាត់ | រោងចក្រ ក៦ | ៤-១-៧៧ | ១៨-១០-៧៧ | D ០២៦៨៤ |
| ៩ | លី ឡេះ | កងពល២៩០ | ២៨-៨-៧៧ | ១៥-១០-៧៧ | បញ្ជីអ្នកទោស |
| ១០ | ម៉ាត់ ម៉ាន | ភូមិភាគពាយ័ព្យ | ២៥-១០-៧៧ | ៤-១១-៧៧ | បញ្ជីអ្នកទោស |
| ១១ | អេល ម៉ាន | កងពល៣១០ | ៧-១២-៧៧ | ៩-១២-៧៧ | បញ្ជីអ្នកទោស |
| ១២ | ហ៊ីម ពុធ | ស-២១យ | ២៧-៣-៧៧ | ១៣-៤-៧៧ | បញ្ជីអ្នកទោស |
| ១៣ | អេល ម៉ាន | វរសេនាតូច៣០១ | ៣០-៤-៧៧ | ៨-៧-៧៧ | បញ្ជីអ្នកទោស |
| ១៤ | សុស ម៉ាត់ | ឡានទឹក | ១៥-៦-៧៧ | ៣-៧-៧៧ | បញ្ជីអ្នកទោស |
| ១៥ | ស្មាន សុក | មន្ទីរ វ.៦៦ | ៥-៦-៧៧ | ៣-៧-៧៧ | បញ្ជីអ្នកទោស |
| ១៦ | ស្មាន នី | ស-២១ | ២៨-៦-៧៧ | ២៩-៦-៧៧ | បញ្ជីអ្នកទោស |
| ១៧ | សាឡេះ យ៉ាស់យ៉ា | មុខកំពូល | (ឥតមាន) | ២-៥-៧៦ | D ០២៦៦២ |
| ១៨ | ម៉ាត់ សាស់ | ពោធិចិនតុង | ២៧-៣-៧៦ | ២៧-៥-៧៦ | បញ្ជីអ្នកទោស |
| ១៩ | សាម៉ាស់ ការីម | ព្រែកព្នៅ | ៨-១-៧៦ | ២៧-៥-៧៦ | D ០២៦៨៦ |
| ២០ | ស៊ីម ម៉េល | ស-២១យ | (ឥតមាន) | ៣០-៤-៧៨ | D ០២៦៧៨ |
| ២១ | កូប ហ៊ីម | តំបន់៥០៥ | ២៧-១២-៧៨ | ៣១-១២-៧៨ | បញ្ជីអ្នកទោស |
| ២២ | សា ម៉ាត់ | ភូមិភាគបូព៌ា | ២៨-៨-៧៨ | ២-៩-៧៨ | D ០២៦៧៩ |
| ២៣ | ចិក ប្រាហ៊ីម | កោះធំ | ២៤-១-៧៦ | ២៦-៥-៧៦ | D ០២៦៨៧ |
| ២៤ | អ៊ីស្មាអេល អះម៉ាត់ | ស្ទឹងត្រង់ | ២-១-៧៧ | (ឥតមាន) | I ០៨៤៥០ |
| ២៥ | រូន ម៉ាត់ | កោះធំ | ?-៩-៧៥ | (ឥតមាន) | D ០២៦៧៤ |
| ២៦ | ស្មាន ស្មេះ | កោះធំ | ១៧-១២-៧៥ | (ឥតមាន) | D ០២៦៨៥ |
| ២៧ | សា ម៉ាត់ | កោះធំ | ?-១១-៧៥ | (ឥតមាន) | D ០២៦៧៦ |
| ២៨ | ហ៊ីម ម៉ាន | ស្អាង | ២២-៧-៧៥ | (ឥតមាន) | D ០២៦៧៣ |

| | | | | | |
|---|---|---|---|---|---|
| ២៩ | ម៉ាន ម៉ាត់ | ពាណិជ្ជកម្មរដ្ឋ | ?-១០-៧៥ | (ឥតមាន) | I ០៩០៦៩ |
| ៣០ | ស្មេះ ហ៊ាត | បាត់ដំបង | ១៨-៦-៧៨ | (ឥតមាន) | D ០២៦៨១ |
| ៣១ | ម៉ាត់ ឡេស | កំពង់ចាម | ២៧-១-៧៨ | (ឥតមាន) | D ០២៦៦១ |
| ៣២ | មូ៉ត ហៀត | បាត់ដំបង | ១៩-៦-៧៨ | (ឥតមាន) | K ០៤៣៧៣ |
| ៣៣ | ម៉ាន តិច | ស-២១យ | ១៧-៦-៧៨ | (ឥតមាន) | K ០២៦១៤ |
| ៣៤ | ម៉ាត់ ល័ស | កំពង់ចាម | ១៣-២-៧៦ | (ឥតមាន) | K ០៥៨០៤ |
| ៣៥ | កែវ អ៊ីប្រាហ៊ីម | កំពង់ចាម | (ឥតមាន) | (ឥតមាន) | K ០៥៨៣៩ |
| ៣៦ | កុហ៊ី | បាត់ដំបង | (ឥតមាន) | (ឥតមាន) | K ០៦៨៧៥ |
| ៣៧ | សុះ | កណ្ដាល | (ឥតមាន) | (ឥតមាន) | K ០៥៧៥៦ |
| ៣៨ | មូ៉ហាម៉ាត់ | កណ្ដាល | ៥-១-៧៦ | (ឥតមាន) | K ០៦៦៨៨ |
| ៣៩ | សុស ទត | កំពង់ចាម | ១២-១-៧៧ | (ឥតមាន) | I ០៨៥៤០ |
| ៤០ | ម៉ាត់ លាស់ | កំពង់ចាម | ១០-២-៧៦ | (ឥតមាន) | I ០៩១៩៧ |
| ៤១ | ម៉ាន យ៉ា | កំពង់ចាម | ?-៧-៧៦ | (ឥតមាន) | I ០៩៣៧១ |
| ៤២ | ឡិប ម៉ាត់ | កំពង់ចាម | ១២-២-៧៧ | (ឥតមាន) | I ០៩៧៩៧ |

**អ៊ីសា ឧស្មាន**

***(តមកពីទំព័រទី១៥)*** កម្មាភិបាលនិងយុទ្ធជនទាំងអស់ជ្រួតជ្រាបតាមការណែនាំរបស់បក្ស ។ ចំណុចខ្សោយបញ្ហាធ្វើស្រូវស្រាលពិតមែនតែយល់តែក៏នៅស៊ីសស្វាស ឃើញខបសគ្គអីចេះអីចុះ ទន្ទឹមនេះការចុះប្រឡូកដាក់ស្តែងរបស់កម្មាភិបាលក៏នៅខ្វះខាត ។

***◆ឯកសារលេខ L ១៨៤៩: កំណត់ហេតុនៃការប្រជុំលេខាអនុលេខាកងពលវរសេនាធំឯករាជ្យថ្ងៃទី១៦-៩-៧៦ ម៉ោង៧,០០***

សមមិត្ត ពីនៈ ១) ថ្ងៃ៣-៩ នៅភូមិស្រែចាមមានកាំភ្លើងផ្ទុះ ហើយពួកចាមនាំគ្នាសំលៀងកាំបិត ឈប់ធ្វើការ ត្រៀមបះបោរវាយខ្មែរ ។ ២) មានមនុស្ស៨នាក់ជិះទូកបំរុងរត់ទៅកោះត្រល់ ។ ចាប់បានវិញបញ្ជូនឲ្យមូលដ្ឋានហើយ ។

***◆ឯកសារលេខ L ១៨៥១: កំណត់ហេតុនៃការប្រជុំលេខានិងភ័ស្តុភាររបស់កងពលនិងវរសេនាធំថ្ងៃទី២-៨-៧៦ ម៉ោង៧***

សមមិត្ត ពីនៈ ១) សភាពការណ៍ខ្មាំង យប់ថ្ងៃ១៦-៩ នៅមន្ទីរខស្សរាហកម្មមានមនុស្សឡើងផ្ទះបង សាយ នាំគ្នាព័ទ្ធតែចាប់មិនបាន ។ ២) សភាពការណ៍បង្កបង្កើនផលៈ ស្រូវស្រាលផែនការ៣០០ហិកតា ស្ទូងបាន៣០១ហិកតា... ។

***◆ឯកសារលេខ L ១៥០០: កំណត់ហេតុនៃការប្រជុំលេខានិងអនុលេខាកងពលនិងវរសេនាធំឯករាជ្យ ថ្ងៃទី៩-១០-៧៦ ម៉ោង១៤***

សមមិត្ត ពីនៈ បញ្ហាពួកក្បត់និងវិធានការរបស់បក្សសុំយល់ស្របទាំងស្រុង ។ មូលហេតុក្បត់មកពីពួកទំនាស់មុខមាត់បុណ្យសក្តិ ។ ពិសោធពួកក្បត់វាមានជំហរដាច់ខាត ទោះបីមេវាត្រូវយើងចាប់ក៏នៅតែធ្វើសកម្មភាព ។ បញ្ហាក្តាប់អង្គភាពក្រោយរៀនសូត្រនិងសំរិតសំរាំងជាបន្តបន្ទាប់ អាចធានាការពារបក្សបាន ។ មាននៅសេសសល់ខ្លះពួកចចេចចចូច ពួកលួចឆក់ពួកទំនាស់មុខមាត់បុណ្យសក្តិ បានប្រមូលផ្តុំចំនួន៨០នាក់ ។ ពួកនេះគ្មានលទ្ធភាពបន្តបដិវត្តបាននឹងគេទេព្រោះមិនជ្រះស្រឡះជាមួយបដិវត្តន៍ ។ កម្មាភិបាលអនុសេនាធំម្នាក់ទំនាស់ជាមួយថ្នាក់លើរបស់ខ្លួន ដល់សមូហភាពកសាងពុតធ្វើប្រកាច់ ។

**សាន់ កល្យាណ**

***(តពីលេខមុន)*** ជនល្មើសដែលចាប់បានគឺជាទាហានក្នុងកងពល ១៧០ ដែលជាកងពលមួយបំបែកចេញពីកងពលលេខ១ ក្រោយពីខែមេសា ឆ្នាំ១៩៧៥ និងដែលជ្រើសរើសទ័ពពីភូមិភាគបូព៌ាក្នុងអំឡុងពេលសង្គ្រាមស៊ីវិល ។ នៅពេលផ្ទុះគ្រាប់បែកនោះ កម្លាំងកងពល១៧០ឈរជើងនៅជាយក្រុងភ្នំពេញ ជាកន្លែងដែលទាហានត្រូវបានចាត់តាំងឲ្យធ្វើស្រែជាការងារមួយដែលទាហានភាគច្រើនយល់ថាការងារអន់ ។



**សម្លេងពីមន្ទីរ ស-២១**
**ជំពូកទី៣: ការជ្រើសរើសសត្រូវ**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

ដោយធ្វើតាមបញ្ជារបស់មន្ទីរសន្តិសុខស-២១ដែលមានការសហការជាមួយនឹងសន្តិសុខជុំវិញនោះ ជនល្មើសត្រូវបានបង្ខំឲ្យរៀបរាប់ឈ្មោះមេរបស់ខ្លួន ។ មិនយូរប៉ុន្មានជនសង្ស័យក៏និយាយពាក់ព័ន្ធដល់ ចាន់ ចក្រី ដែលជាយោធានៅភូមិភាគបូព៌ានិងជាអតីតលោកសង្ឃ ។ ចក្រី មាននាទីជាស្នងការនយោបាយកងពលលេខ១៧០ ។ ក្រៅពីមុខងារនេះ ចក្រី ដែលមានអាយុ៣៣ឆ្នាំក៏មានតួនាទីជាអនុលេខាសេនាធិការជាតិដែលទើបតែបង្កើតថ្មី ក្រោមការគ្រប់គ្រងរបស់ សុន សេន ។

ចក្រី ធ្លាប់បានរត់ចោលជួរយ៉ាងហោចណាស់ ១ដងដែរ ។ កាលពីឆ្នាំ១៩៧៥ ចក្រី ត្រូវបានតាមដានដោយបក្សកុម្មុយនិស្តកម្ពុជា ។ ហើយមកដល់ថ្ងៃទី១៩ ខែឧសភា ក៏ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ ដែលនៅទីនោះ ចក្រី ត្រូវបានពាក់ផ្លាកលេខរ៉ូម៉ាំង I នៅលើ "ខ្សែមេៗ"របស់ជនដែលត្រូវចោទថាជាជនក្បត់ដែលមានចំនួនរហូតដល់ទៅ២០នាក់នៅចុងឆ្នាំ១៩៧៥ ។ នៅក្នុងរយៈពេល៤ខែនៃការសួរចម្លើយរបស់អង្គការ ចក្រី បានឆ្លើយថាមានពាក់ព័ន្ធជាមួយនឹងរដ្ឋាភិបាល លន់ ណុល និងជាប់ជាខ្មែរសេរីដែលជាកងទ័ពនិងចលនាប្រឆាំងនឹងសម្តេច សីហនុ ដែលមានមូលដ្ឋាននៅវៀតណាមខាងត្បូងរហូតមកដល់ឆ្នាំ ១៩៧៥ ។ ក្រៅពីនេះ ចក្រី បាននិយាយថា ខ្លួនមានផែនការធ្វើឃាតសម្តេច សីហនុ និងដាក់ថ្នាំបំពុល"បងៗថ្នាក់លើ" ។ ក្រោយពីមានការចាប់ខ្លួន ចក្រី រួចមក លី វ៉ាយ អនុលេខាកងពលលេខ១៧០ (លេខ II) ត្រូវបានចាប់បញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ។ នៅក្នុងចម្លើយសារភាពរបស់ខ្លួន លី វ៉ាយ និយាយទាំងមិនច្បាស់លាស់ថាខ្លួន"ចង់បង្កអសន្តិសុខនៅក្នុងទីក្រុងភ្នំពេញ" ។ ចំណែកឯ ចក្រី វិញនិយាយពាក់ព័ន្ធដល់ លី ផេន (លេខIV) ស្នងការនយោបាយទ័ពភូមិភាគបូព៌ា រស់ ភួង នៅកងពលលេខ១៧០ (លេខ VII) និង សួស នៅ ហៅ ឈូក (លេខ VIII) ដែលជាលេខា តំបន់២៤ ភូមិភាគបូព៌ា ។ លី ផេន ត្រូវបានចាប់ខ្លួននៅខែមិថុនា ឆ្នាំ១៩៧៦ រស់ ភួង នៅខែកក្កដា និង ឈូក នៅខែសីហា ។

ឈូក គឺជាមនុស្សរបស់លេខាភូមិភាគឈ្មោះ សោ ភឹម ជាអ្នកបដិវត្តជាន់ខ្ពស់ដែលធ្វើការជិតដិតជាមួយនឹងមជ្ឈិមបក្ស ប៉ុន្តែត្រូវបានសង្ស័យរួចទៅហើយថាក្បត់ ពីព្រោះគាត់មានទំនាក់ទំនងជាមួយកម្មាភិបាលវៀតណាមកាលពីទសវត្សរ៍ឆ្នាំ៥០ ។ សោ ភឹម ពេលនោះជាគណៈកម្មាធិការសន្តិសុខយោធាដែលត្រូវបានចោទថាបានចេញនយោបាយវិសុទ្ធកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ចម្លើយសារភាពរបស់ ឈូក ត្រូវនឹងអ្វីដែលមជ្ឈិមបក្សចង់បាន ពីព្រោះ ឈូក មានទំនាក់ទំនងជាមួយនឹង សោ ភឹម ។ នៅក្នុងសេចក្តីដកស្រង់មួយចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៦ ដែលជាពាក្យប្រឌិតមានលក្ខណៈដូចជាបណ្ណសារដែរនោះ សរសេរថា សោ ភឹម បានរៀបចំសួរចម្លើយខ្លួន ។ យើងដឹងតាមរយៈចម្លើយសារភាពរបស់ ភួង កាលពីឆ្នាំ១៩៧៨ ថា ការចាប់ខ្លួន ឈូក កាលពីឆ្នាំ១៩៧៦ ត្រូវបានពន្យារពេល

រហូតដល់ពេល សោ ភឹម ត្រឡប់មកពីបេសកកម្មនៅប្រទេសចិន ដូចនេះការសួរចម្លើយត្រួសៗអាចត្រូវបានធ្វើឡើង ។ សេចក្តីដកស្រង់មានដូចខាងក្រោម÷

នៅក្នុងដំណាក់កាលទីពីរដែលបក្សបានសួរចម្លើយខ្ញុំ ដោយប្រើទារុណកម្ម (ឈូក សរសេរ) ខ្ញុំនិយាយអំពីការណែនាំរបស់ បងភឹម ដោយយល់ស្របធ្វើការចោទប្រកាន់ទៅលើឈ្មោះ កែវ មាស ។ អង្គការនៅតែមិនជឿខ្ញុំទៀត ព្រោះខ្ញុំមិនបានផ្តល់ចម្លើយពិតប្រាកដច្បាស់លាស់អំពីសកម្មភាពក្បត់ ។ ខ្ញុំមិនដឹងថាតើនរណាខ្លះនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍របស់មជ្ឈិមបក្សក្បត់ទេ ។ ខ្ញុំមិនដឹងតើមានប៉ុន្មាននាក់ក្បត់ទេ... ហើយក៏មិនដឹងថាគេបានធ្វើអ្វីដែរ ។ ខ្ញុំនិយាយពាក់ព័ន្ធដល់ កែវ មាស ប៉ុន្តែមិនដឹងថាគាត់នៅទីណាឡើយ ។ ខ្ញុំឆ្លើយដាក់វៀតណាមយ៉ាងលម្អិតតែសុទ្ធតែជាការប្រឌិតទាំងអស់ ។ សភាពរបស់ខ្ញុំចេះតែយ៉ាប់ទៅៗ ព្រោះអង្គការបានឲ្យខ្ញុំរែកមុខថ្នាក់ដឹកនាំរបស់អង្គការចាត់តាំង ។ ខ្ញុំបានព្យាយាមធ្វើការវាយតម្លៃនិងថ្លឹងថ្លែងរឿងពីរ÷ តើអ្នកណាខ្លាំងជាង... ក្រុមរបស់ខ្ញុំ ឬក៏បក្ស? ...ខ្ញុំប្រកាន់ខ្ជាប់នូវជំនឿជាក់ថា ទោះជាសន្តិសុខអប់រំខ្ញុំនិងដដឹកសួរខ្ញុំយ៉ាងណាក៏ដោយ ក៏ខ្ញុំអាចលាក់បាំងនូវមនុស្សក្បត់របស់ ភឹម ដែរ ខ្ញុំនិយាយឡប់ចុះឡប់ឡើងធ្វើឲ្យពាក់ព័ន្ធដល់ក្រុមហាណូយ ក្រុមប្រឆាំង និងក្រុមតូចៗផ្សេងៗទៀត ។ ក៏ប៉ុន្តែដោយសារមានការវិភាគរបស់បក្ស បក្សមិនព្រមទទួលយកនូវរបាយការណ៍របស់ខ្ញុំទេដោយនិយាយថា របាយការណ៍ទាំងអស់មិនច្បាស់ ហើយក៏ឲ្យខ្ញុំសរសេរម្តងទៀត ។ នេះជាពាក្យរបស់បក្សជាលើកចុងក្រោយសុំឲ្យខ្ញុំពិចារណាឡើងវិញ ។ ពេលនោះ...ទោះជាខ្ញុំត្រូវបាត់បង់ជីវិតក៏ខ្ញុំត្រូវតែប្តេជ្ញាចិត្តឆ្លើយនឹងសំណួររបស់បក្សដោយស្មោះត្រង់ស្តីអំពីអំពើក្បត់របស់ សោ ភឹម ...ខ្ញុំសូមសន្យាថានឹងដើរតាមបក្សដាច់ខាត ។

## ការធ្វើវិសុទ្ធកម្មទៅលើកម្មាភិបាលជាន់ខ្ពស់ក្នុងឆ្នាំ១៩៧៦

អ្នកក្រៅពី សោ ភឹម ដែល ឈូក បានឆ្លើយដាក់ក៏មានកម្មាភិបាលជាន់ខ្ពស់មួយចំនួនទៀត ដូចជា ណៃ សារ៉ាន់ (ហៅ យ៉ា លេខ IX) លេខាភូមិភាគឦសាន កែវ មាស (លេខ X) ជនបដិវត្តដើមចាស់ដែលឥឡូវនេះត្រូវបានឃុំខ្លួន និង នង សួន ហៅ ជ័យ (លេខ XII) ដែលកំពុងបម្រើការជាលេខាខាងកសិកម្មរបស់កម្ពុជាប្រជាធិបតេយ្យ ។ អ្នកទាំងអស់នេះមិនមានអ្នកណាប្រាប់ថាបក្សមានការសង្ស័យលើខ្លួនឡើយ ហើយចេះតែធ្វើការជាធម្មតា ។ នៅក្នុងខែកក្កដានិងខែសីហាបក្សកុម្មុយនិស្តកម្ពុជាបានរៀបចំការប្រជុំមួយដើម្បីឲ្យសមាជិកបក្សមានការជ្រួតជ្រាបអំពីផែនការ៤ឆ្នាំដែលហៀបនឹងចេញប្រកាសជាផ្លូវការនៅក្នុង ខែកញ្ញា ។ នៅក្នុងខែកញ្ញា ណៃ សារ៉ាន និង កែវ មាសត្រូវបាននាំយកមកមន្ទីរសន្តិសុខស-២១ ។ នង សួន ត្រូវចាប់ខ្លួននៅដើមខែវិច្ឆិកា ។

មនុស្សទាំងបីនាក់នេះមានអ្វីៗដូចគ្នាច្រើនណាស់ ។ ក្រៅពីអាយុស្របាលគ្នា អ្នកទាំងបីស្ទើរតែគ្មានអ្វីដូចគ្នាទៅនឹង ប៉ុល ពត ឡើយ ។ ទាំងបីនាក់បានចូលរួមចលនាប្រឆាំងនឹងបារាំងក្នុងឆ្នាំ១៩៤៥ និងឆ្នាំ១៩៤៦ ។ អ្នកទាំងបីបានរៀនអំពីលិទ្ធិម៉ាក្ស-ឡេនីន មុនពីកម្មាភិបាលកុម្មុយនិស្តវៀតណាម ឬមកពីជនជាតិខ្មែរដែលទៅរៀនសូត្រនៅប្រទេសវៀតណាម ។ គ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងបីបានទៅរៀននៅប្រទេសបារាំងឡើយ ។ មិនដូចបងធំទីមួយនិងទីពីរទេ នង សួន និង កែវ មាស បានចេញធ្វើសកម្មភាពជា ចំហកាលពីទសវត្សរ៍ឆ្នាំ៥០ ។ ណៃ សារ៉ាន់ បង្រៀននៅសាលាជាមួយ សាឡុត ស ។ កែវ មាស បានឈរ ឈ្មោះជាបេក្ខជនតំណាងរាស្ត្រប្រឆាំងពីរលើក ចំណែក៦ នង សួន ត្រូវបានចាប់ដាក់គុកដោយរាជការសម្តេចសីហនុ នៅឆ្នាំ១៩៦២ ។ អ្នកទាំងពីរនេះបានចូលជាគណៈកម្មាធិការមជ្ឈិមបក្សនៅខែកញ្ញា ឆ្នាំ១៩៦០ ជាមួយនឹងសាឡុត ស ដែលខ្លួនស្គាល់ជិតដិត ។ នៅឆ្នាំ១៩៦៣ ណៃ សារ៉ាន់ និង កែវ មាស បានចូលធ្វើការជាមួយ ប៉ុល ពត និងមនុស្សមួយក្តាប់តូចនៅក្នុងមន្ទីរ១០០ដែលជាមូលដ្ឋានវៀតណាមនៅតាមព្រំដែនកម្ពុជា-វៀតណាម ។ អ្នកទាំងពីររស់នៅទីនោះរហូតដល់ឆ្នាំ១៩៦៥ ។ ចាប់ពីពេលនោះមកអ្នកទាំងបីក៏បែកផ្លូវផ្សេងពីគ្នា ។ នង សួន ត្រូវបានដោះលែងពីគុកនៅក្នុងឆ្នាំ១៩៧០ ហើយចូលបម្រើម៉ាកគីសនៅជិតភ្នំពេញ ណៃ សារ៉ាន់ ក្លាយជានាយទាហាននៅភូមិភាគឦសាន រីឯ កែវ មាស ធ្វើការនៅទីក្រុងប៉េកាំងនិងហាណូយតំណាងឲ្យរដ្ឋាភិបាលរណសិរ្សរួបរួមជាតិនិរទេស ។ ពេលដែលត្រឡប់មកដល់ប្រទេស

កម្ពុជាវិញនៅឆ្នាំ១៩៧៥ កែវ មាស ដែលប្រហែលជាត្រូវបានសង្ស័យថាជាអ្នកគាំទ្រវៀតណាមត្រូវបានឃុំឃាំងក្នុងផ្ទះ មិនឲ្យចេញទៅណា ។

នៅឯមន្ទីរសន្តិសុខ ស-២១ កែវ មាស ណៃ សារ៉ន និង នង សួន ត្រូវបានចោទប្រកាន់ថាបានបង្កើត «បក្សពលករកម្ពុជា» ដើម្បីបង្កប់ប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជា ។ ពាក្យថា «បក្សពលករកម្ពុជា» គឺជាអក្សរកាត់តំណាងឲ្យអំពើក្បត់ដែលប្រព្រឹត្តដោយសមាជិកបក្សកុម្មុយនិស្តកម្ពុជាក្រោយពី ប៉ុល ពត បានឡើងកាន់មជ្ឈិមបក្សកាលពីឆ្នាំ១៩៦០ ។ នៅក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ «បក្ស»ប្រឆាំងបានក្លាយជាចំណុចក្ដៅក្នុងការចោទប្រកាន់ដូចដែលឃើញនៅមន្ទីរសន្តិសុខ ស-២១ ស្រាប់ ។ បក្សគឺជាចំណុចដែលអាចធ្វើចលនាបាន ហើយ «បក្សពលករកម្ពុជា» ឈរឲ្យពាក្យពីរម៉ាត់គឺ «សេ.អ៊ី.អា» ឬ «កា.ហ្វេ.បេ» ។ ដោយសារតែបក្សកុម្មុយនិស្តកម្ពុជាត្រូវបានយល់ថាជាប្រភពខ្លាំងអចិន្ត្រៃយ៍ មេដឹកនាំរបស់បក្សនេះត្រូវបាននិយាយថានៅមានសកម្មភាពនៅឡើយ ។ ឧទាហរណ៍នៅខែកក្កដា ឆ្នាំ



យុទ្ធជនមន្ទីរ ស-២១ កំពុងហ្វឹកហាត់ក្បាច់ប្រយុទ្ធ

១៩៧៨ ជិតពីរឆ្នាំក្រោយពី កែវ មាស ត្រូវបានចាប់ខ្លួននិងសម្លាប់ចោល និងមួយខែក្រោយពី សោ ភឹម សម្លាប់ខ្លួនឯង ប៉ុន បានសរសេរនៅក្នុងសៀវភៅកំណត់ហេតុរបស់ខ្លួនថា “ស្វែងរកមេៗរបស់បក្សពលករកម្ពុជា ។ សំខាន់ណាស់” ។

ប៉ុន្តែគួរឲ្យអស់សំណើចដូចដែលអ្នកទោសដែលមានឋានៈជាច្រើនបានដឹងច្បាស់ នៅក្នុងឆ្នាំ១៩៦០ បក្សរបស់ ប៉ុល ពត បានយកឈ្មោះបក្សពលករកម្ពុជាជាឈ្មោះរបស់បក្សខ្លួន ។ ទោះបីជាការប្តូរឈ្មោះនេះប្រហែលជាត្រូវបានអនុម័តយល់ព្រមដោយវៀតណាមក៏ដោយ ប៉ុន្តែគ្មានភ័ស្តុតាងបញ្ជាក់ច្បាស់ថាបក្សប្រឆាំងដែលប្រើឈ្មោះនេះត្រូវបានបង្កើតឡើយ ។ ផ្ទុយទៅវិញ បក្សត្រូវបានស្គាល់ថាបក្សពលករកម្ពុជារហូតដល់ពាក់កណ្តាលឆ្នាំ១៩៦៦ ពេលនោះ ប៉ុល ពត ក៏ប្តូរឈ្មោះដោយសម្ងាត់ម្តងទៀតថា “បក្សកុម្មុយនិស្តកម្ពុជា” ។



ទោះបីជាមានការផ្ទុយគ្នាដូច្នេះក៏ដោយ ក៏គំនិតដែលថា កែវ មាស បានបង្កើតបក្សបង្កប់ដែលមានឈ្មោះថា “បក្សពលករកម្ពុជា” នៅតែមាននៅឡើយក្នុងឆ្នាំ១៩៧៨ ពេលដែល វន វ៉េត ឧបនាយករដ្ឋមន្ត្រីត្រូវបានចាប់ខ្លួន ។ នៅក្នុងចម្លើយសារភាពរបស់ខ្លួន វន វ៉េត បានសរសេរថា បក្សប្រឆាំង “ត្រូវបានដាក់បញ្ចូលគ្នាដោយមានជំនួយពីវៀតណាមដែលមានឈ្មោះ កែវ មាស ជាអ្នកបង្កើត ដើម្បីឲ្យវៀតណាមអាចកសាងកម្លាំងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ។ ក្រុមសេ.អ៊ី.អា បានចូលរួមជាមួយបក្សនេះ ។ តាមរូបភាពមើលទៅហាក់ដូចជារបស់វៀតណាម តែតាមការពិត...វាជារបស់សេ.អ៊ី.អា ។ វាមានទម្រង់ជាបក្សកុម្មុយនិស្តកម្ពុជាដើម្បីដឹកនាំការងារ” ។

កែវ មាស និង ណៃ សារ៉ន ត្រូវបានចាប់ខ្លួននៅពេលចលាចលមួយដែលចាប់ផ្តើមនៅខែសីហា ឆ្នាំ១៩៧៦ ពេលដែលផែនការ៤ឆ្នាំរបស់បក្សកុម្មុយនិស្តកម្ពុជាត្រូវបានលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំថ្នាក់កម្មាភិបាល និងជិតដល់ខែតុលាដែលពោរពេញទៅដោយភាពចម្រូងចម្រាស់ទៅលើរឿងថ្ងៃបង្កើតបក្សកុម្មុយនិស្តកម្ពុជាដែលអនុវត្តដោយមជ្ឈិមបក្សដែលដោះត្រូវបានដោះស្រាយតាមគំនិតរបស់ ប៉ុល ពត ។ បើពិនិត្យទៅលើរឿងទាំងអស់នេះ ព្រឹត្តិការណ៍ទាំងអស់ដែលបានកើតឡើងនិងការចាប់ខ្លួន គឺជាចំណុចរបត់មួយនៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យនិងមន្ទីរសន្តិសុខស-២១ ។ នៅចុងឆ្នាំនោះ ជាលទ្ធផល ការប្រកាសរបស់មជ្ឈិមបក្សបានក្លាយជាមានលក្ខណៈទុទិដ្ឋិនិយមនិង ភាពប្រទូស្តរាយ ។ នៅដើមឆ្នាំ១៩៧៧ វិសុទ្ធកម្មបានឡើងដល់ប្រព័ន្ធសសៃប្រសាទរបស់បក្សកុម្មុយនិស្តកម្ពុជា ។ ដោយហេតុផលនេះ ដំណើរវិវត្តនៃព្រឹត្តិការណ៍ដែលកើតឡើងចាប់ពីខែសីហាដល់ខែតុលា ឆ្នាំ១៩៧៦ ត្រូវតែបានរៀបរាប់ដោយលម្អិត ។ **(នៅមានត)**

## មូលន័យសង្ខេប

តើយុទ្ធជនវ័យក្មេងមន្ទីរស-២១ជាជនដៃដល់សម្លាប់មនុស្សឬជាជនរងគ្រោះ? តើយុទ្ធជនវ័យក្មេងមន្ទីរ ស-២១ក្លាយជាជនដៃដល់និងក្លាយជាជនរងគ្រោះដោយរបៀបណា?




ខ្ញុំស្រាវជ្រាវឃើញថា យុទ្ធជនវ័យក្មេងមន្ទីរស-២១គឺជាជនរងគ្រោះក្នុងចំណោមជនរងគ្រោះជាច្រើនទៀតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គំហើញនេះផ្ទុយស្រឡះអំពីទស្សនៈដែលយល់ឃើញថា យុទ្ធជនវ័យក្មេងនៅមន្ទីរស-២១គឺជាជនដៃដល់សុទ្ធសាធដោយមូលហេតុថាយុទ្ធជនទាំងនោះធ្វើការនៅមន្ទីរដ៏សំខាន់និងសម្ងាត់បំផុតរបស់ខ្មែរក្រហម ដែលមន្ទីរនេះបានសម្លាប់ជនស្លូតត្រង់អស់ប្រមាណ ២០០០០នាក់ក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ។ អត្ថបទស្រាវជ្រាវនេះនឹងបង្ហាញហេតុផលអំពីចលនានិងមូលហេតុដែលកុមារនៃតំបន់៣១ចូលបម្រើក្នុងជួរបដិវត្តន៍ខ្មែរក្រហមជាបន្តបន្ទាប់ច្រើនដំណាក់កាល រហូតទីបំផុតក្លាយខ្លួនជាយុទ្ធជនវ័យក្មេងមន្ទីរស-២១ ។ កុមារតំបន់៣១ (ខេត្តកំពង់ឆ្នាំង) ត្រូវបានប្រធានភូមិ ឃុំ និងស្រុក របស់ខ្មែរក្រហមចាប់បង្ខំឲ្យចូលបម្រើកងទ័ពបដិវត្តន៍ខ្មែរក្រហម មានភារកិច្ចជាកងឈ្លបភូមិ ឃុំ ឬស្រុក ។ បន្ទាប់មក កងឈ្លបកុមារត្រូវប្រធានឃុំ ឬលេខាស្រុក ចាត់តាំងឲ្យឡើងឡានដើម្បីទៅបម្រើអង្គការនៅមជ្ឈិម ។ កុមារទាំងនោះពុំបានដឹងខ្លួនឡើយថាតើពួកខ្លួននឹងក្លាយទៅជាអ្វី ធ្វើការអ្វី នៅកន្លែងណានោះទេ ។ កងឈ្លបភូមិឃុំដែលក្លាយជាយុទ្ធជនបដិវត្ត ត្រូវបានបំពាក់មនោគមវិជ្ជាឲ្យស្រឡាញ់លទ្ធិបដិវត្តន៍ខ្មែរក្រហម ហើយកាត់ផ្តាច់មនោសញ្ចេតនាចំពោះឪពុកម្តាយនិងបងប្អូនញាតិមិត្តរបស់ខ្លួន ។

កុមារតំបន់៣១ក្លាយខ្លួនទៅជាយុទ្ធជនមន្ទីរស-២១ ដែលជាទាសករបម្រើបដិវត្តន៍ខ្មែរក្រហមដោយមិនដឹងខ្លួន ព្រមទាំងទទួលរងទុក្ខយ៉ាងខ្លោចផ្សា កណ្តោចកណ្តែង និងរហូតភាគច្រើនត្រូវបាត់បង់ជីវិតក្នុងកាលៈទេសៈបុព្វហេតុដ៏គ្មានន័យក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យុទ្ធជនដែលរស់ពីស្លាប់ត្រូវទទួល

រងនូវស្លាកស្នាមឈឺចាប់ទាំងរាងកាយនិងសតិអារម្មណ៍ដែលគ្មានឱកាសនឹងស្រាកស្រាន្តធូរស្បើយ ។ មូលហេតុខាងលើទាំងនេះហើយដែលជាអំណះអំណាងបង្ហាញថា យុវជនវ័យក្មេងមន្ទីរស-២១ក៏ជាជនរងគ្រោះនៃបដិវត្តន៍ខ្មែរក្រហម ។

## សេចក្តីផ្តើម

មន្ទីរស-២១គឺជាមូលដ្ឋានសម្ងាប់រង្គាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្ថិតនៅក្នុងសង្កាត់ទួលស្វាយព្រៃ ភាគខាងត្បូងទីក្រុងភ្នំពេញ ។ ស-២១ គឺជាឈ្មោះតំណាងឲ្យ“មន្ទីរសន្តិសុខ២១” ។ មន្ទីរនេះជាអតីតអនុវិទ្យាល័យទួលស្វាយព្រៃក្នុងរបបសាធារណរដ្ឋខ្មែរ ដែលក្រោយមកត្រូវបានខ្មែរក្រហមប្រែក្លាយជាកន្លែងដ៏សម្ងាត់ប្រើប្រាស់ក្នុងការសួរចម្លើយនិងធ្វើទារុណកម្ម ។

មន្ទីរសន្តិសុខ២១នេះគឺជារចនាសម្ព័ន្ធដ៏អាថ៌កំបាំងបំផុតមួយនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មន្ទីរនេះត្រូវបានខ្មែរក្រហមប្រើប្រាស់ដើម្បីឃុំឃាំងជនណាដែលជាសត្រូវរបស់បដិវត្តន៍មកពីគ្រប់ទិសទីដែលរួមមានទាំងមកពីបរទេសផង ។ មន្ទីរស-២១មានសាខាជាច្រើនកន្លែងដែលរួមមានដូចជា ស-២១គនៅតាខ្មៅជាសាលាបច្ចេកទេសហាត់ក្បួនយុទ្ធសាស្ត្រទ័ពរបស់កងពល៧០៣ ។ ស-២១យ ឬមន្ទីរ២៤ គឺជាមន្ទីរកែប្រែនិងដាំដុះដំណាំកសិកម្មផ្គត់ផ្គង់ដល់គ្រប់សាខាទាំងអស់របស់មន្ទីរស-២១ និង ស-២១យ ឬមន្ទីរ២៤ ស្ថិតនៅក្នុងខណ្ឌដង្កោ ក៏ជាមន្ទីរឃុំឃាំងក្រោមរណបមន្ទីរស-២១ដែរ ។ ទីតាំងចិញ្ចឹមសត្វយកសាច់ដើម្បីផ្គត់ផ្គង់ជីវភាពកម្មាភិបាលនិងយុវជនមន្ទីរស-២១ ស្ថិតនៅបឹងទំពុនចម្ងាយប្រហែល៥គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ក៏ជាសាខារបស់មន្ទីរស-២១ ។ ចំណែកស-២១កបឹងជើងឯក ដែលជាកន្លែងសម្លាប់ដ៏ធំបំផុតមួយរបស់មន្ទីរស-២១ គឺស្ថិតនៅខាងលិចចម្ងាយប្រមាណ១៨គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ។

មន្ទីរស-២១កើតឡើងនៅដំណាច់ខែឧសភា ឆ្នាំ១៩៧៦ ដែលកម្លាំងសរុបមានចំនួនប្រមាណ១៦៨៥នាក់ហើយចែកចេញជា៤ផ្នែក÷

១) កម្លាំងខាងក្នុងចំនួន១៨២នាក់ ។

២) រដ្ឋបាលចំនួន១៤៨នាក់ ។

៣) សួរចម្លើយចំនួន៥៨នាក់ ។

៤) កម្លាំងដែលអាចធ្វើការបានចំនួន១៣៧៧នាក់ ។

កម្មាភិបាលនិងយុវជនទាំងអស់ដែលធ្វើការនៅមន្ទីរស-២១ សុទ្ធតែត្រូវឆ្លងកាត់ការជ្រើសរើសប្រវត្តិរូបបដិវត្តន៍ ការហាត់ពត់លត់ដំ ក៏ដូចជាគោលជំហរនយោបាយយ៉ាងហ្មត់ចត់ជាទីបំផុត ។ យុវជនមន្ទីរស-២១ទាំងនោះ មកពីគ្រប់តំបន់ ស្រុក និងភូមិ ទូទាំងប្រទេស ហើយភាគច្រើនគឺជាកុមារ ។

ខាងក្រោមនេះគឺជាការបង្ហាញអំពីដំណើរការនៃការចូលរួមរបស់កុមារខេត្តកំពង់ឆ្នាំងក្នុងចលនាបម្រើបដិវត្តន៍ខ្មែរក្រហមពិសេសនៅក្នុងមន្ទីរសម្ងាត់និងមានសារៈសំខាន់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ ហៅមន្ទីរស-២១ ។

ខេត្តកំពង់ឆ្នាំងស្ថិតនៅភាគខាងជើងនៃទីក្រុងភ្នំពេញចម្ងាយ៩១គីឡូម៉ែត្រ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខេត្តនេះត្រូវបានហៅថាតំបន់៣១ ដែលមានស្រុកទាំងអស់ចំនួន៦គឺស្រុកសាមគ្គីមានជ័យ ហៅស្រុក១២ ស្រុកកំពង់ត្រឡាចហៅស្រុក១៨ ស្រុករលាប្អៀរ ហៅស្រុក២០ ស្រុកទឹកផុសហៅស្រុក១៤ ស្រុកកំពង់លែង ហៅស្រុក១៦ និងស្រុកបរិបូណ៌ហៅស្រុក១០ ។

យុវជនការពារ យុវជនសួរចម្លើយ យុវជនចាប់អ្នកទោសនិងយុវជនក្នុងកងផ្សេងទៀតដែលបម្រើការងារនៅមន្ទីរស-២១ ស្ទើរសុទ្ធតែត្រូវបានពិពណ៌នាថាជាឃាតករដ៏សាហាវនៅក្នុងរបបប្រល័យពូជសាសន៍នៅប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ ផ្ទុយទៅវិញ បើយើងពិនិត្យនិងស្វែងយល់ឲ្យគ្រប់ជ្រុងជ្រោយយើងនឹងបានឃើញថា យុវជនវ័យក្មេងមន្ទីរស-២១នេះគឺជាកុមារដែលត្រូវខ្មែរក្រហមដកហូតនិងរំលោភសិទ្ធិយ៉ាងធ្ងន់ធ្ងរដោយចាប់បង្ខំនិងរុញទម្លាក់ទៅក្នុងពិភពមួយដែលកុមារទាំងនោះមើលមិនឃើញនិងនឹកស្មានមិនដល់ ។ អត្ថបទស្រាវជ្រាវនេះនឹងលើកភស្តុតាងដើម្បីបង្ហាញឲ្យឃើញថា “យុវជនវ័យក្មេងមន្ទីស-២១មិនមែនជាឃាតករសុទ្ធសាធនោះទេ ពីព្រោះយុវជនទាំងនោះត្រូវស្លាប់បាត់បង់ជីវិតនិងរងទុក្ខក្នុងបុព្វហេតុបម្រើចលនាបដិវត្តន៍ខ្មែរក្រហមដែរ” ។

ខ្ញុំនឹងរៀបចំធ្វើការការពារគំហើញក្នុងអត្ថបទស្រាវជ្រាវនេះ





ជាពីរផ្នែក ។ ទី១ ខ្ញុំបង្ហាញអំពីលទ្ធផលសិក្សារបស់អ្នកចិត្តវិទ្យាចំពោះកុមារដែលលទ្ធផលនេះបញ្ជាក់ពីភាពស្អាតស្អំបរិសុទ្ធនិងភាពងាយទទួលរងនូវការប៉ះទង្គិចរបស់កុមារ ។ រួមនឹងការសិក្សាស្រាវជ្រាវរបស់អ្នកសិក្សាប្រវត្តិសាស្ត្រដែលបង្ហាញពីគោលបំណងខ្មែរក្រហមដែលទាមទារចង់បានកុមារឲ្យបម្រើចលនាបដិវត្តន៍ខ្មែរក្រហម ព្រោះតែខ្មែរក្រហមយល់ឃើញ ថាកុមារគឺជាឧបករណ៍ប្រើប្រាស់ដ៏ងាយស្រួលនិងមានប្រសិទ្ធភាព ។ ទី២ ខ្ញុំនឹងបង្ហាញអំពីដំណើរធ្លាក់ខ្លួនក្លាយជាជនរងគ្រោះនៃកុមារទាំងនោះក្នុងបុព្វហេតុចលនាបដិវត្តន៍របស់ខ្មែរក្រហម ។

កុមារភាពក្នុងវ័យសិក្សាតែងតែចង់លេងសប្បាយដេញចាប់ជាមួយគូកនក្មេងប្រុសស្រីរបស់ខ្លួនតាមភូមិនិងលើវាលស្រែ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កុមារតំបន់៣១ក៏ដូចជាកុមារទូទាំងប្រទេសដែរ គឺត្រូវទទួលរងការគំរាមកំហែងពីសំណាក់ប្រធានភូមិ ឃុំ ឬស្រុក ឲ្យចូលបម្រើកងទ័ពបដិវត្តន៍ខ្មែរក្រហម ។ ដំបូងកុមារទាំងនោះត្រូវចាប់បង្ខំឲ្យធ្វើជាឈ្លបភូមិ ឃុំ ឬស្រុក នៅទីបំផុតត្រូវប្រធានឃុំឬស្រុកបង្ខំឲ្យចាកចេញពីផ្ទះសម្បែង ឪពុកម្តាយ បងប្អូន គូកន ទៅបម្រើ“អង្គការមជ្ឈិមបក្ស”ក្នុងភារកិច្ចជាយុទ្ធជនមន្ទីរស-២១ ។

ប្រធានឃុំឬលេខាស្រុកបានធ្វើការឃោសនាកុមារថា កងឈ្លបកុមារត្រូវចេញទៅធ្វើការជិតភូមិស្រុករបស់ខ្លួនមិនមែនទៅឆ្ងាយទេ ។ កុមារដែលរួញរាមិនចង់ចាកចេញពីភូមិស្រុកផ្ទះសម្បែង ត្រូវទទួលរងការចាប់បង្ខំឲ្យរៀបចំបង្វេចខោអាវទាំងកណ្តាលយប់អធ្រាត ដែលធ្វើឲ្យកុមារទាំងនោះកាន់តែភ័យខ្លាចហើយចាកចេញដោយក្តីភ័យតក់ស្លុត បារម្ភ និងមន្ទិលពីទីកន្លែងដែលខ្លួនត្រូវទៅ ជាពិសេសចម្ងល់អំពីភារកិច្ចដែលខ្លួនត្រូវបំពេញ ។

ក្រោយពីចាកចេញពីផ្ទះសម្បែងភូមិកំណើតទៅដល់មជ្ឈិម កងឈ្លបកុមារទាំងនោះត្រូវបានអង្គការបញ្ជូនទៅហាត់ហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រយោធានៅតាខ្មៅ ។ នៅក្នុងសាលាបច្ចេកទេសយោធា យុទ្ធជនវ័យក្មេងត្រូវហ្វឹកហាត់ផងនិងធ្វើការងារផងទាំងយប់ទាំងថ្ងៃ ប៉ុន្តែទទួលបានត្រឹមតែបបរលាយជាមួយដំឡូងជារបបអាហារប្រចាំថ្ងៃប៉ុណ្ណោះ ។ ដើម្បីរស់ យុទ្ធជនទាំងនោះត្រូវបង្ខំចិត្តស៊ីសូម្បីតែសត្វកន្លាត រហូតយុទ្ធជនខ្លះធ្លាក់ខ្លួនមានជំងឺនិងស្លាប់ព្រោះតែការធ្វើការងារបាក់កម្លាំងនិងហូបចុកមិនគ្រប់គ្រាន់ ។

យុទ្ធជនទាំងអស់ត្រូវពង្រឹកស្មារតីដោយការបំពាក់បំប៉នមនោគមវិជ្ជាបដិវត្តខ្មែរក្រហមឲ្យមើលឃើញតែអំពើល្អរបស់បក្ស ឲ្យគោរពស្រឡាញ់តែអង្គការ ហើយមិនត្រូវមានមនោសញ្ចេតនានឹកនាគិតបារម្ភដល់ឪពុកម្តាយឬបងប្អូនដាច់ខាត ។ ចំពោះភារកិច្ចយុទ្ធជនបដិវត្តន៍ត្រូវតែមានចិត្តគំនិតស្រឡាញ់ការងារបដិវត្តន៍ និងអង្គការបដិវត្តន៍ឲ្យអស់ពីចិត្តពីថ្លើម ជាពិសេសនៅក្នុងដំណាក់កាលក្លាយខ្លួនទៅជាជាបម្រើបដិវត្តន៍ក្នុងនាមជាយុទ្ធជនកងការពារ យុទ្ធជនសួរចម្លើយ ក៏ដូចជាយុទ្ធជនកងដទៃទៀតនៃមន្ទីរស-២១ ។

**(នៅមានត)**

# រង្វាស់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងប្រទេសកម្ពុជា

## *សេចក្តីផ្តើម*

ឆ្នាំ១៩៩៩ គឺជាឆ្នាំទីប្រាំនៃការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការចុះធ្វើផែនទីរណ្តៅសាកសពប្រល័យពូជសាសន៍ហើយរបាយការណ៍នេះ មានរៀបរាប់អំពីការងារចុះតាមមូលដ្ឋាន ។ របាយការណ៍ការងារនៅឆ្នាំនេះ មានរៀបរាប់លម្អិតអំពីបេសកកម្មនៃក្រុមធ្វើផែនទីនៅក្នុងខេត្តក្រុងចំនួន១៧ ក្នុងចំណោមខេត្តក្រុងទាំង២១នៃប្រទេសកម្ពុជា រួមមានខេត្តបន្ទាយមានជ័យ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តកណ្តាល ខេត្តក្រចេះ ក្រុងភ្នំពេញ ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តតាកែវ ខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី ។ ដូចនេះរបាយការណ៍បានឱបក្រសោបគ្រប់ជ្រុងជ្រោយទាំងអស់របស់ប្រទេសកម្ពុជាចាប់ពីភាគខាងត្បូងដែលមានដង់ស៊ីតេប្រជាជនខ្ពស់ទៅដល់ភាគខាងជើងដែលហ៊ុមព័ទ្ធទៅដោយតំបន់ព្រៃស្រោងចាប់ពីតំបន់ដាច់ស្រយាលនៅភាគខាងកើតរហូតដល់ជម្រកស្រូវនៅចុងបស្ចិម និងខេត្តផ្សេងៗទៀតដែលស្ថិតនៅក្នុងភូមិភាគកណ្តាលនៅជុំវិញបឹងទន្លេសាប ។

ដូចជានៅក្នុងឆ្នាំមុនៗដែរ គឺមានការរកឃើញដូចៗគ្នា÷ សាក្សីធ្វើជាកសិណចំពោះការធ្វើទារុណកម្មនិងឃាតកម្មដ៏ច្រើនហួសនិស្ស័យ ហើយសំណល់ភ័ស្តុតាងជារណ្តៅសាកសពរួមនិងអតីតគុកខ្មែរក្រហមផ្តល់នូវកសិណសាក្សីស្រាប់ដែលរាយប៉ាយនៅក្នុងប្រទេសកម្ពុជាគឺជាភ័ស្តុតាងជាក់ស្តែងនៃឧក្រិដ្ឋកម្ម ។ ករណីនេះបញ្ជាក់ថា អំពើគួរឲ្យរន្ធត់កើតមានច្រើននិងជាប្រព័ន្ធទៀតផង ដែលបំពេញលក្ខណៈវិនិច្ឆ័យមួយក្នុងនិយមន័យស្តីអំពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ មូលន័យសង្ខេបមួយនៃការរកឃើញទិដ្ឋភាពមួយចំនួននាឆ្នាំនេះជាការបញ្ជាក់កាន់តែច្បាស់ថែមទៀត ។

## **អំពើទារុណកម្ម**

ថ្មីៗនេះប្រវត្តិវិទូ ដេវីដ ឆេនដល័រ បានបោះពុម្ពផ្សាយនូវស្នាដៃដ៏ឆ្នើមមួយទៀតរបស់លោកមានចំណងជើងថា "សម្លេងពីមន្ទីរស-២១ៈ អំពើភេរវកម្មនិងប្រវត្តិគុកសម្ងាត់របស់ ប៉ុល ពត" ។ ចំពោះប្រធានបទនេះ លោក ឆេនដល័រ អះអាងថា អំពើទារុណកម្មគឺជាបញ្ហាមួយដែលធ្វើឲ្យមន្ទីរស-២១ដែលជាទីចាត់ការនៃគុកសម្ងាត់របស់ខ្មែរក្រហមមានលក្ខណៈពិសេសតែមួយគត់នៅក្នុងប្រព័ន្ធទូទាំងប្រទេសនៃទីតាំងសន្តិសុខផ្ទៃក្នុងរបស់កម្ពុជាប្រជាធិបតេយ្យ ។

"ប្រជាជនទាំងបុរសទាំងស្ត្រីរាប់ពាន់នាក់ដែលត្រូវបានចោទប្រកាន់ពីបទល្មើសបន្តិចបន្តួច ឬដែលត្រូវបានចាប់ដាក់គុកទទួលនូវរងនូវការខ្វះជីវជាតិបំប៉ន ជំងឺ និងការធ្វើទុកបុកម្នេញនៅក្នុងគុកនៅតាមខេត្ត ប៉ុន្តែជាទូទៅប្រជាជនទាំងនេះមិនត្រូវបានធ្វើទារុណកម្មដើម្បីឲ្យបង្ហាញពីទោសកំហុសរបស់ខ្លួនឡើយ ។

ភ័ស្តុតាងដែលទទួលបានតាមរយៈកិច្ចសម្ភាសន៍ជាមួយសាក្សីរាប់រយនាក់ដែលបានឃើញហេតុការណ៍នៅក្នុងគុកតាមខេត្តដែលត្រូវបានប្រមូលដោយក្រុមការងារស្រាវជ្រាវផែនទីរណ្តៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅអំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ មិនត្រូវគ្នាទៅនឹងការសន្និដ្ឋានបែបនេះតែរហូតទេ ។ តាមពិតទារុណកម្មក្នុងទម្រង់ផ្សេងៗហាក់ដូចជាមានលក្ខណៈទូទៅនៅគុកស្ទើរគ្រប់ភូមិភាគ តំបន់ និងថ្នាក់ស្រុក ដែលដំណើរការដោយសន្តិសុខខ្មែរក្រហមទូទាំងប្រទេសកម្ពុជា ហើយជួនកាលគុកត្រូវបានប្រើប្រាស់ជាកន្លែងសម្រាប់ចម្រាញ់ការទទួលកំហុសរបស់អ្នកទោស ។ ទិន្នន័យឆ្នាំ១៩៩៩បានបញ្ជាក់ពីករណីនេះ ។

ឧទាហរណ៍នៅខេត្តក្រចេះ សាក្សីបានរៀបរាប់អំពីទារុណកម្មធ្ងន់ធ្ងរដែលធ្វើឡើងដើម្បីស្រង់យកភ័ស្តុតាងបញ្ជាក់ពី "ទោសកំហុស" ។ នៅវាលឃ្លីងក្នុងខេត្តក្រចេះ ឈ្មោះ ទី ញ៉ិៈ អះអាងថាគាត់បានឃើញខ្មែរក្រហមវាយអ្នកទោសស្រង់យកចម្លើយ ហើយបានបន្ថែមថា ពួកខ្មែរក្រហមវាយមនុស្ស "ដូចជាសត្វធាតុ" ។ ទី ញ៉ិៈ និយាយថា អ្នកទោសនៅព្រែកកូនផៃ "ត្រូវពួកខ្មែរក្រហមវៃសួរចម្លើយ" ។ សាក្សីទីពីរឈ្មោះ ប៊ីង វិន បានបញ្ជាក់ថា នៅកន្លែងនេះអ្នកទោសត្រូវបាន

"វៃបន្ទំឲ្យឆ្អើយ"។ យោងតាមសាក្សីឈ្មោះ ញិះ វិធីមួយផ្សេងទៀតនៃការធ្វើទារុណកម្មគឺថា ខ្មែរក្រហមយកអ្នកទោសទៅកប់ដីត្រឹមកទាំងរស់។ ទីតាំងមួយទៀតនៅក្នុងខេត្តក្រចេះ អ្នកទោសនៅក្នុងគុកឃុំកញ្ជែរត្រូវបានវាយធ្វើទារុណកម្ម។ សាក្សីឈ្មោះ ឃិន ឈិន បាននិយាយថា រូបគាត់ផ្ទាល់ត្រូវបានកងសន្តិសុខធ្វើទារុណកម្មលើរាងកាយរហូតដល់បាក់ឆ្អឹងជំនី។ គាត់ថែមទាំងនិយាយថា មានអ្នកទោសមួយចំនួនត្រូវស្លាប់ដោយអត់អាហារ។ លោក ប៉ោង បូជាវិទ្ធិ នៅទីស្នាក់ការសាលាស្រុកបានធ្វើការទាក់ទងអំពីរឿងទីតាំងប្រល័យពូជសាសន៍ដែរថា អ្នកទោសនៅក្នុងភូមិរលាកត្រូវបានលត់ដំនិងធ្វើទារុណកម្មយ៉ាងខ្លាំងមុនពេលយកទៅសម្លាប់ចោល។ លោក ហេង បេ និយាយថា អ្នកទោសដែលជាប់គុកនៅសន្តិសុខព្រែកកូនដើត្រូវពួកខ្មែរក្រហមធ្វើទារុណកម្មជាទម្ងន់មុនពេលយកទៅសម្លាប់ចោល។ សាក្សីបួនរូបដែលត្រូវបានឃុំឃាំងដោយខ្មែរក្រហមនៅក្នុងខេត្តកំពង់ធំ នៅទីតាំងគុកពីរផ្សេងគ្នាដែលមានឈ្មោះថាត្រដែតនិងវត្តបារាយណ៍ជាន់ដែក បានបញ្ជាក់ច្បាស់ថា ខ្លួនក៏ត្រូវបានវាយធ្វើបាបយ៉ាងឃោរឃៅដោយឆ្មាំគុករហូតដល់បាក់ឆ្អឹងជំនី។ ដោយមានសុខភាពទ្រុឌទ្រោមផង ការវាយដំប្រចាំឆាក់ទាំងនេះអាចបណ្តាលឲ្យមានរបួសគ្រាំគ្រាដល់ជនរងគ្រោះដែលជាអ្នកទោសទាំងអស់។ ដោយសារតែធ្លាប់រស់នៅក្នុងគុករបស់ខ្មែរក្រហម អ្នកទោសទាំងបួនរូបដែលនៅរស់រានមានជីវិត នៅមានស្លាកស្នាមនៅលើជើងរបស់ខ្លួននៅឡើយដោយសារតែការដាក់ខ្នោះ ហើយករណីនេះអាចចាត់ចូលជាអំពើទារុណកម្មបាន។ រឿងរ៉ាវប្រហាក់ប្រហែលគ្នានេះដែលនិយាយពីការវាយដំដ៏ឃោរឃៅដោយសន្តិសុខខ្មែរក្រហម គឺត្រូវបានរៀបរាប់ប្រាប់ដោយឈ្មោះ ចាប ប៊ុន រស់នៅខេត្តកំពង់ធំ។ ចាប ប៊ុន និយាយថា សន្តិសុខខ្មែរក្រហមនៅគុកត្រដែតបានវាយគាត់រហូតដល់ធ្លាក់ឈាមតាមមាត់។ នៅខេត្តសៀមរាបក៏មានរឿងហេតុប្រហាក់ប្រហែលគ្នានេះដែរ។ ឈ្មោះ អួម សឿន រស់នៅក្នុងឃុំបន្ទាយស្រី បាននិយាយថា អ្នកទោសត្រូវបានចាប់ចងធ្វើទារុណកម្មនៅឯវត្តត្បែង។ ការធ្វើទារុណកម្មក្នុងទម្រង់ផ្សេងមួយទៀតគឺមើលទៅហាក់ដូចជាមានបំណងធ្វើឲ្យជនរងគ្រោះមានការឈឺចាប់ខ្លាំង ដូចដែលស្ត្រីម្នាក់ឈ្មោះ ប៉ាល់ រ៉ន បានរៀបរាប់អំពីការដែលខ្លួនគាត់ត្រូវបានឃុំឃាំងនៅវត្តខ្នុររកា ក្នុងខេត្តកណ្តាល។ រ៉ន បានរ៉ាយរ៉ាប់ពីអំពើកើតឡើងពេលដែលគាត់ជាប់នៅក្នុងគុកថា "ជួនកាលពេលដែលអ្នកទោសកំពុងដេកលក់នៅលើរនាបឫស្សី ខ្មែរក្រហមបានយកចំពុះទង់ចាក់ពីក្រោមបណ្តាលឲ្យរបួសខ្លងអ្នកខ្លះត្រូវដើងនាំឲ្យមានរបួសឈឺចាប់យ៉ាងខ្លាំង"។ ស្ត្រីរូបនេះបានពោលថា កម្មាភិបាលខ្មែរក្រហមមើលការខុសត្រូវនៅគុកនេះ"ឃោរឃៅណាស់"។



ក្នុងពេលដែលទិន្នន័យចេះតែត្រូវបានបន្តប្រមូលពីស្រុកឃុំទូទាំងប្រទេសកម្ពុជា មានពត៌មានកាន់តែច្រើនឡើងៗ បញ្ជាក់ពីការរំលោភរបស់ខ្មែរក្រហមលើផ្លូវភេទនិងអំពើឃោរឃៅទៅលើរាងកាយរបស់ស្ត្រីភេទដែលជាអ្នកទោស។ ឧទាហរណ៍ នៅក្នុងខេត្តកំពង់ឆ្នាំង នៅទីតាំងមួយហៅថាព្រៃត្រពាំងអំពិល សាក្សីម្នាក់ឈ្មោះ បិន ម៉េត អះអាងថាកម្មាភិបាលខ្មែរក្រហមតែងតែរំលោភអ្នកទោសស្រីៗជាប្រចាំមុនពេលយកទៅសម្លាប់ចោល។ ករណីនេះក៏អាចចាត់ទុកថាជាប្រភេទទារុណកម្មមួយដែរ។

វាអាចត្រឹមត្រូវដូចដែលលោក ឆេនដល័រ បាននិយាយដូច្នេះដែរថា អំពើទារុណកម្មក្នុងបំណងស្រង់យកចម្លើយសារភាពគឺមិនត្រូវបានធ្វើឡើងជាលក្ខណៈប្រព័ន្ធនៅតាមប្រព័ន្ធគុកតូចតាចថ្នាក់ក្រោមរបស់ខ្មែរក្រហមទេ ដោយសារតែទារុណកម្មបែបនេះជាចំណុចកំពូលរបស់ប្រព័ន្ធមន្ទីរស-២១ (គុកទួលស្លែង) ។ ក្នុងករណីជាច្រើនទារុណកម្មអាចត្រូវបានប្រើនៅតាមគុកថ្នាក់ក្រោមជាវិធីមួយសម្រាប់បង្កការឈឺចាប់ឬសម្លាប់«ខ្មាំង» ។ ហើយហាក់ដូចជាការច្បាស់ណាស់ថាវិធីសាស្ត្រនៃការធ្វើទារុណកម្មនៅមន្ទីរស-២១មានលក្ខណៈតឹងតែងជាងនៅអង្គការចាត់តាំងមនុស្សឃាតថ្នាក់ទាបរបស់ខ្មែរក្រហម ។ ភាគច្រើន អំពើទារុណកម្មនៅតាមភូមិភាគ តំបន់ ថ្នាក់ស្រុក ថ្នាក់ឃុំ និងថ្នាក់ភូមិ ត្រូវបានប្រព្រឹត្តឡើងដោយដៃទទេឬដោយព្រនង់ឈើឬព្រនង់ដែកសម្រាប់វាយអ្នកទោសទាល់តែចេញឈាមនិងឡប់សតិ ឬទាល់តែស្លាប់ ។

ទាក់ទងនឹងការស្លាប់និងការរស់នៅតាមប្រព័ន្ធគុកថ្នាក់ទាបរបស់ខ្មែរក្រហម យើងឮថា ជារឿយៗឆ្មាំសន្តិសុខតែងតែដាក់ខ្នោះអ្នកទោសតាមឋានៈ ហើយដាក់ចូលក្នុងគុកបង្អត់អាហារដូនកាលបង្អត់ទឹកទៀតរហូតដល់ខ្សោះទឹកស្លាប់ ។ ករណីនេះមានលក្ខណៈដូចគ្នាទៅនឹងការសម្លាប់ដែលមានបច្ចេកទេស និងផលប៉ះពាល់កម្រិតទាប ។ សូមមើលរឿងរ៉ាវដែលកើតឡើងនៅគុកព្រៃដីស្រុតដែលរៀបរាប់ដោយលោក គីម ពន រស់នៅខេត្តកំពង់ឆ្នាំង ឬក៏លោក ឱ យឿង ដែលរស់នៅក្នុងខេត្តកំពង់ធំដែលបាននិយាយអំពីរឿងអ្វីដែលគាត់ធ្លាប់ជួបប្រទះនៅក្នុងគុកត្រដែត ។ យើងសូមប្រកាន់ជំហរថាការប្រព្រឹត្តនេះដែលហាក់ដូចជាមានលក្ខណៈប្រព័ន្ធបង្កើតបានជាទម្រង់ឃោរឃៅមួយនៃអំពើទារុណកម្មទោះមិនមានការយល់ដឹងជាលក្ខណៈប្រពៃណីនៃអំពើទារុណកម្មយ៉ាងណាក៏ដោយ ។ ចំពោះខ្ញុំយល់ថាការបង្អត់អាហារបន្តិចម្តងៗទាល់តែស្លាប់ទៅលើជនរងគ្រោះដែលត្រូវបានដាក់នៅក្នុងបន្ទប់ដែលពោរពេញទៅដោយការឈឺចាប់ហាក់ដូចជាការធ្វើទុកបុកម្នេញតាមវិធីមួយដែលគួរឲ្យភ័យខ្លាចជាងការបណ្តើរជនរងគ្រោះទាំងហ្វូងៗយកទៅមាត់រណ្តៅ ហើយវាយដោយដំបងដែកចំកញ្ចឹងកឲ្យស្លាប់ធ្លាក់ចូលក្នុងរណ្តៅទៅទៀត ។

## ការសម្លាប់

ក្រៅពីអំពើទារុណកម្ម មុខងាររបស់បណ្តាញសន្តិសុខខ្មែរក្រហមគឺកម្ទេចមនុស្សដែលអង្គការយល់ថាជាខ្មាំងរបស់របបខ្លួន ។ មានមនុស្សជាច្រើនសន្ធឹកសន្ធាប់ត្រូវបានសម្លាប់ ។ ជារឿយៗតែងតែមានការលើកឡើងនូវសំណួរថា «ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជនកម្ពុជាយ៉ាងច្រើនបែបនេះ?» ។ របាយការណ៍នៃការចុះស្រាវជ្រាវនិងធ្វើផែនទីយ៉ាងហោចណាស់ក៏អាចផ្តល់មួយផ្នែកនៃចម្លើយនេះដែរ ទោះបីជាចម្លើយនេះពិបាកនឹងគម្រូវចិត្តអ្នកសួរយ៉ាងណាក៏ដោយ ។ សូម្បីតែការកំណត់ពីមូលហេតុដែលថាហេតុអ្វីបានមានការកាប់សម្លាប់ប្រជាជនក៏នៅតែមិនត្រូវចិត្តចំពោះខ្លួនឯង ។

គ្រាន់តែធ្វើជានគរបាល ទាហាន ឬធ្វើជាបុគ្គលិកបម្រើការឲ្យរបបចាស់ ក៏ជាការគ្រប់គ្រាន់នឹងការទទួលការកាត់ទោសប្រហារជីវិត ។ ហើយការជាប់សាច់ឈាមឬការរៀបអាពាហ៍ពិពាហ៍ជាមួយ«ខ្មាំងវណ្ណៈ»ទាំងនោះក៏ជាការគ្រប់គ្រាន់សម្រាប់ទទួលរងនូវពូថៅរបស់ពេជ្ឈឃាត ។ ដូចដែលសាក្សីមួយរូបឈ្មោះ អុក ទួន កត់សម្គាល់សកម្មភាពខ្មែរក្រហមនៅក្នុងគុកដីស្រុតស្ថិតក្នុងខេត្តកំពង់ឆ្នាំងថា «គ្មានសាច់ញាតិណាម្នាក់របស់ជនជាប់ចោទត្រូវបានទុកជីវិតឲ្យរស់ឡើយ» ។ ករណីដូចគ្នានេះដែរកើតឡើងនៅក្នុងព្រៃតាគុចក្នុងខេត្តកំពង់ឆ្នាំង តាមសម្តីរបស់អ៊ុក យុន បានឲ្យដឹងថា ខ្មែរក្រហមបាននាំយកប្រជាជនទាំងគ្រួសារៗយកទៅសម្លាប់ ។ ពត៌មាននេះមានលក្ខណៈដូចគ្នាទៅនឹងសេចក្តីរាយការណ៍ដែលយើងបានទទួលក្នុងអំឡុងប្រាំឆ្នាំនៃការងារធ្វើផែនទីរណ្តៅសាកសព ។

លើសពីនេះទៀត គ្រាន់តែធ្លាប់ធ្វើជាមន្ត្រីរដ្ឋការឬប្រជាជនធម្មតាទូទៅក៏ត្រូវបានចាត់ទុកជាខ្មាំងដែរ ។ អតីតនិស្សិតដែលខ្មែរក្រហមចាត់ទុកថាជា«បញ្ញវ័ន្ត» ក៏ត្រូវបានកត់ចូលបញ្ជីនៅលើគេបង្អស់ក្នុងចំណោមជនដែលជាមុខសញ្ញាយកទៅកម្ទេចដែរ ។ ហើយការចូលសាលានិងរៀនអានអក្សរក៏ធ្វើឲ្យមនុស្សស្លាប់បានដែរ ។ សាក្សីម្នាក់រស់នៅខេត្តរតនៈគីរីឈ្មោះប៊ុន វ៉ាន់ថា ជឿថារូបគាត់ត្រូវបានខ្មែរក្រហមចាប់ខ្លួនដោយសារតែគាត់សរសេរសំបុត្រមួយច្បាប់ទៅឲ្យខ្មែរក្រហមប៉ុណ្ណោះ ។

ជំពូកខ្មាំងវណ្ណៈផ្សេងទៀតដែលត្រូវបាននាំយកទៅសម្លាប់ទាំងហ្វូងៗដែរគឺ«ពួកមូលធន» ។ ក្នុងគំនិតរបស់ខ្មែរក្រហម ជនរងគ្រោះប្រភេទនេះរួមមានអ្នកធ្វើការយ៉ាងនឿយហត់ដូចជាអ្នកលក់គុយទាវតាមផ្លូវនិងអ្នករត់ឡានឈ្នួល ។ «ពួកសក្តិភូមិ» ដែលមានភក្តីភាពចំពោះសម្តេច សីហនុ ក៏ត្រូវទទួលទោសប្រហារជីវិត ។

រាល់ករណីទាំងអស់នេះដែលរួមមានការធ្វើទាហាន និស្សិត បុគ្គលិករដ្ឋការ អនុធនលក់ដូរ អ្នកគាំទ្រព្រះមហាក្សត្រ ឬការជាប់សាច់ញាតិជាមួយប្រជាជនប្រភេទដូចរៀបរាប់នេះ ត្រូវបានចាត់ទុកថា«មានជាប់និន្នាការ» ។ ខ្មែរក្រហមមានទំនោរសម្លាប់ជនដែលមាន«និន្នាការ» ។

ដោយមានការបោសសម្អាតផ្ទៃក្នុងរបស់បក្សកុម្មុយនិស្តកម្ពុជា លែងមានការប្រហារជីវិតអ្នកដែលជាបុគ្គលិករដ្ឋការរបបមុនទៀតហើយ ប៉ុន្តែអ្នកបម្រើការនៅរបបកម្មាភិបាលរបស់អង្គការកម្ពុជាប្រជាធិបតេយ្យខ្លួនឯងផ្ទាល់ត្រូវបានប្រមូលយកទៅសម្លាប់ចោលយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ហើយនៅពេលដែលការបោសសម្អាតខ្សែមេដឹកនាំចេះតែកើនឡើង ក៏មានការសម្លាប់អ្នកបានបម្រើកម្មាភិបាលនិងអ្នកដែលមានតួនាទីប្រហាក់ប្រហែលនឹងកម្មាភិបាលដែលត្រូវបានយកទៅសម្លាប់រួចហើយ ។ មានសក្ខីកម្មយ៉ាងមាំបញ្ជាក់ដោយលោក ចាន់ តូច ដែលរស់នៅខេត្តមណ្ឌលគិរីអំពីករណីដែលមានចារឹកដូចគ្នានេះ ។ លោក ចាន់ តូច និយាយថា កាលពីឆ្នាំ១៩៧៧ «អ្នកដែលពាក់ព័ន្ធជាមួយនឹងមេដឹកនាំជាន់ខ្ពស់ពីរនាក់ឈ្មោះ ហម និង ខាំ ភួន សុទ្ធតែត្រូវបានចាប់ខ្លួនហើយបញ្ជូនទៅដាក់គុកភ្នំក្រោល ។ ចុងបញ្ចប់ ការគ្រប់គ្រងមានលក្ខណៈយ៉ាងតឹងតែងរហូតដល់មានការចាត់ទុកប្រជាជនធម្មតាដែលរស់នៅអតីតតំបន់ដែលគ្រប់គ្រងដោយអ្នកដែលពេលនេះត្រូវបានចាត់ទុកជា«ជនក្បត់» ហើយឈ្មោះប្រជាជនទាំងនោះត្រូវបានគេបន្ថែមចូលក្នុងបញ្ជី ដូចឃើញស្រាប់នូវការបោសសម្អាតនៅភូមិភាគបូព៌ា ។

ក្រៅពីការសម្លាប់ដោយមូលហេតុរើសអើងវណ្ណៈ ពោលគឺភាពជាសមាជិកនៃក្រុមដែលខ្មែរក្រហមមិនពេញចិត្ត ដូចជាអតីតនិស្សិតជាដើម មានប្រជាជនជាច្រើនក៏ត្រូវបានសម្លាប់ចោលដោយសារបានប្រព្រឹត្ត«កំហុស» ។ ទោសកំហុសដែលអាចដាក់ទណ្ឌកម្មដល់ជីវិតមានកម្រិតផ្សេងៗគ្នា ។ ឧទាហរណ៍នៅខេត្តបន្ទាយមានជ័យ សាក្សីបានរៀបរាប់អំពីប្រភេទផ្សេងៗជាច្រើននៃ«កំហុសធ្ងន់»ដែលអាចបណ្តាលឲ្យមនុស្សម្នាក់ត្រូវបានថ្កោលទោស ។ «ជនណាដើរពីភូមិមួយទៅភូមិមួយទៀតដោយគ្មានការអនុញ្ញាត» ត្រូវចាត់ទុកជា«ខ្មាំង» ហើយត្រូវសម្លាប់ចោលភ្លាម ។

ជនណាដែលរកបានអាហារហូបចុកដោយគ្មានការអនុញ្ញាតត្រឹមត្រូវក៏ត្រូវស្លាប់ដែរ ។ ដូចដែលសាក្សីមួយចំនួនរស់នៅក្នុងស្រុកថ្មពួកខេត្តបន្ទាយមានជ័យបញ្ជាក់ថា ប្រជាជនណាម្នាក់ដែលត្រូវចាប់បានដោយឃើញកាន់ត្រី ក្តាម ខ្យង ឬបន្លែ ជីងចក់ ជួនកាលត្រូវសម្លាប់ចោលភ្លាមមួយរំពេចដោយចោទថាហូបលើសពីរបបកំណត់សម្រាប់ប្រជាជនទូទៅ ។ ការប្រព្រឹត្តបែបនេះមានលក្ខណៈប្រហាក់ប្រហែលនឹងការចោទប្រកាន់ពីបទប៉ុនប៉ងចង់រួចផុតពីការអត់ឃ្លានដោយគ្មានការអនុញ្ញាត ។

នៅក្នុងខេត្តបន្ទាយមានជ័យដដែលនេះ មានការរៀបរាប់អំពីការសម្លាប់ដោយការប្រឌិតហេតុផលឡើង ។ កម្មាភិបាលបញ្ជាកសិករដើរខាងស្តាំដៃនៃគន្លងន័ង្គលតាមក្រោយគោ ប៉ុន្តែដោយខុះការប្រុងប្រយ័ត្នកសិករទាំងនោះក៏ដើរតាមគន្លងនង្គ័លខាងឆ្វេងដៃដែលជាទម្លាប់របស់ខ្លួនតាំងពីយូរយារណាស់មកហើយ ។ ចុងបញ្ចប់«កសិករត្រូវបានចោទប្រកាន់ថាជាខ្មាំង ហើយសម្លាប់ចោលភ្លាមនៅចំពោះមុខកសិករទាំងប៉ុន្មានដែលកំពុងភ្ជួររាស់នៅទីនោះ» ។

ស្នេហាមិនត្រឹមត្រូវក៏ជាមូលហេតុនាំដល់ការស្លាប់ដែរ ។ ខ្មែរក្រហមមានការពិនិត្យតាមដានច្បាស់លាស់ណាស់ចំពោះបញ្ហាស្នេហានិងការរួមភេទ ។ ករណីនេះដូចជាករណីផ្សេងៗទៀតដែរ គឺចាត់ទុកខ្មែរក្រហមថាជាអង្គការដែលមានលក្ខណៈផ្តាច់ការបំផុតក្នុងចំណោមរបបផ្តាច់ការផ្សេងៗនៅក្នុងប្រវត្តិសាស្ត្រ ។ ក្នុងន័យនេះខ្មែរក្រហមបានយកឈ្នះលើចិត្តគំនិតរបស់ប្រជាជន បើមិនដូច្នេះទេប្រជាជនច្បាស់ជាស្លាប់ ។ ប៉ុន្តែមិនស្លាប់ទាំងអស់ទេក្នុងចំណោមអ្នកដែលត្រូវបានខ្មែរក្រហមចាប់ខ្លួន ។ ***(នៅមានត)***

**របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា**

# គំរូមួយនៃភ័ស្តុតាងឯកសារភ្ជាប់មេដឹកនាំថ្នាក់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជាដែលនៅរស់ នៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ភាគ២)

បន្ទាប់មក សុន សេន ក៏ឡើងសរុបសេចក្ដីថា ទី១ «អ្នកដែលមានវត្តមាននៅទីនេះ» សូមឯកភាពជាមួយបក្សក្នុងការគិតថា ការចាប់ខ្លួនពួកក្បត់ទាំងនេះគឺជាជោគជ័យដ៏ធំទៅលើពួកសេរីនិយមដែលកំពុងតែដើរតាមផ្លូវសម្ងាត់និងលួចជ្រៀតចូលអស់ជាង១០ឆ្នាំហើយ ។ ទី២ «ព្រឹត្តិការណ៍ទាំងនេះយើងត្រូវលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នខ្ពស់» ។ ទី៣ «បទពិសោធន៍នេះបានលើកកម្ពស់ការព្រួយបារម្ភរបស់យើងចំពោះពួកដែលមានប្រវត្តិមិនល្អ ពួកគិតពីឋានៈបុណ្យសក្តិ និងអ្នកដែលចូលបដិវត្តន៍ដោយគ្មានលក្ខណៈសមស្របដូចជា ចក្រី យ៉ា និង កែវ មាស ។ ចំណុចចុងក្រោយ «ឥឡូវនេះយើងម្នាក់ៗដឹងថា សកម្មភាពវាយប្រហារតូចតាចមកលើបដិវត្តន៍...បញ្ហាទាំងអស់នេះបណ្ដាលមកពីខ្មែរក្បត់ទាំងអស់ហ្នឹងឯង ។ ដូច្នេះទោះបីជាបក្សបានកម្ទេចខ្មាំងផ្ទៃក្នុងអស់រលីង និងជាយុទ្ធសាស្ត្រដោយសារតែវាធ្វើការកម្ទេចមេក្បត់ធំៗរបស់វាយ៉ាងណាក៏ដោយ តែយើងម្នាក់ៗមិនត្រូវមានគំនិតអត្តនោម័តិនិងគិតថាការតស៊ូកម្ចាត់បានឈានដល់ទីបញ្ចប់ឲ្យសោះ» ។

ប៉ុន្តែវានៅតែសំខាន់ក្នុងការយកចិត្តទុកដាក់ចំពោះខ្មាំងនៅសេសសល់បង្កប់ផ្ទៃក្នុង ដើម្បីកុំឲ្យពួកវាធ្វើសកម្មភាព និងដើម្បីការពារបក្ស ។ ទោះបីជា«យើងបានកម្ទេចខ្មាំងអស់ជាស្ថាពរ និងជាយុទ្ធសាស្ត្រក៏ដោយ... ក៏ខ្មាំងនឹងនៅតែអាចវាយយើងតទៅទៀត ខ្មាំងខឹងនឹងយើងណាស់» ។ ដូច្នេះត្រូវលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ ហើយជាពិសេសប្រុងប្រយ័ត្នចំពោះការធ្វើសកម្មភាពជាក់ស្ដែង» ។ គ្មានកន្លែងណាដែលគ្មានការប្រុងប្រយ័ត្នទេ ។ «វាជាការសំខាន់ក្នុងការបោសសម្អាតឲ្យអស់នូវពួកសមាសភាពមិនល្អក្នុងលក្ខណៈតស៊ូវណ្ណៈ» ។ សុន សេន វែកញែកពន្យល់ថា ការបោសសម្អាតនេះផ្ដោតទៅលើមនុស្សបីជំពូក÷

ពួកទី១ៈ ពួកដែលប្រកបដោយគ្រោះថ្នាក់ ពួកនេះត្រូវតែកម្ទេចឲ្យអស់ដាច់ខាត ។

ពួកទី២ៈ ពួកសេរីធម្មតា ពួកនេះត្រូវតែធ្វើការអប់រំកសាងម្ដងហើយម្ដងទៀតនៅក្នុងសាលារៀនរបស់យើង ។

ពួកទី៣ៈ ពួកដែលត្រូវបានខ្មាំងអូសទាញ ។ មុនដំបូងត្រូវអប់រំណែនាំកុំឲ្យជឿខ្មាំងតទៅទៀត ។

សុន សេន ក៏បានណែនាំពី«បញ្ហាវិភាគឬវែកមុខខ្មាំង» ។ សុន សេន និយាយថា ប្រសិនបើ«ហេតុភេទមិនល្អនេះកើតមានហើយ មិត្តទាំងអស់ត្រូវរកហេតុផលនិងប្រភពឲ្យបានច្បាស់» ។ ដូច្នេះ «មានកើតឡើងនៅកន្លែងណាត្រូវតែពិនិត្យនៅទីនោះ» ហើយប្រសិនបើមានតម្រុយហើយ ត្រូវតាមដានឲ្យជាប់» ។ នៅពេលទន្ទឹមគ្នានេះដែរ «គ្រប់អង្គភាពទាំងអស់ត្រូវតែរៀបចំត្រឹមត្រូវ ហើយត្រូវក្ដាប់ប្រវត្តិរូបកម្មាភិបាលយុទ្ធជនឲ្យបានច្បាស់លាស់ម្ដងទៀតនៅពេលពិនិត្យម្ដងហើយ» ។

ចុងបញ្ចប់ សុន សេន ធ្វើការណែនាំថា ឈ្មោះ«អ្នកក្បត់» ត្រូវផ្សាយឲ្យសាធារណជនបានដឹងពុ ។ ដូច្នេះ «ក្នុងការអប់រំបងប្អូន»ដែលជាកូនទាហានតូចតាច ត្រូវអប់រំពីសតិអារម្មណ៍និងគោលជំហរ គឺមិនមែននិយាយអំពីបញ្ហាច្បាប់ណាមួយឡើយ ។

នៅក្នុងសម្ដីរបស់ សុន សេន ទាំងប៉ុន្មាន សុន សេន មិនដែលនិយាយច្បាស់ថាអ្នកដែលត្រូវបានចាប់ខ្លួនពីបទក្បត់ត្រូវបាននាំយកទៅសម្លាប់ចោលឡើយ ប៉ុន្តែការដែល សុន សេន បានប្រើពាក្យ«កម្ទេច»ជាញឹកញាប់ និងហៅខ្មែរមេៗថាជា«អាមេក្បត់» គឺវាជាការបញ្ជាក់យ៉ាងច្បាស់ថា ការកាប់សម្លាប់ពិតជាកើតមានឡើង ។ ការលើកឡើងពីប្រភេទសមាសភាពគ្រោះថ្នាក់ដែលត្រូវបោសសម្អាតដើម្បីធ្វើការដោះស្រាយតាមមធ្យោបាយលើសពីការកសាងខ្លួននោះ ក៏បញ្ជាក់ពីការកាប់សម្លាប់ដែរ ទោះបីជាមិនសូវច្បាស់ក៏ដោយ ។

មុត និង ម៉ែត បានចូលរួមនៅក្នុង«កិច្ចប្រជុំកងពលធំពេញអង្គ»ធ្វើឡើងនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ដែរ ។

នៅក្នុងកិច្ចប្រជុំនោះកម្មាភិបាលបានធ្វើសេចក្ដីរាយការណ៍អំពី "សភាពការណ៍ខ្មាំង" ។ ទោះបីជានៅក្នុងកិច្ចប្រជុំនេះ មុត និង ម៉ែត មិនបានលើកឡើងពីបញ្ហាបោសសម្អាតខ្មាំង ឬការចាប់ខ្លួននៅក្នុងកងពលលេខ១៦៤ និង ៥០២ ក៏ដោយ ក៏អ្នកទាំងពីរបានស្ដាប់ពួរបាយការណ៍នានាទាក់ទងនឹងបញ្ហានេះដែលលើកឡើងដោយកម្មាភិបាលដទៃទៀត ។ អ្នកដែលចូលមកជំនួស ចក្រី ដែលជាលេខាកងពលលេខ១៧០ ឈ្មោះ កែវ សាន ហៅ សុខ (ដែលក្រោយមកត្រូវបានបោសសម្អាត) និយាយថាខ្លួនបាន"ចាប់ខ្មាំងបានម្នាក់មកពីមូលដ្ឋាន" ។ លេខាកងពលធំលេខ៤៥០ឈ្មោះ សួង បានរាយការណ៍ថាបាន"ចាប់ខ្លួនអ្នកដែលបានលួចទុក" ។ លេខាកងពលលេខ២៩០ឈ្មោះ មាស គាល់ បានរាយការណ៍ថាបានចាប់ខ្លួន"មនុស្សចំនួន៧នាក់" ហើយបន្ថែមថា "គេថាគេជាប្រជាជនមកពីកងចល័តស្រុកស្អាង តំបន់២៥ ភូមិភាគនិរតី" ។ អ្នកទាំងពីរក៏បានស្ដាប់របាយការណ៍របស់លេខាវរសេនាធំឯករាជលេខ៤៨៨ឈ្មោះ អ៊ុច គុល ហៅ ភាព (ក្រោយមកត្រូវបានបោសសម្អាត) ដែលនិយាយថាយុទ្ធជនខ្លះ"បានសុំទៅផ្ទះទៅនៅជាមួយឪពុកម្ដាយ ដោយលើកហេតុផលថាមានគេសម្លាប់ឪពុកម្ដាយរបស់ខ្លួន" ។ **លេខាវរសេនាធំលេខ១៥២ ឈ្មោះ ប៉ាន់ ស៊ីម ហៅ សែល (ក្រោយមកត្រូវបានបោសសម្អាត) និយាយថាខ្លួនបាន"ចាប់ខ្លួនក្មេងប្រុសពីរនាក់ដែលរត់ពីស៊ីងមានជ័យ" ស្ថិតនៅជាយក្រុងភ្នំពេញ ។ ក្មេងទាំងពីរនាក់និយាយថាខ្លួនបានព្យាយាមរត់គេចក្នុងពេលមើលគោ ។**

នៅក្នុងកិច្ចប្រជុំមួយនៅពាក់កណ្ដាលខែធ្នូ ឆ្នាំ១៩៧៦ ម៉ែត បានរាយការណ៍ថា កន្លងមកនៅក្នុងកងពលធំលេខ៥០២ "សភាពការណ៍ផ្ទៃក្នុងពុំមានអ្វីប្លែកឡើយ" ។ ម៉ែត រាយការណ៍ថានៅក្នុងអង្គភាពរបស់ខ្លួនមាន"បងប្អូនយើងអួតថាមាគ៌ារបស់បក្សគឺអនុវត្តលឿនជាងគេ" ។ ប៉ុន្តែ ម៉ែត និយាយថា មានយុវជនបក្សកុម្មុយនិស្តមួយក្រុម"មិនអាចអនុវត្តឲ្យទាន់អ្នកដទៃទេដោយសារតែមាគ៌ាបក្ស"ស៊ីជម្រៅពេក គេមិនអាចយល់ដល់" ។ ម៉ែត បានស្ដាប់លេខាកងពលលេខ១៧០ឈ្មោះ សុខ រាយការណ៍ថាមានបញ្ហាខ្លះជាមួយនឹងយុទ្ធជននៅក្នុងអង្គភាពនោះ ពីព្រោះគេមាន"សាច់ញាតិ"ដែលត្រូវបានអង្គការយកទៅដោយគ្មានដឹងមូលហេតុច្បាស់លាស់ ។ ក្រោយពេលស្ដាប់របាយការណ៍ទាំងអស់រួចហើយ សុន សេន សរុបឡើងវិញថា ទោះបីជា "ខ្មាំងផ្ទៃក្នុង"របស់បដិវត្តន៍ត្រូវវាយឲ្យខ្ចាត់ខ្ចាយយ៉ាងណាក៏ដោយ ប៉ុន្តែនៅពេលទន្ទឹមគ្នានេះដែរក៏នៅមាន...ធាតុភាពមួយចំនួនដែលជាការបង្ហាញថាខ្មាំងនៅតែមាន ហើយបន្តបង្កប់ធ្វើសកម្មភាពផ្ទៃក្នុងកងទ័ពយើង ។ សុន សេន ពន្យល់ហេតុផលថា៖ "ឧទាហរណ៍មានពាក្យស្លោកវាយប្រហារប្រព័ន្ធសហករណ៍យើង នៅមានការបន្ទុចបង្អាក់និងបំផ្លាញសម្ភារ មានការលួចនិងមានការបោះខិតប័ណ្ណជាអនាមិក ។ ហេតុភេទទាំងអស់នេះបង្ហាញឲ្យឃើញថាខ្មាំងមិនទាន់អស់នៅឡើយទេ ហើយមូលហេតុដែលខ្មាំងនៅមិនទាន់អស់បែបនេះគឺដោយសារតែមានទំនាស់ផ្ទៃក្នុង ។ តាមអ្វីដែលយើងដឹង ពួកសេរីរើសូវៀតនិងវៀតណាមកំពុងតែបន្តធ្វើសកម្មភាពកាន់តែខ្លាំងឡើងៗនៅក្នុងប្រទេសរបស់យើង ទោះបីជាពួកវាត្រូវបានកម្ទាត់ជាមូលដ្ឋានហើយក៏ដោយ ។ ពួកសេ.អ៊ី.អាក៏ត្រូវបានកម្ទេចអស់ជាមូលដ្ឋានដែរ ប៉ុន្តែពួកវាក៏នឹងបន្តសកម្មភាពរបស់វាទៀតដែរ" ។

សុន សេន បានស្នើសុំឲ្យមានការយកចិត្តទុកដាក់ប្រុងប្រយ័ត្នដើម្បីធ្វើការ"បោសសម្អាតក្នុងជួរកងទ័ពឲ្យបានស្អាត" ដោយសង្កត់ធ្ងន់ពីបញ្ហាចាប់អារម្មណ៍និងតាមដានហេតុភេទតូចតាចសេសសល់ទាំងនេះ ។ តាមការពិតគឺថាមូលហេតុរបស់វាមានការទាក់ទងគ្នាពីមួយទៅមួយ ។ កុំគិតថាបញ្ហាទាំងអស់នេះជារឿងធម្មតាឲ្យសោះ ។ មធ្យោបាយវែកមុខរកពួកវាគឺត្រូវតាមដាន ហើយបើបានជួបហើយត្រូវធ្វើការវាយតម្លៃហេតុភេទទាំងអស់នោះ...សំខាន់ត្រូវប្រយ័ត្នចំពោះខ្មាំងផ្ទៃក្នុងដែលនៅសេសសល់ ។ ប្រសិនបើយើងសម្ងំសុខប្រកាន់យកជំហរសន្តិភាពនិយម ពួកវានឹងទាញយកផលប្រយោជន៍នេះធ្វើការវាយប្រហារមកលើបដិវត្តន៍យើងជាមិនខាន ។ ដូច្នេះវានៅតែសំខាន់ដដែលក្នុងការបោសសម្អាតពួកដែលប្រកបដោយគ្រោះថ្នាក់ទាំងអស់នេះឲ្យអស់ពីអង្គភាពរបស់អង្គការដោយផ្អែកទៅលើកំហុសជាក់ស្ដែងរបស់ពួកវា៖ ធ្វើអ្វីៗដែលត្រូវធ្វើ កុំឲ្យឆ្វេង កុំឲ្យស្ដាំ ។ កន្លងមកមានការក្ដាប់ប្រវត្តិរូបល្អ

ប៉ុន្តែក៏នៅតែមានមិត្តខ្លះនៅលាក់ប្រវត្តិរបស់ខ្លួន ។ ត្រូវប្រុងប្រយ័ត្នខ្ពស់ចំពោះអ្នកដែលមានឪពុកម្តាយឬក៏បងប្អូនត្រូវបានបោសសម្អាតរួចហើយ» ។

ម៉េត ក៏បានចូលរួមក្នុងកិច្ចប្រជុំកម្មាភិបាលកងពលដែលរៀបចំធ្វើឡើងដោយ សុន សេន នៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៧ ។ របៀបវារៈនៃកិច្ចប្រជុំរួមមានមិនត្រឹមតែ «សភាពការណ៍ខ្មាំងខាងក្នុង» តែថែមទាំងអំពី «ការបោសសម្អាតនិងសម្រិតសម្រាំងនៅក្នុងអង្គភាពអង្គការ» ទៀតផង ។ ម៉េត បានប្រកាសថា ឥឡូវនេះវា«ច្បាស់ណាស់ថាសមាសភាពជាច្រើន» ពីកងពលធំលេខ៥០២ ដែល«ត្រូវបានចាប់ខ្លួនលើកមុនគឺពិតជាពួកខ្មាំងមែន» ហើយថា សមាសភាពមិនល្អជាង៥០នាក់ចេញពីអង្គភាពកងពល «ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខស-២១រួចហើយ» ។ ម៉េត ក៏បានរាយការណ៍អំពីសភាពការណ៍ខ្មាំងថ្មីៗចំនួនបីទៀតដែលមានការពាក់ព័ន្ធជាមួយនឹងកងពលធំៈ ទី១គឺ «សភាពការណ៍ខ្មាំងនៅប៉ុស្តិ៍ស្ថិតនៅជិតពេទ្យលោកសង្ឃ» ភ្នំពេញ ដែលនៅពេលនោះមានម្នាក់ឆក់យកកាតពីអ្នកយាមប៉ុស្តិ៍ដែលស្ថិតនៅក្នុងកងពល ។ ទី២ «ឃាត់នារីកសិកម្មម្នាក់ដើរនៅជិតសាលាបណ្ឌិតសភាយោធាខ្មាំងនៅក្នុងទីក្រុង» ។ ទី៣ និយាយពី«ការចងគ្រាប់បែកក្នុងគោលបំណងសម្លាប់សមមិត្តយើងម្នាក់» ។ ម៉េត ប្រកាសថា កងពលធំលេខ៥០២អាចទទួលបាននូវការទុកចិត្តផ្នែកនយោបាយប្រសិនបើលេខាអនុសេនាតូច៥នាក់ត្រូវបានផ្លាស់ប្តូរចេញ ។

ម៉េត បានស្តាប់ពុសេចក្តីរាយការណ៍មួយរបស់លេខាកងពលលេខ៩២០ ឈ្មោះ ឈិន ដែលហៀបនឹងត្រូវបោសសម្អាតថា សមាសភាពនៅក្នុងកងពលនេះដែលពីមុនធ្លាប់ធ្វើការជាមួយវៀតណាម និងអ្នកដែលជាកូនរបស់ទាហាន ប្រធានឃុំ និងប៉ូលិស ត្រូវបានបោសសម្អាតនិងបញ្ជូនខ្លួនទៅធ្វើស្រែនៅមួយកន្លែង ប៉ុន្តែនៅតែមានខ្មាំងបង្កប់ ហើយពុទៀតថា ឈិន កំពុងតែតាមដានហើយ ។ ម៉េត បានស្តាប់សេចក្តីរាយការណ៍របស់លេខាកងពលលេខ៤៨៨ ឈ្មោះ ភាព ស្តីពីការឃុំឃាំង «មនុស្សម្នាក់...ពីព្រោះវានៅជិតគៀមលក់ដូរ» ហើយនិងសេចក្តីរាយការណ៍អំពីបញ្ហាមួយចំនួនដោយសារតែកម្មាភិបាលថ្នាក់ក្រោមនៅក្នុងវរៈសេនាធំ បានបញ្ចុះបញ្ចូលអូសទាញឲ្យយុទ្ធជនដឹកស្រាឬធ្វើល្មើសនឹងបម្រាមបេះផ្លែឈើ ។ ម៉េត បានពុកម្មាភិបាលដឹកនាំកងពលលេខ ៤៥០ ឈ្មោះ យ៉ាន និយាយមិនត្រឹមតែថា «នៅមានខ្មាំងបង្កប់នៅក្នុងអង្គភាពនៅឡើយ» តែថែមទាំងថា«អាចមានសមាសភាពរហូតដល់ទៅ ៦០០នាក់ដែលត្រូវកម្ចាត់ចេញ» ។ ម៉េត បានស្តាប់របាយការណ៍របស់លេខាកងពលវរសេនាធំលេខ១៥២ឈ្មោះ ស៊ឹម ដែលថាអង្គភាពបានចាប់ខ្លួនមនុស្សពីរ-បីនាក់នៅភូមិភាគនិរតី តំបន់២៥ ...ដែលបន្ទំខ្លួនជាមួយតំបន់៣៧ ។ ក្មេងប្រុសដែលត្រូវឃាត់ខ្លួនបាននិយាយថា មានការណែនាំចំពោះខ្លួនថាប្រសិនបើមានបញ្ហាអ្វីកើតឡើងត្រូវឆ្លើយដាក់ទ័ពរបស់អង្គការ ។

បន្ទាប់មក ម៉េត បានស្តាប់ការឡើងសរុបមតិរបស់ សុន សេន ដែលសង្កត់ធ្ងន់ថា សភាពការណ៍ឥឡូវកាន់តែធ្ងន់ធ្ងរទៅៗជាងអ្វីដែលបក្សបានគិតនៅចុងឆ្នាំ១៩៧៦ ។ នៅក្នុងការរៀបរាប់អំពីជម្លោះនិងទំនាស់ផ្ទៃក្នុងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលមានរួចមកហើយ កំពុងមាន និងទៅអនាគត សុន សេន បានពន្យល់ថា សំណូមពរដើម្បីតម្រង់ទស្សនៈវិភាគរបស់បក្សតទៅទៀតអំពីសភាពការណ៍ទំនាស់បដិបក្ខនិងទំនាស់ផ្ទៃក្នុង ដោយកន្លងមកមានព្រឹត្តិការណ៍ថ្មីៗថែមទៀតដែលបំភ្លឺយើងអំពីទំនាស់ក្នុងសភាពការណ៍កម្ពុជាបច្ចុប្បន្ន ព្រោះកន្លងមកទស្សនៈរបស់បក្សយើង កងទ័ពយើង វិភាគទំនាស់ក៏បានត្រឹមត្រូវដែរ តែព្រឹត្តិការណ៍ថ្មីៗបញ្ជាក់ថាទស្សនៈរបស់យើងមិនទាន់ជ្រួតជ្រាបក្នុងសាច់ការដូចសព្វថ្ងៃនេះទេ ។ ព្រឹត្តិការណ៍បញ្ជាក់ថាខ្មាំងសេ.អ៊ី.អា ជាយួន ជាសេរី វាបន្តធ្វើសកម្មភាពដើម្បីបំផ្លាញបដិវត្តន៍យើងខ្លាំងក្លាណាស់ក្នុងគោលបំណងដើម្បីវាយរំលំបដិវត្តន៍យើង បក្សយើង វាយរំលំកងទ័ព ហើយរារាំងដល់កិច្ចការបដិវត្តន៍របស់យើង ។ ខ្មាំងសេ.អ៊ី.អាវាយយើងពីក្រៅ តែជាពិសេសវាស៊ីរូងផ្ទៃក្នុងយើងបក្សនិងកងទ័ព ។

ដូច្នេះទោះបីជានៅចុងឆ្នាំ១៩៧៦ បក្សបានកម្ចាត់បណ្តាញក្បត់ដែលជាលេខាតំបន់២៤ ភូមិភាគបូព៌ា ឈ្មោះ ឈូក និងលេខាភូមិភាគឦសានឈ្មោះ យ៉ា ក៏ដោយ ប៉ុន្តែតាំងពីពេលនោះមក បក្សបានវែកមុខខ្សែក្បត់មួយចំនួនទៀតដែលមក

ដល់ឥឡូវនេះត្រូវបានកម្ទេចជាមូលដ្ឋានហើយ នេះគឺជាមហាជ័យជម្នះធំណាស់មួយទៀត ។ ក្រោយមក សុន សេន ធ្វើការអះអាងថាៈ យើងចាប់ពួកអាក្បត់ ឈូក យ៉ា និង ចក្រី... ជាពិសោធន៍សំខាន់នាំឲ្យយើងមើលឃើញទំនាស់បដិបក្ខរកឃើញខ្មាំងឆ្នាំ៧៧កាន់តែច្បាស់ ។ កន្លងមកយើងមើលឃើញទំនាស់បដិបក្ខនិងទំនាស់ផ្ទៃក្នុងនៅពុំទាន់ជ្រាលជ្រៅ យើងច្រើនកំណត់ជាទំនាស់ផ្ទៃក្នុង ។ ឧទាហរណ៍ៈ ខ្សែក្បត់របស់អា ឈូក យ៉ា និង ចក្រី ជាខ្សែសេរីរី យើងពុំកំណត់ធន់ជាសេ.អ៊ី.អាទេ ។ តាមពិតអាទាំងនេះជាខ្សែសេ.អ៊ី.អាដែលបង្កប់ខ្លួននៅក្នុងបក្សយើងយូរមកហើយ ។ អាខាងកើតនិងអាខាងលិចបានប្រមូលគ្នាវាយបដិវត្តន៍យើង ។ វាម្នាក់ៗជាសេ.អ៊ី.អាដែលផ្អែកលើពួកសេរីរីនៅក្រៅប្រទេសនិងពួកក្បត់ក្នុងប្រទេសយើងវាយបដិវត្តន៍យើង ។ វាចាត់តាំងអ្នកបដិត្តឬក៏សាច់ញាតិបដិវត្តន៍ដែលពុករលួយនិងលោភលន់ ឬខ្មាំងក្នុងគុកដែលជាពួកសេ.អ៊ី.អាឲ្យចូលស៊ីរូងបដិវត្តន៍ស៊ីរូងបក្សនិងកងទ័ពដោយប្រើពាក្យស្លោកបដិវត្តន៍ ហើយកសាងកម្លាំងបង្កប់បំភ្លៃមាគ៌ាបដិវត្តន៍យើងបណ្តើរៗដោយប្រើពាក្យស្លោក "ដុតឲ្យខ្លោច រោចឲ្យឆៅ" ។ សរុបមក សេ.អ៊ី.អានិងសេរីរីគឺតែមួយ ប្រឆាំងបដិវត្តន៍ត្រឹមត្រូវដូចគ្នា ។ បញ្ហាដែលត្រូវយកចិត្តទុកដាក់គឺទំនាស់បដិបក្ខមកពីខាងក្រៅឲ្យដល់កម្រិតបានន័យថាខ្មាំងពីខាងក្រៅមកបង្កប់វាយបដិវត្តន៍យើង ។ បដិវត្តន៍យើងត្រូវបន្តប្រឆាំងខ្មាំងរបស់បដិវត្តន៍នៅលើសកលលោកតទៅទៀត ព្រោះកម្លាំងក្បត់ក្នុងប្រទេសយើងសុទ្ធតែជាប់នឹងខ្មាំងខាងក្រៅទាំងអស់ ។ ប្រុងប្រយ័ត្នមានន័យថាវាយសម្រុកខ្មាំងស៊ីរូងផ្ទៃក្នុងឲ្យជាប់ ឲ្យដាច់ខាត បើមិនវាយសម្រុកខ្មាំងជាប់ទេ កុំនិយាយពីការកសាងប្រទេសព្រោះបើមានខ្មាំងស៊ីរូងវារារាំងយើងជាប់ ។ ន័យបដិវត្តន៍សង្គមនិយមមិនមែនមានន័យតែត្រឹមកម្ចាត់កម្មសិទ្ធឯកជនប៉ុណ្ណោះទេ តែត្រូវវាយខ្មាំងប្រឆាំងបដិវត្តន៍លើសកលលោកថែមទៀត ។ ទំនាស់បដិបក្ខក្នុងប្រទេសនិងក្រៅប្រទេសនៅជាទំនាស់ស្រួចស្រាល់ ។

នេះមានន័យថាត្រូវបន្តអប់រំនយោបាយសតិអារម្មណ៍តទៅទៀត តែត្រឹមអប់រំមិនគ្រប់គ្រាន់ទេ ត្រូវបន្តសម្រិតសម្រាំងដាច់ខាតតទៅទៀត ។ ដូច្នេះត្រូវតែសម្រិតសម្រាំងសមាសភាពមិនល្អ ។ កន្លងមកយើងកម្ចាត់បានខ្សែក្បត់សំខាន់ៗច្រើន តែត្រូវប្រុងប្រយ័ត្នបដិវត្តតទៅទៀត ព្រោះពួកសេសសល់នៅមាន ហើយពួកក្បត់ថ្មីនឹងកើតមានបន្តទៀត ។ សុន សេន បានសង្កត់ធ្ងន់ទៀតថា ខ្មាំងកំពុងតែបំផ្លាញយើងជាបាតុភាពច្រើនគ្រប់យ៉ាង ។ ទំនាស់ផ្ទៃក្នុងត្រូវអប់រំ ឯទំនាស់បដិបក្ខត្រូវមានវិធានការចាត់តាំងដាច់ខាត ។ សុន សេន ហាក់ដូចជាបែងចែកក្រុមមនុស្សដែលត្រូវបោសសម្អាតជា៣ប្រភេទៈ ទី១ សមាសភាពខ្មាំងដែលត្រូវតែដកដាច់ខាត ។ ទី២ ពួកសេរីដែលត្រូវតែប្រមូលផ្តុំឲ្យបង្កបង្កើនផលមួយអង្គភាព ។ ទី៣ ពួកដែលជិពាក់ជិពិនដែលត្រូវតែអប់រំហើយប្រមូលផ្តុំ ។

បន្តិចក្រោយមក ម៉ែត ក៏សហការតាមការណែនាំរបស់ សុន សេន ដោយចាប់និងបញ្ជូនខ្លួនកម្មាភិបាលយុទ្ធជនមួយចំនួនមកមន្ទីរសន្តិសុខ ស-២១ ។ បណ្តាកម្មាភិបាលយុទ្ធជនទាំងនេះជាអ្នករត់ចោលជួរនិងពាក់ព័ន្ធសកម្មភាពសេរី ឬមិនគោរពអន្តការវិន័យ និងដែលត្រូវបានអ្នកចាប់មុនៗឆ្លើយដាក់ ។ ចំណាររបស់ ម៉ែត ផ្ញើជូនចំពោះ ឌុច នៅថ្ងៃទី១ និង ទី២ ខែមិថុនា ឆ្នាំ១៩៧៧ បានឲ្យហេតុផលក្នុងការពន្យល់អំពីមូលហេតុដែលមនុស្សនៅក្នុងកងពលធំលេខ៥០២ ត្រូវបានចាប់បញ្ជូនឲ្យប្រធានមន្ទីរសន្តិសុខ ស-២១ ។ ចំណារប្រហាក់ប្រហែលគ្នានេះដែរជូនចំពោះ ឌុច ដែលចុះថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៧ មានរាយឈ្មោះអ្នកទោសពីរនាក់ផ្សេងទៀត ។ **(នៅមានត)**

**ស្ទីវ ហេដ័រ**

## សេចក្តីកែតម្រូវ

ទស្សនាវដ្តីស្វែងរកការពិតលេខ១២ ទំព័រទី១ ផ្នែកសំបុត្រដែលមានចំណងជើងថា "គ្មានយុត្តិធម៌ គ្មានសន្តិភាព គ្មានតុលាការ គ្មានយុត្តិធម៌" ត្រង់កូឡោនទី១ បន្ទាត់ទី២៥ ដែលសរសេរថា "...និងបញ្ហាប្រទេសជឿនលឿន..." សូមកែមកជា "...និងបណ្តាប្រទេសជឿនលឿន..." វិញ ។

សូមអរគុណ ។

# ការសងសឹកមកពីជំនាន់ប៉ុលពត

**(តពីលេខមុន)** “ឈាមក្រហមប្រាល ស្រោចស្រពក្រុងកម្ពុជា មាតុភូមិ ឈាមកម្មករកសិករដ៏ឧត្តម ឈាមយុទ្ធជនយុវនារី បដិវត្តន៍ ។ ឈាមប្រែក្លាយជាកំហឹងខ្លាំងក្លា តស៊ូមោះមុត ១៧ មេសា ក្រោមទង់បដិវត្តន៍ ឈាមរំដោះផុតពីខ្ញុំគេ ។ ជយោ ជយោ ១៧ មេសា ជោគជ័យមហាអស្ចារ្យ មានន័យធំធេង លើសសម័យអង្គរ ។ យើងរួបរួមគ្នា កសាងកម្ពុជានិងសង្គមថ្មី បវរ ប្រជាធិបតេយ្យ សមភាពនិងយុត្តិធម៌ តាមមាគ៌ាម្ចាស់ការ ឯករាជ្យរឹងមាំ ប្ដេជ្ញាដាច់ខាត ការពារមាតុភូមិទឹកដីបដិវត្តន៍ដ៏រុងរឿង ។ ជយោ ជយោ ជយោ កម្ពុជាថ្មី ប្រជាធិបតេយ្យ សម្បូររុងរឿងថ្កុំថ្កើង ប្ដេជ្ញាលើកទង់បដិវត្តន៍ក្រហមខ្ពស់ឡើង សាងមាតុភូមិយើងឲ្យចម្រើនលោតផ្លោះ មហារុងរឿង មហាអស្ចារ្យ” ។

មិនខុសពីចម្រៀងជាតិទេ “ទង់ជាតិក្រហម” ដែលការបូជាឈាម ពណ៌ឈាម និងការជំរុញទឹកចិត្ត “វាយកម្ទេចខ្មាំង” បានក្លាយជាសារមួយច្បាប់ដែលផ្ដាំទៅកម្មាភិបាលទាំងអស់ឲ្យខិតខំបន្តកំហឹងវណ្ណៈរបស់ខ្លួនរហូតទាល់តែគ្មាន “ពួកចក្រពត្តិប្រតិកិរិយា” មួយក្បាលសល់នៅកម្ពុជា ។

ដោយដឹងច្បាស់ថាមនុស្សប្រភេទណាដែលត្រូវនឹងមនោគមវិជ្ជារបស់ខ្លួន ខ្មែរក្រហមបានយកប្រជាជនទីទ័លក្រ និងក្មេងៗឲ្យធ្វើការនៅតាមមូលដ្ឋានស្ថិតក្រោមការគ្រប់គ្រងប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ ។ អ្នកទាំងនេះមានហេតុផលគ្រប់គ្រាន់ក្នុងការស្អប់ “ខ្មាំងវណ្ណៈ” និងមានភក្ដីភាពចំពោះអ្នកគាំទ្ររបស់ខ្លួនគឺអង្គការ ។ ការឃោសនារបស់ខ្មែរក្រហមព្យាយាមចង់ឲ្យការចងចាំរបស់ខ្លួននៅរស់រវើកជានិច្ចចំពោះអ្វីដែលប្រជាជនទីក្រុងធ្វើឲ្យខ្លួនឈឺចាប់និងអាម៉ាស់មុខ ។ ដូចដែលវិទ្យុផ្សាយសំឡេងបានផ្សាយរំឭកដល់ប្រជាជនក្រខ្សត់ថា “បងប្អូនរស់នៅដោយវេទនាទទួលការលំបាកគ្រប់បែបយ៉ាង... ។ បងប្អូនមិនដែលមានបាយហូបគ្រាប់គ្រាន់ មិនដែលបានសប្បាយនិងមានឱកាសបានរៀនសូត្រឡើយ ។ បងប្អូនយើងត្រូវបានជិះជាន់មើលងាយមើលថោកដូចសត្វធាតុ” ។ ការឃោសនាដែលបង្កប់ទៅដោយការអប់រំនយោបាយ នោះមានប្រសិទ្ធភាពណាស់ក្នុងការជំរុញឲ្យកម្មាភិបាលតូចតាចតាមមូលដ្ឋានធ្វើការសងសឹកចំពោះខ្មាំងវណ្ណៈរបស់ខ្លួន ។ មានប្រជាជន “មូលដ្ឋាន” ម្នាក់បាននិយាយដល់ការផ្លាស់ប្ដូរចិត្តគំនិតរបស់ប្រធានភូមិរបស់គាត់ឈ្មោះ បឿន ដោយសារមនោគមវិជ្ជារបស់ខ្មែរក្រហម “មុនដំបូងបឿនហ្នឹងដូចតែគេដូចតែឯងអីចឹង ។ តែក្រោយពេលដែលដុះខាត់សតិអារម្មណ៍ហើយចិត្តគំនិតគាត់ផ្លាស់ប្ដូរអស់រលីង ។ គាត់បែរជាខឹងប្រជាជនជាពិសេសអ្នកមាននិងទាហាន ។ បឿន ជាមនុស្សមិនចេះអក្សរ ហើយចេះតែសរសេរបន្តិចបន្តួចប៉ុណ្ណោះ... ។ ប៉ុន្តែគាត់ស្រលាញ់អង្គការហើយរាយការណ៍ពីមនុស្សដែលស្លាប់” ។ ហាំង ង៉ៅ បាននិយាយលេងសើចជាមួយប្រជាជនថ្មីនៅក្នុងក្រុមគាត់ថា កម្មាភិបាលខ្មែរក្រហមរបៀបនេះមិនមែនជាជន “កុម្មុយនិស្ត” ទេ តែជាជន “គុំមនុស្ស” ។ “នេះហើយជាកម្មាភិបាលថ្នាក់ក្រោម ។ អ្វីដែលកម្មាភិបាលទាំងនោះដឹងគឺថាប្រជាជនដូចជាយើងធ្លាប់បានជិះជាន់សង្កត់សង្កិនពួកខ្លួន ហើយពេលនេះជាឱកាសដែលពួកខ្លួនត្រូវសងសឹកហើយ ។ កម្មាភិបាលខ្មែរក្រហមវាអីចឹងឯង ពោលគឺកុម្មុយនិស្តនៅលើ គុំមនុស្សនៅក្រោម” ។

តាមរយៈការរធ្វើទុកបុកម្នេញអមនុស្សធម៌ចំពោះ “ប្រជាជនថ្មី” ព្រមទាំងមនោគមវិជ្ជាដែលបង្កឲ្យមានកំហឹងវណ្ណៈនិងអំពើឃោរឃៅប្រឆាំងនឹងខ្មាំងរបស់ខ្មែរក្រហម វាគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយដែលថា ការសម្លាប់សងសឹកគ្នាចេះតែបន្តរហូតដល់ក្រោយពេលនៃវិសុទ្ធកម្មរបស់កម្ពុជាប្រជាធិបតេយ្យ ។ ក្រោយពីការកម្ទេចខ្មែរដឹកនាំមួយចំនួនធំរបស់ លន់ ណុល រួចហើយខ្មែរក្រហមបានបន្តកម្ចាត់ “ខ្មាំងវណ្ណៈ” ជាបណ្ដើរៗ ដូចជា អ្នកមាន “មូលធន” បញ្ញវ័ន អ្នកជំនាញការនិងទាហានតូចតាច ប៉ូលិសនិងបុគ្គលិករដ្ឋការ ។ កម្មាភិបាលមូលដ្ឋានបានបន្តតាមដានស្រាវជ្រាវតាមដានប្រវត្តិរូបប្រជាជនឥតឈប់ឈរ ។



នៅពេលមកដល់ភូមិថ្មី ស្ត្រីម្នាក់ឈ្មោះ យ៉ុម បាននិយាយថា កម្មាភិបាលម្នាក់បានមក «សួរប្តីខ្ញុំថាធ្វើអី ។ ប្តីខ្ញុំបាននិយាយករកម្មាភិបាលថាគាត់ជាអ្នកធាក់ស៊ីក្លូ និងយាមផ្ទះឲ្យគេ ។ កម្មាភិបាលសួរទៀតថា បើសិនជាធាក់ស៊ីក្លូមែនហេតុអ្វីបានជាដៃជើងមុខមាត់ស្អាតបាតម្ល៉េះ? ។ ពួកវាបានឲ្យប្តីខ្ញុំចុះភ្ជួរស្រែធ្វើចម្ការដើម្បីបង្ហាញថាគាត់ជាអ្នកមកពីជនបទពិតមែន» ។ ដោយសារតែគាត់មានដើមកំណើតជាអ្នកស្រែចម្ការ ប្តីរបស់ យ៉ុម អាចធ្វើអ្វីដែលកម្មាភិបាលខ្មែរក្រហមបានបញ្ជាឲ្យធ្វើ ។ ប៉ុន្តែនៅទីបញ្ចប់ខ្មែរក្រហមនៅតែរកឃើញថាប្តីរបស់ យ៉ុម ធ្លាប់ធ្វើជាទាហាន។ យ៉ុម បានបន្ថែមថា «មានប្រជាជនមួយចំនួននៅក្នុងភូមិដឹងថាប្តីខ្ញុំធ្វើអ្វីពីមុន ។ ដូច្នេះអ្នកដែលស្អប់យើងក៏បានប្រាប់ខ្មែរក្រហមថាប្តីខ្ញុំជាទាហាន» ។ ក្រោយពីដឹងថាគ្រួសាររបស់បងស្រី យ៉ុម ជាទាហាន លន់ ណុល មន្ទីរសន្តិសុខស្រុកក៏ចេញបញ្ជាឲ្យឈ្លបមកយកគាត់ទៅសម្លាប់ក្លាម ។ បងស្រី យ៉ុម យំខ្សឹកខ្សួលនៅពេលដែលរៀបរាប់អំពីបងប្រុសរបស់ប្តីគាត់ដែលបាត់ខ្លួនរហូតចាប់ពីពេលដែលគាត់មកដល់ផ្ទះនាពេលយប់មួយដែលមានភ្លៀងធ្លាក់ផង ។ «ថ្ងៃនោះមេឃងងឹតឈឹងហើយមានភ្លៀងធំទៀតផង ។ បងប្រុសប្តីខ្ញុំក៏មកដល់ផ្ទះជាមួយនឹងកាំភ្លើងពីរ-បីដើមនិងលក្ខខណ្ឌមួយចំនួន ហើយក៏ចេញទៅជាមួយបងប្អូនប្រុសពីរ-បីនាក់ទៀតបាត់ឈឹងលុះដល់ឥឡូវ» ។



គ្រួសាររបស់ស្ត្រីវ័យជំទង់ម្នាក់ឈ្មោះ ជិន ក៏ទទួលនូវវិវាសនាប្រហាក់ប្រហែលគ្រួសារបង យ៉ុម ដែរ ។ ពេលនេះខ្ញុំនឹងលើកយកមកបង្ហាញជូនយ៉ាងពិស្តារ ។ ពេលដែលមន្ត្រីមូលដ្ឋានចាប់ផ្តើមស៊ើបស្រាវជ្រាវប្រវត្តិរូប តើអ្នកណាធ្វើអីៗ គ្រួសាររបស់ ជិន មិនអាចលាក់បាំងការពិតបានឡើយ ។ ឪពុករបស់ ជិន ឈ្មោះ តាក ធ្លាប់ធ្វើជាគ្រូបង្រៀនក្នុងជំនាន់ លន់ ណុល ។ ថ្ងៃមួយគាត់ទៅសម្រាកនៅមន្ទីរពេទ្យមូលដ្ឋាន ដោយគាត់មានជំងឺហើមក្រពះដោយសារកង្វះអាហារ ។

ពីរ-បីថ្ងៃក្រោយ អ៊ីតាក ត្រូវបានប្រាប់ឲ្យរៀបចំឥវ៉ាន់ដើម្បីបញ្ជូនទៅពេទ្យតំបន់ ។ អ៊ីតាក មិនបានទៅដល់ពេទ្យតំបន់ដូចដែលខ្មែរក្រហមប្រាប់ឡើយ ប៉ុន្តែបែរជាត្រូវបញ្ជូនទៅខាងក្រោយពេទ្យ ហើយក៏សម្លាប់ចោលទៅ ។ មានសាក្សីឃើញផ្ទាល់ភ្នែកបានប្រាប់ ជិន ថា ពេលដែលពួកពេជ្ឈឃាតត្រឡប់មកវិញ ខ្លួនប្រាណអ្នកទាំងនោះប្រឡាក់ប្រឡូសទៅដោយឈាម ។

ក្នុងចំណោមពេជ្ឈឃាតទាំងអស់មានម្នាក់ឈ្មោះ ហ៊ាន ដែលធ្លាប់ជាកូនសិស្សរបស់ អ៊ីតាក ដែរ ។ ជិន ពន្យល់ថា “ឪពុករបស់ខ្ញុំតឹងរ៉ឹងណាស់ពេលបង្រៀន ហើយគាត់តែងតែវាយសិស្សដើម្បីឲ្យសិស្សខំរៀន ។ ហ៊ាន ជាសិស្សខ្ជិលនៅក្នុងថ្នាក់ មិនគោរពវិន័យឡើយ ហើយតែងតែត្រូវរំពាត់ជាញឹកញយ ។ ហ៊ាន មានការឈឺចាប់ណាស់ពេលដែលត្រូវរំពាត់ច្រើនបែបនេះ ដូច្នេះហើយបានជា ហ៊ាន ចងគំនុំនឹងឪពុកខ្ញុំ” ។ ក្រោយមកទៀត មានអ្នកខ្លះនិយាយថាបានឮ ហ៊ាន សម្តុត អ៊ីតាក មុនពេលសម្លាប់ថា “ពេលអ្ហែងធ្វើគ្រូអញអ្ហែងវ៉ៃអញឈឺណាស់ ។ ឥឡូវដល់ពេលដែលអញត្រូវសងសឹកគុណវិញហើយ ។ អញនឹងសម្លាប់អ្ហែងកុំឲ្យធ្វើជាគ្រូកាចទៀត” ។

ប្រហែលពីរ-បីខែក្រោយមក ម្តាយរបស់ ជិន ក៏ទៅពេទ្យចាក់ថ្នាំ ។ មុនពេលចាក់ថ្នាំ គ្រូពេទ្យឈ្មោះ លុន បានសួរថា “តើអ៊ឹងជាប្រពន្ធអ៊ីតាកមែនទេ?” ពេលដែលគាត់ប្រាប់តាមត្រង់ លន់ ក៏បូមទឹកសដាក់ក្នុងសឺរ៉ាំងចាក់ថ្នាំ ។ ក្រោយពីចាក់ទឹកចូល ហើយម្តាយរបស់ ជិន ក៏ត្រូវស្លាប់មួយរំពេច ។ នៅព្រឹកមុនពេលទៅពេទ្យ មានកម្មាភិបាលមកសួរថា តើម៉ែរបស់ឯងទៅណាហើយ? ហើយនៅពេលដែលដឹងថាម្តាយរបស់ ជិន ទៅពេទ្យហើយក៏ប្រញាប់ប្រញាល់មកប្រាប់ពេទ្យ លន់ ។ ជិន មិនមានការសង្ស័យបន្តិចឡើយថាម្តាយរបស់ខ្លួនពិតជាត្រូវឈ្មោះ លន់ ចាក់ថ្នាំសម្លាប់ ។

បងប្អូនស្រី៣នាក់របស់ ជិន គឺជាអ្នកបន្ទាប់ដែលត្រូវសម្លាប់ ។ បងស្រីបង្អស់របស់ ជិន ឈ្មោះ កូលាប មានក្រមាសូត្រមួយដែលប្រើប្រាស់កាលពិធីរៀបអាពាហ៍ពិពាហ៍របស់ឪពុកម្តាយខ្លួន ។ ប្រធានឃុំឈ្មោះ រ៉ុំ ឃើញក្រមានោះក៏សុំពី កូលាប ប៉ុន្តែ កូលាប មិនឲ្យពីព្រោះជាក្រមាដែលបង្កប់ដោយមនោសញ្ចេតនារបស់ឪពុកម្តាយដែលខ្មែរក្រហមសម្លាប់ចោលអស់ហើយ ។ ជិន ពន្យល់ថា “ពេលដែលបងស្រីខ្ញុំមិនព្រមឲ្យក្រមា រ៉ុំ ក៏ខឹងចំពោះប្រជាជនថ្មីម្នាក់នេះដែលធ្វើឫកគ្រាន់បើជាងប្រជាជនចាស់ដូចជារូបខ្លួន ។ រ៉ុំ បានគុំបងស្រីខ្ញុំហើយរង់ចាំឱកាសមកដល់នឹងធ្វើការសងសឹក” ។ ពីរ-បីថ្ងៃក្រោយមក ពេលកំពុងស្ទូងស្រែ កូលាប ក៏ជេរគោខ្លួនឯង ។ រ៉ុំ ធ្វើការនៅជិតនោះក៏ឮដែរហើយស្មានថា កូលាប ជេរខ្លួន ។ លុះដល់ល្ងាចឡើងកូនចៅរបស់ រ៉ុំ បានប្រាប់ទៅ កូលាប ថា រ៉ុំ ចង់ជួប ។ បងស្រីរបស់ ជិន ម្នាក់ទៀតសុំទៅជាមួយដែរ ពីព្រោះគាត់ខ្លាចមានរឿងរ៉ាវមិនល្អកើតឡើងចំពោះ កូលាប ។ កូលាប និងបងស្រីក៏ទៅជាមួយគ្នាថែមទាំងនាំយកប្អូនតូចដែលនៅបៅដោះនៅឡើយទៅជាមួយផង ។

ក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ឈ្មោះ បេង ដែលធ្លាប់ធ្វើការនៅឃុំជាមួយ រ៉ុំ បានប្រាប់ ជិន ថា កូលាប និងបងស្រីត្រូវបាន រ៉ុំ និងមនុស្សមួយក្រុមមានគ្នាបួន-ប្រាំនាក់ ចាប់ចងហើយបណ្តើរទៅសម្លាប់នៅវាលពិឃាតឯមូលដ្ឋាន ។ រ៉ុំ និយាយទៅ កូលាប ថា “ឯងតឹងរ៉ឹងចំពោះអញណាស់មិនឲ្យក្រមាមកអញទេ ។ នេះហើយជាអំពើដែលឯងត្រូវទទួល” ។ ក្រោយពីឮដូច្នេះ កូលាប ទោះបីជាមានចំណងជាប់នឹងដៃក៏ទាត់អ្នកចាប់គាត់ធ្វើឲ្យដាច់ចំណងខ្លះ ។ ឃើញដូច្នេះ រ៉ុំ ខឹងមែនទែន ។ ជិន បន្តថា “ពួកវាបានហែកខោអាវគាត់ចេញអស់ទុកឲ្យនៅស្រាតនលកណ្តាលចំណោមក្រុមរបស់វាដែលមានស្រីខ្លះប្រុសខ្លះ ។ មានអាម្នាក់ចាប់យកប្អូនស្រីតូចបោកនឹងគល់ឈើឮសូរតែ ផស់! ក្បាលប្អូនស្រីខ្ញុំក៏បែកឈាមហូរហោម” ។ ក្រោយមក ក្រុមរបស់ រ៉ុំ ក៏ឲ្យ កូលាប សម្លឹងមើលការកាប់សម្លាប់បងស្រីរបស់ខ្លួន ។ រ៉ុំ និងពេជ្ឈឃាតដទៃទៀតចាប់ផ្តើមវាយ កូលាប សព្វប្រាណ ។ “ទម្រាំតែស្លាប់អញធ្វើឲ្យឯងវេទនាយូរបន្តិច” ។ ក្រុមពេជ្ឈឃាតបានទាត់ធាក់ កូលាប ទាល់តែស្លាប់ ។ “កូលាប ពិតជាទទួលការឈឺចាប់ណាស់ ។ ពួកវាសាហាវណាស់” ។ ពីរ-បីថ្ងៃក្រោយមក ជិន និងប្អូនស្រីម្នាក់ទៀតក៏ព្យាយាមរត់ចេញពីភូមិ ។ ប៉ុន្តែប្អូនប្រុសរបស់ ជិន ៤នាក់ទៀតកំពុងតែរស់នៅជាមួយឪពុកមានៅក្នុងតំបន់នោះនៅឡើយទេ ។ រ៉ុំ បានបញ្ជូននិងបង្ខំឲ្យប្អូនប្រុសទាំង៤នាក់របស់ ជិន

ធ្វើការនៅក្នុងបរិវេណវត្តនៅក្នុងភូមិដែលត្រូវបានពួកខ្មែរក្រហមបំប្លែងធ្វើជាគុករួចទៅហើយ ។ ការងាររបស់កុមារទាំង៤គឺកើបលាមករបស់អ្នកទោស ។ ជិតដល់ទីចុងបំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្មេងៗទាំង៤នាក់ត្រូវបានសម្លាប់ទាំងអស់បន្ទាប់ពីជីករណ្តៅសម្រាប់កប់ខ្លួនឯងរួចមក ។

ការបំផ្លាញគ្រួសាររបស់ ជិន គឺបង្ហាញពីការប៉ុនប៉ងរបស់ខ្មែរក្រហមក្នុងការសងសឹកដោយមិនសមរម្យនៅក្នុងរបៀបផ្តាញ់ផ្តាល ។ ដោយសារតែមានអំណាចខ្លាំង ខ្មែរក្រហមបានធ្វើការផ្តាញ់ផ្តាលយ៉ាងឃោរឃៅចំពោះខ្សែខ្មាំងរបស់ខ្លួន ។ ជិន បាននិយាយទាំងក្រៀមក្រំថា "ពួកខ្មែរក្រហមចងគំនុំនឹងគ្រួសារខ្ញុំពីព្រោះឪពុករបស់ខ្ញុំជាអ្នករដ្ឋការនៅក្នុងរបបចាស់ ។ ពួកវាមានកំហឹងឈឺចាប់ហើយចង់សងសឹកប្រជាជនថ្មីដូចជាយើងអ៊ីចឹង ។ ខ្មែរក្រហមចង់សម្លាប់បំផុតពូជដើម្បីកុំឲ្យយើងសងសឹកនឹងវាវិញនៅពេលក្រោយទៀត" ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានគ្រួសារខ្មែរជាច្រើនណាស់ដែលត្រូវបានខ្មែរក្រហមសម្លាប់ចោលតាមរបៀបប្រហាក់ប្រហែលគ្នានេះ ។ ឧទាហរណ៍ជាក់ស្តែងបងប្អូនបង្កើតរបស់ប្តីបងស្រី យ៉ុម ចំនួន៨នាក់ក្នុងចំណោម៩នាក់ ត្រូវបានសម្លាប់ចោលគ្មានសល់ (៧នាក់ជាទាហាន) ។ ជួនកាលខ្មែរក្រហមយករថយន្តមកដឹក"ប្រជាជនថ្មី"យកទៅសម្លាប់ចោលទាំងគ្រួសារៗ ។ ពាក្យស្លោករបស់ខ្មែរក្រហមគឺ "ជីកស្មៅត្រូវជីកទាំងឫស" ពិតជាបានជំរុញឲ្យមានអំពើសម្លាប់បំផុតពូជបែបនេះ ។ មិនខុសពីមនុស្សជាច្រើនទៀតទេ អតីតគណៈភូមិរបស់ ជិន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានប្រាប់ខ្ញុំថាឃ្លានេះមានន័យថា "ត្រូវតែសម្លាប់ឲ្យអស់នូវគ្រួសារខ្មាំងដែលរួមមានប្តី ប្រពន្ធ កូន ហើយជួនកាលជីដូនជីតាទៀតផងមិនឲ្យសល់ម្នាក់ឡើយ... សម្លាប់បែបនេះគឺដើម្បីកុំឲ្យសមាជិកនៃគ្រួសារដែលត្រូវបានសម្លាប់មានឱកាសសងសឹកចំពោះខ្លួនវិញ" ។

ដូច្នេះអំពើឃោរឃៅដែលយ៉ាងហោចណាស់ជាផ្នែកមួយនៃការសម្លាប់របស់របបកម្ពុជាប្រជាធិបតេយ្យ គឺកើតឡើងដោយសារកុម្មុយនិស្តនិងគំនិតចង់សងសឹក ។ ប្រជាជនក្រខ្សត់ជាច្រើននាក់មានការខឹងសម្បារនឹងអ្នកមានទ្រព្យសម្បត្តិនិងមានអំណាចដែលមើលងាយមើលថោកនិងធ្វើបាបខ្លួន ។ មនោគមវិជ្ជារបស់ខ្មែរក្រហមបានបញ្ឆេះកំហឹងនេះឲ្យកាន់តែឆេះសន្ធោសន្ធៅ ដោយព្យាយាមបំពាក់បំប៉នឲ្យអ្នកដែលដើរតាមខ្លួនឲ្យមានកំហឹងឈឺចាប់ចង់មានការសងសឹកវណ្ណៈ ។ បងរបស់អតីតកម្មាភិបាលជាន់ខ្ពស់របស់ខ្មែរក្រហមម្នាក់បានពន្យល់ហេតុផលថា "ការសម្លាប់ប្រជាជនខ្មែរអាចនិយាយបានថាកើតឡើងដោយសារការឈឺចាប់និងដោយសារអ្នកទីទ័លក្រដែលទទួលនូវការមើលងាយមើលថោក...ការឈឺចាប់របស់ប្រជាជនប្រភេទនេះ បានកជាខ្ទុះឈាម ក្លាយទៅជាកំហឹងសងសឹកនៅពេលដែលខ្លួនបានឡើងកាន់អំណាច...កំហឹងនេះត្រូវបានសងវិញដោយការសម្លាប់ ។ មុនដំបូងសម្លាប់ទាហាននិងថ្នាក់ដឹកនាំរបស់របប លន់ ណុល ហើយបន្ទាប់មកក៏ចាប់ផ្តើមកម្ចាត់ជនដែលខ្លួនសង្ស័យថាជាខ្មាំងដែលភាគច្រើនគឺសម្លាប់អស់ទាំងពូជតែម្តង" ។ ខ្មែរក្រហមបានព្យាយាមទាំងក្នុងការផ្តាញ់ផ្តាលនិងការទប់ស្កាត់មិនឲ្យមានអំពើសងសឹកចំពោះខ្លួនបាននៅថ្ងៃក្រោយ ។

ដូចដែលបានបង្ហាញនូវការសម្លាប់សងសឹកនៅចុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងអ៊ីចឹង ខ្មែរក្រហមមិនបានទទួលជោគជ័យឡើយក្នុងការទប់មិនឲ្យមានការសងសឹកវិញ ។ មានស្ត្រីម្នាក់បានរៀបរាប់អំពីករណីមួយរបស់ សុន ជាប្រធានភូមិដ៏កាចសាហាវម្នាក់ ។ គាត់បានមើលឃើញ សុន សម្លាប់វៀតណាមពីរនាក់ផ្ទាល់នឹងភ្នែក ហើយក្រោយមក សុន ក៏ត្រូវបានសម្លាប់វិញដោយមនុស្សមួយក្រុម ។ "ប្រជាជនខឹងសម្បារចំពោះអ្វីដែល សុន បានប្រព្រឹត្ត ។ ខ្ញុំទៅមើលឃើញប្រជាជនយ៉ាងច្រើនចោមរោមវ៉ៃ ព្រមទាំងកាត់ក្បាល សុន ទៀតផង" ។ ដូចគ្នានេះដែរ អ្នកធ្វើការជាមួយ រុំ ម្នាក់ឈ្មោះ ផាត បានរត់ចូលព្រៃពេលដែលវៀតណាមចូលមកក្នុងប្រទេសកម្ពុជា ។ បន្ទាប់ពីលាក់ខ្លួនក្នុងព្រៃអស់២-៣ថ្ងៃរួចមក យប់មួយ ផាត ក៏ព្យាយាមលបជ្រៀតចូលក្នុងភូមិរកលួចម្ហូបអាហារ ហើយត្រូវបានបាញ់ឲ្យរបួស ។ មិនយូរប៉ុន្មានមានមនុស្សកកកុញនាំគ្នាមកចោមរោមវាយ ផាត ។ ស្ត្រីម្នាក់ដែលប្តីរបស់គាត់ត្រូវ ផាត សម្លាប់ចោល និយាយថា "មនុស្សមិនដឹងជាមកពីណាពីណីទេ មកកាន់តែច្រើនឡើងៗទាំងក្មេងទាំងចាស់ ។ ប្រជាជនទាំងអស់ស្អប់ ផាត យ៉ាងខ្លាំងពីព្រោះ ផាត បានសម្លាប់មនុស្សអស់

ជាច្រើននាក់ណាស់ ។ ពេលនោះខ្ញុំក៏បានវ៉ៃវា២ដៃ ។ ស្អប់ព្រោះវាបានសម្លាប់ប្តីខ្ញុំ ។ ខ្ញុំចង់សងសឹកវិញ» ។ ប្រជាជនខ្មែរជាច្រើនអាចនិយាយរឿងទាក់ទងនឹងអំពើឃោរឃៅសងសឹកចំពោះអតីតកាលកម្មាភិបាលខ្មែរក្រហមប្រហាក់ប្រហែលគ្នានេះនៅក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ ។

ប្រជាជនខ្មែរភាគច្រើនដែលរងនូវការឈឺចាប់ខ្លោចផ្សានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ចេះតែបន្តចងកំហឹងនឹងខ្មែរក្រហម ។ ពេលដែលខ្ញុំសួរថាតើបងមានអារម្មណ៍បែបណានៅពេលឃើញឈ្មោះ ហៀន ម្តងម្កាល ជិន ឆ្លើយថា «ខ្ញុំក្តៅនឹងក្នុងចិត្តហើយមានកំហឹងយ៉ាងខ្លាំង ។ ចិត្តខ្ញុំនៅតែចង់សងសឹក ។ ខ្ញុំចង់សួរវាថាតើឪពុកខ្ញុំបានធ្វើអ្វីខុះបានជាអ្នកឯងមកសម្លាប់គាត់? អ្នកឯងខ្ជិលរៀនបានជាគាត់វ៉ៃ ។ ពេលដែលខ្ញុំនឹកដល់គាត់ ខ្ញុំខឹងខ្លាំងណាស់» ។

តើធ្វើយ៉ាងដូចម្តេចទៅទើបអាចរកយុត្តិធម៌ឲ្យជនរងគ្រោះដូចជា ជិន និងសមាជិកគ្រួសាររបស់គាត់? តើធ្វើយ៉ាងដូចម្តេចទើបអាចចៀសវាងបាននូវការសងសឹកមិនចេះចប់មិនចេះហើយនៅពេលអនាគត? ទាំងនេះគ្រាន់តែជាបញ្ហាស្មុគស្មាញដែលប្រជាជនខ្មែរកំពុងតែប្រឈមមុខជាមួយនឹងការផុតរលត់របស់របបខ្មែរក្រហម ។ ទីមួយត្រូវប្រុងប្រយ័ត្នកុំយកតម្រាប់តាមគ្នា ។ ប្រជាជនក្រីក្រភាគច្រើនមិនចងកំហឹងវណ្ណៈទេ មាន«ប្រជាជនចាស់»មួយចំនួនជួយយកអាសារដល់«ប្រជាជនថ្មី»ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជួនកាល«ប្រជាជនចាស់»និងកម្មាភិបាលខ្មែរក្រហមក៏រស់នៅដោយការភ័យខ្លាចបាត់បង់ជីវិតដែរ ។ ទីពីរមានប្រជាជនទីក្រុងជាច្រើនមិនត្រឹមតែមិនបានមើលងាយមើលថោកចំពោះអ្នកក្រខ្សត់ទេ ប៉ុន្តែផ្ទុយមកវិញបានជួយយកអាសាគ្នាទៀតផង ។ ជួនពេលខ្លះសូម្បីតែកម្មាភិបាលខ្មែរក្រហមតាមមូលដ្ឋានក៏បានព្យាយាមរាំងស្កាត់ឬក៏កម្ចាត់មិនឲ្យមានការកាប់សម្លាប់នៅក្នុងតំបន់ដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់ខ្លួនដែរ ។ មិនដូចទៅនឹងពាក្យថា «ខ្លាំង» និង «សត្រូវ» ដែលដាក់ផ្លាកដោយខ្មែរក្រហមឡើយ តាមពិតមានប្រជាជនច្រើនបែបច្រើនសណ្ឋានណាស់ ដូច្នេះកើតជាមនុស្សត្រូវតែមានការយោគយល់និងអត់ឱនឲ្យគ្នាទៅវិញទៅមក ។

ទ្រឹស្តីព្រះពុទ្ធចែងអំពីវិធីសំខាន់មួយទៀតក្នុងការដោះស្រាយជាមួយនឹងកំហឹងឈឺចាប់ ។ ដើម្បីចៀសវាងនូវការសងសឹក ទ្រឹស្តីព្រះពុទ្ធទូន្មានថា ទោសៈ មោហៈ កើតឡើងដោយអវិជ្ជា ហើយថាមនុស្សគ្រប់រូបអាចទប់ចិត្តរំសាយកំហឹងបាន ។ ដូចសម្តេចព្រះមហាឃោសនន្ទាបានមានសង្ឃដីកាដូច្នេះដែរថា ផ្លូវទៅកាន់សុគតិភពគឺជាដំណើរមួយជំណាក់ម្តងៗនៃការសន្តោសប្រណី ។ ប្រជាជនខ្មែរភាគច្រើនបានដើរតាមពុទ្ធោវាទនេះក្នុងការដោះស្រាយទុក្ខសោករបស់ខ្លួនក្នុងជំនាន់ ប៉ុល ពត ។ នៅចុងបញ្ចប់ ធម៌កម្មបានចែងថា អ្នកធ្វើបាបនឹងទទួលបាបនៅជាតិក្រោយ ។ ដូច្នេះមានប្រជាជនខ្មែរមួយចំនួនដូចជា ជិន អ៊ីចឹងនិយាយថា ប៉ុល ពត ព្រមទាំងមេដឹកនាំខ្មែរក្រហមនឹងចុះនរកអវិចី ឬក៏ចាប់កំណើតទៅជាប្រេត ឬសត្វស្មោកគ្រោកផ្សេងៗទៀតដែលរស់នៅជាមួយនឹងភក់ជ្រាំ ។ ការអនុវត្តច្បាប់និងការអប់រំអាចត្រូវបានធ្វើការផ្លាស់ប្តូរតាមកម្រិតប្រហាក់ប្រហែលគ្នា ។ ឧទាហរណ៍ប្រសិនបើអំពើពុករលួយនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាត្រូវបានកាត់បន្ថយ ប្រជាជនខ្មែរអាចមានអារម្មណ៍ធូរស្រាលក្នុងការសងសឹកចំពោះអ្នកដែលធ្វើអំពើអាក្រក់មកលើខ្លួន ម្យ៉ាងវិញទៀត គ្រូបង្រៀនអាចធ្វើការវិភាគវែកញែកលទ្ធផលដែលនាំឲ្យមានគ្រោះថ្នាក់ និងពន្យល់ណែនាំនូវជម្រើសផ្សេងៗទៀតក្នុងការសងសឹក ។ ហើយចំណុចចុងក្រោយនេះគឺថា ការជំនុំជម្រះក្តីខ្មែរក្រហមមួយដែលមានលក្ខណៈដូចនៅនូរិមប៊ឺកដែលឥឡូវនេះកំពុងតែត្រូវបានជ្រោមជ្រែងឲ្យកើតមានឡើងដោយអ្នកច្បាប់ អ្នកនយោបាយ និងអ្នកសិក្សាជាន់ខ្ពស់ មើលទៅហាក់ដូចជាជួយឲ្យប្រជាជនខ្មែរដូចជា ជិន អាចរកយុត្តិធម៌ចំពោះការឈឺចាប់និងបាត់បង់អ្វីៗគ្រប់បែបយ៉ាងរបស់គាត់បាន ។ ការចងក្រងឯកសារប្រកបទៅដោយសុក្រឹតភាពនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជា អាចដើរតួយ៉ាងសំខាន់ចំពោះជោគជ័យនៃដំណើរការជំនុំជម្រះក្តីបាន ។ ទោះតាមមធ្យោបាយណាក៏ដោយ ប្រជាជនខ្មែរនឹងទទួលបានផលប្រយោជន៍យ៉ាងក្រាស់ក្រែលប្រសិនបើការបំផ្ទិចបំផ្លាញ ដែលបណ្តាលឲ្យមានការសងសឹកមិនចេះចប់មិនចេះហើយត្រូវបានបញ្ចប់នោះ ។

**អាឡិច ហ៊ិនតុន**

# ការលើកលែងទោស

**(តពីលេខមុន) អនុសញ្ញាផ្សេងៗ ទៀត**

ប្រទេសកម្ពុជាជាភាគីមួយនៃអនុសញ្ញាស្ដីពីអំពើទារុណកម្ម ដែលមានប្រការ១ ក្នុងមាត្រា៧ មានការទាក់ទងនឹងកាតព្វកិច្ច ក្នុងការជម្រះទោស ។ ទាក់ទងនឹងប្រការ១នេះ គណៈកម្មាធិការសិទ្ធិមនុស្សយល់ថាមាត្រានេះបង្កើតជាកាតព្វកិច្ចឲ្យមានការស៊ើបអង្កេតអំពើទារុណកម្មនិងជម្រះទោសជនណាដែលទទួលខុសត្រូវ និងធ្វើឲ្យជនរងគ្រោះមានភាពស្របច្បាប់ក្នុងការទទួលនូវដំណោះស្រាយដូចជាសំណងទៅលើការខូចខាតរបស់ខ្លួនជាដើម ។ ទាក់ទងនឹងការលើកលែងទោស ÷

"គណៈកម្មាធិការកត់សម្គាល់ឃើញថា ភាគីរដ្ឋខ្លះបានផ្ដល់ការលើកលែងទោសចំពោះអំពើទារុណកម្ម ។ ជាទូទៅ ការលើកលែងទោសមានលក្ខណៈផ្ទុយទៅនឹងកាតព្វកិច្ចរបស់រដ្ឋក្នុងការស៊ើបអង្កេតអំពីបទល្មើស ធានាកុំឲ្យអំពើនេះរួចផុតពីដែនសមត្ថកិច្ចរបស់ខ្លួន និងធានាឲ្យប្រាកដថាវានឹងមិនកើតមានឡើងម្ដងទៀតឡើយនៅថ្ងៃខាងមុខ" (ណាមមី ទំព័រ២៩) ។

លើសពីនេះទៀត ប្រទេសកម្ពុជាជាភាគីមួយនៅក្នុងសន្ធិសញ្ញាជាច្រើនទាក់ទងនឹងផ្នែកសិទ្ធិមនុស្ស ដូចជាអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយជាដើម ។ មិនខុសពីសន្ធិសញ្ញាសិទ្ធិមនុស្សដទៃទៀតទេ អនុសញ្ញានេះមានចែងពីកាតព្វកិច្ចច្បាស់លាស់ចំពោះភាគីចុះកិច្ចសន្យា "ក្នុងការធានាចំពោះបុគ្គលគ្រប់រូបរបស់នៅក្នុងទឹកដីនៃរដ្ឋខ្លួន និងមានសិទ្ធិទទួលនូវដែនសមត្ថកិច្ចដែលទទួលស្គាល់ដោយកិច្ចព្រមព្រៀងនេះ" ។ មិនទាន់មានកាតព្វកិច្ចច្បាស់លាស់ណាមួយក្នុងការជម្រះក្ដីអំពើរំលោភផ្នែកសិទ្ធិមនុស្សនៅឡើយទេ ។ ប៉ុន្ដែបើតាមសម្ដីរបស់ ណាមមី រ៉ែត អារីហ្សា មកដល់ឥឡូវនេះមានការទទួលស្គាល់ជាទូទៅហើយថាសេចក្ដីថ្លែងការណ៍មួយចំនួនដែលធានាឲ្យមានសិទ្ធិគ្រប់គ្រាន់នៅក្នុងសន្ធិសញ្ញាបានចែងច្បាស់អំពីកាតព្វកិច្ចរបស់រដ្ឋនីមួយៗ (ណាមមី ទំព័រ២៩) ។ កាតព្វកិច្ចរបស់ប្រទេសចុះកិច្ចសន្យាក្នុងការផ្ដល់"ដំណោះស្រាយមានប្រសិទ្ធភាព" ចំពោះជនរងគ្រោះនៃការរំលោភច្បាប់អាចចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (មើលសៀវភៅ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ទំព័រ២៣១ និពន្ធដោយ ជេហ្វ្រី រ៉ូប៊ឺតសុន) ។

**កាតព្វកិច្ចដែលមិនយកសន្ធិសញ្ញាផ្សេងៗជាមូលដ្ឋាន**

សន្ធិសញ្ញាមិនមែនជាប្រភពតែមួយគត់នៃកាតព្វកិច្ចច្បាប់អន្តរជាតិទេ ។ រដ្ឋមួយអាចតម្រូវឲ្យជម្រះក្ដីចំពោះជនដែលប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរដោយផ្អែកលើប្រភពផ្សេងពីសន្ធិសញ្ញា ។ ប្រភពផ្សេងៗទៀតដែលសំខាន់មានដូចជា ÷

១) ច្បាប់ទម្លាប់ដែលជាច្បាប់អន្តរជាតិ "ត្រូវបានអនុវត្តទូទៅនិងដូចៗគ្នាដោយរដ្ឋក្នុងន័យកាតព្វកិច្ចច្បាប់" ។

២) គោលការណ៍ច្បាប់ទូទៅដែលមានចែងមាត្រាដូចគ្នាទៅនឹងប្រព័ន្ធច្បាប់ភាគច្រើន ឬក៏ច្បាប់ទូទៅដែលវិវឌ្ឍនៅក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ (ណាមមី ទំព័រ៤៦) ។

ដើម្បីឲ្យមានការពាក់ព័ន្ធជាមួយនឹងរឿងតុលាការ ខ្ញុំសូមលើកយកបញ្ហាមួយចំនួនដូចខាងក្រោមដែលបង្ហាញពីកម្រិតនៃការផ្ទុយគ្នារវាងការលើកលែងទោសចំពោះ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ជាមួយនឹងប្រភពផ្សេងៗនៃច្បាប់អន្តរជាតិ÷

**ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**

ក្នុងការសិក្សាវែកញែកមួយផ្អែកទៅលើអំពើឃោរឃៅរបស់ខ្មែរក្រហម អាប្រាម និង រ៉ាតន័រ អះអាងថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅតែជាមូលដ្ឋានសំខាន់សម្រាប់អ្នកដែលចង់នាំយកមេដឹកនាំខ្មែរក្រហមយកមកកាត់ទោស (រ៉ាតន័រ អាប្រាម ទំព័រ២៤៧) ។ មានការឲ្យនិយមន័យផ្សេងៗពីគ្នាចំពោះពាក្យថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនេះ ។ ប៉ុន្ដែទោះជាយ៉ាងណាក៏មានការឯកភាពជាទូទៅមួយទៅលើធាតុផ្សំភាគច្រើនស្ទើរតែទាំងអស់របស់ឧក្រិដ្ឋកម្មនេះ ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជាអំពើអមនុស្សធម៌ដែលមានលក្ខណៈធ្ងន់ធ្ងរប្រព្រឹត្តឡើងជាលក្ខណៈជាទ្រង់ទ្រាយធំនិងលក្ខណៈប្រពន្ធ័ទៅលើជនស៊ីវិល ដោយហេតុផលនយោបាយ ជាតិពន្ធ ឬមូលហេតុសាសនា

(អានសៀវភៅ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" និពន្ធដោយ ជេហ្វ្រី រ៉ូប៊ឺតសុន ទំព័រ២៧៨ បោះពុម្ពផ្សាយនៅឆ្នាំ១៩៩៩ នៅទីក្រុងឡុង) ។ អំពើទាំងឡាយនោះត្រូវតែមានការជាប់ពាក់ពន្ធ័ជាមួយនឹងចំណាត់ការរបស់រដ្ឋាភិបាល ហើយនៅក្នុងនិយមន័យរបស់វាកាលពីក្រោយសង្គ្រាមលោកលើកទីពីរ អំពើនេះត្រូវតែបានប្រព្រឹត្តឡើងក្នុងជម្លោះប្រដាប់អាវុធ ។ និយមន័យមួយជាក់លាក់មាននៅក្នុងធម្មនុញ្ញរបស់តុលាការសឹកអន្តរជាតិ នៅនូរិមប៊ឺក÷

"ឃាតកម្ម ការកម្ទេចអំពើទាសភាព ការនិរទេស និងអំពើផ្សេងៗទៀតមានលក្ខណៈអមនុស្សធម៌ដែលត្រូវបានប្រព្រឹត្តទៅលើជនស៊ីវិលមុន ឬក្នុងអំឡុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ ជាតិសាសន៍ ឬសាសនា ដែលអនុវត្តឬមានការពាក់ពន្ធ័នឹងឧក្រិដ្ឋម្មនៅក្នុងក្របខ័ណ្ឌដែនសមត្ថកិច្ចរបស់តុលាការ ទោះបីជាដែនសមត្ថកិច្ចនេះមានឬមិនមានការរំលោភទៅលើច្បាប់ក្នុងស្រុករបស់ប្រទេសដែលបទល្មើសត្រូវបានប្រព្រឹត្តក៏ដោយ" ។


អៀង សារី

ធម្មនុញ្ញនិងចំណាត់ថ្នាក់បន្តបន្ទាប់ធ្វើឡើងដោយគណៈកម្មការច្បាប់អន្តរជាតិនិងសច្ចាប័នរបស់សន្និបាតអង្គការសហប្រជាជាតិមិនតម្រូវឲ្យភាគីរដ្ឋដាក់ទណ្ឌកម្មចំពោះអំពើទាំងនេះឡើយ ប៉ុន្តែឲ្យមានការជម្រះក្តីនឹងផ្តល់នូវមូលដ្ឋានច្បាប់ (ណាមមី ទំព័រ៥១) ។ ទោះជាយ៉ាងនេះក៏ដោយ ប្រភពផ្សេងៗនៃច្បាប់អន្តរជាតិបញ្ជាក់ថាមានការរួមមតិគ្នាទៅលើចំណុចមួយថា កាតព្វកិច្ចកើតមានឡើងដើម្បីជម្រះទោសជនជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ប្រភពទាំងនេះរួមមានសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៦៧ ដែលជំរុញឲ្យភាគីរដ្ឋមិនផ្តល់សិទ្ធិជ្រកកោនចំពោះជនណាជាប់សង្ស័យពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ក្រៅពីសេចក្តីប្រកាសនេះមានអនុសញ្ញាស្តីពីការមិនអនុវត្តនៃដែនសមត្ថកិច្ចចំពោះឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលចេញចំហឲ្យមានការចុះហត្ថលេខានៅឆ្នាំ១៩៦៨ ព្រមទាំងគោលការណ៍នៃសហប្រតិបត្តិការអន្តរជាតិក្នុងការស៊ើប ការចាប់ខ្លួន ការបញ្ជូនខ្លួន និងការផ្តន្ទាទោសចំពោះជនដែលត្រូវបានរកឃើញកំហុសពីបទឧក្រិដ្ឋម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលអនុម័តដោយអង្គសន្និបាតរបស់អង្គការសហប្រជាតិនៅឆ្នាំ១៩៧៣ ។ ប្រភពទាំងអស់ដែលរៀបរាប់មកនេះមានការផ្តោតសំខាន់ទៅលើកាតព្វកិច្ចចំពោះរដ្ឋក្នុងការដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (រ៉ូប៊ឺតសុន ទំព័រ២៣២) ។

ដូច្នេះទាំង រ៉ូប៊ឺតសុន និងអ្នកនិពន្ធដទៃទៀត ទាញបានសេចក្តីសន្និដ្ឋានថា ច្បាប់អន្តរជាតិតម្រូវឲ្យរដ្ឋធ្វើការជំនុំជម្រះក្តីចំពោះបទឧក្រិដ្ឋម្មប្រឆាំងនឹងមនុស្សជាតិ ។ រ៉ូប៊ឺតសុន ធ្វើការសន្និដ្ឋានថា "រួមសេចក្តីមក ច្បាប់អន្តរជាតិឥឡូវនេះបានដាក់កាតព្វកិច្ចចំពោះភាគីរដ្ឋក្នុងការស៊ើបអង្កេតនិងជំនុំជម្រះក្តីចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទោះបីច្បាប់នេះលុបបំបាត់ច្បាប់លើកលែងទោស នឹងមានការប៉ះពាល់ខ្លះជាមួយនឹង



ក្រុមអ្នកជំនាញការច្បាប់របស់អង្គការសហប្រជាជាតិ

អំពើផ្តួលរំលំរបបមួយតាមរយៈការធ្វើបដិវត្តន៍ក៏ដោយ (ទំព័រ២៨៧) ។

ច្បាប់របស់តុលាការអន្តរអាមេរិកាំងនិងគណៈកម្មការសិទ្ធិមនុស្ស ព្រមទាំងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរអាមេរិកាំង ក៏បញ្ជាក់ដែរថា ការលើកលែងទោសមិនអាចអនុវត្តចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ រួមទាំងការធ្វើឲ្យបាត់ខ្លួនមនុស្ស (ដូឌ្លាស ឌាសែលៈ គំរូអន្តរជាតិទាក់ទងនឹងការលើកលែងទោសចំពោះអំពើឃោរឃៅៈ ច្បាប់ និងបញ្ហាកើតឡើងសព្វថ្ងៃ ដែលបោះពុម្ពផ្សាយនៅឆ្នាំ១៩៩៧ ទំព័រ១៩៧) ។

ទាក់ទងនឹងឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ព្រះរាជអាជ្ញាគួរតែបញ្ជាក់និងប្រកាន់យកជំហរច្បាស់លាស់ថារាល់ការលើកលែងទោសក្នុងស្រុកទាំងឡាយមិនអាចអនុវត្តបានឡើយ ។

## សេចក្តីសន្និដ្ឋាន

បើចង់បង្កើតឲ្យមានអង្គតុលាការពិតប្រាកដមួយដោយមានការចូលរួមគាំទ្រពីសំណាក់សហគមន៍អន្តរជាតិមែននោះ វប្បធម៌លើកលែងទោសនៅកម្ពុជាដែលធ្វើឲ្យសហគមន៍អន្តរជាតិអស់សំណើចនេះគួរតែត្រូវផ្លាស់ប្តូរចេញ ។

ក្នុងអតីតកាល ពួកខ្មែរក្រហមដែលទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងនៅក្នុងប្រទេសនោះត្រូវបានរដ្ឋាភិបាលកម្ពុជាទុកឲ្យចោលមិនអើពើដោះស្រាយតាមផ្លូវច្បាប់ ហើយធ្វើការលើកលែងទោសទាំងផ្លូវការទាំងមិនផ្លូវការច្រើនចំពោះពួកទាំងនេះ ។

ក្នុងនាមជាភាគីមួយនៅក្នុងសន្ធិសញ្ញាជាច្រើននិងក្រោមច្បាប់ទម្លាប់អន្តរជាតិ ប្រទេសកម្ពុជាមានកាតព្វកិច្ចជំនុំជម្រះក្តីបទឧក្រិដ្ឋនានាដែលមកដល់ពេលនេះត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិនោះ ។ បទឧក្រិដ្ឋកម្មទាំងនេះរួមមានឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងអំពើទារុណកម្ម ។ ការលើកលែងចំពោះឧក្រិដ្ឋកម្មដែលបានរៀបរាប់មកនេះវាផ្ទុយទៅនឹងកាតព្វកិច្ចនិងបង្ហាញពីការរំលោភទៅលើកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្រោមច្បាប់អន្តរជាតិ ។ ដូច្នេះការលើកលែងទោសនេះមិនអាចឲ្យកើតមានឡើយក្នុងការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។

**យ៉ន ឆាំង គ្រីនធិន**

# សារជាតិនៃសេចក្តីព្រាងច្បាប់ខ្មែរក្រហម

ភាពគានតឹងរវាងបំណងប្រាថ្នារបស់អង្គការសហប្រជាជាតិដែលចង់បានតុលាការមួយមានកម្រិតអន្តរជាតិនិងបំណងប្រាថ្នារបស់រាជរដ្ឋាភិបាលកម្ពុជាដែលចង់បានតុលាការមួយទៀតក្នុងផ្លូវបញ្រ្ជាសគ្នាដើម្បីធ្វើការជម្រះក្តីសមាជិកខ្មែរក្រហមចំពោះបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្ត ហាក់ដូចជាបញ្ចប់ទៅដោយរាជរដ្ឋាភិបាលកម្ពុជាជាអ្នកបានទទួលជ័យជម្នះ ។ រាជរដ្ឋាភិបាលកម្ពុជាបានទាញហេតុផល "អធិបតេយ្យភាព" របស់ប្រទេសខ្លួន ។ អង្គការសហប្រជាជាតិបានបញ្ឈប់កិច្ចពិភាក្សាស្តីអំពីបញ្ហាបង្កើតតុលាការតាំងពីពេលដែលរាជរដ្ឋាភិបាលកម្ពុជាបដិសេធមិនព្រមធ្វើតាមសំណើរបស់ខ្លួន ហើយបែរជាបញ្ចប់ភារកិច្ចដោយខាងរាជរដ្ឋាភិបាលកម្ពុជាស្ថិតនៅក្នុងសភាពអ្វីដែលខ្ញុំជឿជាក់ថាជាការសើចចំអកដល់ការស្វែងរកយុត្តិធម៌ដ៏ពិតប្រាកដមួយ ។ ជាការច្បាស់ណាស់ចំពោះប្រជាជនកម្ពុជាភាគច្រើនដែលថារាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងធ្វើយ៉ាងណាដើម្បីចៀសវាងក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកជម្រះក្តី ។ ទង្វើនេះបានគូសបញ្ជាក់យ៉ាងច្បាស់អំពីភាពកង្វះឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ក៏ប៉ុន្តែ អង្គការសហប្រជាជាតិបានជ្រើសរើសផ្លូវដើរតាមរាជរដ្ឋាភិបាលកម្ពុជាគ្រប់ពេលទាំងអស់ដោយដឹងថាកង្វះនូវឆន្ទៈនយោបាយនេះហើយគឺជាចំណុចសំខាន់បំផុតដែលនាំដល់ការបរាជ័យក្នុងការស្វែងរកយុត្តិធម៌ ។

គំនិតរបស់អង្គការសហប្រជាជាតិមិនមានលក្ខណៈច្បាស់លាស់ទាល់តែសោះ ។ មានភ័ស្តុតាងមួយបញ្ជាក់ថា អង្គការសហប្រជាជាតិដើរតាមពីក្រោយសហរដ្ឋអាមេរិកនៅក្នុងការប៉ុនប៉ងរបស់ខ្លួនចាប់តាំងពីឆ្នាំ១៩៩១ ដើម្បីកសាងទំនាក់ទំនងជាមួយនឹងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាមេដឹកនាំនឹងអាចទទួលយកសំណើរបស់អង្គការសហប្រជាជាតិហើយនឹងធ្វើឲ្យក្រុមការងាររបស់ខ្លួនអាចធ្វើការងារជាមួយសម្តេចនាយករដ្ឋមន្ត្រីនិងក្រុមជំនិតរបស់សម្តេចបានដោគជ័យ ។ នៅពេលដែលតុលាការត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា វាមិនមែនជារឿងយុត្តិធម៌ទេ ប៉ុន្តែគឺជារឿងនយោបាយទៅវិញ ។ អង្គតុលាការនឹងពិនិត្យមើលទៅលើគ្រប់កាយវិការទាំងអស់ ពោលគឺមានលក្ខណៈដូចគ្នាទៅនឹងតុលាការដែលត្រូវបានរៀបចំជម្រះទោស អៀង សារី និង ប៉ុល ពត ក្នុងពេលដែលប្រទេសកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងដោយរដ្ឋាភិបាលមួយលើកបន្ទុបឡើងដោយវៀតណាមក្រោយពេលរបបខ្មែរក្រហមដួលរលំភ្លាម ។

ចំពោះខ្ញុំ ចំណុចខាងក្រោមនេះបញ្ជាក់ថា អង្គការសហប្រជាជាតិមិនដែលធ្វើការងារឲ្យបានមាំទាំឡើយក្នុងការបង្កើតតុលាការដើម្បីធានាឲ្យប្រាកដម្តងនិងជារៀងរហូតទៅថាឧក្រិដ្ឋជនខ្មែរក្រហមពិតជាត្រូវបាននាំយកមកវិនិច្ឆ័យតាមច្បាប់ប៉ុន្តែយ៉ាងហោចណាស់តាមទម្រង់មួយដែលមានលក្ខណៈសមស្រប÷

- អង្គការសហប្រជាជាតិមិនបានព្យាយាមធ្វើសេចក្តីព្រាងច្បាប់ផ្សេងមួយទៀត ពោលគឺពឹងផ្អែកទៅលើសេចក្តីព្រាងច្បាប់របស់ប្រទេសកម្ពុជា ។ អង្គការសហប្រជាជាតិមិនបានព្យាយាមឲ្យអ្នកជំនាញច្បាប់កម្ពុជាមកចូលរួមក្នុងកិច្ចចរចាឡើយ ។ ការដែលមិនមានកិច្ចពិភាក្សាជាសាធារណៈ ដោយសារកិច្ចចរចានេះគ្មានតម្លាភាព ។

- តាមសំណើរបស់កម្ពុជាចំពោះសន្តិសុខផ្ទាល់ខ្លួនរបស់ជនសង្ស័យ សាក្សីនិងអ្នកជំនាញការគឺស្ថិតក្នុងដែនគរបាលរបស់រាជរដ្ឋាភិបាលកម្ពុជា ។ តាមដែលខ្ញុំដឹង អង្គការសហប្រជាជាតិមិនបានដេញដោលពីរឿងនេះទាល់តែសោះ ។

- **ដំណើរការជំនុំជម្រះក្តី:** ជនសង្ស័យដែលត្រូវបានចាប់ខ្លួននិងចោទប្រកាន់ នឹងត្រូវបាន "នាំមកជំនុំជម្រះក្តីតាមនីតិវិធីដែលមានស្រាប់ និងនៅជាធរមាននៅឡើយ" ។ ច្បាប់ដែលគ្រសោបដំណើរការជំនុំជម្រះក្តីគឺជាច្បាប់កម្ពុជាស្តីអំពីនីតិវិធីផ្នែកព្រហ្មទណ្ឌឆ្នាំ១៩៩៣ ។ ច្បាប់នេះពុំបាននិយាយអំពីតួនាទី

របស់មេធាវីការពារក្តីនៅក្នុងដំណើរការជម្រះក្តី ។ មិនតែប៉ុណ្ណោះទៀតសោត ច្បាប់នីតិវិធីព្រហ្មទណ្ឌថែមទាំងមិនមានអំណាចច្បាប់ទៀតផង ដោយសារតែច្បាប់នេះត្រូវបានបង្កើតឡើងដោយរបបរដ្ឋកម្ពុជាដែលមិនមានអំណាចតាក់តែងច្បាប់ ពីព្រោះនៅក្រោយថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ អំណាចតាក់តែងច្បាប់ត្រូវបានផ្តល់ដល់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ។

ការអនុវត្តជាក់ស្តែងដែលមានស្រាប់របស់នគរបាលកម្ពុជាចំពោះជនសង្ស័យត្រូវបានដឹងពុជាទូទៅថាមានលក្ខណៈឃោរឃៅ ។ វាមិនមែនជាការបំផ្លើសឡើយក្នុងការនិយាយថាភាគច្រើននៃអ្នកដែលត្រូវបានចាប់ខ្លួនគឺត្រូវបានទទួលរងនូវទារុណកម្មឬក៏ការគាបសង្កត់ទាំងផ្នែករាងកាយ និងផ្នែកសតិអារម្មណ៍មុនពេលនាំយកទៅជម្រះក្តីនៅចំពោះមុខព្រះរាជអាជ្ញាឬតុលាការដែលផ្ទុយទៅវិញគឺជាអ្នកបន្តរំខាននិងប្រមាថដល់ជនជាប់ចោទ ។

ប្រព័ន្ធច្បាប់ស៊ីវិលដែលយកលំនាំតាមបារាំង ទាក់ទងនឹងការឆ្លើយសារភាពដែលមានចៅក្រមស៊ើបអង្កេត បម្រើឲ្យការស្រង់ចម្លើយជាជាងការធានាដល់យុត្តិធម៌ពិតប្រាកដ ។ ច្បាប់អ៊ុនតាក់ស្តីអំពីទារុណកម្មដោយនគរបាលគឺមិនគ្រប់គ្រាន់ទេ ដូចដែលបានបញ្ជាក់ច្បាស់ដោយលោក ម៉ាក ផ្ទាន់ខេត ដែលជាព្រះរាជអាជ្ញាពិសេសអ៊ុនតាក់ថា «បទល្មើសនៃការបំពារបំពានមិនអាចផ្តន្ទាទោសបានឡើយ វៀរលែងតែបទល្មើសនេះបណ្តាលឲ្យមានការរងរបួសជាអចិន្ត្រៃយ៍ឬរបួសដែលមានរយៈពេលរហូតដល់៦ខែ» ។ ករណីនេះខុសប្លែកឆ្ងាយពីច្បាប់នៃប្រទេសនានាឧទាហរណ៍ដូចជាប្រទេសអូស្ត្រាលីដែលចាត់ទុកបំណងប្រព្រឹត្តអំពើអាក្រក់ជាការបំពារបំពានដែលអាចផ្តន្ទាទោសបាន ។ តាមការយល់ដឹងពីបទពិសោធន៍របស់ខ្ញុំកន្លងមកឃើញថានគរបាលកម្ពុជាមានជំនាញគ្រប់គ្រាន់ក្នុងការធ្វើទុកបុកម្នេញលើរាងកាយជនសង្ស័យដោយមិនធ្វើឲ្យមានរបួសអចិន្ត្រៃយ៍ឬរហូតដល់រយៈពេល៦ខែ ។ លើសពីនេះទៀត ប្រព័ន្ធច្បាប់នេះមិនបានរារាំងទប់ទល់និងវិធីសាស្ត្រប្រើកម្លាំងរបស់នគរបាលកម្ពុជាឡើយ ។ ទោះបីជាទង្វើនេះមិននាំដល់បទល្មើសព្រហ្មទណ្ឌក៏ដោយក៏គួរតែមានច្បាប់ទប់ស្កាត់ទង្វើនេះដែរ ។

- សន្តិសុខអចិន្ត្រៃយ៍នៃការងាររបស់អង្គចៅក្រមៈ នេះជាចំណុចសំខាន់នៃឯករាជ្យភាពនៃប្រពន្ធ័តុលាការរបស់ប្រទេសមួយ ។ កម្ពុជាមិនទាន់មានច្បាប់ស្តីអំពីឋានៈរបស់ចៅក្រមដែលអាចធានាដល់ឯករាជ្យភាពនៃប្រព័ន្ធតុលាការរបស់ប្រទេសខ្លួននៅឡើយទេ ។ ទោះបីជាច្បាប់ចែងថា ទាំងចៅក្រមនិងព្រះរាជអាជ្ញាមានឯករាជ្យភាពពីរាជរដ្ឋាភិបាលកម្ពុជានៅក្នុងអំឡុងពេលជំនុំជម្រះទោសខ្មែរក្រហមយ៉ាងណាក៏ដោយ ច្បាប់មិនបានធានាសោះឡើយថា ព្រះរាជអាជ្ញានិងចៅក្រមនឹងនៅតែរក្សាមុខតំណែងនិងការងាររបស់ខ្លួនក្រោយពីបេសកម្មបានចប់សព្វគ្រប់ប្រសិនបើខ្លួនមិនបានចេញសាលក្រមដែលត្រូវបានគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជាទេនោះ ។ មិនតែប៉ុណ្ណោះ នៅក្នុងសេចក្តីព្រាងច្បាប់មិនមានប្រការណាមួយការពារឧត្តមក្រុមប្រឹក្សានៃចៅក្រម មិនឲ្យមានការបណ្តេញចេញស្រេចតែទំនើងចិត្តទេ ។ មាត្រាទី ១០២ នៃសេចក្តីព្រាងច្បាប់ខ្មែរក្រហមចែងថា អង្គចៅក្រមទាំងអស់មានឯករាជ្យភាពក្នុងការងាររបស់ខ្លួន ហើយមិនត្រូវទទួលយកឬស្វែងរកការណែនាំពីប្រភពណាមួយឡើយ ។ ប៉ុន្តែសេចក្តីព្រាងច្បាប់នេះមិនបានចែងអំពីការដាក់ទណ្ឌកម្មក្នុងករណីដូចបានចែងនេះកើតឡើង ហើយថែមទាំងមិនបានចែងអំពីការពិន័យក្នុងការជ្រៀតជ្រែកផ្នែកនយោបាយទៀតផង ។ ដូច្នេះច្បាប់នេះមានតម្លាភាពតិចតួចណាស់ ។

លើសពីនេះនៅមានចំណុចខ្វះខាតមួយចំនួនទៀតដូចជាសេចក្តីព្រាងច្បាប់ខ្មែរក្រហមចែងថា អង្គចៅក្រមនិងព្រះរាជអាជ្ញានឹងត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលអាចមើលឃើញថាជាអវៈយវៈរបស់គណបក្សប្រជាជនកម្ពុជា ដែលមានសម្តេច ជា ស៊ីម ជាប្រធានគណបក្សប្រជាជនកម្ពុជាផ្ទាល់និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមខ្លួនឯងផ្ទាល់ក៏មិនមានចែងអំពីសន្តិសុខការងាររបស់សមាជិករបស់ខ្លួនឡើយ ។ ដូច្នេះដើម្បីរក្សាការងារនិងមុខតំណែងរបស់ខ្លួនចៅក្រមនិងព្រះរាជអាជ្ញា ចង់ឬមិនចង់គឺត្រូវតែស្តាប់និងគោរពតាមអ្នកដែលគាំទ្រផ្នែកនយោបាយរបស់ខ្លួន ។ វាមិនមែនជាការបំផ្លើសឡើយក្នុងការនិយាយថា ទាំងអ្នកធ្វើការនៅក្នុងប្រពន្ធ័ច្បាប់និងច្បាប់របស់ប្រទេសកម្ពុជាផ្ទាល់តែម្តង សុទ្ធតែជាចំណាប់ខ្មាំង

របស់គណបក្សនយោបាយ ។ សម្តេច ជា ស៊ីម ជាអ្នកជំនួស ឯកឧត្តម ឱក មន្នី ដែលជាសមាជិកមួយរូបដ៏មានឥទ្ធិពលរបស់គណៈកម្មាធិការកណ្តាលនិងគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សប្រជាជនកម្ពុជា ដែលឥឡូវជាប្រធានតុលាការជាន់ខ្ពស់កម្ពុជា ។ ជំទាវ លី វួចឡេង ដែលជាបក្ខជនគណៈកម្មាធិការកណ្តាលនៃគណបក្សប្រជាជនកម្ពុជា ក៏ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងជាចាងហ្វាងសាលាឧទ្ធរណ៍ដែរ ។ ទោះបីជាច្បាប់របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចែងថា ការចូលរួមរបស់សម្តេច ជា ស៊ីម នៅក្នុងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមិនខុសច្បាប់យ៉ាងណាក៏ដោយ ច្បាប់ដែលអនុញ្ញាតឲ្យសមាជិករបស់សម្តេច ជា ស៊ីម ចូលទៅក្នុងអង្គការគតិយុត្តិ គឺអាចជាការរំលោភទៅលើច្បាប់រដ្ឋធម្មនុញ្ញនៃការបែងចែកអំណាច ។ ដូច្នេះទាំងច្បាប់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនិងការចូលរួមការងាររបស់សម្តេច ជា ស៊ីម គឺអាចមានភាពមិនត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ។

◆ នៅក្នុងប្រទេសកម្ពុជាគ្មានច្បាប់និយាយអំពីភ័ស្តុតាង ។ តាមរយៈបទពិសោធន៍របស់ខ្ញុំដែលធ្លាប់ជាស្មាក្តីសាធារណៈ នៅក្នុងប្រទេសកម្ពុជា ភាគច្រើននៃចៅក្រមទោះបីជាមិនមែនទាំងអស់ក៏ដោយ គឺពុំបានរៀនសូត្រអំពីច្បាប់ស្តីអំពីភ័ស្តុតាងទេ ។ ទោះបីជាមានច្បាប់ហាមប្រាមការសួរចម្លើយដោយបង្ខិតបង្ខំយ៉ាងណាក៏ដោយ ក៏ការអនុវត្តជាក់ស្តែងរបស់នគរបាលកម្ពុជាក្នុងការធ្វើទារុណកម្មឬការបង្ខំជនសង្ស័យឬជនជាប់ចោទដើម្បីសួរយកចម្លើយ នៅតែមានដដែលជាដដែល ។ ស្ទើរតែរាល់ករណីទាំងអស់ ចៅក្រមទទួលយកនូវចម្លើយដែលស្រង់យកមកដោយខុសច្បាប់ ហើយគ្មានការសាកសួរថាតើចម្លើយនេះបានមកដោយរបៀបណា ។ ក្នុងករណីខ្លះដូចដែលបានបង្ហាញតាមរយៈរបាយការណ៍របស់តំណាងពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាឆ្នាំ(១៩៩៧) តុលាការថែមទាំងបានលាក់ឬបង្ក្រាបសក្ខីកម្មរបស់ចុងចោទដែលបង្ហាញពីអំពើឃោរឃៅរបស់នគរបាលកម្ពុជា ដោយស្រែកខ្លាំងៗដាក់ជនជាប់ចោទថា “តុលាការមិនមែនជាកន្លែងដោះស្រាយពីកំហុសរបស់នគរបាលទេ” ។ នៅក្នុងករណីនោះមានការបង្ហាញអំពីចម្លើយសារភាព ប៉ុន្តែមិនបានបង្ហាញអំពីភ័ស្តុតាងនៃការគាបសង្កត់របស់នគរបាលកម្ពុជា ។ ទាក់ទងនឹងបញ្ហានៃអំពើឃោរឃៅរបស់នគរបាលកម្ពុជានេះ ច្បាប់អន្តរកាលគឺស្ថិតនៅខាងនគរបាលកម្ពុជា ។ ច្បាប់នេះត្រូវបានព្រាងឡើងដោយចេតនាតាមវិធីនេះឯង ។ នៅក្រោមច្បាប់នេះ ការរំលោភគឺមិនមែនជាបទឧក្រិដ្ឋឡើយ ដរាបណាការរំលោភនេះមិនបណ្តាលឲ្យមានរបួសជាអចិន្ត្រៃយ៍ ឬក៏មានរយៈពេល៦ខែទេនោះ ។ ដូច្នេះទោះបីជាមានការប៉ុនប៉ងដាក់ទណ្ឌកម្មនគរបាលកម្ពុជាពីបទប្រើប្រាស់ការគាបសង្កត់ឬកាយវិការឃោរឃៅ ក៏គ្មានបានផ្លែផ្កាអ្វីដែរដរាបណាច្បាប់មិនត្រូវបានផ្លាស់ប្តូរ ។ វិធីមួយនៅក្នុងក្របខ័ណ្ឌច្បាប់សព្វថ្ងៃមិនត្រូវបញ្ចូលករណីស្រង់ចម្លើយសារភាពដោយការបង្ខិតបង្ខំទេ ធ្វើដូច្នេះដើម្បីបង្រៀននគរបាលកម្ពុជាថាវិធីសាស្ត្រឃោរឃៅរបស់ខ្លួនមិនអាចទទួលផលបានឡើយ ។ ក៏ប៉ុន្តែដូចដែលបានរៀបរាប់មកខាងដើម ករណីនេះហាក់ដូចជាមិនអាចទៅរួច ។

◆ សេចក្តីព្រាងច្បាប់នេះមិនមានដំណើរការ ហើយត្រូវការអំណាចក្នុងការពិនិត្យសាឡើងវិញដោយផ្អែកតាមផ្លូវច្បាប់ ។ ដូច្នេះក្រុមប្រឹក្សារដ្ឋធម្មនុញ្ញដែលមានស្រាប់គឺជាអង្គការមួយមានសមាជិក៦រូបក្នុងចំណោមសមាជិក៩រូប ជាបុគ្គលដែលត្រូវបានតែងតាំងដោយគណបក្សប្រជាជនកម្ពុជា ហើយរាល់ការសម្រេចចិត្តត្រូវបានធ្វើឡើងដោយមតិភាគច្រើន(ប្រាំរូប) នឹងមានដែនយុត្តាធិការក្នុងការពិនិត្យសើរើឡើងវិញនូវតាមផ្លូវច្បាប់នូវបញ្ហាទាំងនេះ ។ នេះជាចំណុចសំខាន់មួយទៀតដែលខ្ញុំគិតថាគួរតែត្រូវបានលើកមកដេញដោលដោយអង្គការសហប្រជាជាតិ ។

◆ អ្វីដែលជាគុណវិបត្តិផ្អែកច្បាប់គឺថា ច្បាប់នេះមិនចែងអំពីការការពារក្តី ។ តាមការពិត ច្បាប់បច្ចុប្បន្នទាំងអស់រួមទាំងច្បាប់ព្រហ្មទណ្ឌអន្តរកាលឬច្បាប់អ៊ិនតាក់ មិនអនុញ្ញាតឲ្យមានការការពារក្តីជាមូលដ្ឋានឡើយ ។ នៅក្រោមច្បាប់អ៊ិនតាក់ ការការពារខ្លួន ភាពវិកលចរិត និងការការពារក្តីមានលក្ខណៈវិជ្ជមានផ្សេងៗទៀត មិនមែនជាការការពារក្តីទេ ប៉ុន្តែវាជាស្ថានភាពសម្រាលទោសតែប៉ុណ្ណោះ ។

ចំណុចមួយទៀតដែលមានលក្ខណៈអវិជ្ជមានគឺការយល់

ព្រមជាក់ស្តែងរបស់អង្គការសហប្រជាជាតិជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងបញ្ហាថាតើអ្នកណានឹងត្រូវបាននាំយកមកជម្រះទោស ។ ដើម្បីកំណត់ទំហំនៃការជម្រះទោស អង្គការសហប្រជាជាតិបានបន្ថែមពាក្យ "ភាគច្រើន" ទៅក្នុងសេចក្តីព្រាងច្បាប់ខ្មែរក្រហម ។ គោលបំណងនៃច្បាប់នេះគឺជម្រះទោស "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលមានការទទួលខុសត្រូវច្រើននៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ" ។ យោងតាមសេចក្តីកត់សម្គាល់បន្ថែមទៅលើសេចក្តីព្រាងច្បាប់ ហេតុផលដែលនាំឲ្យអង្គការសហប្រជាជាតិបន្ថែមពាក្យនេះគឺថា "លទ្ធផលនេះគឺជាក់ស្តែងមិនមែនជាចេតនារបស់រដ្ឋាភិបាលទេ..." ។ ដូច្នេះហើយបានជាគណៈប្រតិភូរបស់អង្គការសហប្រជាជាតិបានបន្ថែមពាក្យ "ភាគច្រើន" ជាការបញ្ជាក់អំពីរបៀបកំណត់ទំហំនៃដែនយុត្តាធិការរបស់បុគ្គលក្នុងវិធីមួយដែលសមហេតុសមផល ។ ប្រសិនបើដំណោះស្រាយដទៃទៀតត្រូវបានពិចារណាហ្មត់ចត់ក្នុងគោលបំណងសម្រេចឲ្យបានលទ្ធផលដូចគ្នានេះ អង្គការសហប្រជាជាតិត្រូវរៀបចំខ្លួនដើម្បីពិនិត្យបញ្ហាទាំងនេះ ។ តាមសំណើរបស់ឯកឧត្តម សុខ អាន គណៈប្រតិភូរបស់អង្គការសហប្រជាជាតិបានពិនិត្យដំណោះស្រាយទាំងនេះ ហើយបានបញ្ជាក់ច្បាស់ថា ការបង្កើតមាត្រានេះគឺជាការសម្រេចចិត្តផ្នែកនយោបាយដែលនឹងត្រូវសម្រេចដោយថ្នាក់ជាតិ ។ សេចក្តីបញ្ជាក់នោះបន្តទៀតថា ជាមួយបដិញ្ញនេះ យើងសូមជូនជាយោបល់គួរតែដាក់ឃ្លាផ្សេងថា "និងជនដៃដល់ដ៏ឃោរឃៅបំផុតដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្មនិងការរំលោភដ៏ធ្ងន់ធ្ងរ" ។

ចំពោះបញ្ហានេះអ្នកសិក្សាជាន់ខ្ពស់អំពីបញ្ហាកម្ពុជាមួយរូបឈ្មោះ ស៊ីវ ហេឌ័រ បានបញ្ជាក់យ៉ាងត្រឹមត្រូវថា "នេះបញ្ជាក់ច្បាស់ថាអង្គការសហប្រជាជាតិបានចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការស្វែងរករូបមន្តមួយដែលអាចទទួលយកបានតាមលក្ខណៈនយោបាយ ហើយប្រការនេះនឹងធានាដល់ការរួចទោសរបស់សមាជិកមួយចំនួននៃគណបក្សប្រជាជនកម្ពុជាសព្វថ្ងៃ ។ ហើយថាការសម្រេចចិត្តនេះនឹងផ្អែកទៅលើមូលដ្ឋាននយោបាយ ទោះជាយុត្តិកម្មនៃការអនុវត្តជាក់ស្តែងត្រូវបានបន្ថែមដើម្បីជួយជំរុញការទាញហេតុផលក៏ដោយចុះ ។

កេរ្តិ៍ឈ្មោះមុខមាត់គឺពិតជារឿងច្បាប់គួរឲ្យអស់សំណើច ។ វាបានបង្ហាញឲ្យឃើញអំពីយុទ្ធនាការឃោសនាដែលមិនមែនជារឿងពិត ហើយនិងបង្ហាញឲ្យឃើញថាជារឿងនយោបាយដែលមិនមែនជារឿងយុត្តិធម៌ ។ កេរ្តិ៍ឈ្មោះមុខមាត់កើតឡើងមិនមែនមកពីដំណើរការតុលាការទេ ប៉ុន្តែមកពីយុទ្ធនាការឃោសនា ។ "មេដឹកនាំជាន់ខ្ពស់" និង "ជនដៃដល់ដ៏ឃោរឃៅ" គឺជាការបង្កើតរូបមន្ត ដែលមិនរួមបញ្ចូលអ្នកដែលត្រូវបានវៀតណាម សាធារណរដ្ឋប្រជាមានិតកម្ពុជា និងប្រព័ន្ធឃោសនាអន្តរជាតិចាត់ទុកជាជនឃោរឃៅ ។ អ្វីដែលលើកឡើងនេះគឺជាការចៀសវាងអំពីរូបមន្តអព្យាក្រឹតដែលដាក់ដោយអ្នកជំនាញការរបស់អង្គការសហប្រជាជាតិៈ "អ្នកដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភដ៏ធ្ងន់ធ្ងរ ។ ឃ្លានេះបញ្ជាក់ថា ដំណោះស្រាយគឺមិនអាចទទួលយកបានដោយសារតែវាអាចបញ្ចូលសមាជិកមួយចំនួននៃគណបក្សប្រជាជនកម្ពុជា និងមិនរួមបញ្ចូល "មេដឹកនាំជាន់ខ្ពស់" និង "ជនដៃដល់ឃោរឃៅ" ដែលបានប្រព្រឹត្តបាបកម្មផ្នែកនយោបាយប្រឆាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជា អង្គការសហប្រជាជាតិ សហរដ្ឋអាមេរិក ជាដើម ។ល ។ ដូច្នេះការប្រព្រឹត្តបាបកម្មនេះក្លាយជាល្បែងនយោបាយស្មើភាពដោយមិនគិតថាជនទាំងអស់នេះជាឧក្រិដ្ឋជនដ៏អាក្រក់បំផុតនៅក្នុងរបបខ្មែរក្រហមឡើយ" ។

មានភស្តុតាងមួយចំនួនបញ្ជាក់ថាឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយ អៀង សារី និង ប៉ុល ពត មិនអាចធ្ងន់ណាស់ណាជាងឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយ នួន ជា និង សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ហេតុអ្វីក៏ នួន ជា និង សុន សេន មិនត្រូវយកមកជម្រះទោសនៅក្នុងឆ្នាំ១៩៧៩? វាហាក់ដូចជាហេតុផលដែលអ្នកទាំងបីមិនត្រូវបាននាំយកមកជម្រះទោស (ឬត្រូវវៀតណាម របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ចាត់ទុកជាបិសាច) ពីព្រោះវៀតណាមចាត់ទុក នួន ជា សុន សេន និង សោ ភឹម ជា "មនុស្សរបស់យើង" ហើយជាពិសេស នួន ជា តែម្តងដែលត្រូវបានចាត់ទុកជា "មនុស្សនិងមិត្តសំឡាញ់ជិតដិត" ។ នេះជា

សម្តីរបស់ ឡេ យន់ អគ្គលេខាបក្សកុម្មុយនិស្តវៀតណាម ដែលបាននិយាយនៅក្នុងកិច្ចជំនួបជាមួយនឹងឯកអគ្គរដ្ឋទូតសហភាពសូវៀតប្រចាំនៅប្រទេសវៀតណាមនាដើមឆ្នាំ១៩៧៦ ។ (សួរថាតើពាក្យនេះជាពាក្យប្រឌិតរបស់ ឡេ យន់ ក្នុងការជំរុញឲ្យមានការបោសសម្អាតផ្ទៃក្នុងដែលជាល្បិច "បំបែកហើយកាន់កាប់" ឬក៏ជារឿងមួយផ្សេង?) ។ ប៉ុន្តែរឿងដែលសំខាន់នោះគឺថា មានតែមនុស្សពីរនាក់ប៉ុណ្ណោះត្រូវបានបកអាក្រាតពោលគឺ ប៉ុល ពត និង អៀង សារី ។ ឧទាហរណ៍មួយទៀតគឺរឿងតាម៉ុក ។ ឈ្មោះថា "ជនដៃដល់ខាងកាប់សម្លាប់" គឺជាឈ្មោះដែលបណ្តាញសារពត៌មានជាអ្នកដាក់ឲ្យទេ ។

## ច្បាប់ក្លែងក្លាយ

### ១) បញ្ហាដែនយុត្តាធិការ

ការខុសប្លែកគ្នារវាងតុលាការអន្តរជាតិនិងតុលាការជាតិធម្មតាគឺសមត្ថកិច្ចក្នុងការវិនិច្ឆ័យក្តីពីបទឧក្រិដ្ឋកម្មដែលមានចរិតផ្សេងៗគ្នាដូចជាតុលាការអន្តរជាតិវិនិច្ឆ័យក្តីពីបទឧក្រិដ្ឋកម្មអន្តរជាតិ ហើយតុលាការជាតិវិនិច្ឆ័យក្តីពីបទឧក្រិដ្ឋកម្មក្នុងស្រុក ។ ដើម្បីតុលាការជាតិអាចកាត់ទោសបទឧក្រិដ្ឋកម្មបានលុះត្រាតែមានវិធានការច្បាប់និងវិធានការស្របច្បាប់ទើបបាន ។ ការបង្កើតច្បាប់ទាក់ទងនឹងប្រការផ្សេងៗស្តីអំពីបទឧក្រិដ្ឋកម្មនៃសេចក្តីព្រាងច្បាប់ខ្មែរក្រហម តាមគំនិតខ្ញុំគឺវាមិនមានលក្ខណៈស្របច្បាប់ឡើយ ។

មាត្រាទី១នៃសេចក្តីព្រាងច្បាប់ចែងថា "ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា រំលោភទៅលើច្បាប់និងទម្លាប់អន្តរជាតិ ហើយនិងរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩" ។

មានបញ្ហាពីរចំពោះមាត្រានេះនិងមាត្រាផ្សេងៗទៀតដែលទាក់ទងនឹងឧក្រិដ្ឋកម្មអន្តរជាតិ÷

១) ច្បាប់នេះបង្ហាញពីការរើសអើងដែលជម្រះទោសចំពោះតែខ្មែរក្រហម ប៉ុន្តែមិនបញ្ចូលសហរដ្ឋអាមេរិកដែលធ្វើការទម្លាក់គ្រាប់បែកដាក់ប្រជាជនកម្ពុជាដោយមិនរើសមុខ ។ ដោយយោងតាមរបាយការណ៍របស់តំណាងពិសេសរបស់អគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សក្នុងឆ្នាំ១៩៩៦ ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកបានសម្លាប់ប្រជាជនកម្ពុជាចំនួន៧សែននាក់ និងធ្វើឲ្យមនុស្ស២លាននាក់ទៀតគ្មានផ្ទះសម្បែង ។ ព្រឹត្តិការណ៍នេះកើតឡើងពីរ-បីឆ្នាំប៉ុណ្ណោះមុនពេលដែលខ្មែរក្រហមកាន់កាប់អំណាច ។ ច្បាប់ខ្មែរក្រហមថែមទាំងមិនបានបញ្ចូលការជម្រះក្តីសមាជិកនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាទៀតផង ។ ជាការពិតដែលថានៅពេលដែលវៀតណាមចូលមកប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៩ ការងារ "ក-៥" (ក្នុងឆ្នាំ១៩៨៤-៨៩) បានបណ្តាលឲ្យមានមនុស្សស្លាប់យ៉ាងហោចណាស់ក៏៨ម៉ឺននាក់ដែរ នេះមិនគិតពីអ្នកដែលពិការនិងមានជំងឺផង ។ ហើយមិនតែប៉ុណ្ណោះ ស្ថានការណ៍សិទ្ធិមនុស្សនៅតែមានភាពយ៉ាប់យ៉ឺនដូចដែលបញ្ជាក់នៅក្នុងរបាយការណ៍គណៈកម្មាធិការសិទ្ធិមនុស្សឆ្នាំ១៩៨៥ថា "សភាពការណ៍សព្វថ្ងៃគឺមានការរំលោភផ្នែកសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរដោយរបបដឹកនាំបច្ចុប្បន្នដែលនាំទៅដល់ការមិនគោរពវិធាននៃច្បាប់" ។

២) មាត្រានេះមិនត្រឹមត្រូវតាមផ្លូវច្បាប់ដោយសារតែស្ថានភាពនៃបទឧក្រិដ្ឋកម្មអន្តរជាតិនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងកំណត់សម្គាល់នៃកិច្ចចរចារវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា គ្មានការលើកឡើងអំពីដែនការ ឬក៏ថាតើឧក្រិដ្ឋកម្មទាំងនេះនឹងស្ថិតនៅក្រោមដែនយុត្តាធិការនៃតុលាការខ្មែរក្រហមយ៉ាងណានោះឡើយ ។ ប្រសិនបើមាត្រានេះឈប់ត្រឹមអ្វីដែលបានលើកឡើងនិងមិនមានដែនការក្នុងការបង្កើតសន្ធិសញ្ញា ព្រមទាំងបញ្ចូលបទឧក្រិដ្ឋលក្ខណៈអន្តរជាតិនៅក្នុងច្បាប់ជាតិនៃប្រទេសកម្ពុជាទេនោះ តុលាការនឹងមិនមានសមត្ថកិច្ចក្នុងការវិនិច្ឆ័យបទឧក្រិដ្ឋកម្មដូចជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បានទេ ។

ជាការពិតណាស់ថា ប្រទេសកម្ពុជាគឺជាភាគីមួយក្នុងគ្រប់សន្ធិសញ្ញាដែលរៀបរាប់ខាងលើ លើកលែងតែឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ព្រោះវាមិនមែនជាកាតព្វកិច្ចដែលផ្អែកតាម

សន្ធិសញ្ញា ។ នៅក្នុងឆ្នាំ១៩៩៨ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានបាត់ចូលទៅក្នុងលក្ខន្តិកៈរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលក្នុងលក្ខន្តិកៈនោះប្រទេសកម្ពុជាមិនមែនជាភាគីចុះកិច្ចសន្យា ។ ទោះបីជាប្រទេសកម្ពុជាជាភាគីចុះកិច្ចសន្យាយ៉ាងណាក៏ដោយ ក៏លក្ខន្តិកៈរ៉ូមមិនអាចមានប្រតិសកម្មដែរ ។ អ្វីដែលកម្ពុជាកំពុងធ្វើបច្ចុប្បន្នចំពោះសន្ធិសញ្ញាឧក្រិដ្ឋកម្មនិងសន្ធិសញ្ញាទូទៅនៅក្នុងតុលាការក្នុងស្រុក បង្កើតឲ្យមានបញ្ហានៃការអនុវត្តច្បាប់នៃសេចក្តីព្រាងច្បាប់និងការវិនិច្ឆ័យទោសជនទាំងឡាយណាដែលជាប់ចោទប្រកាន់ដោយតុលាការក្នុងស្រុកពីបទឧក្រិដ្ឋកម្មអន្តរជាតិដូចជាឧក្រិដ្ឋកម្មសង្គ្រាមជាដើម ។

មាត្រាទី៣១នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ចែងថា “ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរព (សម្គាល់ៈ មិនសង្កេតការណ៍ទេ) សិទ្ធិមនុស្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីសិទ្ធិមនុស្សនិងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ” ។ មាត្រាទី២៦ ចែងទាំងមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយថា ព្រះមហាក្សត្រឡាយព្រះហស្តលេខានិងផ្តល់សច្ចាប័នចំពោះសន្ធិសញ្ញាអន្តរជាតិក្រោយពីមានការយល់ព្រមពីសភាជាតិកម្ពុជា ។ ដូច្នេះការលើកយកសន្ធិសញ្ញាឬអនុសញ្ញាសិទ្ធិនិងកាតព្វកិច្ចអន្តរជាតិមកពិនិត្យពិភាក្សាជាមួយនឹងច្បាប់ទម្លាប់នៅក្នុងស្រុកវាមិនមានលក្ខណៈច្បាស់លាស់ឡើយថាតើកម្ពុជាជ្រើសរើសយកគំនិតទ្វិកភាពនិយមឬឯកាភាពនិយមនៃច្បាប់អន្តរជាតិ ។

ក្នុងការព្យាយាមបញ្ជាក់ច្បាស់អំពីតួនាទីនៃសន្ធិសញ្ញានេះនៅក្នុងតុលាការកម្ពុជា នៅឆ្នាំ១៩៩៣ អ៊ុនគាត់ បានផ្តល់យោបល់គណៈកម្មការសេចក្តីព្រាងច្បាប់នៃសភាជាតិកម្ពុជាថា “សន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាប្រហែលជាភាគីមួយដែរនោះ អាចអនុវត្តបានដរាបណាច្បាប់នៃប្រទេសកម្ពុជាបានចូលជាធរមានព្រមទាំងផ្សព្វផ្សាយដោយរដ្ឋរបស់ប្រទេសនោះ” ។ ការទទួលយកនូវការផ្តល់យោបល់នេះអាចទាញប្រទេសកម្ពុជាឲ្យដើរស្របគ្នាជាមួយនឹងរដ្ឋធម្មនុញ្ញរបស់ប្រទេសបារាំង ។ មាត្រាទី៥៣ នៃរដ្ឋធម្មនុញ្ញបារាំងចែងថា សន្ធិសញ្ញាភាគច្រើនតម្រូវឲ្យមានការយល់ព្រមពីសភាមុនពេលផ្តល់សច្ចានុម័ត ។ មាត្រាទី៥៥ ចែងឲ្យមានអនុវត្តន៍ជាស្វ័យប្រវត្តិក្នុងស្រុកនៃសន្ធិសញ្ញាដែលទទួលបានសច្ចាប័នត្រឹមត្រូវហើយ ។ នេះជាការផ្តល់អំណាចខ្ពស់លើសពីលក្ខន្តិកៈជាតិទៅទៀត ។ ក៏ប៉ុន្តែគណៈកម្មាធិការធ្វើច្បាប់ដែលមានអនុប្រធានដ៏មានឥទ្ធិពល (ឯកឧត្តម ចែម ស្គួន) បានច្រានចោលនូវយោបល់នេះដោយបណ្តាលស្ថានភាពផ្លូវច្បាប់នៃសន្ធិសញ្ញាអន្តរជាតិស្ថិតក្នុងភាពអាប់កំបាំង ។

បញ្ហានេះត្រូវបានបញ្ជាក់វែកញែកច្បាស់នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជាដាក់ជូននូវរបាយការណ៍ឆ្នាំ១៩៩៧ របស់ខ្លួនចំពោះគណៈកម្មការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកអនុសញ្ញាអន្តរជាតិស្តីអំពីការលុបបំបាត់ការរើសអើងជាតិសាសន៍គ្រប់ប្រភេទ ។ នៅក្នុងរបាយការណ៍នេះ កម្ពុជានិយាយថា “កតិកាសញ្ញានិងអនុសញ្ញាទាំងនេះអាចមិនត្រូវបានអនុវត្តដោយផ្ទាល់មុនតុលាការនិងរដ្ឋអំណាចរដ្ឋបាលឡើយ”ៈ CERD/C/29/add.2, ថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៩៧ ។ គឺឯកឧត្តម ចែម ស្គួនដដែល ដែលធ្វើជាប្រធានគណៈកម្មាធិការរបាយការណ៍អន្តរក្រសួងនេះ ។ នេះសបញ្ជាក់ឲ្យឃើញថា ប្រទេសកម្ពុជាបានជ្រើសរើសយកគំនិតទ្វិកភាពនិយមនៃច្បាប់អន្តរជាតិ ហើយការខកខានមិនបានធ្វើតាមការណែនាំជាយោបល់របស់អ៊ុនគាត់អាចត្រូវបានយល់ឃើញជាទូទៅថាជាការធ្វើឡើងដោយចេតនារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប៉ុនប៉ងរារាំងលទ្ធភាពរបស់ជនរងគ្រោះដែលទទួលរងការរំលោភផ្នែកសិទ្ធិមនុស្ស មិនឲ្យស្វែងរកសំណងផ្លូវច្បាប់នៅក្នុងតុលាការ “ជាតិ” ។

ក្នុងខណៈដែលប្រទេសបារាំងជ្រើសរើសយកគោលការណ៍ឯកាភាពដូចដែលមានបង្ហាញស្រាប់នៅក្នុងរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋទី៥របស់ខ្លួន ការមិនពិនិត្យសើរើឡើងវិញដោយប្រសិទ្ធភាពផ្នែកប្រព័ន្ធតុលាការបាននាំឲ្យមានការអនុវត្តនៅក្នុងប្រទេសបារាំងនូវបណ្តុំសន្ធិសញ្ញាផ្សេងៗតាមរយៈវិសោធនកម្មផ្លូវការទៅលើច្បាប់ជាតិ ។ “អនុវត្តន៍បែបនេះដែលជាបណ្តុំរវាងទ្វិកភាពនិងឯកាភាព មានផលប្រយោជន៍ដល់ការទាក់ទាញការយកចិត្តទុកដាក់ពីសំណាក់អាជ្ញាធរសាធារណៈ តុលាការ ព្រមទាំងសាធារណជនទូទៅ ចំពោះច្បាប់ដែលអាចអនុវត្តបាន” (ជីន

ម៉ារ៉េឡូត ១៩៧០) ។

ក្រៅពីនេះ ដោយសារតែសន្ធិសញ្ញានេះមានឥទ្ធិពលទៅលើសិទ្ធិរបស់ប្រជាជន សេចក្តីថ្លៃថ្នូរនិងកាតព្វកិច្ច និងជាពិសេសកាលៈទេសៈដែលកម្ពុជាយល់ព្រមឬអនុម័តសន្ធិសញ្ញាទាំងនេះ វាជាការត្រឹមត្រូវនិងជាការគួរឲ្យប៉ងប្រាថ្នាណាស់ដែលប្រទេសកម្ពុជាបានជ្រើសរើសយកគំនិតទ្វិកភាព ។ ការជ្រើសរើសផ្លូវផ្សេងពីនេះអាចមិនសមស្របដោយសារសភាជាតិកម្ពុជាមិនមានឱកាសពិភាក្សាមួយមាត្រាម្តងៗទៅលើសន្ធិសញ្ញាទាំងនេះមុនពេលចាប់ផ្តើមដំណើរការឬអនុម័ត ។ តាមពិតសន្ធិសញ្ញាភាគច្រើនទោះបីមិនមានទាំងអស់ក្តីដែលប្រទេសកម្ពុជាបានយល់ព្រមឬអនុម័ត ត្រូវបានអនុម័តឬយល់ព្រមតាមរយៈច្បាប់នីតិប្រតិបត្តិ ។ ឧទាហរណ៍នៅក្នុងសំបុត្រមួយច្បាប់ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៥០ សម្តេចបវរសេដ្ឋា សឺន សាន ក្នុងនាមជារដ្ឋមន្ត្រីក្រសួងការបរទេសអមលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានមានប្រសាសន៍ថា «រាជរដ្ឋាភិបាលកម្ពុជារបស់ព្រះករុណាសម្តេចព្រះ នរោត្តម សីហនុ នៃព្រះរាជាណាចក្រកម្ពុជាតាមរយៈគណៈរដ្ឋមន្ត្រីបានប្រកាសច្បាស់អំពីសិទ្ធិទទួលយករបស់ព្រះរាជាណាចក្រកម្ពុជាចំពោះអនុសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ដែលចែងនៅក្នុងលក្ខខណ្ឌផ្សេងៗនៃមាត្រាទី១១នៃអនុសញ្ញានោះ» ។ គ្មានការពិភាក្សាណាមួយត្រូវបានធ្វើឡើងដោយសភាជាតិកម្ពុជាឡើយ ។ គ្រាន់តែឲ្យសភាអនុម័តមុនឬក្រោយពេលទទួលយកដោយគ្មានការពិភាក្សាដេញដោល វាជាការស្រេចទៅហើយ ។ ប៉ុន្តែជាផលវិបាកបំផុតនោះវាជាការរំលោភទៅលើប្រព័ន្ធការងាររបស់សភាតំណាងយ៉ាងឆាយនិងមិនស្របតាមរដ្ឋធម្មនុញ្ញទៀតផង ។ មិនតែប៉ុណ្ណោះទៀតសោត ករណីនេះក៏មិនមែនជាករណីគួរឲ្យប៉ងប្រាថ្នាដែរ ។

លោក វ៉ាយដាប៊ើរ (១៩៦៨) បានសរសេរថា «ប្រសិនបើនីតិបញ្ញត្តិប្រឈមមុខជាមួយនឹងអង្គហេតុដែលមិនអាចកែប្រែបានស្តីអំពីសន្ធិសញ្ញាកាតព្វកិច្ចអន្តរជាតិ នោះការសម្រេចចិត្តផ្នែកនីតិបញ្ញត្តិសឹងតែគ្មានសេរីភាពទាល់តែសោះ... ។ ច្បាប់ដែលមានមូលដ្ឋានប្រជាធិបតេយ្យតម្រូវឲ្យសភាចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងសន្ធិសញ្ញាក្នុងផ្លូវមួយដែលមានន័យនិងឲ្យសភានៅខាងក្រោយការប្រកាសតាមរយៈការបន្ថយល្បឿននៃការសម្រេចចិត្តតែឯកឯងរបស់រដ្ឋាភិបាល» ។

វាមិនទាន់ជាការគ្រប់គ្រាន់ទេចំពោះសេចក្តីព្រាងច្បាប់ក្នុងការនិយាយយោងថា តុលាការមានដែនយុត្តាធិការក្នុងការវិនិច្ឆ័យក្តី «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដូចដែលបានចែងនៅក្នុង (អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍) មាត្រាទី៤ ។ ចំពោះមាត្រាទី៥ មាត្រាទី៦ មាត្រាទី៧ និងមាត្រាទី៨ ក៏ដូច្នេះដែរ ពីព្រោះដូចដែលបានរៀបរាប់មកខាងដើមហើយថា ដើម្បីឲ្យតុលាការជាតិកម្ពុជាជម្រះក្តីឧក្រិដ្ឋកម្មអន្តរជាតិបាន សភាជាតិកម្ពុជាត្រូវតែអនុម័តច្បាប់ណាមួយដែលជួយសម្រួលដល់ដំណើរការតុលាការសិន មុនពេលដែលតុលាការអាចបើកសវនាការស្តាប់បទឧក្រិដ្ឋកម្មទាំងនេះ ។ អនុវត្តន៍បែបនេះគឺកើតមានឡើងនៅចក្រភពអង់គ្លេស សហរដ្ឋអាមេរិក (លើកលែងតែ «សន្ធិសញ្ញាស្វ័យប្រតិបត្តិ») និងនៅប្រទេសអូស្ត្រាលី ដែលបានអនុម័តច្បាប់អនុសញ្ញាទីក្រុងហ្សឺណែវ (ឆ្នាំ១៩៥៧) ច្បាប់អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ (ឆ្នាំ១៩៤៩) ច្បាប់ឧក្រិដ្ឋកម្មសង្គ្រាម(ឆ្នាំ១៩៥៧) ច្បាប់ឧក្រិដ្ឋកម្ម (ជនដែលត្រូវបានការពារដោយអនុសញ្ញា) (ឆ្នាំ១៩៧៦) និងច្បាប់ឧក្រិដ្ឋកម្ម (ការធ្វើទារុណកម្ម អនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងទណ្ឌកម្មឃោរឃៅអមនុស្សធម៌ឬធ្វើឲ្យបាត់បង់តម្លៃមនុស្ស) (ឆ្នាំ១៩៨៨) ។ ការខកខានមិនបានអនុម័តច្បាប់ជាក់លាក់ណាមួយនឹងអាចបណ្តាលឲ្យចុងចោទខ្មែរក្រហមដើរហើរដោយសេរី ដោយសារតែកំហុសឆ្គងនៃនីតិវិធីជាមូលដ្ឋានដែលជួយការពារបុគ្គលទាំងនោះ ។

មាត្រា៣នៃសេចក្តីព្រាងច្បាប់ចែងថា «ដែនអាជ្ញាយុកាលចែងនៅក្នុងឆ្នាំក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នឹងអាចពន្យាតសុពលភាពរបស់ខ្លួនរហូតដល់២០ឆ្នាំទៀត» ។ ការបន្ថែមពេលវេលាចំពោះដែនអាជ្ញាយុកាលដែលអាចអនុវត្តបានបែបនេះប្រហែលជាមិនអាចធ្វើឲ្យមានការពិនិត្យសើរើឡើងវិញតាមលក្ខណៈច្បាប់បានទេ ដោយសារតែរដ្ឋធម្មនុញ្ញចែងថាលក្ខន្តិកៈឧក្រិដ្ឋកម្មត្រូវតែបានស្រាយបំភ្លឺបញ្ជាក់តាមសំណើរបស់ជនដែលត្រូវបានចោទប្រកាន់ ។ គំនិតល្អជាងនេះប្រហែលជាការឲ្យសភាជាតិកម្ពុជាអនុម័តច្បាប់ដើម្បីផ្អាកដំណើរការក្រមព្រហ្មទណ្ឌក្នុងរបបខ្មែរក្រហមនិងផ្តល់

សច្ចាប័នក្រុមព្រហ្មទណ្ឌជាបន្តបន្ទាប់ជាថ្មីឡើងវិញ ។

**បញ្ហាការឲ្យនិយមន័យ**

**មាត្រា៤ៈ អំពើប្រល័យពូជសាសន៍**

ប្រហែលជាមូលហេតុដែលថាអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍តម្រូវឲ្យមានការបញ្ចូលគ្នាតាមរយៈលក្ខន្តិកៈគឺពីព្រោះដោយសារតែនិយមន័យរបស់អនុសញ្ញាមានន័យទូលំទូលាយពេក ហើយដូចដែលអ្នកច្បាប់ជាន់ខ្ពស់បានលើកឡើងដូច្នេះដែរថា កំហុសសំខាន់មុនបង្អស់នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ដែលមិនអាចត្រឡប់ថយក្រោយវិញបានគឺបញ្ហានៃការផ្តោតសំខាន់និងបញ្ហាការឲ្យនិយមន័យ ។ នៅក្នុងការប្រើពាក្យដែលយកពីប្រព័ន្ធច្បាប់និយមន័យនៅក្នុងមាត្រា២និងមាត្រា៣នៃអនុសញ្ញា (និងមាត្រា៤នៃសេចក្តីព្រាងច្បាប់) មានលក្ខណៈមិនច្បាស់លាស់និងទូទៅពេក មានចរិតតាមទំនើងចិត្ត និងមិនដូចគ្នា ព្រមទាំងមិនសមហេតុផលតាមលក្ខន្តិកៈទាំងចំពោះការបង្កើតនិងអនុវត្តន៍ជាក់ស្តែង ។ និយមន័យទាំងនេះជាការរំលោភដល់នីតិវិធីត្រឹមត្រូវតាមច្បាប់ និងមិនអាចប្រឈមមុខចំពោះអធិការកិច្ចតាមផ្លូវច្បាប់ពីសំណាក់តុលាការត្រឹមត្រូវណាមួយឡើយ ។ ក្នុងចរិតជាឧក្រិដ្ឋកម្ម ក) "ការសម្លាប់សមាជិកនៃក្រុមមួយ" មិនអាចឲ្យមានការការពារ ។ ខ) "ការបង្កការឈឺចាប់និងខូចខាតយ៉ាងធ្ងន់ធ្ងរខាងផ្នែករាងកាយឬសតិបញ្ញាដល់សមាជិកទាំងឡាយនៃក្រុម" មិនបញ្ជាក់ច្បាស់លាស់អំពីកម្រិតប៉ះពាល់ដល់សតិបញ្ញា ឬបែងចែកឲ្យដាច់ថាតើរបួសបែបនេះរួមបញ្ចូលការធ្វើឲ្យវង្វេងស្មារតីខុសពីធម្មជាតិ ។ គ) "ការបង្កឡើងដោយចេតនានូវមហន្តរាយឬការហិនហោចដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្ស ដោយយកម្ចេចបំផ្លិចបំផ្លាញក្រុមទាំងស្រុងឬផ្នែកខ្លះនៃសង្គម" អាចនាំដល់ការចោទប្រកាន់ដែលលើកឡើងដោយក្រុមជនជាតិភាគតិចដែលទទួលផលវិបាកផ្នែកសេដ្ឋកិច្ចដូចជាជីវភាពរស់នៅក្នុងសភាពមិនគួរបើ ឧទាហរណ៍ទ័លក្រ ។ ឃ) "ការដាក់បន្ទុកនូវវិធានការនានាដែលបង្ការមិនឲ្យមានកំណើតទារកនៅក្នុងសង្គម" អាចនាំដល់ការប្តឹងផ្តល់ប្រឆាំងនឹងភ្នាក់ងាររដ្ឋាភិបាលដោយប្រមូលបាននូវការការពារ ឬប្រឆាំងនឹងមន្ត្រីរដ្ឋាភិបាល...ដែលបានអនុញ្ញាតឲ្យមានការពន្លូតកូន ។ ង) "ការយកក្មេងចេញពីសង្គមមួយទៅដាក់ក្នុងសង្គមមួយទៀតដោយបង្ខំ" អាចពាក់ព័ន្ធដល់ការដាក់កុមារនៃជនជាតិភាគតិចដែលគ្មានពំនាក់នៅក្នុងកន្លែងផ្សេងដែលមិនមានសាច់ញាតិបង្កើតរបស់ខ្លួនរស់នៅ"ៈ រ៉ូប៊ីត ហ្រេនឡែនឌ័រ(១៩៨៦) ។

មិនខុសពីអនុសញ្ញានេះទេ សេចក្តីព្រាងច្បាប់មិនបានបញ្ជាក់ច្បាស់អំពីទំហំនៃក្រុមជនរងគ្រោះសំខាន់ៗ នៅក្នុងមាត្រាទី៤ ។ ដូច្នេះសេចក្តីព្រាងច្បាប់អាចលើកឡើងនូវលទ្ធភាពមួយដែលថាជនរងគ្រោះម្នាក់នៃក្រុមរបស់ខ្លួនអាចជាការគ្រប់គ្រាន់ក្នុងការបង្ហាញអំពីការចោទប្រកាន់លើអំពើប្រល័យពូជសាសន៍បាន ។

ដូចអនុសញ្ញានេះដែរសេចក្តីព្រាងច្បាប់នេះបានផ្តួចផ្តើតជានិយមន័យថាអំពើ "ប្រល័យពូជសាសន៍" នៃការឃុបឃិត ការប៉ុនប៉ង និងការចូលដៃដើង ឲ្យពាក្យថា "complicity" ដែលប្រែមកជាខ្មែរថា "ចូលរួម" ហើយប្រែមកជាអង់គ្លេសថា "participation" ជាពាក្យមិនមានន័យផ្នែកច្បាប់ច្បាស់លាស់ឡើយ ។ នេះសបញ្ជាក់ឲ្យឃើញថាអ្នកដែលធ្វើសេចក្តីព្រាងច្បាប់នោះគឺមិនមែនជាអ្នកច្បាប់ ។ "គ្មានទម្រង់ណាមួយនៃអំពើដែលអាចទទួលការផ្តន្ទាទោសមានធាតុផ្សំសំខាន់ទាល់តែសោះ ។ គ្មានសញ្ញាណាមួយទាក់ទងនឹងអ្វីដែលជាការវិភាគតាមក្បួនច្បាប់ដើម្បីធានាដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌពាក់ព័ន្ធនឹងសកម្មភាពដែលលើកយកមកនិយាយខាងលើឡើយ" ។

មិនតែប៉ុណ្ណោះទៀតសោត ការឃុបឃិត ការយល់ព្រម (ប្រព្រឹត្តអំពើខុសច្បាប់) ត្រូវបានរំលាយចោលនៅពេលដែលអំពើនេះត្រូវបានប្រព្រឹត្តដូចជាករណីខ្មែរក្រហម ។ ហើយការឃុបឃិតខ្លួនឯងផ្ទាល់គឺមិនមែនជាបទឧក្រិដ្ឋឡើយ ។ វាជាសេចក្តីព្រាងច្បាប់មិនច្បាស់លាស់ ហើយគ្មានប្រយោជន៍ក្នុងការលើកយកមកនិយាយនៅទីនេះ ពីព្រោះមានចែងនៅក្នុងមាត្រាទី២៩រួចហើយ ។ កង្វះខាតផ្នែកនិយមន័យក៏អាចបណ្តាលឲ្យមានការចោទប្រកាន់ពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមដែលកំពុងត្រូវបានលើកលែងឈប់ប្តឹងដោយសារនៅក្នុងអនុសញ្ញាដូចដែលបានលើកឡើងដោយលោកស៊ីហ្វាន ម៉ាក្ស ថា ការសម្លាប់ក្រុមមួយនៃជនជាតិរបស់ខ្លួនឧទាហរណ៍ខ្មែរសម្លាប់ខ្មែរមិនមែនជាអំពើប្រល័យពូជសាសន៍

ឡើយ ។ ច្បាស់ជាងនេះទៅទៀត ខ្មែរក្រហមមិនបានប្រព្រឹត្ត អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងប្រជាជនខ្មែរទេ ទោះបីជាអ្វីដែលខ្មែរក្រហមបានប្រព្រឹត្តអាចជាបទឧក្រិដ្ឋកម្មសង្គ្រាមឬឧក្រិដ្ឋកម្មផ្សេងៗទៀតនៅក្រោមច្បាប់អន្តរជាតិ ។

លើសពីនេះទៀត ការចោទប្រកាន់ប្រឆាំងនឹងខ្មែរក្រហមចំពោះអំពើកាប់សម្លាប់ក្រុមជនជាតិភាគតិច អាចមិនត្រូវបានបង្ហាញឲ្យបានច្បាស់លាស់ដោយហេតុផលដូចតទៅនេះៈ ក) គ្មានឃើញនយោបាយជាលក្ខណៈរដ្ឋក្នុងការកម្ចាត់ជនជាតិភាគតិច ។ បទបញ្ញារបស់ខ្មែរក្រហមដែលចេញនៅក្នុងឆ្នាំ១៩៧៦ ទាក់ទងនឹងជនជាតិភាគតិចអាចក្លាយជាភ័ស្តុតាងតិចតួចស្តួចស្តើងណាស់ប្រឆាំងនឹងខ្មែរក្រហម ។ ខ) ភាគច្រើននៃមេដឹកនាំខ្មែរក្រហមធាតុពិតកើតចេញពីក្រុមជនជាតិភាគតិចទាំងនេះឯង ។ ឧទាហរណ៍ អៀង សារី និង សុន សេន គឺជាជាតិពន្ធចិនកាត់វៀតណាម ។ ប៉ុល ពត តាម៉ុក និង ខៀវ សំផន ហើយអាចរួមទាំង ឌុច ដែលជាប្រធានគុកទួលស្លែងផងជាជាតិពន្ធចិន ។ ជួន ប្រាសិទ្ធិ ក៏ជាជាតិពន្ធវៀតណាមដែរ ។ ជីដូនជីតារបស់ ជួន ប្រាសិទ្ធិ គឺមានដើមជាជនជាតិវៀតណាមសុទ្ធសាធតែម្តង ។

ភ័ស្តុតាងក៏បញ្ជាក់ថាជនជាតិចាមក៏បានចូលរួមចំណែកក្នុងការធ្វើទារុណកម្មនិងការកាប់សម្លាប់ប្រជាជនដែរ ឧទាហរណ៍ អ្នកធ្វើទារុណកម្មឃោរឃៅគ្មានក្តីមេត្តានៅគុកទួលស្លែងគឺជាជនជាតិចាមដែលមានឈ្មោះថា ស៊ឹម ម៉េល (យោងតាមការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ។ ម៉ាត់ លី ដែលជាជនជាតិចាមម្នាក់ទៀត (ដែលឥឡូវនេះជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សនៃគណបក្សប្រជាជន) ក៏ធ្លាប់ជាកម្មាភិបាលជាន់ខ្ពស់របស់ខ្មែរក្រហមដែរ ។ ខ្មែរលើម្នាក់ឈ្មោះ សារ៉ន ដែលក្លាយជាកូនចិញ្ចឹមរបស់ ប៉ុល ពត បន្ទាប់ពីឈ្មោះ កុំ គឺជាកម្មាភិបាលម្នាក់ដែលទទួលខុសត្រូវនៅ ប-៣០ ឬមណ្ឌលអប់រំកសាងខ្លួនបឹងត្របែក ដែលនៅទីនោះមានអ្នកត្រឡប់មកពីបរទេសវិញចំនួនប្រហែល១ពាន់នាក់ ។ ហើយក្នុងចំនួននេះមានតែ២៥០នាក់ប៉ុណ្ណោះដែលរួចពីសេចក្តីស្លាប់ ។ អ៊ី ឈាន ដែលសព្វថ្ងៃជាអភិបាលក្រុងប៉ៃលិនក៏ជាខ្មែរលើ (ចារ៉ាយ) ។ ឧត្តមសេនីយ៍ ប៊ូ ថង ក៏ជាខ្មែរលើ (ទំពួន) ។ ឧត្តមសេនីយ៍ ស៊ីយ កែវ គឺជាជនជាតិឡាវ ។ ឯកឧត្តម សាយ ភូថង ជាជនជាតិថៃ ។ នី កន ក៏ជាជនជាតិខ្មែរកាត់ចិន ។

## មាត្រា៥ៈ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

ប្រការនេះនៅក្នុងសេចក្តីព្រាងច្បាប់ខ្មែរក្រហមមានលក្ខណៈអន់ជាងប្រការដែលចែងពីអំពើប្រល័យពូជសាសន៍ទៅទៀត ដោយសារតែភាពមានន័យមិនច្បាស់លាស់របស់វា ។ គ្មានអ្នកណាដឹងថា តើអ្នកធ្វើច្បាប់យោងតាមគោលការណ៍ច្បាប់អន្តរជាតិណាមួយឡើយ ។ ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅតែមិនទាន់ត្រូវបានដោះស្រាយស្រេចបាច់ភាគច្រើននៅឡើយ ទទាក់ទងនឹងទំនាក់ទំនងជាមួយនឹងសង្គ្រាម ហើយនិងធាតុជំរុញ ។ បើគ្មានការឲ្យនិយមន័យឲ្យច្បាស់លាស់ទេនោះ ដំណើរការជម្រះក្តីពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនឹងមិនផ្តល់ជាលទ្ធផលដែលប្រកបដោយយុត្តិធម៌ចំពោះជនរងគ្រោះឡើយ ហើយជាថ្មីម្តងទៀត នឹងធ្វើឲ្យចុងចោទដើរហើរដោយសេរីដោយសារតែភាពមានន័យមិនច្បាស់លាស់ឬការលំបាកក្នុងដំណើរនីតិវិធី ។

មានការខុសប្លែកគ្នារវាងសេចក្តីព្រាងច្បាប់ជាភាសាខ្មែរនិងជាភាសាអង់គ្លេស ។ ក្នុងសេចក្តីព្រាងច្បាប់ជាភាសាខ្មែរ "ធ្វើមនុស្សឃាត" មានន័យថា "Manslaughter" ប៉ុន្តែនៅក្នុងភាសាអង់គ្លេសសរសេរថា "Murder" ។ នៅក្នុងច្បាប់អ៊ុនតាក់របស់ប្រទេសកម្ពុជា ពាក្យថា "សម្លាប់មនុស្ស" ត្រូវបានចែកចេញជាបីផ្នែកៈ ១) ឃាតកម្ម ២) មនុស្សឃាតដោយចេតនា និង ៣) មនុស្សឃាតដោយអចេតនា ។ វាមិនមានអ្វីគួឲ្យច្បាស់លាស់ថាតើអ្នកព្រាងច្បាប់យកទង្វើទី២ឬទី៣ ។ ប៉ុន្តែជាការច្បាស់ណាស់ថា អ្នកព្រាងច្បាប់ចង់និយាយទង្វើមួយក្នុងចំណោមទង្វើទាំងពីរនេះ ។ ប្រសិនជាដូច្នេះមែន អំពើមនុស្សឃាតមិនមែនជាមនុស្សឃាតក្រោមប្រការនេះឡើយ ។ នេះជារឿងគួរឲ្យចង់សើច ។ វាមិនមែនជាការបំផ្លើសទេក្នុងការនិយាយថាអ្នកព្រាងច្បាប់នេះថែមទាំងមិនចេះច្បាប់ និងមិនចេះភាសាអង់គ្លេសច្បាស់លាស់ត្រឹមត្រូវទៀតផង ។ ការបកប្រែច្បាប់ឧក្រិដ្ឋកម្មពីភាសាអង់គ្លេសមកខ្មែរ គឺមិនមានលក្ខណៈច្បាស់លាស់ពិតប្រាកដស្មើរតែជាភាសារបស់កូនក្មេង ដែលជាការបង្កើតឲ្យមានការខុស

ប្លែកគ្នាគួរឲ្យគ្រោះថ្នាក់ ។

មាត្រានេះមិនមាននិយាយអំពីឧក្រិដ្ឋកម្មនៃការបង្ខំឲ្យធ្វើពលកម្មដូចដែលជូនជាយោបល់ដោយអ្នកជំនាញការអង្គការសហប្រជាជាតិនោះទេ ។ អំពើទាសភាពមានធាតុផ្សំខុសគ្នាច្រើនពីធាតុផ្សំនៃការបង្ខំឲ្យធ្វើពលកម្ម ។ ចំណុចនេះអាចត្រូវបានយកមកទាញហេតុផលថា ការបង្ខំឲ្យធ្វើពលកម្មនៅក្នុងសម័យខ្មែរក្រហមមិនអាចបង្កើតជាអំពើទាសភាពទេ ដោយសារតែផលិតផលកសិកម្មនិងផលិតផលទូទៅដែលចេញពីកម្លាំងពលកម្ម (យ៉ាងហោចណាស់ក៏ជាទ្រឹស្តីដែរ) ជារបស់ប្រជាជនជាមូហភាព ។

ការខកខានមិនបញ្ចូលឧក្រិដ្ឋកម្មនៃការបង្ខំឲ្យធ្វើពលកម្មអាចជាចេតនារបស់អ្នកចរចារបស់កម្ពុជាដើម្បីចៀសវាងកុំឲ្យមានការពាក់ព័ន្ធដល់ផែនការ "ក-៥" ដែលត្រូវបានផ្តើមធ្វើឡើងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

មាត្រាទី៦ មាត្រាទី៧ និងមាត្រាទី៨ នៃសេចក្តីព្រាងច្បាប់រឹងរឹតតែមិនមានន័យច្បាស់លាស់ទៅទៀត ។ មាត្រាបីនេះគឺទាក់ទងទៅនឹងសន្ធិសញ្ញាអន្តរជាតិដែលក្នុងនោះចៅក្រមកម្ពុជាដែលកំពុងធ្វើការសព្វថ្ងៃមិនមានយោបល់អ្វីទាំងអស់ ។

### មាត្រា២៩៖ ការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ

គោលបំណងនៃមាត្រានេះគឺហាក់ដូចជាចង់គ្របចំណុច "ការចូលរួម" ។ ដូច្នេះមាត្រានេះពាក់ព័ន្ធទៅដល់មាត្រា៤ដែលនិយាយអំពី"ការចូលរួមក្នុងអំពើប្រល័យពូជសាសន៍" ។ ការចូលរួមខ្លួនឯងផ្ទាល់គឺពុំមែនជាឧក្រិដ្ឋកម្មក្រោមច្បាប់របស់ប្រទេសកម្ពុជាឡើយ ។ ប៉ុន្តែការចូលរួមពង្រីកការទទួលខុសត្រូវ ។ ការដាក់ពាក្យ "ផែនការ" ចូលនៅទីនេះ ក៏មិនមានលក្ខណៈច្បាស់លាស់តាមផ្លូវច្បាប់ដែរ ។ តើវាមានន័យថាអ្នកព្រាងច្បាប់ចង់ធ្វើ "ការគ្រោងផែនការ" ឲ្យក្លាយជាបទឧក្រិដ្ឋឬ? ។ ពាក្យថា "ការដាក់ផែនការ" នៅក្នុងច្បាប់ មិនមានស្ថិតក្នុងការចូលរួមទេ ហើយពាក្យនេះមិនមានលក្ខណៈច្បាស់លាស់ទៀតផង ។

នៅក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះអំពើមួយ ឧទាហរណ៍អំពើឃាតកម្ម ដើម្បីឲ្យអំពើនេះក្លាយជាអំពើឧក្រិដ្ឋកម្មបានលុះត្រាតែអំពើនោះយ៉ាងហោចណាស់ឈានដល់ដំណាក់កាលទីបីក្នុងដំណាក់កាលទាំងបួនដូចដែលរៀបរាប់ខាងក្រោម÷ ១) ចេតនា ២) ការរៀបចំ (គម្រោងការ) ៣) ការចាប់ផ្តើមសកម្មភាព និង ៤) ការសម្រេចលទ្ធផល ។ អំពើនៅក្នុងដំណាក់កាលទី១និងទី២មិនអាចបង្កើតបានជាឧក្រិដ្ឋកម្មឡើយ ។ ក៏ប៉ុន្តែពេលដែលអំពើមួយឈានដល់ដំណាក់កាលទី៣ ឧទាហរណ៍ពេលដែលអំពើខុសច្បាប់ត្រូវបានចាប់ផ្តើមហើយប៉ុន្តែមិនបានសម្រេចតាមគោលដៅដែលប៉ងទុក វានឹងក្លាយជា "ការប៉ុនប៉ង" ។ នៅដំណាក់កាលទី៤ ប្រសិនបើអំពើនោះត្រូវបានសម្រេចនោះ វានឹងក្លាយជា "ឃាតកម្ម" ។ ដូច្នេះវានៅតែមិនច្បាស់ថាតើអ្នកព្រាងច្បាប់ចង់មានន័យយ៉ាងដូចម្តេចចំពោះពាក្យថា "ផែនការ" ។ ជាផលវិបាកតើនៅក្នុងច្បាប់ពាក្យថា "ការដាក់ផែនការ"សំដៅទៅលើអ្វី?

ដូចដែលបានរៀបរាប់ជូនខាងលើ សេចក្តីព្រាងច្បាប់នៅក្នុងទម្រង់សព្វថ្ងៃនេះគឺនៅមានកង្វះខាត ។ សេចក្តីព្រាងច្បាប់នេះមិនបានចែងអំពីការការពារខ្លួនតាមផ្លូវច្បាប់ជាមូលដ្ឋានទេ ហើយស្ថានភាពសម្រាលទោសក៏ទេដែរ ទោះបីជាមានការឲ្យយោបល់ពីអ្នកជំនាញការច្បាប់របស់អង្គការសហប្រជាជាតិថាការការពារខ្លួនគួរតែត្រូវបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់នេះ ។ តើអ្វីនឹងកើតឡើងចំពោះអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលតាមរយៈអំពើទាំងនេះអ្នកប្រព្រឹត្តត្រូវបានចោទប្រកាន់ ប៉ុន្តែអ្នកដែលមានជំងឺវិកលចរិតត្រូវទទួលរងការបង្ខំ និង(ឬ)មិនដឹងទាល់តែសោះថាវាជានយោបាយរបស់រដ្ឋនៅសម័យនោះ ជាពិសេសអ្នកដែលបានប្រព្រឹត្តបទល្មើសស្រាល(ឧបមាថាអ្នកប្រព្រឹត្តមានអាយុ១២ឆ្នាំ) ដែលប្រហែលជាត្រូវបានដុសខាត់ស្មារតីឲ្យជឿជាក់ថាការសម្លាប់ជាការធម្មតាក្នុងជីវភាពរស់នៅព្រមទាំងឲ្យជឿជាក់លើកាតព្វកិច្ចរដ្ឋ? ចំពោះបញ្ហានេះ សេចក្តីព្រាងច្បាប់នេះផ្ទុយទៅនឹងគោលការណ៍យុត្តិធម៌ទាំងអស់ ។

### ផ្នែកទី៣៦៖ ការប្តឹងឧទ្ធរណ៍ដោយជនជាប់ចោទ ជនរងគ្រោះនិងព្រះរាជអាជ្ញា

ការអនុញ្ញាតឲ្យជនជាប់ចោទប្តឹងឧទ្ធរណ៍អាចទទួលយកបានដោយស្របច្បាប់ត្រឹមកម្រិតណាមួយ ប៉ុន្តែការអនុញ្ញាតឲ្យជនរងគ្រោះនិងព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ដោយផ្អែកលើកំហុសអង្គហេតុនិងច្បាប់ ជាការរំលោភដល់គោលការណ៍នៃការប្រឈមមុខនឹងការកាត់ទោសពីរដង ដូចដែលបានចែងនៅក្នុងកតិកា

ស្តីអំពីសិទ្ធិស៊ីវិលនិងនយោបាយដែលក្នុងនោះប្រទេសកម្ពុជាជាភាគីក្នុងកិច្ចសន្យានោះដែរ ។

**មាត្រាទី៤០៖ ការគ្រាប្រណីទោស និង ការលើកលែងទោស**

ពាក្យទាំងពីរនេះមិនទាន់ត្រូវបានឲ្យនិយមន័យច្បាស់លាស់ទេ ដូច្នេះឥទ្ធិពលឬទម្ងន់របស់ពាក្យនេះមិនទាន់មានអ្នកណាដឹងច្បាស់នៅឡើយដែរ ។ ពាក្យថា «លើកលែងទោស» ដែលហៅជាភាសាអង់គ្លេសថា "pardon" និង «គ្រាប្រណីទោស» ដែលហៅជាភាសាអង់គ្លេសថា "amnesty" នៅក្នុងន័យច្បាប់គឺមិនត្រឹមត្រូវទេ ដោយសារពាក្យទាំងពីរនេះ «លើកលែងទោស និង គ្រាប្រណីទោស» ជាពាក្យដែលមានសទិសន័យតែមួយក្នុងភាសាខ្មែរ ។ ប៉ុន្តែពាក្យ "pardon and amnesty" មានអត្ថន័យខុសគ្នានៅក្នុងផ្លូវច្បាប់ ។ ពាក្យថា "pardon" គឺត្រូវបានប្រើប្រាស់ក្រោយការចេញសាលក្រមបញ្ជាក់ពីពិរុទ្ធភាព ប៉ុន្តែពាក្យ "amnesty" គឺត្រូវបានប្រើប្រាស់មុនពេលចេញសាលក្រមបញ្ជាក់ពីពិរុទ្ធភាព ។ ពាក្យខ្មែរដែលប្រើសម្រាប់ពាក្យ "amnesty" ឲ្យត្រឹមត្រូវគឺ «និរទោសកម្ម» ។ មិនតែប៉ុណ្ណោះទៀតសោត មានការខុសប្លែកពីគ្នាដ៏ធំមួយរវាងសេចក្តីព្រាងច្បាប់ជាភាសាអង់គ្លេសនិងភាសាខ្មែរ ។ នៅក្នុងភាសាអង់គ្លេសមានន័យ(អាន)ថា «រាជរដ្ឋាភិបាលកម្ពុជាមិនអាចស្នើសុំឲ្យមានការលើកលែងទោសនិងគ្រាប្រណីទោស "amnesty ឬ pardon" ដល់ជនណាម្នាក់ដែលអាចត្រូវបានស៊ើបអង្កេត ឬជាប់ចោទពីបទឧក្រិដ្ឋណាមួយ...» ។ នៅក្នុងភាសាអង់គ្លេសមានការបញ្ជាក់ច្បាស់ថា ទាំងការលើកលែងទោសប្រើក្រោយការចេញសាលក្រមបញ្ជាក់ពីពិរុទ្ធភាព និងការលើកលែងទោសប្រើមុនពេលចេញសាលក្រមបញ្ជាក់ពីពិរុទ្ធភាពគឺមិនអនុញ្ញាតឲ្យប្រើឡើយ ។ ក៏ប៉ុន្តែនៅក្នុងភាសាខ្មែរវិញបានបកប្រែចេញថា «**រាជរដ្ឋាភិបាលកម្ពុជាមិនអាចស្នើសុំឲ្យមានការលើកលែងទោសដល់ទណ្ឌិតណាមួយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានចែងក្នុងមាត្រា៣ ៤ ៥ ៦ ៧ និង ៨ នៃច្បាប់នេះបានឡើយ**» ។ នេះជាការបើកផ្លូវឲ្យមានការគ្រាប្រណីទោសមុនពេលចេញសាលក្រមបញ្ជាក់ពីពិរុទ្ធភាពដោយរដ្ឋាភិបាលកម្ពុជា ។

សរុបមក បញ្ហាដែលច្បាស់លាស់នៅក្នុងសេចក្តីព្រាងច្បាប់មានតែមួយ គឺការកាន់កាប់យ៉ាងម៉ឺងរបស់កម្ពុជានៅក្នុងដំណើរការតុលាការ ។ គ្មានអ្នកណាម្នាក់ភ្ញាក់ផ្អើលឡើយនៅពេលដែលវៀតណាមនិងបរទេសផ្សេងទៀតជួយជ្រោមជ្រែងបង្កើតការ «ជំនុំជម្រះក្តីតាមវិធាននយោបាយមិនមែនដើម្បីយុត្តិធម៌» នៅក្នុងឆ្នាំ១៩៧៩ ដើម្បីវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម ។ ប៉ុន្តែជាការសោកស្តាយជំនួសជនរងគ្រោះរបស់ខ្មែរក្រហមរាប់លាននាក់ដែលអង្គការសហប្រជាជាតិដើរតាមផ្លូវដដែលជាមួយនឹងរបបមួយដែលពោរពេញដោយការរួចទោសនិងការអត់ឱនចំពោះឃាតកម្មលើប្រជាជនខ្លួនឯង ។ ប្រជាជនកម្ពុជាត្រូវការយុត្តិធម៌ ក៏ប៉ុន្តែក្នុងការបង្កើតឲ្យមានតុលាការខ្មែរក្រហមមួយទោះជាត្រូវតែចំណាយអ្វីក៏ដោយនិងតាមវិធាននៃច្បាប់និងយុត្តិធម៌ពិតប្រាកដនោះមិនមែនជាចម្លើយទេ ។ ប្រជាជនកម្ពុជាសមតែទទួលបានទាំងអស់ឬក៏គ្មានទាល់តែសោះ ។ អង្គការសហប្រជាជាតិមិនគួរសម្របសម្រួលបទដ្ឋាននៃច្បាប់អន្តរជាតិនិងសិទ្ធិមនុស្សឡើយ ។

◆ កុំឱ្យឃាតករសម្លាប់យើង២ដង ទី១គឺសម្លាប់រូបរាងកាយយើង ទី២គឺសម្លាប់ការចងចាំរបស់យើង។

*Elie Wiezel*

*ជ័យលាភីណូបែលសន្តិភាព*

◆គ្រូវយកការខារធ្វើគ្រូ តែកុំធ្វើគ្រូការខារឱ្យសោះ។

*(យុវជននិងយុវនារីបដិវត្តន៍ លេខ ខែកុម្ភៈ ឆ្នាំ១៩៧៤)*

**ពាក្យស្លោកប្រចាំឆ្នាំ១៩៧៧**

◆វាយសំរុកខ្លាំងក្លាបំផុត ជាប់ជានិច្ច ដោយចលនាមហាជន មហាលោតផ្លោះ មហាអស្ចារ្យ។

◆បក្សស្អាតគឺបក្សខ្លាំង ចលនាបដិវត្តខ្លាំង។

◆មជ្ឈិមបក្សស្អាត មជ្ឈិមបក្សខ្លាំង ដឹកនាំចលនាបដិវត្តទូទាំងប្រទេសខ្លាំង។

*(ដកស្រង់ពីទង់បដិវត្តន៍ លេខ៦ ខែមិថុនា ឆ្នាំ១៩៧៧)*

# សៀវភៅកំណត់ហេតុជីវិត

***(តពីលេខមុន)  ម័រហ្គាត  ថ្ងៃទី១៩  ខែសីហា  ឆ្នាំ១៩៧៥***

ជូ អ៊ី មានថ្ងៃខ្លះខ្ញុំសែននឹកបងណាស់ ថ្ងៃដែលខ្ញុំដើរលេង នៅរុយអ៊ីមហ្រ្វែតម្នាក់ឯងគត់តាមដងស្ទឹងអូលដេស ខ្ញុំសែន នឹកទៅបងណាស់ បើសិនជាយើងបានដើរលេងទាំងអស់គ្នា មិនដឹងជាសប្បាយយ៉ាងណាទេ? តើសព្វថ្ងៃបងនៅឯណា? សុខទុក្ខយ៉ាងណា? ធ្វើអ្វីណ៎? ខ្ញុំមិនអាចទាយឬស្មានត្រូវសោះ? ខ្ញុំតែងគិតទៅបងរាល់ពេលរាល់វេលាឥតដែលខាន តើបងវិញ មាននឹកមកខ្ញុំឬទេ? ចិត្តដែលស្រឡាញ់បងនៅតែដដែល ខ្ញុំតែងតែ គិតជានិច្ចថាខ្ញុំស្រឡាញ់តែបងម្នាក់គត់ ទោះបីខ្ញុំមិនសង្ឃឹមថា បានជួបបងក៏ដោយ តើហេតុអ្វីទើបខ្ញុំជាប់ចិត្តលើបងខ្លាំងម្ល៉េះ ។ តើបងមានស្រឡាញ់ខ្ញុំដូចខ្ញុំស្រឡាញ់បងឬទេ? ស្តាយណាស់ យើងបែកគ្នាជាលើកទី៦ ដោយឥតបានលាគ្នាមួយម៉ាត់សោះ ឱ! គួរឲ្យស្តាយណាស់មែនទេ? ។ ពេលឮថាស្រុកយើងឈប់ច្បាំង ខ្ញុំចង់តែត្រឡប់ទៅវិញភ្លាមទេ គ្មានចង់នៅស្រុកអាបារាំងស្អីគេ នេះទេ ។ បាត់ដំណឹងបងសូន្យ ខ្ញុំសែនពិបាកគិតពិបាកយល់ ណាស់ ។ តើបងនៅទីណា? ទីណា? តើអ៊ីអាចប្រាប់ខ្ញុំបាន ឬទេ? ឱ! លោកអើយហេតុអ្វីក៏ដូច្នេះ ។ មានតែការព្រាត់ប្រាស មួយចប់ ។



រមណីយដ្ឋានជាប្រភពនៃសុភមង្គល ។ មាតុភូមិរបស់ខ្ញុំដ៏សុខដុមរម្យទាណាស់ ព្រោះក្នុងភូមិនីមួយៗប្រកបទៅដោយទិដ្ឋភាពនិងទស្សនីយភាពសែនមនោរម្យ ។ ខ្ញុំចង់រស់នៅក្នុងលំនៅស្ថានដែលប្រកបដោយសួនច្បារនិងដំណាំគ្រប់យ៉ាងនេះណាស់ ។

***ម័រហ្គាត  ថ្ងៃទី៧  ខែកញ្ញា  ឆ្នាំ១៩៧៥***

ឱស្រុកកំណើតអើយ! តើថ្ងៃណាខ្ញុំបានវិលត្រឡប់ទៅវិញ? តើពេលណាខ្ញុំបានជួបជុំគ្រួសារ? តើអ្នកម្តាយជាទីស្រឡាញ់ នៅឯណាឥឡូវនេះ កូនតែងនឹកលោកទាំងពីរណាស់ ចិត្តគិត ខ្វល់ខ្វាយគ្មានរសាយ ។ ចិត្តចង់តែត្រឡប់ទៅវិញទៅវិញដើម្បី បានយល់ច្បាស់នូវសុខទុក្ខរបស់លោកទាំងពីរជាទីគោរព និងបានចូលរួមចំណែកក្នុងការកសាងកម្ពុជាថ្មី រូបខ្ញុំដែលប្រទេស ខ្មែរជាអ្នកថ្មែ ខ្ញុំត្រូវតែបម្រើប្រយោជន៍ខ្មែរ កម្លាំងពលំដែលខ្ញុំ

បានមកពីការផ្តល់ចំណីអាហារនៃប្រទេសខ្មែរជាទីស្រឡាញ់ ខ្ញុំត្រូវតែដឹងគុណអ្នក ដៃខ្ញុំ កម្លាំងខ្ញុំ បញ្ញាខ្ញុំ ត្រូវតែជួយជ្រោមជ្រែងអ្នកវិញ ។ ខ្ញុំត្រឡប់ទៅវិញឲ្យបានឆាប់មិនមែនដើម្បីជួប Y ទេ មិនមែនដោយសេចក្តីស្នេហាទេ ដែលខ្ញុំត្រឡប់ មនសិការស្នេហាជាតិលាន់រណ្តំក្នុងគំនិតខ្ញុំមិនអាចឲ្យខ្ញុំរស់នៅស្រុកនេះយូរទេ គ្មានបានប្រយោជន៍អ្វីទេ ការបង្អឹកយូរទៅរឹតតែខាត ។ ទោះជាយ៉ាងណាលំបាកម្តេចម្តាខ្ញុំត្រូវតែត្រឡប់ទៅវិញឲ្យឃើញច្បាស់នឹងភ្នែកនូវព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងស្រុកជាទីស្រឡាញ់ ។ ឱជីវិត! តើមានប្រយោជន៍អ្វីខ្លះទៅ? តើខ្ញុំមួយអាចជួយជាអ្វីខ្លះដល់ស្រុកខ្មែរដ៏តូចនេះ ។

**ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៧៥**

ឱ! ទឹកសមុទ្រខៀវស្រងាត់ មើលទៅរលករត់រមេញប្រដេញគ្នាបោកមកលើច្រាំងខ្សាច់និងលើផ្ទាំងសិលាលាន់ឮរំពង ដូចបានជាសំឡេងតន្ត្រីធម្មជាតិមួយដ៏សែនពីរោះ ឱទឹករលក! អ្នកបោកខ្លួនគ្រាំគ្រែងហាក់មានកំហឹងនឹងអ្នកណាម្នាក់ តើមែនឬទេ? ធាតុអាកាសត្រជាក់រហ៊ឹមនៃខែកញ្ញាក្រោមពន្លឺព្រះអាទិត្យចាំងថែង ធ្វើឲ្យខ្ញុំមានចិត្តគិតនឹកថាថ្ងៃណាមួយខ្ញុំនឹងបានជួបធាតុអាកាសនេះម្តងទៀត ។ ខ្ញុំជាប់ចិត្តស្រឡាញ់ទឹកសមុទ្រណាស់ ទេសភាពសមុទ្រធ្វើឲ្យចិត្តខ្ញុំទូលំទូលាយដូចផ្ទៃជលសា ។ ថ្វីត្បិតតែមានថ្ងៃ តែអាកាសធាតុនៅតែត្រជាក់គួរដែរ ។ ឃើញទឹកសមុទ្រខ្ញុំនឹកដល់ស្រុកកំណើត នឹកដល់មិត្តម្នាក់ដែលជាអ្នកនៅស្រុកសមុទ្រដែលតែងនិយាយថាៈ យកដៃក្បង់ទឹកសមុទ្រដើម្បីលុបមុខបំភ្លេចទុក្ខព្រួយ ខ្ញុំខំយកដៃទៅក្បង់ទឹកសមុទ្រមកលុបមុខ តែទុក្ខព្រួយទាំងប៉ុន្មានរបស់ខ្ញុំនៅតែដដែល ។ ខ្ញុំខំបំភ្លេចរឿងរ៉ាវទាំងឡាយដែលមានក្នុងគំនិតខ្ញុំ តែវាមិនអាចលុបរលាយទៅបានសោះ ។ ឱ! ជីវិតស្គាល់តែទុក្ខ ស្គាល់តែការព្រាត់ប្រាស់និរាសខ្មោចផ្សារមិនចេះចប់ ប្រៀបដូចរលកដែលប្រដេញគ្នាមិនចេះដាច់ដូច្នេះដែរ ។ ឱសមុទ្រអើយ! បើសិនជាអ្នកចេះនិយាយ ខ្ញុំនឹងសាស័ព្ទជាមួយអ្នកនូវទុក្ខកង្វល់របស់ខ្ញុំដើម្បីឲ្យបានធូរទ្រូង ។ បញ្ហាដែលចោទក្នុងខួរក្បាលខ្ញុំមានរយដំពូក មានបញ្ហាជាតិ បញ្ហាគ្រួសារ បញ្ហាក្រពះ បញ្ហាការរៀនសូត្រ បញ្ហាកិច្ចការ ឱ! មួយម៉ឺនបញ្ហា បញ្ហាមិនចេះចប់ ។ ចិត្តមួយគិតថាត្រូវតែត្រឡប់ទៅវិញជួយធ្វើការបម្រើជាតិ រកជួបជុំឪពុកម្តាយជាទីស្រឡាញ់ តែបញ្ហាជាតិនេះវាធ្វើឲ្យខ្ញុំពិបាកយល់ឲ្យបានច្បាស់ពិតប្រាកដទៅទៀត អ្វីៗឋិតនៅក្នុងភាពស្រពេចស្រពិលទាំងអស់ ទាំងនេះហើយដែលធ្វើឲ្យខ្ញុំពិបាកគិត ពិបាកសម្រេចថាត្រូវធ្វើដូចម្តេច ។ គេទាំងអស់គ្នាតែងឃាត់កុំឲ្យខ្ញុំត្រឡប់ទៅវិញ? តើនៅទីនេះធ្វើអ្វី ស៊ីឈ្នួលបារាំង! នេះហើយគឺជាបញ្ហា ខ្ញុំជាកូនខ្មែរត្រូវតែបម្រើជាតិខ្មែរ ព្រោះខ្មែរជាអ្នកចិញ្ចឹមខ្ញុំ ខ្ញុំត្រូវតែសងគុណអ្នក ។ ម៉ែជាទីគោរពស្រឡាញ់តែមួយត្រូវតែទៅជួប ឪពុកជាទីគោរពជាទីស្រឡាញ់តែមួយក៏ត្រូវតែទៅជួប ដូច្នេះហើយបានជាហាក់សម្រេចចិត្តមួយថាខ្ញុំត្រូវត្រឡប់ទៅវិញ ត្រឡប់ទៅវិញ ទោះលំបាកម្តេចម្តាក៏ដោយកាយា កុំឲ្យតែពិបាកចិត្ត នោះខ្ញុំពិតជារស់បានប្រសើរជាងនៅស្រុកនេះដែលស្គាល់តែការព្រួយមិនចេះចប់ ។ មានលុយ មានរបស់ញ៉ាំ អាចដើរលេងបានតាមចិត្ត តែខាងផ្លូវចិត្តវិញគឺគ្មានជាស្រួលសោះ ដូច្នេះខ្ញុំត្រូវតែត្រឡប់ទៅវិញ ។ សូមសមុទ្រមេត្តានាំវាចាខ្ញុំទាំងប៉ុន្មាននេះទៅប្រាប់មិត្តទាំងអស់នៅស្រុកខ្ញុំថា ខ្ញុំនឹងត្រឡប់ទៅវិញជាមិនខានណ៎ា ។**(នៅមានត)**



ម្ចាស់រូបគំនូរខាងលើ អាយុ១១ឆ្នាំ

សូមសរសេរលិខិត

ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក

**ទស្សនាវដ្តី "ស្វែងរកការពិត"**

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

ឬ Email: dccam@bigpond.com.kh

## សភាជាតិអនុម័តសេចក្តីព្រាងច្បាប់ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម

# វិនិច្ឆ័យអតីតកាល
# ដើម្បីយុត្តិធម៌ និង ការចងចាំ




កំណត់ហេតុស្តីអំពីអង្គប្រជុំរបស់សភាជាតិនៃព្រះរាជាណាចក្រកម្ពុជាលើ
សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

# យុត្តិធម៌កំពុងតែត្រូវបានស្វែងរក

នៅទីបញ្ចប់ប្រជាជនកម្ពុជា ជាពិសេសជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ បានស៊ូទ្រាំរស់នៅរហូតដល់ថ្ងៃដែលខ្លួនបានពុទ្ធិងឃើញកិច្ចពិភាក្សាដេញដោលលើច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះក្តីវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ ។ ប្រធានក្រុមចរចារបស់រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាបានបំពេញកាតព្វកិច្ចខ្លួនសម្រាប់ប្រទេសកម្ពុជា ។ ចំណែកឯអង្គការសហប្រជាជាតិក៏ដូច្នេះដែរ ។ នៅពេលទន្ទឹមគ្នានេះ ខ្ញុំសូមបន្ថែមចំណុចពីរដែលជាគន្លឹះដ៏សំខាន់នៅក្នុងព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ ។

ចំណុចទី១គឺតួនាទីរបស់ប្រជាជនកម្ពុជាទាំងមូលនិងអង្គការនានា ។ ប្រជាជនកម្ពុជាដែលបានរង់ចាំអស់រយៈពេល២០ឆ្នាំមកហើយនោះរួមជាមួយនិងអង្គការនានាបានបញ្ជាក់ដល់រាជរដ្ឋាភិបាលកម្ពុជាថា ***ក្រៅពីយុត្តិធម៌ដ៏ពេញលេញមួយគឺជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យមិនអាចទទួលយកបានឡើយ*** ។ បច្ចុប្បន្ននេះ មិនមែនត្រឹមតែសហគមន៍អន្តរជាតិតែប៉ុណ្ណោះទេដែលបានជួយជំរុញឲ្យមានយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា សូម្បីតែការគាបសង្កត់ក្នុងស្រុកនិងប្រព័ន្ធឃោសនាដែលបានផ្តោតអត្តិភាពទៅលើព្រឹត្តិការណ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានការកើនឡើងជាងពេលណាៗទាំងអស់ ។ ចំណុចទី២គឺតួនាទីរបស់សភាជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលស្ថិតនៅក្នុងដំហរមួយកម្រមាន ។ សភាជាតិបានសុំយោបល់មតិសាធារណៈអំពីសេចក្តីព្រាងច្បាប់ដែលបានដាក់ជូនដោយរាជរដ្ឋាភិបាលកម្ពុជាកាលពីខែមករា ឆ្នាំ២០០០កន្លងទៅនេះ ។ ក្នុងខណៈនោះមានការឆ្លើយតបជាមតិជំនួយស្មារតីជាច្រើនទៅលើសេចក្តីព្រាងច្បាប់ខ្មែរក្រហម ។ ប្រសិនបើចំណុចទាំងពីរខាងលើត្រូវបានលើកយកមកធ្វើជាសេចក្តីផ្តើមនៅពេលចាប់ដំណើរការពិភាក្សាដេញដោលច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងរដ្ឋសភាជាតិម្ល៉េះដំណើរការនេះនឹងមានភាពឥតខ្ចោះ ។ **ឆាំង យុ**


នួន ជា


ខៀវ សំផន


ឌុច


អៀង សារី


អៀង ធីរិទ្ធ


កែ ពក


តាម៉ុក

# សម័យប្រជុំលើកទី ៥ នីតិកាលទី២ អំពីការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០

*ថ្លែងដោយឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារ សហប្រតិបត្តិការជាមួយអ្នកជំនាញច្បាប់បរទេស ដើម្បីរៀបចំនីតិវិធីសម្រាប់កាត់ទោសឧក្រិដ្ឋជនខ្មែរក្រហម*

*ជាបឋមទូលបង្គំខ្ញុំបាទ មុននឹងធ្វើអត្ថាធិប្បាយជាសេចក្តីផ្តើមនៃសេចក្តីព្រាងច្បាប់ដ៏សំខាន់នេះ សូមព្រះរាជានុញ្ញាត សូមអនុញ្ញាតកត់សម្គាល់នូវចំណុច២ ។*

*ទី១៖ ថ្ងៃនេះគឺថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ។ ហើយទូលបង្គំខ្ញុំបាទនៅចងចាំថា ពីរឆ្នាំមុនគឺថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ គឺជាថ្ងៃដែលថ្នាក់ដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមបានធ្វើដំណើរមកភ្នំពេញដើម្បីសុំចុះចូលជាមួយរាជរដ្ឋាភិបាល ។ ដូច្នេះ នៅថ្ងៃនេះក៏មានន័យនៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យដែរ ។ ចំណុចមួយទៀតដែលទូលព្រះបង្គំខ្ញុំបាទធ្វើការកត់សម្គាល់គឺឯកឧត្តម សម រង្ស៊ី លោកបានមានប្រសាសន៍ថា ម្សិលមិញបានសួរទូលព្រះបង្គំខ្ញុំបាទអំពីខ្លឹមសារនៃច្បាប់ថាតើមានការឃុបឃិតគ្នាជាមួយនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិឬទេ? ហើយប្រសិនបើដូចគ្នាឯកឧត្តមគាំទ្រ ។ ទូលព្រះបង្គំខ្ញុំបាទក៏បានធ្វើការកត់សម្គាល់លើចំណុចនេះដែរ ពីអ្វីដែលទូលបង្គំខ្ញុំបាទបានឆ្លើយ គឺថាបានជំរាបជូនឯកឧត្តមថា ឯកឧត្តមជ្រាបហើយ នេះគឺជាការចរចា ដូចនេះរាល់ការចរចាមិនអាចភាគីម្ខាងមានជំហរដូចភាគីម្ខាងទៀតទេ បើដូចគ្នាបេះបិទ១០០ភាគរយទៅនឹងជំហរភាគីម្ខាងទៀតនោះ មិនមែនជាការចរចារទេ នោះគឺជាការចម្លងតាម គឺជាការទទួលបញ្ជា ហើយការចរចាគឺមានន័យជាការចរចា ប៉ុន្តែអ្វីដែលគួរជាទីរីករាយគឺថាយើងបានឯកភាពគ្នាលើគោលការណ៍សំខាន់ៗ លើគោលការណ៍ធំៗដែលទូលព្រះបង្គំខ្ញុំបាទយល់ថា បទឧទ្ទេសនាមជាសេចក្តីផ្តើមរបស់ទូលបង្គំខ្ញុំបាទនឹងឆ្លុះបញ្ចាំងជាក់ស្តែងនូចចំណុចទាំងនេះ ។ នៅក្នុងបទអត្ថាធិប្បាយនេះ ទូលបង្គំខ្ញុំបាទសូមលើកឡើងនូវចំណុចចំនួន៥÷ ទី១៖ គឺសុំទូលថ្វាយនិងជម្រាបជូនអង្គសភាដ៏ឧត្តុងឧត្តមអំពីប្រវត្តិនៃតុលាការអន្តរជាតិឬក៏អ្វីដែលគេហៅថាតុលាការកាត់សេចក្តី លើបទឧក្រិដ្ឋកម្ម ហើយតើតុលាការរបស់យើងនេះមានសារជាតិជាតុលាការអ្វី? ទី២៖ ទូលបង្គំខ្ញុំបាទនឹងលើកឡើងនូវទស្សនៈទាននិងគោលការណ៍សំខាន់ៗដែលជាមូលដ្ឋានគ្រឹះនៃសេចក្តីព្រាងច្បាប់ដ៏សំខាន់នេះ ។ ទី៣៖ គឺដំណើរការដែលចាប់ផ្តើមតាំងពីឆ្នាំ១៩៩៧រហូតមកដល់ថ្ងៃនេះ ជាដំណើរការជាក់ស្តែងដែលយើងបានឈានដល់សេចក្តីព្រាងច្បាប់ជាក់ស្តែងរបស់យើងដែលអង្គសភាដ៏ឧត្តុងឧត្តមពិភាក្សានៅថ្ងៃនេះ ។ ទី៤៖ គឺជាការសម្រុះសម្រួលធំៗរវាងយើងជាមួយអង្គការសហប្រជាជាតិ បានន័យថា* **(les grands compromis)** *ជាចំណុចសម្រុះសម្រួលគ្នាធំៗ ជាគោលការណ៍ធំៗដែលបង្កើតបាននូវសេចក្តីព្រាងច្បាប់នេះ ។ ទី៥៖ ជាខ្លឹមសារសង្ខេបបំផុតនៃជំពូកនីមួយៗជាខ្លឹមសារសង្ខេបដោយយើងនឹងលើកឡើងជាជំពូកៗ ។ ដូចនេះទូលបង្គំខ្ញុំបាទនឹងសូមទូលថ្វាយនិងជម្រាបជូនអំពីខ្លឹមសារជាក់ស្តែងដោយខ្លីៗបំផុតនៃជំពូកនីមួយៗ ។ ទូលបង្គំខ្ញុំបាទសូមចាប់ផ្តើមនូវចំណុចទី១ដែលលើកឡើងនូវប្រវត្តិនៃតុលាការជាតិផ្សេងៗនៅលើសកលលោកទាំងមូលតាំងពីដើមរហូតមកដល់សព្វថ្ងៃនេះ ។ ទូលបង្គំខ្ញុំបាទក៏សូមបញ្ជាក់ដែរថា សញ្ញាណនៃរដ្ឋដែលហៅថា អេតានោះ ឬស្តេត គឺបានចាប់កំណើតយូរយារណាស់មកហើយ ច្រើនរយឆ្នាំឬក៏រាប់ពាន់ឆ្នាំមកហើយ ហើយកំណាយថ្មីនេះក៏យើងមានមោទនភាពដែរដោយសារការស្រាវជ្រាវថ្មីៗនេះនៅក្នុងខេត្តតាកែវ ដែលគេស្រាវជ្រាវឃើញថាជាទីក្រុងទី១របស់កម្ពុជានោះ គឺអ្នកស្រាវជ្រាវគេពិនិត្យឃើញថានេះជារដ្ឋទី១នៅតំបន់អាស៊ី-អគ្នេយ៍ ។ អ៊ីចឹងទូលបង្គំខ្ញុំបាទក៏សូមវិលចូលមកខ្លឹមសារនេះវិញ គឺថានៅពេលដែលមានរដ្ឋហើយគឺសញ្ញាណមួយគោលការណ៍មួយធំ គឺការគោរពអធិបតេយ្យភាពជាតិរបស់រដ្ឋ គឺទ្រឹស្តីឯករាជ្យអធិបតេយ្យភាពជាតិ ហើយគោលការណ៍នេះជាគោលការណ៍គ្រឹះល្អបំផុតរបស់អង្គការសហប្រជាជាតិ ដែលធម្មនុញ្ញអង្គការសហប្រជាជាតិលើកតម្កើងនិងចាត់ទុកជាគោលការណ៍ដែលត្រូវគោរពដាច់ខាត ។ ដូច្នេះគឺការគោរពអធិបតេយ្យភាពជាតិ នៅក្នុងនោះមានន័យមួយយ៉ាងសំខាន់ចំពោះការរៀបចំតុលាការ គឺថាតុលាការចៅក្រមរបស់ប្រទេសណាគេកាត់សេចក្តីនៅលើដែលដីរបស់ប្រទេសនោះ ដូចជាមានការលើកពីគោលការណ៍ដែនដី ។* **(នៅមានត)**

# វិភាគព្រឹត្តិការណ៍ (១៩៩៩-កុម្ភៈ ២០០០)៖ ការធ្វើពិសោធន៍ទៅលើរូបធាតុ ទួណឺសុល នៃការជំនុំជម្រះទោសពីបទប្រល័យពូជសាសន៍

*(ទួណឺសុល គឺជាធាតុគីមីពណ៌ខៀវដែលអាចប្រែទៅជាពណ៌ក្រហមដោយទឹកអាស៊ីត ហើយអាចក្លាយទៅជាពណ៌ខៀវវិញដោយប្រើជាតិអាល់កាលី)*

កាលពីខែមករា ឆ្នាំ១៩៩៩ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសបញ្ចប់នូវការគំរាមកំហែងពីសំណាក់យោធារបស់ខ្មែរក្រហម ។ ដោយឈរយ៉ាងរឹងមាំក្នុងអំណាច សម្តេចក៏បានត្រៀមខ្លួនចាប់ផ្តើមដំណាក់កាលចុងក្រោយនៃព្រឹត្តិការណ៍ដែលនាំដល់ការជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហម ។

ដំណាក់កាលចុងក្រោយនេះបានចាប់ផ្តើមឡើងជាផ្លូវការនៅឆ្នាំ១៩៩៧ ដោយលិខិតមួយច្បាប់សរសេរទៅកាន់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលក្នុងខ្លឹមសារលិខិតនោះ នាយករដ្ឋមន្ត្រីទី១ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី២ សម្តេច ហ៊ុន សែន បានស្នើសុំជំនួយក្នុងការវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម ។

មកដល់ឆ្នាំ១៩៩៨ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានបង្កើតក្រុមអ្នកជំនាញការមួយក្រុម ហើយបានបញ្ជូនមកកម្ពុជាដឹកនាំដោយលោក នីនាន ស៊ីហ៊ិន (ជនជាតិអូស្ត្រាលី) ។ ហើយនៅក្នុងខែមករា ឆ្នាំ១៩៩៩ ក្រុមអ្នកជំនាញការបានដាក់ជូននូវរបាយការណ៍មួយ ហើយធ្វើការផ្តល់ជាយោបល់អំពីការបង្កើតឡើងនូវតុលាការអន្តរជាតិមួយដើម្បីធ្វើការវិនិច្ឆ័យបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងអំឡុងខ្មែរក្រហមកាន់កាប់អំណាច ។

នៅក្នុងដំណាក់កាលចុងក្រោយ ទស្សនៈវិស័យនៃរដ្ឋាភិបាលកម្ពុជានិងសហគមន៍អន្តរជាតិទាក់ទងទៅនឹងការជំនុំជម្រះក្តីខ្មែរក្រហមត្រូវបានក្លាយទៅជារឿងមួយទៀតដែលមានលក្ខណៈខុសពីរឿងកាលនៅក្នុងដំណាក់កាលដំបូងនាចន្លោះឆ្នាំ១៩៧៩ និងឆ្នាំ១៩៨៩ ។ សហរដ្ឋអាមេរិកនិងសហគមន៍អន្តរជាតិបានអំពាវនាវឲ្យមានដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមតាមផ្លូវច្បាប់ ក្នុងខណៈដែលរដ្ឋាភិបាលរបស់សម្តេច ហ៊ុន សែន គិតថាដំណើរការនេះនឹងក្លាយជាឧបសគ្គដល់ការពង្រឹងអំណាចរបស់ខ្លួន ។

ដោយប្រកាន់យកមាគ៌ានយោបាយមានះរំពឹងតែផលប្រយោជន៍ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងនយោបាយរបស់សហរដ្ឋអាមេរិកនិងសហគមន៍អន្តរជាតិនៅជំហានដំបូងនោះ ដំណើរការយុត្តិធម៌ប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមបម្រើឲ្យគោលបំណងរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានត្រឹមកម្រិតមួយតែប៉ុណ្ណោះ ពោលគឺការធានាឲ្យមានទំនុកចិត្តដល់សហគមន៍ អ្នកផ្តល់ជំនួយអន្តរជាតិក្នុងការផ្តល់ជំនួយមកឲ្យរដ្ឋាភិបាលរបស់សម្តេច ហ៊ុន សែន ។

ប៉ុន្តែរដ្ឋាភិបាលរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានគាបសង្កត់យ៉ាងខ្លាំងដើម្បីឲ្យបញ្ចេញហេតុផលសមរម្យដើម្បីឲ្យសហគមន៍អន្តរជាតិមានជំនឿទៅលើប្រពន្ធ័តុលាការរបស់ខ្លួន ។ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៩ របាយការណ៍របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកមានចំណងជើងថា “របាយការណ៍នៃប្រទេសកម្ពុជាស្តីអំពីការអនុវត្តសិទ្ធិមនុស្សក្នុងឆ្នាំ១៩៩៨” បាននិយាយអំពីប្រពន្ធ័តុលាការកម្ពុជាដែលមានលក្ខណៈមិនគ្រប់ជ្រុងជ្រោយ និងដែលមានការគ្របសង្កត់ដោយប្រព័ន្ធនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន “នៅកណ្តាល” ជជែកជាមួយមេខ្មែរក្រហមផ្តាច់ខ្លួន ខៀវ សំផន “នៅឆ្វេង” និង នួន ជា “នៅខាងស្តាំ” ក្នុងក្រុងភ្នំពេញនាឆ្នាំ១៩៩៨ ។ សម្តេច ហ៊ុន សែន បានមានប្រសាសន៍នាពេលនោះថា ការជំនុំជម្រះក្តីជនទាំងពីររូបនេះនឹងមិនអាចត្រូវបានធ្វើឲ្យមានការព្រួយបារម្ភដល់ផលប្រយោជន៍របស់ប្រទេសជាតិឡើយ ។

របាយការណ៍នោះបានបញ្ជាក់ថា “កង្វះខាតផ្នែកធនធានមនុស្សនិងការបង្រៀនដែលមានកម្រិតទាបបណ្តាលឲ្យមានអសមត្ថភាពនៅក្នុងសាខាតុលាការ ហើយក្នុងការអនុវត្តជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាមិនបានធានាដល់ដំណើរការដាក់លាក់បានឡើយ” ។

ដោយសារការមិនជឿលើមតិសាធារណៈរបស់សម្ដេច ហ៊ុន សែន ការជំនុំជម្រះក្ដីមេដឹកនាំខ្មែរក្រហមបានក្លាយទៅជាការពិសោធន៍មួយក្នុងការស្ទង់ប៉ាន់មើលភាពដែលគួរឲ្យទុកចិត្តរបស់រដ្ឋាភិបាលរបស់សម្ដេច ។

ក្នុងការឆ្លើយតបវិញ រាជរដ្ឋាភិបាលបានចាត់វិធានការជាច្រើនជំហានដើម្បីបង្ហាញពីការតាំងចិត្តរបស់ខ្លួនក្នុងការធ្វើឲ្យពិសោធន៍មួយនេះបានសម្រេចលទ្ធផល ។ ខែមីនា ឆ្នាំ១៩៩៩ ឈិត ជឿន ហៅ ម៉ុក ជាអតីតមេទាហានយោធាខ្មែរក្រហមដែលត្រូវបានស្គាល់ថាជា“ជនឃោរឃៅដៃដល់” ត្រូវបានចាប់ខ្លួនដោយកងទ័ពរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយត្រូវបានចោទប្រកាន់ដោយតុលាការយោធាកម្ពុជាក្រោមច្បាប់ដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់ឆ្នាំ១៩៩៤ ។ ពីរខែក្រោយមក កាំង ហ្គិចអៀវ ដែលត្រូវបានស្គាល់ជាទូទៅថា ឌុច ប្រធានគុកទួលស្លែងឬស-២១ ត្រូវបានចោទប្រកាន់ក្រោមច្បាប់តែមួយ ។

នៅពេលទន្ទឹមគ្នានោះដែរ រាជរដ្ឋាភិបាលកម្ពុជាបានកំពុងទទួលនូវផលចំណេញយ៉ាងក្រាស់ក្រែលក្នុងវិស័យការទូតនិងនយោបាយនៅលើឆាកអន្តរជាតិ ។ នៅឯកិច្ចប្រជុំអ្នកផ្ដល់ជំនួយនាខែមករា ឆ្នាំ១៩៩៩ ដែលជាកិច្ចប្រជុំទីមួយក្រោយពីព្រឹត្តិការណ៍ប្តូមតិមួយទៀតហៅថាការធ្វើរដ្ឋប្រហារឆ្នាំ១៩៩៧ មានទឹកប្រាក់ចំនួន៤៧០លានដុល្លារសហរដ្ឋអាមេរិកត្រូវបានសន្យាផ្ដល់ឲ្យប្រទេសកម្ពុជា ដែលក្នុងនោះ១០០លានជាទឹកប្រាក់មកពីរាជរដ្ឋាភិបាលជប៉ុន ។

ទោះជាយ៉ាងណាក៏ដោយ កិច្ចសន្យាផ្ដល់ជំនួយផ្នែកហិរញ្ញវត្ថុត្រូវបានធ្វើឡើងដោយមានភ្ជាប់លក្ខខណ្ឌឲ្យមានកំណែទម្រង់យោធានិងរាជការស៊ីវិល ហើយឲ្យមានការត្រួតពិនិត្យរៀងរាល់បីខែម្ដង ។ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ ប្រទេសកម្ពុជាបានក្លាយជាប្រទេសទី១០ដែលចូលជាសមាជិកប្រជាជាតិអាស៊ី-អគ្នេយ៍ ហៅកាត់ថា “អាស៊ាន” ។

នាថ្ងៃទី១១ ខែសីហា ដែលស្ថិតនៅចន្លោះពេលកំណត់នៃការជំនុំជម្រះទោស តាម៉ុក នៅថ្ងៃទី៩ ខែកញ្ញា នោះសភាជាតិបានអនុម័តនូវច្បាប់ថ្មីមួយពន្យារពេលវេលានៃការឃុំឃាំងដែលធ្វើឡើងដោយគ្មានការជំនុំជម្រះក្ដីពី៦ខែដល់៣ឆ្នាំចំពោះជនណាដែលត្រូវបានចោទប្រកាន់ពីបទល្មើសធ្ងន់ធ្ងរដូចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាដើម ។

ក្នុងពេលជជែកពិភាក្សាជាមួយនឹងក្រុមចរចារបស់អង្គការសហប្រជាជាតិនាចុងខែសីហា ឆ្នាំ១៩៩៩ បញ្ហាចម្បងគឺការបញ្ជាក់ពីគោលជំហររបស់កម្ពុជាក្នុងការទទូចទាមទារការជម្រះក្ដីដែលមានជនជាតិកម្ពុជាជាអ្នកគ្រប់គ្រង ។ កិច្ចពិភាក្សាត្រូវបានបញ្ចប់ដោយមិនបានឈានទៅដល់កិច្ចព្រមព្រៀងរួមមួយឡើយដោយសារតែភាគីទាំងពីរប្រកាន់យកជំហររៀងៗខ្លួន ។

លោក រ៉ាល់ហ្វ ហ្សាក់លីន ជំនួយការច្បាប់របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលដឹកនាំក្រុមអ្នកជំនាញការច្បាប់អង្គការសហប្រជាជាតិ(ក្រុមទី២) បានមានប្រសាសន៍ថា ប្រសិនបើរដ្ឋាភិបាលប្រទេសកម្ពុជាមិនធ្វើតាមលក្ខខណ្ឌដែលអង្គការសហប្រជាជាតិជឿថាមានលក្ខណៈចាំបាច់ក្នុងការនាំឲ្យមានតុលាការមួយដែលត្រឹមត្រូវតាមគំរូអន្តរជាតិនោះទេ អង្គការសហប្រជាជាតិនឹងបញ្ឈប់ដោយឯកឯងនូវដំណើរការរបស់ខ្លួន ។ អង្គការសហប្រជាជាតិចង់ឃើញនូវតុលាការពិសេសមួយបង្កើតឡើងក្រោមច្បាប់របស់ប្រទេសកម្ពុជា ហើយមានការចូលរួមពីសំណាក់ចៅក្រមអន្តរជាតិដែលមានសំឡេងភាគច្រើន និងព្រះរាជអាជ្ញាតែងតាំងដោយអន្តរជាតិ ។

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការទទូចជាថ្មីម្ដងទៀតថា បើខ្លួនអនុញ្ញាតឲ្យមានការចូលរួមពីអន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជានឹងគ្រប់គ្រងដំណើរការទាំងមូល មិនមែនសហគមន៍អន្តរជាតិទេ ។ ពោលគឺការជំនុំជម្រះក្ដីនឹងត្រូវបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជាក្រោមច្បាប់របស់ប្រទេសកម្ពុជា និងដោយមានការចូលរួមពីចៅក្រមនិងព្រះរាជអាជ្ញាជាតិភាគច្រើន ។

រាជរដ្ឋាភិបាលកម្ពុជាពេលនោះកំពុងចរចាក្នុងគោលជំហរនៃការបង្កើនកម្លាំង ព្រោះយុទ្ធសាស្ត្ររបស់ខ្លួនក្នុងការព្យាយាមទាក់ទាញនូវការគាំទ្រពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិចាប់ផ្ដើមទទួលផ្លែផ្កាហើយ ។ នៅខែសីហា មានក្រុមហិរញ្ញវត្ថុមួយចំនួនមកពីអង្គការរូបិយវត្ថុអន្តរជាតិ “អាយ អ៊ឹម អែហ្វ” និងធនាគារពិភពលោក បានត្រឡប់មកធ្វើការចរចាស្ដីពីការបន្តការប្រើប្រាស់ទឹកប្រាក់

កម្ចីចំនួនរាប់លានបន្តទៅទៀត ។ អង្គការរូបិយវត្ថុអន្តរជាតិមានកម្មវិធីផ្តល់ទឹកប្រាក់ចំនួន១២០លានដុល្លារសម្រាប់រយៈពេលបីឆ្នាំនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែទឹកប្រាក់ពាក់កណ្តាលប៉ុណ្ណោះត្រូវបានបញ្ចេញឲ្យប្រទេសកម្ពុជាស្របជាមួយនឹងធនាគារពិភពលោក ក្រោយពេលដែលខ្លួនផ្អាកជំនួយកាលពីពាក់កណ្តាលឆ្នាំ១៩៩៧ គឺក្រោយពីព្រឹត្តិការណ៍ប្លន្តប្រហារបានសម្រេច ។

នាចុងខែសីហា ឆ្នាំ១៩៩៩ អង្គការរូបិយវត្ថុអន្តរជាតិបានឈានដល់កិច្ចព្រមព្រៀងជាគោលការណ៍លើទឹកប្រាក់ចំនួន ៨០លានដុល្លារ ប៉ុន្តែមុនពេលសម្រេចកិច្ចព្រមព្រៀងនោះ អង្គការនេះចង់ឃើញនូវចំណាត់វិធានការចំពោះការគ្រប់គ្រងប្រាក់ចំណូលនិងរុក្ខាប្រមាញ់ ។

ក្នុងការឆ្លើយតបវិញ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម គាត ឈន់ បានមានប្រសាសន៍ថា រដ្ឋាភិបាលនឹងធ្វើតាមល័ក្ខខ័ណ្ឌរបស់អង្គការ អាយ អឹម អែហ្វ ។

**ទស្សនៈរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន**

នៅថ្ងៃទី៧ ខែកញ្ញា តាម៉ុក ត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍ក្រោមក្រឹត្យច្បាប់ឆ្នាំ១៩៧៩ ។ ដោយយោលតាមច្បាប់ថ្មីស្តីអំពីការឃុំខ្លួនជនដែលប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ មានន័យថា តាម៉ុក នឹងត្រូវបានឃុំខ្លួនក្នុងគុករហូតដល់៣ឆ្នាំដោយគ្មានការជំនុំជម្រះក្តី ។ ពីរសប្តាហ៍ក្រោយមក នៅឯអង្គសន្និបាតរបស់អង្គការសហប្រជាជាតិ សម្តេច ហ៊ុន សែន បានជូនឯកសារចំពោះលោកអគ្គលេខាអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បញ្ជាក់ពីគោលគំនិតជម្រើសបីយ៉ាងក្នុងបញ្ហាបង្កើតតុលាការកាត់ទោសខ្មែរក្រហម ។ ជម្រើសទាំងបីរួមមាន÷

១) ផ្តល់ក្រុមអ្នកច្បាប់មកប្រទេសកម្ពុជាដើម្បីជួយមេធាវីកម្ពុជាធ្វើសេចក្តីព្រាងច្បាប់ និងចាត់តាំងចៅក្រមនិងព្រះរាជអាជ្ញានៅក្នុងប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ។

២) ផ្តល់តែក្រុមជំនាញការច្បាប់ ប៉ុន្តែមិនអាចចូលរួមក្នុងដំណើរការជំនុំជម្រះក្តី ។

៣) ដកខ្លួនឲ្យផុតពីដំណើរកាត់ក្តីដែលបានស្នើឡើង ។

ជាភ័ស្តុតាងចំពោះការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើការកាត់ក្តីតាមល័ក្ខខ័ណ្ឌរបស់ខ្លួន ឯកឧត្តម សុខ អាន ប្រធានដឹកនាំការងារសម្រាប់រៀបចំតុលាការដើម្បីកាត់ទោសមេខ្មែរក្រហម បានមានប្រសាសន៍ថា ក្រុមអ្នកច្បាប់របស់លោកនឹងបញ្ចប់សេចក្តីព្រាងច្បាប់របស់ខ្លួនក្នុងរយៈពេលពីរបីសប្តាហ៍ខាងមុខ ហើយស្វែងរកការគាំទ្រពីសំណាក់គណៈរដ្ឋមន្ត្រីរដ្ឋសភានិងព្រឹទ្ធសភាជាតិ ។

នៅថ្ងៃទី២៨ ខែកញ្ញា ក្រោយថ្ងៃចេញសេចក្តីប្រកាសរបស់ឯកឧត្តម សុខ អាន លោក គីអូស៊ូ ហ៊ីណូ សាវ៉ា ប្រធានសហប្រតិបត្តិការមូលនិធិសេដ្ឋកិច្ចក្រៅប្រទេសរបស់ជប៉ុន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃប្រទេសកម្ពុជា ឯកឧត្តម គាត ឈន់ បានចុះហត្ថលេខាពង្រីកឥណទានមានទឹកប្រាក់៤,១៤កោដិយ៉េន ស្មើនឹង៤០លានដុល្លារសហរដ្ឋអាមេរិកដែលមានការប្រាក់ទាបមកឲ្យប្រទេសកម្ពុជា ។ នេះគឺជាផ្តល់ប្រាក់កម្ចីលើកដំបូងបង្អស់របស់រដ្ឋាភិបាលជប៉ុនដល់ប្រទេសកម្ពុជាក្នុងរយៈពេល៣០ឆ្នាំ ។ ដើម្បីបញ្ជាក់ថាសេដ្ឋកិច្ចកម្ពុជាមានការអភិវឌ្ឍនិងឈរលើពិភពលោកដែរ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ វេង សេរីវុឌ្ឍ បានថ្លែងនៅថ្ងៃទី២៧ ខែកញ្ញា ថា វិស័យទេសចរណ៍ក្នុងឆមាសទីមួយដើមឆ្នាំ១៩៩៩ មានកំណើន៣៧ភាគរយបើប្រៀបធៀបទៅនឹងឆ្នាំមុនក្នុងរយៈពេលដូចគ្នា ។ នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជានៅតែប្រកាន់ខ្ជាប់ខ្លួនមិនផ្លាស់ប្តូរនូវការទទូចរបស់ខ្លួនក្នុងការគ្រប់គ្រងទៅលើការកាត់ទោសខ្មែរក្រហម ការយល់ព្រមរបស់មតិអន្តរជាតិទៅលើការជំនុំជម្រះនៅតែមានលក្ខណៈចាំបាច់ក្នុងការធ្វើឲ្យស្ថាប័នហិរញ្ញវត្ថុអន្តរជាតិមានការជឿជាក់ ។ ត្រង់ចំណុចនេះ សហរដ្ឋអាមេរិកដែលនៅតែខាងក្រោយនៃការចរចាបានឈានជើងចូលដើម្បីបំបែកភាពទាល់ច្រកក្នុងកិច្ចចរចារវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។

នៅខែតុលា រាជរដ្ឋាភិបាលសហរដ្ឋអាមេរិកបានឲ្យយោបល់សម្របសម្រួលមួយដែលសុំឲ្យមានការចូលរួមដោយចៅក្រមកម្ពុជាពីររូប និងចៅក្រមតែងតាំងដោយអង្គការសហប្រជាជាតិ២រូប ។ ការសម្រេចចិត្តនានានឹងត្រូវការមតិភាគច្រើនដែលក្នុងនោះយ៉ាងហោចណាស់ក៏មានសមាសភាពមួយរូបតែងតាំងដោយអង្គការសហប្រជាជាតិត្រូវធ្វើការយល់ព្រមចំពោះសាលក្រមណាមួយចេញដោយតុលាការនោះ ។ ថ្ងៃទី១៩ ខែតុលា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសម្តែងការគាំទ្រចំពោះសំណើរបស់សហរដ្ឋអាមេរិកដោយបានបញ្ជាក់ពីឆន្ទៈរបស់ខ្លួន ចង់បន្ទន់តវិយាបថដើម្បីទាញយកនូវផលប្រយោជន៍នៃការយល់ព្រមពីអន្តរជាតិតាមរយៈតុលាការ ។

យុទ្ធសាស្ត្រនេះហាក់ដូចជាទទួលជោគជ័យទាំងប្រផិតប្រផើយ ហើយនៅថ្ងៃទី២៥ ខែតុលា អង្គការរូបិយវត្ថុអន្តរជាតិបានបន្តកម្មវិធីប្រាក់កម្ចីដែលមានទឹកប្រាក់ចំនួន៨១,៦លានដុល្លារសហរដ្ឋអាមេរិកចំពោះប្រទេសកម្ពុជាដែលធ្វើការពិភាក្សារាំងបួងចំពោះបញ្ហាតុលាការនៅខែសីហា ។ លោក គង់ វិបុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ បានមានប្រសាសន៍ថា ការបន្តនូវប្រាក់កម្ចីនេះឡើងវិញគឺបានបង្ហាញថា អង្គការរូបិយវត្ថុអន្តរជាតិកំពុងតែមានការពេញចិត្តចំពោះការសន្យាកែប្រែទម្រង់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ។ លោករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ គាត ឈន់ បានមានប្រសាសន៍ថា ការបន្តឡើងវិញនូវជំនួយរបស់ អាយ អឹម អែហ្វ បានបញ្ជូនសញ្ញាណវិជ្ជមានមួយទៅដល់សហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិ ។ លោករដ្ឋមន្ត្រីបានបញ្ជាក់បន្ថែមទៀតថា ប្រទេសកម្ពុជានឹងខិតខំបន្តពុះពារទៅមុខទៀតតាមរយៈកំណែទម្រង់សំខាន់ៗ គឺដើម្បីធានាដល់ស្ថាប័នហិរញ្ញវត្ថុនានានិងប្រទេសអ្នកផ្តល់ជំនួយថា ជំនឿទុកចិត្តរបស់អង្គការរូបិយវត្ថុអន្តរជាតិចំពោះរដ្ឋាភិបាលពិតជាមិនខុសទេ ។

ដូចដែលបានរៀបរាប់ខាងលើ ការព្រួយបារម្ភសំខាន់ដែលបានស្តែងចេញនាកិច្ចប្រជុំនាខែកុម្ភៈនោះគឺកំណែទម្រង់ផ្នែកស៊ីវិល ។ ប៉ុន្តែការព្រួយបារម្ភចម្បងនោះគឺការរំសាយទ័ពដែលមានចំនួនច្រើនហួសប្រមាណ ។ ក្រុមការងាររំសាយទ័ពដឹកនាំដោយធនាគារពិភពលោក បានសម្តែងនូវការងឿងឆ្ងល់របស់ខ្លួនចំពោះសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដោះស្រាយបញ្ហារំសាយទ័ ។

នៅក្នុងប្រទេសកម្ពុជាមានទ័ពចំនួន១៤៨០០០នាក់ ហើយជិតពាក់កណ្តាលនៃថវិកា៤០០លានដុល្លាររបស់រាជរដ្ឋាភិបាលកម្ពុជា គឺត្រូវបានចំណាយទៅលើវិស័យយោធា ។ ម្យ៉ាងវិញទៀត ជំនួយប្រចាំឆ្នាំពីបរទេសគឺមានចំនួនប្រហាក់ប្រហែលនឹងថវិកាសម្រាប់យោធា ។ មូលដ្ឋាននៃអំណាចរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺមួយផ្នែកត្រូវបានសាងឡើងតាមរយៈការបង្កើតទ័ព ហើយការកាត់នូវប្រាក់ចំណាយចំពោះវិស័យយោធាដែលធ្វើឲ្យមានឱកាសពុករលួយកាន់តែរាលដាលនោះបានធ្វើឲ្យមានការពិបាកក្នុងការក្តាប់អំណាចនិងសម្រេចចិត្តរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការឆ្លើយតបចំពោះការមិនជឿលើមតិទូទៅរបស់សហគមន៍អ្នកផ្តល់ជំនួយថា ខ្លួននឹងត្រៀមកាត់បន្ថយទ័ពចំនួន៥៥០០០នាក់ ហើយបង្វែរប្រាក់ចំណាយនេះទៅលើវិស័យផ្សេងៗទៀតដូចជាវិស័យអប់រំនិងសុខាភិបាលជាដើម ។ ដើម្បីជាការធានាដល់ប្រទេសអ្នកផ្តល់ជំនួយអំពីកិច្ចសន្យារបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្តីប្រកាសជាទៀងទាត់អំពីការរីកចម្រើនរបស់ខ្លួន ។ នៅខែមិថុនា ឆ្នាំ១៩៩៩ នៅក្នុងកិច្ចជំនួបមួយជាមួយតំណាងនៃប្រទេសអ្នកផ្តល់ជំនួយ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ថា “ក្រោយរយៈពេលតែពីរ-បីខែតែប៉ុណ្ណោះ យើងបានកាត់បន្ថយទ័ពអស់ចំនួន ១២ ៨៦៨ នាក់ និងទ័ពខ្មោចចំនួន ១០៥ ២៣៨ នាក់ ទៀតពីបញ្ជីប្រាក់ខែ ។ ជាលទ្ធផល ថវិកាប្រហែល៩កោដិរៀល “ស្មើនឹង២,៤លានដុល្លារសហរដ្ឋអាមេរិក” ត្រូវបានសន្សំបានក្នុងឆ្នាំសារពើពន្ធនេះ” ។ នៅខែសីហា មានមន្ត្រីរដ្ឋាភិបាលម្នាក់បានធ្វើសេចក្តីប្រកាសថា មានទ័ពខ្មោចរាប់ពាន់នាក់និងទ័ពនៅក្នុងបន្ទុករបស់ខ្លួនរាប់សែននាក់ទៀតត្រូវបានរកមុខឃើញដែលជាការបន្ថែមទៅលើតួលេខកាលពីខែមិថុនា ។ គ្រាន់តែមុនកិច្ចប្រជុំត្រីមាសនៃខែតុលា របាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញថា មានទ័ពខ្មោចប្រមាណ ១៥ ១៥១ នាក់ ត្រូវបានរកឃើញក្នុងបញ្ជីបើកប្រាក់បៀវត្សរ៍ខែមករា-កញ្ញា ។

## ការរីកចម្រើនតិចតួចនៃការរំលោភទំព

ចំណាត់វិធានការរបស់រាជរដ្ឋាភិបាលកម្ពុជាទៅលើការរំលោភទំពមានលក្ខណៈយ៉ាងគ្រប់គ្រាន់ក្នុងការបំពេញចិត្តអ្នកផ្ដល់ជំនួយ ហើយនាកិច្ចប្រជុំត្រីមាសនាថ្ងៃទី២៧ ខែតុលា អ្នកផ្ដល់ជំនួយនិងរាជរដ្ឋាភិបាលកម្ពុជាបានបន្តកិច្ចព្រមព្រៀងរបស់ខ្លួនវិញ ។ ទោះជាមានការរកឃើញនូវទំពខ្មោចយ៉ាងណាក៏ដោយ ក៏ការរីកចម្រើនពិតប្រាកដមានតិចតួចតែប៉ុណ្ណោះក្នុងការរំលោភទំពដែលជាកំណែទម្រង់សំខាន់ចម្បងជាងគេ ។ ហើយទោះបីជាមានការកែទម្រង់សារពើពន្ធបាននាំឲ្យមានពន្ធប្រាក់ចំណូលកើនឡើងក៏ដោយ ក៏ការចំណាយលើផ្នែកសុខាភិបាលនិងវិស័យអប់រំនៅតែមានកម្រិតទាបដដែល ហើយការចំណាយលើវិស័យយោធានៅតែមានកម្រិតស្មើរតែស្មើនឹងពាក់កណ្ដាលនៃថវិកាជាតិដដែលជាដដែល ។

ស្ថិតិដែលមានលក្ខណៈលេចធ្លោគួរឲ្យបារម្ភជាងគេនៅក្នុងកិច្ចប្រជុំនោះគឺការកើនឡើងយ៉ាងរហ័សនៃឧក្រិដ្ឋកម្មឃោរឃៅ ។ ប្រតិឃាតនៃឧក្រិដ្ឋកម្មឃោរឃៅមានផលប៉ះពាល់ដល់ការអំពាវនាវរបស់កម្ពុជាចំពោះអ្នកផ្ដល់ជំនួយនិងអ្នកវិនិយោគទុនធំៗ នេះមិនទាន់និយាយដល់ការគំរាមកំហែងទៅលើការជឿទុកចិត្តរបស់ប្រជាជនទៅលើប្រពន្ធ័ច្បាប់ក្នុងស្រុករបស់ខ្លួនផង ។

ស្ថានការណ៍នេះបានផ្ដល់ឱកាសយ៉ាងសុក្រឹតចំពោះសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងការពង្រឹងអំណាចរបស់ខ្លួនក្នុងខណៈដែលមានការសង្កត់ធ្ងន់ទៅលើការព្រួយបារម្ភរបស់សហគមន៍អ្នកផ្ដល់ជំនួយវិស័យច្បាប់នៅក្នុងប្រទេសកម្ពុជា ។ នាសប្ដាហ៍ទីមួយនៃខែធ្នូ ឆ្នាំ១៩៩៩ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញបញ្ជាឲ្យចាប់ខ្លួនចុងចោទដែលត្រូវបានរាយការណ៍មកថាត្រូវបានមន្ត្រីតុលាការដោះលែងក្រោយពីទទួលប្រាក់សំណូករាប់សែនដុល្លាររួចមក ។ លើសពីនេះទៀត ប្រធានតុលាការក្រុងភ្នំពេញនិងប្រធានព្រះរាជអាជ្ញាត្រូវបានបញ្ឈប់ជាបណ្ដោះអាសន្នពីការងារ ក្រោមការចោទប្រកាន់ពីបទប្រព្រឹត្តអំពើពុករលួយ ។

ក្នុងការឆ្លើយតបទៅនឹងការបង្ក្រាបនោះ លោក ថូម៉ាស ហាម៉ាប៊ឹក តំណាងពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានមានប្រសាសន៍ថា វិធានការដែលចាត់ឡើងទាំងនោះមិនត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញឡើយ ព្រោះមានតែអង្គការកំពូលគឺក្រុមប្រឹក្សាអង្គចៅក្រមទេ ទើបមានសិទ្ធអំណាចក្នុងការចាត់វិធានការប្រឆាំងនឹងចៅក្រមនិងព្រះរាជអាជ្ញាដែលត្រូវបានចោទប្រកាន់ថាបានរំលោភនឹងច្បាប់នោះ ។ វិធានការរបស់សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានគាំទ្រដោយទូរទស្សន៍ជាតិកម្ពុជាដែលអះអាងថា មានមនុស្សរាប់ពាន់អ្នកបានផ្ញើនូវលិខិតស្វាគមន៍ចំពោះការបង្ក្រាបឧក្រិដ្ឋកម្មនិងអំពើពុករលួយ ។

ទោះបីជាមានការជំទាស់ពីសំណាក់សកម្មជនសិទ្ធិមនុស្សដែលមានការភ័យខ្លាចថាការបង្ក្រាបនឹងឈានទៅដល់ការកាន់កាប់អំណាចទាំងស្រុងក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តសកម្មភាពរបស់ខ្លួនប្រឆាំងនឹងឧក្រិដ្ឋកម្មនិងអំពើពុករលួយដូចជាផ្ដល់រង្វាន់ដល់នគរបាលក្នុងការចាប់ខ្លួនឧក្រិដ្ឋជនដែលបានសូកប៉ាន់ឲ្យរួចខ្លួនពីការដាក់ទោស ។

នៅពេលដែលកិច្ចចរចារវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិស្ដីអំពីទម្រង់នៃតុលាការខ្មែរក្រហមចូលដល់វគ្គបញ្ចប់នោះ មានសំណួរមួយសួរថា តើសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មានឆន្ទះដល់កម្រិតណាក្នុងការសាកល្បងអំពីទំហំនៃអំណាចរបស់ខ្លួនលើយោធា ហើយពិសេសអតីតមេដឹកនាំខ្មែរក្រហម ដើម្បីបំពេញតម្រូវការរបស់សហគមន៍អន្តរជាតិក្នុងការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ។ អនុក្រឹត្យដែលសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មានសម្រាប់សាកល្បងកម្លាំងអំណាចរបស់ខ្លួននោះ អាស្រ័យទៅលើបញ្ហាថាតើសហគមន៍អន្តរជាតិមានឆន្ទៈកម្រិតណាក្នុងការសម្របសម្រួលជំហររបស់ខ្លួន ។

ចាប់ពីដើមរហូតដល់ចុងបញ្ចប់នៃដំណើរការចរចា ភាគីម្ខាងៗបានព្យាយាមមានះប្រកាន់យកតែជំហររៀងៗខ្លួន ។ លោក កូហ្វី អាណាន់ បានទទូចថា អង្គការសហប្រជាជាតិនឹងចូលរួមក្នុងតុលាការចម្រុះមួយដែលមាន“សារជាតិអន្តរជាតិ” និងដែលមានយុត្តិធម៌ ។ លោកមានប្រសាសន៍បែបនេះនៅក្នុងខណៈដែលសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអះអាងថា នឹងចាត់ចែងឲ្យតុលាការដំណើរការទៅមុខប្រសិនបើអង្គការសហប្រជាជាតិមិនព្រមទទួលយកនូវតួនាទីបន្ទិចបន្តួចនោះទេ ។

តាំងពីខែធ្នូរហូតមក កិច្ចចរចារវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិលើចំណុចលម្អិតៗទាំងឡាយនៃច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមបានបន្តក្នុងលក្ខណៈប្រចុចញ៉ុច ។ នៅក្នុងដំហាននីមួយៗនៃដំណើរការចរចា រដ្ឋាភិបាលកម្ពុជាបានប៉ុនប៉ងអាននូវល័ក្ខខ័ណ្ឌនានា ដោយអំពាវនាវឲ្យអង្គការសហប្រជាជាតិឆ្លើយតបចំពោះសេចក្តីព្រាងច្បាប់ផ្សេងៗរបស់ខ្លួនឲ្យបានប្រញាប់បំផុត ។

នៅថ្ងៃច័ន្ទ ទី២០ ខែធ្នូ មុនពេលដាក់ជូនសភាជាតិ រាជរដ្ឋាភិបាលកម្ពុជាបានជូនសេចក្តីព្រាងច្បាប់មួយចំពោះអង្គការសហប្រជាជាតិបញ្ជាក់ថាខ្លួននឹងមិនរង់ចាំឲ្យហួសថ្ងៃសុក្រ ទី២៤ ខែធ្នូ ឡើយ ។ នាថ្ងៃទី២៧ ខែធ្នូ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានធ្វើការឆ្លើយតបចំពោះសេចក្តីព្រាងច្បាប់តាមរយៈលិខិតមួយច្បាប់មករាជរដ្ឋាភិបាលកម្ពុជា ។ ក្រោយពីទទួលបាននូវការឆ្លើយតបហើយ ឯកឧត្តម សុខ អាន បានប្រកាសថា អង្គការសហប្រជាជាតិបានបញ្ជាក់ថាខ្លួននឹងជ្រើសរើសយកជម្រើសទីពីរក្នុងចំណោមជម្រើសទាំងបីដែលសម្តេច ហ៊ុន សែន បានគូសបញ្ជាក់យ៉ាងលម្អិតរួចហើយកាលពីខែកញ្ញាកន្លងទៅនៅក្នុងកិច្ចប្រជុំនាទីក្រុងញូវយ៉ក ។ ជម្រើសនោះបានផ្តល់នូវយន្តការមួយដល់អង្គការសហប្រជាជាតិក្នុងការផ្តល់អ្នកជំនាញការច្បាប់មកជាជំនួយការងារដល់មេធាវីរបស់កម្ពុជាក្នុងការធ្វើសេចក្តីព្រាងច្បាប់ដែលមានលក្ខណៈសំខាន់ៗ តែមិនមានសិទ្ធិចូលរួមក្នុងដំណើរការក្នុងតុលាការឡើយ ។ ថ្ងៃបន្ទាប់មក រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្តីព្រាងច្បាប់ដើម្បីឲ្យខ្លួនអាចធ្វើការចំណាយផ្នែកហិរញ្ញវត្ថុចំពោះចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិករបស់ខ្លួនផ្ទាល់ ហើយអង្គការសហប្រជាជាតិចំណាយលើបុគ្គលិករបស់ខ្លួនដែរ ។ កាលពីមុន រាល់ការចំណាយត្រូវធ្វើឡើងដោយអង្គការសហប្រជាជាតិ ។ នាថ្ងៃទី២៨ ខែធ្នូ សេចក្តីព្រាងច្បាប់ទី២ត្រូវបានជូនទៅអគ្គលេខាធិការដ្ឋាន ហើយសុំឲ្យឆ្លើយតបជាបន្ទាន់ ។

សប្តាហ៍ក្រោយនាថ្ងៃទី៦ ខែមករា ឆ្នាំ២០០០ ប៉ុន្មានម៉ោងមុនពេលដែលគណៈរដ្ឋមន្ត្រីកម្ពុជាធ្វើការបោះឆ្នោតសម្តែងមតិគាំទ្រទៅលើសេចក្តីព្រាងច្បាប់នោះ លោក ហេន កូរែល អគ្គលេខាធិការរងរបស់អង្គការសហប្រជាជាតិ បានធ្វើការឆ្លើយតបចំពោះសេចក្តីព្រាងច្បាប់តាមរយៈលោកឯកអគ្គរដ្ឋទូតកម្ពុជានាទីក្រុងញូវយ៉កដោយនិយាយជាទូទៅថា អង្គការសហប្រជាជាតិនៅតែមានការព្រួយបារម្ភអំពីសេចក្តីព្រាងច្បាប់នោះ ហើយបានស្នើឲ្យរដ្ឋាភិបាលកម្ពុជាបញ្ជូនតំណាងរបស់ខ្លួនទៅកាន់ក្រុងញូវយ៉កជាបន្ទាន់ ។

ទោះបីជាសហរដ្ឋអាមេរិកមានការជំរុញដែលបង្ហាញនូវភាពផ្លាស់ប្តូរក៏ដោយ ក៏គណៈរដ្ឋមន្ត្រីកម្ពុជានៅតែអនុម័តលើសេចក្តីព្រាងច្បាប់ជាលើកចុងក្រោយ ហើយសម្រេចយកជាផ្លូវការ ។ សម្តេច ហ៊ុន សែន បានបដិសេធនូវការស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជាបញ្ជូនតំណាងរបស់ខ្លួនទៅទីក្រុងញូវយ៉ក ប៉ុន្តែថា សម្តេចមានឆន្ទៈចង់ធ្វើកិច្ចពិភាក្សានៅទីក្រុងភ្នំពេញ ។ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ដំណើរការបានរកឃើញផ្លូវថ្មីមួយក្រោយពីដំណើរទស្សនកិច្ចរបស់លោកនាយករដ្ឋមន្ត្រីប្រទេសជប៉ុន កីហ្សូ អ៊ូប៊ូជី នៅកម្ពុជា ។ ក្នុងអំឡុងពេលធ្វើទស្សនកិច្ចនៅកម្ពុជា លោក អ៊ូប៊ូជី បានសម្តែងការគាំទ្រចំពោះកំណែទម្រង់ផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយបានសន្យាថានឹងផ្តល់ជំនួយជាទឹកប្រាក់ចំនួន១៨លានដុល្លារដល់កម្ពុជា ។ ជាការតបស្នងវិញ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានជូនរង្វាន់មួយដល់ លោក អ៊ូប៊ូជី គឺការប្រកាសថារដ្ឋាភិបាលលោកនឹងធ្វើការពិនិត្យសើរើសាជាថ្មីម្តងទៀតនូវសេចក្តីព្រាងច្បាប់ដើម្បីអនុញ្ញាតឲ្យមានការចូលរួមពីចៅក្រមបរទេសក្នុងដំណើរការជំនុំជម្រះក្តី ។ នៅថ្ងៃទី១៤ ខែមករា គណៈរដ្ឋមន្ត្រីបានធ្វើវិសោធនកម្មជាផ្លូវការរបស់ខ្លួន ។

ថ្ងៃទី១៨ ខែមករា អង្គការសហប្រជាជាតិបានទទួលនូវសេចក្តីព្រាងច្បាប់បកប្រែជាផ្លូវការពីរាជរដ្ឋាភិបាលកម្ពុជា ។ ថ្ងៃបន្ទាប់មក ឯកឧត្តម សុខ អាន បានដាក់សេចក្តីព្រាងច្បាប់នេះជូនសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានសភាជាតិ ។ ទោះជាសភាជាតិកំពុងស្ថិតក្នុងវិស្សមកាលរបស់ខ្លួនយ៉ាងណាក៏ដោយ ក៏នឹងបើកកិច្ចប្រជុំពិគ្រោះពិភាក្សាពិសេសមួយនាថ្ងៃទី២១ ខែកុម្ភៈ ជាពេលដែលអង្គការសហប្រជាជាតិត្រូវបានរំពឹងថានឹងធ្វើការឆ្លើយតបចំពោះសេចក្តីព្រាងច្បាប់ដែលទើបតែពិនិត្យសាជាថ្មីនេះ ។ ប៉ុន្តែការឆ្លើយតបតាមពេលកំណត់របស់អង្គការសហប្រជាជាតិក៏មិនបានធ្វើ ហើយកិច្ចប្រជុំពិសេសរបស់សភាជាតិកម្ពុជាក៏ខកខាន ។

មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំដើរព្រួលជាស្រេចថានឹងធ្វើការជំនុំជម្រះទោសក្រុមមេដឹកនាំខ្មែរក្រហមទោះបីជាគ្មានការចូលរួមពីសំណាក់អង្គការសហប្រជាជាតិក៏ដោយ ។ តាំងពីដើមដំបូងនៃការចរចារហូតមក រាជរដ្ឋាភិបាលកម្ពុជាគ្រប់គ្រងនូវដំណើរការនេះទាំងស្រុង ។ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្តីព្រាងច្បាប់តែម្នាក់ឯង ហើយដាក់ជូនអង្គការសហប្រជាជាតិឲ្យឆ្លើយតបក្នុងរយៈពេលខ្លីបំផុត ។ យុទ្ធសាស្ត្រនេះបានបង្ខំឲ្យអង្គការសហប្រជាជាតិមានប្រតិកម្មចំពោះការទាមទាររបស់រាជរដ្ឋាភិបាលកម្ពុជា ហើយជាបន្តបន្ទាប់ហាក់ដូចជាត្រូវបានរិះគន់ទៅវិញ ។

ថ្ងៃទី២៩ ខែមករា សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ បានត្អូញត្អែរថា អង្គការសហប្រជាជាតិមិនទាន់ធ្វើការឆ្លើយតបមកវិញនៅឡើយទេចំពោះសេចក្តីព្រាងច្បាប់ចុងក្រោយដែលត្រូវបានបញ្ជូនឲ្យកាលពី១១ថ្ងៃមុន ហើយព្រះអង្គនឹងផ្ញើលិខិតមួយច្បាប់ទៀតទទូចសុំឲ្យអង្គការសហប្រជាជាតិចូលរួមក្នុងដំណើរការកាត់ក្តីនេះ ។ នេះជាព្រះបន្ទូលដកស្រង់របស់សម្តេចក្រុមព្រះ "អង្គការសហប្រជាជាតិមិនទាន់បានឆ្លើយតបវិញទេ ។ តើយើងត្រូវធ្វើយ៉ាងដូចម្តេចបើដូច្នេះ ។ យើងមិនដឹងថាគេពេញចិត្តឬមិនពេញចិត្តយ៉ាងណានោះទេ ។ អង្គការសហប្រជាជាតិគួរតែបញ្ចេញគំនិតរបស់ខ្លួន" ។

**ចំណុចមានបញ្ហា**

ទោះបីជាយ៉ាងណាក៏ដោយ ចំពោះកិច្ចចរចាជាមួយអង្គការសហប្រជាជាតិដែលកំពុងប្រព្រឹត្តទៅ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការពិនិត្យសាជាថ្មីលើចំណុចសំខាន់ៗជាច្រើនដើម្បីឆ្លើយតបតាមការទាមទាររបស់អង្គការសហប្រជាជាតិ ទោះបីជាខ្លួនមិនបានសម្តែងចេញឲ្យឃើញយ៉ាងណាក៏ដោយ ។ ប៉ុន្តែការខ្វែងគំនិតគ្នាលើចំណុចសំខាន់ៗមួយចំនួនក៏នៅតែមាននៅឡើយ ។ ចំណុចដែលសំខាន់បំផុតនោះគឺបញ្ហាថាតើព្រះរាជអាជ្ញាជាតិនិងអន្តរជាតិអាចធ្វើការចោទប្រកាន់ជនជាប់សង្ស័យដោយឯករាជ្យដែរឬទេ ។ នៅពេលដែលសម្តេច ហ៊ុន សែន ប្រកាសថាព្រះរាជអាជ្ញានឹងនាំឲ្យមានភាពចលាចលនោះ អង្គការសហប្រជាជាតិបានធ្វើការជជែកវែកញែកថាសហព្រះរាជអាជ្ញាដែលធ្វើការជាមួយគ្នានឹងធ្វើឲ្យមានដំណើរស្របគ្នាហើយធ្វើឲ្យមេដឹកនាំខ្មែរក្រហមមួយចំនួនរួចផុតពីការចោទប្រកាន់ ។

ថ្ងៃទី៨ ខែកុម្ភៈ លោក កូហ្វី អាណាន់ បានធ្វើការឆ្លើយតបចំពោះសេចក្តីព្រាងច្បាប់ចុងក្រោយតាមរយៈលិខិតមួយច្បាប់ជូនចំពោះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ សារលិខិតនោះបញ្ជាក់ថា មានបញ្ហា៤សំខាន់ៗដែលមានការពាក់ព័ន្ធដល់ការចូលរួមរបស់អង្គការសហប្រជាជាតិ ។ ក្រៅពីបញ្ហាព្រះរាជអាជ្ញាបរទេស នៅមានបញ្ហាមួយចំនួនទៀតស្តីពីការចាប់ខ្លួនជនជាប់សង្ស័យ ការបន្ធូរបន្ថយទោស និងចំនួននៃការចូលរួមរបស់សមាសភាពចៅក្រមអន្តរជាតិ ។

ជាការឆ្លើយតបជាលើកដំបូងចំពោះលោក កូហ្វី អាណាន់ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា ធ្វើដូច្នេះមិនយុត្តិធម៌ឡើយសម្រាប់ប្រជាជនកម្ពុជា ។ ភាពមិនជឿទុកចិត្តរបស់អង្គការសហប្រជាជាតិចំពោះស្ថាប័នច្បាប់ប្រទេសកម្ពុជាដែលចេះតែបន្តរហូតមកនេះ មិនរួមបញ្ចូលការកែទម្រង់នានាដែលត្រូវបានធ្វើរួចមកហើយនោះទេ ។ តែទោះជាយ៉ាងណាក៏ដោយ មេដឹកនាំទាំងពីរភាគីបានបញ្ចេញសំឡេងសុទិដ្ឋិនិយមក្នុងកិច្ចជំនួបដោយឡែកមួយនៅសប្តាហ៍បន្ទាប់ ពោលគឺនៅក្នុងសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍ ហៅកាត់ថា "UNCTAD" ធ្វើឡើងនៅទីក្រុងបាងកកប្រទេសថៃ ។

ថ្ងៃពុធសប្តាហ៍មុន ក្រុមអ្នកជំនាញការច្បាប់របស់អង្គការសហប្រជាជាតិដឹកនាំដោយលោក ហេន កូរែល បានចាកចេញពីភ្នំពេញដោយគ្មានការឈានដល់កិច្ចព្រមព្រៀងអ្វីមួយឡើយក្រោយពីការជួបពិភាក្សាសាជាថ្មីម្តងទៀតរួចមក ។ ត្រង់ចំណុចនេះបុគ្គលម្នាក់នៅតែមានចម្ងល់ក្នុងចិត្តថា អ្នកណានឹងខាតបង់ប្រយោជន៍កាន់តែច្រើនទៀតចំពោះអវត្តមាននៃការចូលរួមរបស់អន្តរជាតិក្នុងដំណើរកាត់ក្តី ហើយការព្រួយបារម្ភរបស់ជនរងគ្រោះឧក្រិដ្ឋកម្មក្រោមរបបខ្មែរក្រហមនឹងមានអំណាចសម្រេចចិត្តដល់កម្រិតណា ។

**ចច ឈីហ្គាស**

**ប្រែសម្រួលដោយ សួ ប៊ុនស៊ី**

ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភាជាតិ ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

1/17/00 9:34 AM

ស្តីពី

ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃ

កម្ពុជាប្រជាធិបតេយ្យ

* * *

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១ .-

[illegible] ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩ ។

## ជំពូកទី ២

## សមត្ថកិច្ច

មាត្រា ២ .-

[illegible] ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩ ។

លើកទៅជាអង្គជំនុំកម្ពុជាប្រជាធិបតេយ្យ និង អ្នកទទួលខុសត្រូវខ្ពស់បំផុតលើរបស់ ហៅថា " **ជនសង្ស័យ** " ។

**មាត្រា ៣ ._**

អង្គជំនុំជម្រះវិសាមញ្ញមានសមត្ថកិច្ចកាត់ទោសជនសង្ស័យទាំងឡាយណា ដែលបានប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ :

- មនុស្សឃាត មាត្រា ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និង ៥០៨
- ទារុណកម្ម មាត្រា ៥០០
- ការរំលោភបំពានលើសាសនា មាត្រា ២០៩ និង ២១០ ។

អាជ្ញាយុកាលនៃបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលបានចែងខាងលើ ត្រូវបានពន្យារពេលបន្ថែម ២០ឆ្នាំទៀត សម្រាប់អាជ្ញាយុកាលនៃបទល្មើសទាំងឡាយ ដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ ។

**មាត្រា ៤ ._**

អង្គជំនុំជម្រះវិសាមញ្ញមានសមត្ថកិច្ចកាត់ទោសជនសង្ស័យទាំងឡាយ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដូចមានចែងក្នុងអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឆ្នាំ ១៩៤៨ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ។

អំពើប្រល័យពូជសាសន៍ ដែលគ្មានអាជ្ញាយុកាល គឺជាអំពើណាមួយក្នុងចំណោមអំពើដូចខាងក្រោម ហើយដែលបានប្រព្រឹត្ត ក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬ មួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ណាមួយ ដូចជា ៖

- ការធ្វើមនុស្សឃាតលើសមាជិកនៃក្រុម
- ការធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរដល់រូបរាងកាយ ឬ សតិបញ្ញាសមាជិកនៃក្រុម
- ការធ្វើដោយចេតនាអោយក្រុមនេះ ស្ថិតនៅក្នុងស្ថានភាពការរស់នៅមួយដែលបានរៀបចំឡើង សំរាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុងឬមួយផ្នែក
- ការដាក់វិធានការនានា ដែលមានបំណងរារាំងមិនអោយមានការផ្តល់កំណើតនានា
- ការបង្ខំផ្ទេរកុមារដោយបង្ខំ ពីក្រុមមួយទៅអោយក្រុមមួយផ្សេងទៀត ។

បទល្មើសខាងក្រោមត្រូវផ្តន្ទាទោសដូចគ្នាទៅនឹងបទល្មើសខាងលើនេះ ៖

- ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍
- ការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍
- ការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។

**មាត្រា ៥ ._**

អង្គជំនុំជម្រះវិសាមញ្ញមានសមត្ថកិច្ចកាត់ទោសជនសង្ស័យទាំងឡាយ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ។

២

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលគ្មានអាជ្ញាយុកាល គឺជាអំពើណាមួយដូចមានរាយខាងក្រោម ដែលបានប្រព្រឹត្ត ជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅនឹងប្រជាជនស៊ីវិលដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនាណាមួយដូចជា ៖

- ការធ្វើមនុស្សឃាត
- ការសម្លាប់រង្គាល
- ការធ្វើអោយទៅជាទាសករ
- ការនិរទេស
- ការដាក់គុកនិងឃុំឃាំង
- ការធ្វើទារុណកម្ម
- ការរំលោភសេពសន្ថវៈ
- ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា
- អំពើអមនុស្សធម៌ផ្សេងទៀត ។

**មាត្រា ៦ ៈ**

អង្គជំនុំជំរះវិសាមញ្ញមានសមត្ថកិច្ចកាត់ទោសជនសង្ស័យទាំងឡាយណាដែលបានប្រព្រឹត្ត ឬបានបញ្ជាអោយប្រព្រឹត្ត អំពើរំលោភធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុង ហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ដូចជាអំពើប្រឆាំងមនុស្សជាតិ ឬ ទ្រព្យសម្បត្តិដែលត្រូវការពារដោយបទប្បញ្ញត្តិនៃ អនុសញ្ញាខាងលើហើយដែលបានប្រព្រឹត្តក្នុងកំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ៖

- ការធ្វើមនុស្សឃាតដោយចេតនា
- ការធ្វើទារុណកម្ម ឬ ការធ្វើបាបដោយអមនុស្សធម៌
- ការបង្កដោយចេតនានូវការឈឺចាប់ខ្លាំង ឬ អោយមានការរងរបួសធ្ងន់ធ្ងរដល់រាងកាយ ឬ សុខភាព
- ការបំផ្លាញ ឬ ធ្វើអោយខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិដោយគ្មានហេតុផលចាំបាច់ខាងយោធា ដែលធ្វើឡើងដោយខុសច្បាប់ និង គ្មានត្រាប្រណី
- ការបង្ខំអោយអ្នកទោសសង្គ្រាម ឬ ជនស៊ីវិល បំរើការនៅក្នុងកងកម្លាំងរបស់សត្រូវ
- ការដកហូតដោយចេតនាពីអ្នកទោសសង្គ្រាម ឬ ជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជំរះក្តីដោយ យុត្តិធម៌ និង ទៀងទាត់
- ការនិរទេស ការផ្លាស់ប្តូរ ឬ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់
- ការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង ។

**មាត្រា ៧ ៈ**

អង្គជំនុំជំរះវិសាមញ្ញមានសមត្ថកិច្ចកាត់ទោសជនសង្ស័យទាំងឡាយ ដែលទទួលខុសត្រូវចំពោះការ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ក្នុងពេលមានជំលោះប្រដាប់អាវុធ យោងតាមអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤ ស្តីពីការ

៣

ការពារសម្បត្តិវប្បធម៌ក្នុងករណីមានជម្លោះប្រដាប់អាវុធ ហើយដែលបានប្រព្រឹត្តក្នុងរវាងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ។

**មាត្រា ៨ .-**

អង្គជំនុំជំរះវិសាមញ្ញមានអំណាចកាត់ទោសជនសង្ស័យទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មប្រឆាំងទៅលើអ្នកដែលទទួលបានការការពារជាអន្តរជាតិ ស្របតាមអនុសញ្ញាឆ្នាំ ១៩៦១ ស្តីពីការបម្រើ និងទំនាក់ទំនងការទូត ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលទទួលបានការការពារជាអន្តរជាតិ ដែលរួមមានភ្នាក់ងារការទូតជាដើម ហើយដែលបានប្រព្រឹត្តក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ។

## ជំពូកទី ៣
## សមាសភាពរបស់អង្គជំនុំជំរះវិសាមញ្ញ

**មាត្រា ៩ .-**

សាលាដំបូងជំនុំជំរះ ជាអង្គជំនុំជំរះវិសាមញ្ញដែលមានចៅក្រមវិជ្ជាជីវៈប្រាំរូប ដែលក្នុងនោះមានចៅក្រមខ្មែរ បីរូប មួយរូបធ្វើជាប្រធាន និងមានចៅក្រមបរទេសពីររូប និងមានសហព្រះរាជអាជ្ញា ព្រមទាំងក្រឡាបញ្ជីមួយរូប ឬ ច្រើនរូប តាមការចាត់តាំងរបស់ប្រធាន តួនរូប ។

សាលាឧទ្ធរណ៍ជំនុំជំរះ ជាអង្គជំនុំជំរះវិសាមញ្ញដែលមានចៅក្រមប្រាំពីររូប ដែលក្នុងនោះមានចៅក្រមខ្មែរបួនរូប ដែលមួយរូបធ្វើជាប្រធាន និងចៅក្រមបរទេសបីរូប និងមានសហព្រះរាជអាជ្ញា ព្រមទាំងក្រឡាបញ្ជីមួយរូប ឬ ច្រើនរូប តាមការចាត់តាំងរបស់ប្រធាន តួនរូប ។

តុលាការកំពូលជំនុំជំរះជាអង្គជំនុំជំរះវិសាមញ្ញ ដែលមានចៅក្រមប្រាំបួនរូប ដែលក្នុងនោះមានចៅក្រមខ្មែរប្រាំរូប ដែលមួយរូបធ្វើជាប្រធាន និង ចៅក្រមបរទេសបួនរូប និងមានសហព្រះរាជអាជ្ញា ព្រមទាំងក្រឡាបញ្ជីមួយរូប ឬច្រើនរូប តាមការចាត់តាំងរបស់ប្រធាន តួនរូប ។

## ជំពូកទី ៤
## ការតែងតាំងចៅក្រមជំនុំជំរះ

**មាត្រា ១០ .-**

ចៅក្រមជំនុំជំរះនៃអង្គជំនុំជំរះវិសាមញ្ញ ត្រូវបានជ្រើសតាំងក្នុងចំណោមចៅក្រមខ្មែរដែលមានបទពិសោធន៍ និងចៅក្រមដែលបានជ្រើសតាំងបន្ថែម តាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ហើយដែលមានសីលធម៌ខ្ពស់ និងស្មារតីមិនលំអៀង និងសុចរិត មានបទពិសោធន៍ក្នុងការងារយុត្តិធម៌ ។

ចៅក្រមជំនុំជំរះត្រូវឯករាជ្យក្នុងការបំពេញភារកិច្ចរបស់ខ្លួន ហើយមិនទទួលយក ឬ ស្វែងរកការណែនាំពីរដ្ឋាភិបាល ឬ ប្រភពណាមួយផ្សេងទៀតឡើយ ។

៦

**មាត្រា ១១ ..**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវជ្រើសតាំងចៅក្រមខ្មែរយ៉ាងតិចចំនួនប្រាំពីររូប ដោយធ្វើជាចៅក្រមជំនុំជំរះសំរាប់អង្គជំនុំជំរះវិសាមញ្ញ និងជ្រើសតាំងចៅក្រមជំនុំជំរះបម្រុងតាមតម្រូវការ ព្រមទាំងត្រូវជ្រើសតាំងផងដែរនូវប្រធាននៃ អង្គជំនុំជំរះវិសាមញ្ញក្នុងចំណោមចៅក្រមខ្មែរទាំងនោះ តាមវិធីដូចនៃការជ្រើសតាំងចៅក្រមជាធម្មតា ។

ចៅក្រមបំរុងត្រូវជំនួស ចៅក្រមជំនុំជំរះណាមួយ នៅពេលដែលចៅក្រមនោះអវត្តមាន ឬមានធុរៈ ។

ចៅក្រមជំនុំជំរះទាំងនោះអាចជាចៅក្រមកំពុងបំពេញការងារ ឬចៅក្រមដែលចូលនិវត្តន៍ហើយ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមបរទេសយ៉ាងតិចចំនួនបួនរូប ដោយធ្វើជាចៅក្រមជំនុំជំរះសំរាប់អង្គជំនុំជំរះវិសាមញ្ញតាមសំណើរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ឬសំណើពីរដ្ឋាភិបាលនៃប្រទេសសមាជិកនៃអង្គការសហប្រជាជាតិ ឬ ស្ថាប័នដទៃទៀតដែលមានកិច្ចសហការជាមួយអង្គការសហប្រជាជាតិ ក្រោមជំនួយពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

អគ្គលេខាធិការអង្គការសហប្រជាជាតិ ឬ ប្រទេសដែលជាសមាជិកអង្គការសហប្រជាជាតិ ត្រូវផ្ញើបញ្ជីឈ្មោះបេក្ខជនជាចៅក្រមបរទេស ដែលមានចំនួនយ៉ាងតិចពីរដងនៃចំនួនចៅក្រមដែលត្រូវការជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១២ ..**

ចៅក្រមជំនុំជំរះទាំងអស់ដែលស្ថិតក្រោមច្បាប់នេះ មានឋានៈស្មើគ្នា ហើយទទួលបាននូវលក្ខខណ្ឌការងារស្មើគ្នាតាមកំរិតថ្នាក់នៃតុលាការនីមួយៗ ។

ចៅក្រមជំនុំជំរះនីមួយៗត្រូវបានជ្រើសតាំងសំរាប់រយៈពេលនៃការជំនុំជំរះ ។ ក្នុងករណីដែលចៅក្រមជំនុំជំរះបរទេសណាមួយអវត្តមាន ឬ មានធុរៈមិនអាចបំពេញការងារក្នុងអង្គជំនុំជំរះវិសាមញ្ញបាន ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមក្នុងបញ្ជី និង តាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១០ និង ១១ នៃច្បាប់នេះដោយបន្ទាន់ ។

**មាត្រា ១៣ ..**

ចៅក្រមជំនុំជំរះត្រូវមានបុគ្គលិកខ្មែរ និង បុគ្គលិកអន្តរជាតិជាជំនួយការ ទៅតាមតម្រូវការដើម្បីសំរាប់បំពេញការងារតាមភារកិច្ចរបស់ខ្លួន ។

ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការ ចៅក្រមទាំងអស់ត្រូវធ្វើសម្ភាសន៍ និងផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ។ ចំពោះបុគ្គលិក និងអ្នកជំនួយការច្បាប់ ត្រូវជ្រើសរើសដោយផ្អែកលើសមាមាត្រ នៃចៅក្រមខ្មែរ និង ចៅក្រមបរទេស ។

បុគ្គលិកជាជំនួយការខ្មែរត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្រសួងយុត្តិធម៌ ។

៥

## ជំពូកទី ៥

## ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ១៤ ៖**

ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ នៃសាលាដំបូង សាលាឧទ្ធរណ៍ និង តុលាការកំពូល ត្រូវធ្វើតាមការបោះឆ្នោតជាឯកច្ឆន្ទ ក្នុងករណីមិនអាចធ្វើបាន ដែលមានចែងនៅខាងក្រោម ៖

ក. ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង ត្រូវមានការយល់ព្រមពីការបោះឆ្នោតគាំទ្រពីចៅក្រម បួន រូប យ៉ាងតិច ។

ខ. ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាឧទ្ធរណ៍ ត្រូវមានការយល់ព្រមពីការបោះឆ្នោតគាំទ្រពីចៅក្រម ប្រាំ រូប យ៉ាងតិច ។

គ. ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល ត្រូវមានការយល់ព្រមពីការបោះឆ្នោតគាំទ្រពីចៅក្រម ប្រាំមួយ រូប យ៉ាងតិច ។

**មាត្រា ១៥ ៖**

ប្រធាន ត្រូវធ្វើការកោះប្រជុំចៅក្រម បណ្តាលពីការចាំបាច់ ដើម្បីដំណើរការងារនៃអង្គជំនុំជម្រះវិសាមញ្ញ ។

## ជំពូកទី ៦

## សហព្រះរាជអាជ្ញា

**មាត្រា ១៦ ៖**

រាល់ការសម្រេចចោទប្រកាន់ជនជាប់ចោទនៅអង្គជំនុំជម្រះវិសាមញ្ញ គឺជាការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញា ពីរនាក់ ម្នាក់ជាកម្ពុជា និង ម្នាក់ទៀតជាបរទេស ដែលហៅថា " **សហព្រះរាជអាជ្ញា** " ដែលត្រូវធ្វើការរួមគ្នាដើម្បីរៀបចំឯកសារ និង ធ្វើសេចក្តីសម្រេចចោទប្រកាន់ជនសង្ស័យនៅចំពោះអង្គជំនុំជម្រះវិសាមញ្ញ ។

**មាត្រា ១៧ ៖**

សហព្រះរាជអាជ្ញានៃសាលាដំបូង មានសិទ្ធិប្តឹងឧទ្ធរណ៍ ពីសេចក្តីសម្រេចនៃអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ។

សហព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ មានសិទ្ធិប្តឹងសារទុក្ខពីសេចក្តីសម្រេចនៃអង្គជំនុំជម្រះវិសាមញ្ញរបស់សាលាឧទ្ធរណ៍ ។

**មាត្រា ១៨ ៖**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវជ្រើសតាំងព្រះរាជអាជ្ញាខ្មែរ និង ព្រះរាជអាជ្ញាបម្រុងខ្មែរ តាមការចាំបាច់ ពីក្នុងចំណោមចៅក្រមវិជ្ជាជីវៈខ្មែរ ។

- ៦ -

ព្រះរាជអាជ្ញា [illegible] ព្រះរាជអាជ្ញា [illegible] ព្រះរាជអាជ្ញា [illegible] ឬ [illegible] ។

ព្រះរាជអាជ្ញា [illegible] ។

ព្រះរាជអាជ្ញា [illegible] ត្រូវបានជ្រើសតាំង [illegible] អង្គការសហប្រជាជាតិ ឬ [illegible] នៃ អង្គការសហប្រជាជាតិ ឬ ជ្រើសតាំង [illegible] ព្រះរាជាណាចក្រកម្ពុជា ។

[illegible] អង្គការសហប្រជាជាតិ ឬ [illegible] អង្គការសហប្រជាជាតិ ត្រូវ [illegible] ព្រះរាជអាជ្ញា [illegible] ២៥ [illegible] ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៩ ៖

សហព្រះរាជអាជ្ញា ត្រូវបានជ្រើសតាំង [illegible] ព្រះរាជអាជ្ញា [illegible] និង ព្រះរាជអាជ្ញា [illegible] និង [illegible] សុចរិត និង [illegible] ។

មាត្រា ២០ ៖

សហព្រះរាជអាជ្ញាទាំងពីរ ត្រូវ [illegible] ។

មាត្រា ២១ ៖

សហព្រះរាជអាជ្ញា [illegible] ។

ព្រះរាជអាជ្ញា [illegible] ។

ក្នុងករណី [illegible] ព្រះរាជអាជ្ញា [illegible] ឬ [illegible] ក្រុមប្រឹក្សាកំពូលនៃអង្គចៅក្រម ត្រូវជ្រើសតាំង ព្រះរាជអាជ្ញា [illegible] និង [illegible] មាត្រា ១៧ និង ១៨ នៃច្បាប់នេះ [illegible] ។

មាត្រា ២២ ៖

សហព្រះរាជអាជ្ញា [illegible] និង [illegible] ។

ក្នុងការជ្រើសរើស [illegible] សហព្រះរាជអាជ្ញា [illegible] និង [illegible] ។

[illegible] ។

## ជំពូកទី ៥

## ដំណើរការស៊ើបអង្កេត

**មាត្រា ២៣ ._**

រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីររូប ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថា " **សហចៅក្រមស៊ើបអង្កេត** " ។

សហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតដោយអនុវត្តតាមនីតិវិធីជាធរមាន ។

សហចៅក្រមស៊ើបអង្កេត អាចធ្វើការស៊ើបអង្កេត លើព័ត៌មានដែលទទួលបានពីស្ថាប័នណាមួយ រួមមាន រដ្ឋាភិបាល ស្ថាប័នអង្គការសហប្រជាជាតិ ឬ អង្គការក្រៅរដ្ឋាភិបាល ជាដើម ។

សហចៅក្រមស៊ើបអង្កេតមានអំណាចក្នុងការសួរចម្លើយជនសង្ស័យ ជនរងគ្រោះ និង សាក្សី ហើយនិងប្រមូលភស្តុតាងដោយអនុវត្តតាមនីតិវិធីជាធរមាន ។ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតយល់ថាជាការចាំបាច់ សហចៅក្រមស៊ើបអង្កេតអាចចេញដីកាផ្សេងៗដែលចាំបាច់ដើម្បីធ្វើការសាកសួរសាក្សីបន្ថែមទៀត ។

ក្នុងការអនុវត្តភារកិច្ចនេះ សហចៅក្រមស៊ើបអង្កេតអាចស្នើសុំការជួយជ្រោមជ្រែងពីរាជរដ្ឋាភិបាលកម្ពុជា ប្រសិនបើចាំបាច់ សម្រាប់ការស៊ើបអង្កេត ។

**មាត្រា ២៤ ._**

ក្នុងដំណាក់កាលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានជំនួយពីមេធាវីដែលខ្លួនជ្រើសរើសដោយឥតគិតថ្លៃ ប្រសិនបើខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីជួលមេធាវី ព្រមទាំងមានសិទ្ធិទទួលបានអ្នកបកប្រែផ្ទាល់មាត់ជាការចាំបាច់ដល់ការសួរចម្លើយ ជាដើម ។

**មាត្រា ២៥ ._**

សហចៅក្រមស៊ើបអង្កេត ត្រូវបានជ្រើសតាំងក្នុងចំណោមចៅក្រមក្នុងតំណែងបច្ចុប្បន្ន និងចៅក្រមដែលបានជ្រើសតាំងបន្ថែមតាមនីតិវិធី នៃការជ្រើសតាំងចៅក្រមជាធរមាន ហើយដែលមានគុណសម្បត្តិខ្ពស់ខាងសីលធម៌ និងស្មារតីយុត្តិធម៌ សុចរិត មានបទពិសោធន៍ក្នុងការងារជំនាញ ។

**មាត្រា ២៦ ._**

ចៅក្រមស៊ើបអង្កេត និងចៅក្រមស៊ើបអង្កេតបម្រុងខ្មែរ ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ក្នុងចំណោមចៅក្រមវិជ្ជាជីវៈខ្មែរតាមការស្នើសុំតាមនីតិវិធីនៃការជ្រើសតាំងចៅក្រមជាធរមាន ។

ចៅក្រមស៊ើបអង្កេតបម្រុងខ្មែរ ចៅក្រមស៊ើបអង្កេតបម្រុងនេះ ជំនួសចៅក្រមស៊ើបអង្កេតក្នុងករណីអវត្តមាន ឬ មរណៈ ។

ចៅក្រមស៊ើបអង្កេតទាំងនេះអាចបន្តការងារស៊ើបអង្កេតរបស់ខ្លួនរហូតដល់ចប់ដោយមិនគិតពីអាណត្តិ ។

ចៅក្រមស៊ើបអង្កេតបរទេស ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពីក្នុងបញ្ជីឈ្មោះចៅក្រម ដែលអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ឬ រដ្ឋាភិបាលបរទេសដាក់ជូន ។

៧

អង្គការសហប្រជាជាតិ ឬ ជ្រើសរើសចេញពីបញ្ជីរាយនាមបេក្ខជនដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ បានបញ្ជូនមក ជាមុនរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

អគ្គលេខាធិការអង្គការសហប្រជាជាតិ ឬ ប្រភពផ្សេងទៀតដែលជាសមាជិកអង្គការសហប្រជាជាតិ ត្រូវបញ្ជូនបញ្ជីរាយនាមចៅក្រមស៊ើបអង្កេតបរទេស ដែលមានចំនួនយ៉ាងតិចពីរ ២ ដង នៃចំនួនចៅក្រមស៊ើបអង្កេតបរទេស ដែលត្រូវការជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៧ .-**

ចៅក្រមស៊ើបអង្កេតទាំងអស់ដែលបម្រើការក្រោមច្បាប់នេះ មានឋានៈស្មើៗគ្នា ហើយទទួលបានលក្ខខណ្ឌការងារ និងលក្ខខណ្ឌសេវាស្មើៗគ្នា ។

ចៅក្រមស៊ើបអង្កេតទាំងពីររូប ត្រូវសហការគ្នាដើម្បីដឹកនាំដំណើរការនៃការស៊ើបអង្កេត ។

ក្នុងករណីដែលចៅក្រមស៊ើបអង្កេតម្នាក់បានលាលែងពីតំណែង ឬ មានមរណៈ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវជ្រើសតាំងចៅក្រម ក្នុងបញ្ជីរាយនាមតំណាង ដូចមានចែងក្នុងមាត្រា ២៥ និង ២៦ នៃច្បាប់នេះ ជំនួសវិញ ។

**មាត្រា ២៨ .-**

សហចៅក្រមស៊ើបអង្កេត មានបុគ្គលិកខ្មែរ និង បុគ្គលិកអន្តរជាតិជាជំនួយការ ទៅតាមតម្រូវការជាក់ស្តែង សំរាប់បំពេញការងារស៊ើបអង្កេត ។

ក្នុងការជ្រើសរើសបុគ្គលិកជាជំនួយការ សហចៅក្រម ត្រូវពិគ្រោះគ្នា និងផ្តល់យោបល់ទៅលើការជ្រើសរើសបុគ្គលិកនោះ ។

បុគ្គលិកជាជំនួយការខ្មែរ ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋ ។

## ជំពូកទី ៩

## ការទទួលខុសត្រូវជាបុគ្គល

**មាត្រា ២៩ .-**

ជនណាម្នាក់ដែលបានធ្វើផែនការញុះញង់ បញ្ជាប្រព្រឹត្ត ឬ ជួយនិងជំរុញក្នុងការរៀបចំផែនការ ឬ ការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងមាត្រា ៣, ៤, ៥, ៦, ៧ និង ៨ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនោះ ។

តួនាទី ឬ ឋានៈរបស់ជនសង្ស័យមិនអាចរួចផុតពីការទទួលខុសត្រូវ ចំពោះ បទឧក្រិដ្ឋ ឬ ជួយបន្ធូរបន្ថយការផ្តន្ទាទោសឡើយ ។

ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលមានចែងក្នុងមាត្រា ៣,៦,៥,៦,៧ និង ៨ នៃច្បាប់នេះ ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់ មិនអាចរំដោះអ្នកបង្គាប់ពីការទទួលខុសត្រូវ [illegible] ចំណោមឧក្រិដ្ឋកម្មទាំងនេះ ប្រសិនបើមិនបានចាត់វិធានការចាំបាច់ [illegible]

៩

និងការត្រួតពិនិត្យយ៉ាងមានប្រសិទ្ធភាពលើអ្នកនៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹង ឬមានហេតុផលដឹងថាអ្នកនៅក្រោមបង្គាប់ ប្រព្រឹត្ត ឬ បានប្រព្រឹត្តអំពើទាំងនោះ ហើយថ្នាក់លើមិនបានចាត់វិធានការចាំបាច់ និងសមរម្យ ដើម្បីបង្ការអំពើនោះ ឬ ដាក់ទណ្ឌកម្មលើអ្នកប្រព្រឹត្តអំពើនោះ ។

ការពិតដែលថាជនជាប់ចោទបានប្រព្រឹត្តអំពើទាំងនោះតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជា ឬ របស់ថ្នាក់លើណាមួយ មិនអាចជួយជនជាប់ចោទ ឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ ។

## ជំពូកទី ៩

### ការិយាល័យរដ្ឋបាល

**មាត្រា ៣០**

បុគ្គលិកនៃអង្គជំនុំជម្រះវិសាមញ្ញនៅជាប់នៅក្រុមជំនុំជម្រះ ចៅក្រមស៊ើបអង្កេត និង ព្រះរាជអាជ្ញាត្រូវគ្រប់គ្រងដោយការិយាល័យរដ្ឋបាលមួយ ។

ការិយាល័យនេះ មានប្រធានមួយរូប និង បុគ្គលិកមួយចំនួនតាមតម្រូវការជាក់ស្តែង ។

**មាត្រា ៣១**

ប្រធានការិយាល័យរដ្ឋបាលត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា សំរាប់រយៈពេល ២ឆ្នាំ ហើយអាចត្រូវបានតែងតាំងបន្តទៀតបាន ។

ប្រធានការិយាល័យរដ្ឋបាល ត្រូវបានជ្រើសរើសក្នុងចំណោមអ្នកដែលមានបទពិសោធន៍ខ្ពស់ក្នុងការងាររដ្ឋបាលតុលាការ និងមានសញ្ញាប័ត្រនីតិសាស្ត្រ ឬផ្នែកពាក់ព័ន្ធ ដែលប្រកាន់ខ្ជាប់នូវសីលធម៌ជាមនុស្សមានចរិតលក្ខណៈ និង ស្មារតីខ្ពស់ស្មោះត្រង់ ។

ប្រធានការិយាល័យរដ្ឋបាល ត្រូវមានបុគ្គលិកខ្មែរ និង បុគ្គលិកអន្តរជាតិ ជាជំនួយការ តាមតម្រូវការជាក់ស្តែង ។

បុគ្គលិកអន្តរជាតិនៃការិយាល័យរដ្ឋបាល ត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា តាមសំណើរបស់ប្រធានការិយាល័យ ។

បុគ្គលិកខ្មែរ ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣២**

បុគ្គលិកទាំងអស់ដែលបានជាប់កិច្ចសន្យាជាជំនួយការនៅជាប់ចៅក្រមជំនុំជម្រះ ចៅក្រមស៊ើបអង្កេត ព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល ត្រូវទទួលប្រាក់បៀវត្សរ៍សមរម្យ នៅតាមសំណើរបស់ថ្នាក់ដឹកនាំរៀងៗខ្លួន ។

## ជំពូកទី ១០

## កិច្ចដំណើរការកាត់ទោស

**មាត្រា ៣៣ ._**

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅដោយយុត្តិធម៌ និង ឆាប់រហ័សទៅតាម នីតិវិធី ជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និង មានការការពារជនរងគ្រោះ ព្រមទាំងជនរងគ្រោះ និង សាក្សី ។

ជនសង្ស័យដែលត្រូវបានចោទប្រកាន់ ហើយត្រូវបានចាប់ខ្លួន ត្រូវបញ្ជូនខ្លួនមកសាលាដំបូង តាមនីតិវិធី ជាធរមាន ។

រាជរដ្ឋាភិបាល ត្រូវទទួលខុសត្រូវក្នុងការធានាសន្តិសុខ ចំពោះការចូលរួមដោយស្ម័គ្រចិត្ត ការចាប់ខ្លួនជន សង្ស័យដែលត្រូវបានចោទប្រកាន់តាមច្បាប់នេះ ។ ករណីជនសង្ស័យណា ត្រូវបានដឹងបញ្ជូន ដោយអង្គការអន្តរជាតិ ផ្សេងៗទៀតទៅរាជរដ្ឋាភិបាល ដែលមានការកក់ទុកជាមុន ដើម្បីធានាថាជនដែលត្រូវបានចោទប្រកាន់ ត្រូវបានចាប់ខ្លួនមកក្នុងអង្គជំនុំជម្រះ ។ ពិធីដែលការចាប់ខ្លួន និង ឃុំខ្លួន ត្រូវអនុវត្តតាមច្បាប់ជាធរមាន ។

**មាត្រា ៣៤ ._**

អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើជាសាធារណៈ លើកលែងតែអង្គជំនុំជម្រះវិសាមញ្ញសម្រេចថាត្រូវជំនុំជម្រះ ជា សម្ងាត់ ដោយមានហេតុផលតាមនីតិវិធីជាធរមាន ។

**មាត្រា ៣៥ ._**

ជនជាប់ចោទ ត្រូវចាត់ទុកថាគ្មានកំហុសរហូតដល់ទាល់តែការសម្រេចជាស្ថាពរដែលបញ្ជាក់ថាមានកំហុស ។

នៅក្នុងការចោទប្រកាន់ទោសណាមួយ ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និង ស្មើភាព ដូចតទៅ ៖

ក/ ទទួលដំណឹងភ្លាមៗ និងលំអិតជាភាសាដែលខ្លួនយល់អំពីប្រភេទ និង មូលហេតុ នៃ ការចោទប្រកាន់ខ្លួន ។

ខ/ មានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំខ្លួន និង ទាក់ទងជាមួយមេធាវីដែលខ្លួនបានជ្រើសរើស ឬ ទាក់ទងជាមួយមេធាវីដែលចាត់តាំងដោយប្រធានអង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើជនជាប់ចោទគ្មាន លទ្ធភាពគ្រប់គ្រាន់ដើម្បីរកមេធាវី ។

គ/ ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការពន្យារពេល ។

ឃ/ ត្រូវបានកាត់ក្តីនៅចំពោះមុខខ្លួន ឬ តាមរយៈមេធាវីដែលខ្លួនបានជ្រើសរើស ឬ មេធាវី ដែលត្រូវបានចាត់តាំង ក្នុងករណីដែលជនជាប់ចោទគ្មានលទ្ធភាព និង ពុំមានមេធាវីដោយខ្លួនឯង ។

ង/ ពិនិត្យសាក្សី ដាក់បន្ទុក និង ទទួលបាននូវការកោះហៅ និងការពិនិត្យសាក្សីដោះបន្ទុក ដូចគ្នានឹងសាក្សីដាក់បន្ទុកដែរ ។

១១

ង/ មានការជួយឧបត្ថម្ភដោយឥតគិតថ្លៃពីអ្នកបកប្រែភាសា ប្រសិនបើជនជាប់ចោទមិនយល់ ឬ និយាយភាសាដែលប្រើនៅក្នុងតុលាការ ។

ច/ មិនត្រូវបានគេបង្ខំឲ្យធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬ បង្ខំឲ្យសារភាពថាខ្លួនមានកំហុស ។

**មាត្រា ៣៦ ._**

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាឧទ្ធរណ៍ ជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ របស់ជនរងគ្រោះ ឬ របស់សហព្រះរាជអាជ្ញា ក្នុងករណីដូចខាងក្រោម ៖

- ការកាត់ទោសខុសដោយហេតុអង្គហេតុ
- ការកាត់ទោសខុសដោយហេតុអង្គច្បាប់

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាឧទ្ធរណ៍មិនត្រូវបញ្ជូនវិញ ត្រូវដំណើរការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង ។ អង្គជំនុំជម្រះវិសាមញ្ញនេះ អាចតម្កល់សេចក្តីសម្រេច ឬ ធ្វើវិសោធនកម្មសេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង ឬ កែប្រែសេចក្តីសម្រេចនោះ ។ ក្នុងករណីនេះ អង្គជំនុំជម្រះវិសាមញ្ញនៃសាលាឧទ្ធរណ៍ អាចសម្រេចតាមនីតិវិធីជាស្ថាពរបាន ។

**មាត្រា ៣៧ ._**

អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល ជំនុំជម្រះលើបណ្តឹងសារទុក្ខរបស់ជនជាប់ចោទ របស់ជនរងគ្រោះ និងរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាឧទ្ធរណ៍ ក្នុងករណីនេះតុលាការកំពូលត្រូវសម្រេចជាស្ថាពរ ទាំងអង្គហេតុ ទាំងអង្គច្បាប់ ដោយមិនបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះវិសាមញ្ញនៃសាលាឧទ្ធរណ៍វិញ ។

## ជំពូកទី ១១

## ទោសបញ្ញត្តិ

**មាត្រា ៣៨ ._**

ទណ្ឌកម្មទាំងអស់ដែលត្រូវបានកាត់ត្រូវកំណត់ត្រឹមតែការដាក់ពន្ធនាគារ ។

**មាត្រា ៣៩ ._**

ជនទាំងឡាយដែលបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចមានចែងក្នុងមាត្រា ៣, ៤, ៥, ៦, ៧ និង ៨ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ជាប់ពន្ធនាគារពី ៥ ឆ្នាំ រហូតដល់មួយជីវិត ។

ក្រៅពីការដាក់ពន្ធនាគារ អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង អាចសម្រេចរឹបអូសទ្រព្យសម្បត្តិ ជាចលនវត្ថុ និង អចលនវត្ថុ និងលុយកាក់ដែលទទួលបានដោយខុសច្បាប់ ឬ ក៏បានដោយការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ។

ទ្រព្យសម្បត្តិដែលរឹបអូសបាននេះ ត្រូវប្រគល់ជូនរដ្ឋ ។

## ជំពូកទី ១២

## ការលើកលែងទោស និង ការអនុគ្រោះទោស

**មាត្រា ៤០ ._**

រាជរដ្ឋាភិបាលកម្ពុជា មិនអាចស្នើសុំព្រះមហាក្សត្រលើកលែងទោសឬអនុគ្រោះទោសដល់ជនណាម្នាក់ ដែលអាចត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសពីឧក្រិដ្ឋកម្មដែលមានចែងក្នុងមាត្រា ៣. ៤. ៥. ៦. ៧ និង ៨ នៃច្បាប់នេះឡើយ ។

## ជំពូកទី ១៣

## ឋានៈ សិទ្ធិ បុព្វសិទ្ធិ និង អភ័យឯកសិទ្ធិ

**មាត្រា ៤១._**

អនុសញ្ញាស្តីពីសិទ្ធិ និង អភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិ នាថ្ងៃទី ១៣ កុម្ភៈ ឆ្នាំ ១៩៤៦ ត្រូវយកមកអនុវត្តចំពោះចៅក្រមជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញជាជនជាតិអន្តរជាតិ ។

**មាត្រា ៤២ ._**

ចៅក្រមជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និង ក្រឡាបញ្ជីត្រូវមានសិទ្ធិ និងអភ័យឯកសិទ្ធិ ដូចមន្ត្រីការទូតដែរ ។

## ជំពូកទី ១៤

## ទីតាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា ៤៣ ._**

អង្គជំនុំជម្រះវិសាមញ្ញត្រូវរៀបចំឡើងនៅក្នុងសាលាដំបូង សាលាឧទ្ធរណ៍ និង តុលាការកំពូល ដែលមានទីតាំងនៅក្នុងរាជធានីភ្នំពេញ ។

## ជំពូកទី ១៥

## ការរំលាយ

**មាត្រា ៤៤ ._**

ការរំលាយចោលរបស់អង្គជំនុំជម្រះវិសាមញ្ញមាន ៖

១៣

១. ការចំណាយនិងប្រាក់បៀវត្សរ៍ជូនមន្ត្រីខ្មែរ ចំពោះចៅក្រមជំនុំជម្រះ និងចៅក្រមជំនុំជម្រះបម្រុង ចៅក្រមស៊ើបអង្កេត និងចៅក្រមស៊ើបអង្កេតបម្រុង ព្រះរាជអាជ្ញានិងព្រះរាជអាជ្ញាបម្រុងខ្មែរទាំងអស់ ជាបន្ទុករបស់ថវិកាជាតិខ្មែរ ។

២. ការចំណាយនិងប្រាក់បៀវត្សរ៍ជូនបរទេស ចៅក្រមជំនុំជម្រះ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត ដែលបញ្ជូនមកដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាបន្ទុករបស់អគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ ។

៣. ការចំណាយនិងប្រាក់បៀវត្សរ៍ជូនអ្នកបរទេស ចៅក្រមជំនុំជម្រះបរទេស ចៅក្រមស៊ើបអង្កេតបរទេស និងព្រះរាជអាជ្ញាបរទេសផ្សេងទៀត ជាបន្ទុករបស់ប្រទេសដែលបានបញ្ជូនមក ។

៤. ការចំណាយទៅលើសេវាកម្មជំនុំជម្រះនានា ក៏អាចទទួលបានជំនួយឧបត្ថម្ភពីមូលនិធិស្ម័គ្រចិត្តដែលរៀបចំ ដោយរដ្ឋាភិបាលបរទេស ស្ថាប័នអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ហើយនិងបុគ្គលដែលប្រាថ្នាចង់ជួយដល់កិច្ចដំណើរការនេះ ។

## ជំពូកទី ១៦

## ភាសាផ្លូវការ

មាត្រា ៤៥ .-

ភាសាផ្លូវការប្រើប្រាស់ក្នុងអង្គជំនុំជម្រះវិសាមញ្ញ គឺភាសាខ្មែរ ហើយមានការបកប្រែជាភាសាអង់គ្លេស បារាំង និងរុស្ស៊ី ។

## ជំពូកទី ១៧

## អវត្តមានចៅក្រមជំនុំជម្រះ ចៅក្រមស៊ើបអង្កេត ឬ ព្រះរាជអាជ្ញាបរទេស

មាត្រា ៤៦ .-

ដើម្បីធានាការអនុវត្តច្បាប់នេះ បានទាន់ពេលវេលា និង មិនមានការរំខាន ក្នុងករណីគ្មានចៅក្រមជំនុំជម្រះ ឬ ចៅក្រមស៊ើបអង្កេត ឬ ព្រះរាជអាជ្ញាបរទេសណាមកបំពេញមុខងារ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងជ្រើសតាំងចៅក្រមជំនុំជម្រះ ឬ ចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាផ្សេងទៀត ក្នុងចំណោមបញ្ជីដែលមានចែងក្នុងមាត្រា ១១, ១៨ និងមាត្រា ២១ ។ បើគ្មានចៅក្រមជំនុំជម្រះ ឬចៅក្រមស៊ើបអង្កេត ឬ ព្រះរាជអាជ្ញាបរទេសបម្រុងទេ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវជ្រើសតាំងចៅក្រមជំនុំជម្រះ ឬ ចៅក្រមស៊ើបអង្កេត ឬ ព្រះរាជអាជ្ញាដទៃទៀត ឬ ចៅក្រមជំនុំជម្រះ ឬ ចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាខ្មែរ ជំនួស ។

១៥

## ជំពូកទី ១៨

## អវសានប្បញ្ញត្តិ

**មាត្រា ៩៧ .-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ ២០០០ ក្នុង
សម័យប្រជុំរដ្ឋសភាលើកទី នីតិកាលទី ២
រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០០០
ប្រធានរដ្ឋសភា

១៥

# កំណត់ហេតុស្ដីអំពីអង្គប្រជុំរបស់សភាជាតិនៃព្រះរាជាណាចក្រកម្ពុជា
# លើសេចក្ដីព្រាងច្បាប់ស្ដីពី
# ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
# ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

***ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០***

**អគ្គលេខាធិការនៃអង្គប្រជុំ:** *សូមក្រាបថ្វាយបង្គំសម្ដេចក្រុមព្រះ ព្រះប្រធាននៃរដ្ឋសភា សម្ដេចអនុប្រធានទី១ ឯកឧត្ដមអនុប្រធានទី២ អង្គសភាទាំងមូលជាទីគោរព សូមទូលថ្វាយនិងជម្រាបវត្តមានព្រឹកនេះមាន៩៧រូប សូមអរព្រះគុណ អរគុណ ។*

**សម្ដេចក្រុមព្រះ:** *សូមគោរពសម្ដេចអនុប្រធានទី១ ឯកឧត្ដមអនុប្រធានទី២ សូមគោរពអ្នកអង្គម្ចាស់ លោកជំទាវ ឯកឧត្ដមសមាជិកសមាជិកាទាំងអស់នៃរដ្ឋសភាជាតិដ៏ឧត្ដុងឧត្ដម សូមគោរពឯកឧត្ដមតំណាង ឯកឧត្ដមលោកជំទាវតំណាងរាជរដ្ឋាភិបាល ។ យោងសេចក្ដីសម្រេចរបស់អង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នារសៀលថ្ងៃច័ន្ទទី១២ ខែធ្នូ ឆ្នាំ២០០០ និងតាមការស្នើសុំរបស់គណៈកម្មការនីតិកម្ម យោងការអនុម័តបញ្ចូលជារបៀបវារៈទី១០នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី២ ដែលបានអនុម័តដោយសភាពេញអង្គកាលពីថ្ងៃព្រហស្បតិ៍ ទី១៤ ខែធ្នូ ឆ្នាំ២០០០នេះ ។ ខ្ញុំសូមអញ្ជើញឯកឧត្ដម ម៉ោញ សាផាន ប្រធានគណៈកម្មការនីតិកម្ម រាយការណ៍ជូនអង្គសភាពីការងារពិនិត្យសិក្សាស្រាវជ្រាវលើសេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ សូមអញ្ជើញឯកឧត្ដមប្រធាន ម៉ោញ សាផាន ។*

**ឯកឧត្ដម ម៉ោញ សាផាន:** *ទូលបង្គំខ្ញុំបាទសូមក្រាបថ្វាយបង្គំសម្ដេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា សូមគោរពសម្ដេចអនុប្រធានទី១ ឯកឧត្ដមអនុប្រធានទី២ សូមគោរពសម្ដេច ព្រះអង្គម្ចាស់ អ្នកម្នាង ឯកឧត្ដម លោកជំទាវ ។ តាងនាមគណៈកម្មការនីតិកម្មនៃរដ្ឋសភា ទូលព្រះបង្គំខ្ញុំបាទសូមព្រះរាជានុញ្ញាតនិងអនុញ្ញាតនាំមកនូវយោបល់របស់គណៈកម្មការនីតិកម្ម សូមទូលថ្វាយនិងជម្រាបជូនអង្គសភាក្នុងការពិនិត្យក្នុងសេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដូចតទៅ÷*

***ក) អំពីទម្រង់រដ្ឋបាលៈ*** *សេចក្ដីព្រាងច្បាប់នេះត្រូវបានរាជរដ្ឋាភិបាលបញ្ជូនមករដ្ឋសភាសារលិខិតលេខ០៨សលកបចចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០០ ដែលមានភ្ជាប់សេចក្ដីប្រែហេតុលេខ០១សជណកបច ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០០ មកជាមួយផង ព្រមទាំងសេចក្ដីព្រាងច្បាប់ថតចម្លងចំនួន១២២ច្បាប់ដែលបានចែកជូនតំណាងរាស្ត្ររួចហើយ គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាក្រោយពីបានពិនិត្យនិងពិភាក្សានាពេលប្រជុំថ្ងៃទី២១ ខែមករា ឆ្នាំ២០០០ បានឯកភាពបញ្ជូនសេចក្ដីព្រាងច្បាប់នេះមកគណៈកម្មការនីតិកម្មតាមលិខិតលេខ៨៦រស ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០០ ។ ដូចនេះ សេចក្ដីព្រាងច្បាប់ដែលដាក់ជូនអង្គសភាពិភាក្សានិងអនុម័តនាពេលពេលនេះគឺបានធ្វើឡើងត្រឹមត្រូវតាមទម្រង់រដ្ឋបាលដែលមានចែងនៅក្នុងប្រការ ២១ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។*

***ខ) អំពីគតិច្បាប់ៈ*** *តាមការសិក្សាស្រាវជ្រាវរបស់គណៈកម្មការនីតិកម្មនៃរដ្ឋសភា សេចក្ដីព្រាងច្បាប់នេះបានរៀបចំឡើងដោយអ្នកច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាមួយនិងអ្នកច្បាប់អន្តរជាតិ និងដោយផ្អែកលើមូលដ្ឋានសំខាន់ៗដូចតទៅៈ*

- *ច្បាប់នីតិវិធីនិងបទដ្ឋាននានាដែលនៅជាធរមាននៅកម្ពុជា អនុសញ្ញាអន្តរជាតិស្ដីពីការបង្កើតនិងការផ្ដន្ទាទោសចំពោះបទ*

ឧក្រិដ្ឋនៃការប្រល័យពូជសាសន៍ ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅឆ្នាំ១៩៤៨ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ស្តីពីអំពើប្រឆាំងមនុស្សជាតិ ទ្រព្យសម្បត្តិដែលត្រូវការពារ អនុសញ្ញាទីក្រុងឡាអេឆ្នាំ១៩៥៤ ស្តីពីកិច្ចការពារសម្បត្តិវប្បធម៌ក្នុងពេលជម្លោះប្រដាប់អាវុធ អនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត បទល្មើសប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅកម្ពុជា មានលក្ខណៈធំធេងទាក់ទងដល់អាយុជីវិតមនុស្សរាប់លាននាក់ ហើយបានរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាអន្តរជាតិជាច្រើនដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងព្រមប្រតិបត្តិតាម ។ ក្នុងទិសដៅរក្សានូវអធិបតេយ្យភាពជាតិនិងកិត្យានុភាពជាតិ ហើយអាចទទួលយកបានទាំងក្នុងប្រទេសនិងក្រៅប្រទេសចាំបាច់ត្រូវបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញដើម្បីជំនុំជម្រះឧក្រិដ្ឋកម្មនេះក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ដែលមានការចូលរួមពីចៅក្រមព្រះអាជ្ញាកម្ពុជានិងចៅក្រមព្រះរាជអាជ្ញាបរទេស ដែលមានបទពិសោធន៍ក្នុងការងារជំនាញខាងច្បាប់ព្រហ្មទណ្ឌឬច្បាប់អន្តរជាតិ ។ សេចក្តីព្រាងច្បាប់នេះធ្វើឡើងក្នុងគោលបំណងបង្កើតអង្គជំនុំជម្រះវិសាមញ្ញមួយដើម្បីវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់ក្រុមកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម អង្គជំនុំជម្រះវិសាមញ្ញនេះត្រូវបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ហើយមានសមាសភាពក្នុងលំដាប់ថ្នាក់នៃសាលាជម្រះក្តីនីមួយៗដូចតទៅៈ

១) សាលាដំបូងៈ មានចៅក្រមចំនួន៥រូប ក្នុងនោះចៅក្រមខ្មែរ៣រូប មួយរូបជាប្រធាន និងចៅក្រមបរទេស២រូប ។

២) សាលាឧទ្ធរណ៍ៈ មានចៅក្រមចំនួន៧រូប ក្នុងនោះចៅក្រមខ្មែរ៤រូប មួយរូបជាប្រធាន និងចៅក្រមបរទេស៣រូប ។

៣) តុលាការកំពូលៈ មានចៅក្រមចំនួន៩រូប ក្នុងនោះចៅក្រមខ្មែរ៥រូប មួយរូបជាប្រធាន និងចៅក្រមបរទេស៤រូប ។

គ្រប់លំដាប់ថ្នាក់នៃសាលាជម្រះក្តីត្រូវមានសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតខ្មែរ១រូប បរទេស១រូប ការសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញគេយកសំឡេងជាឯកច្ឆ័ន្ទ ក្នុងករណីគ្មានភាពឯកច្ឆ័ន្ទត្រូវធ្វើការសម្រេចតាមការបោះឆ្នោតដែលត្រូវធ្វើឲ្យមានការគាំទ្រយ៉ាងតិចបំផុតពីចៅក្រមបរទេស១រូប ។ ដោយនៅក្នុងសេចក្តីព្រាងច្បាប់ក៏បានកំណត់អំពីការបង្កើតនូវអង្គបុរេជំនុំជម្រះមួយសម្រាប់ដោះស្រាយនូវរាល់បញ្ហាដែលកើតមានឡើងក្នុងក្របខ័ណ្ឌសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេត ។ នៅក្នុងសេចក្តីព្រាងច្បាប់នេះក៏បានកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គជំនុំជម្រះវិសាមញ្ញនិងអំពីសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញផងដែរ ។ ក្នុងការពិនិត្យនិងសិក្សាសេចក្តីព្រាងច្បាប់នេះ គណៈកម្មការនីតិកម្មនៃរដ្ឋសភាបានឯកភាពតាមសំណើសុំការកែប្រែមួយចំនួនរបស់រាជរដ្ឋាភិបាល ដែលជាលទ្ធផលនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលជាមួយតំណាងលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ដូចមានអត្ថបទទី២ថ្វាយនិងជូនរួចមកហើយ ។ ក្រោយពីការពិនិត្យនិងសិក្សាខ្លឹមសារលម្អិតរួចមកគណៈកម្មការនីតិកម្មនៃរដ្ឋសភាបានឯកភាពជាមួយតំណាងរាជរដ្ឋាភិបាល សូមដាក់សេចក្តីព្រាងច្បាប់នេះថ្វាយនិងជូនអង្គសភាពិភាក្សានិងអនុម័តនាពេលនេះ ។ ចំពោះសំណើសុំកែប្រែ និងអំពីមូលហេតុដែលនាំឲ្យមានសំណើសុំកែប្រែនេះ គណៈកម្មការនីតិកម្មនៃរដ្ឋសភានឹងរាយការណ៍ថ្វាយនិងជូនអង្គសភាជ្រាបក្នុងពេលដែលអង្គសភាពិនិត្យដល់ខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះ ។ សេចក្តីរាយការណ៍ដូចបានទូលថ្វាយនិងជម្រាបជូនខាងលើ ទូលព្រះបង្គំខ្ញុំបាទសូមស្នើដល់អង្គសភាមេត្តាទទួលយកសេចក្តីព្រាងច្បាប់នេះទៅពិភាក្សានិងអនុម័តមួយជំពូកម្តងៗដែលចាត់ទុកជាការប្រញាប់តាមការគួរ សូមអរព្រះគុណនិងអរគុណ ។

**សម្តេចក្រុមព្រះៈ** សូមអរគុណឯកឧត្តមប្រធាន តែខ្ញុំសូមបញ្ជាក់ថា នៅក្នុងសេចក្តីរាយការណ៍ របាយការណ៍ដែលបានដាក់ជូនគឺបានសរសេរមួយមាត្រាម្តង ក៏ប៉ុន្តែឯកឧត្តមប្រធានមិនមានការភ័ន្តច្រឡំទេ គឺថាសុំស្នើរដ្ឋសភាសុំឲ្យពិនិត្យពិភាក្សាអនុម័តមួយជំពូកម្តងៗ ។ សូមយោងមាត្រាប្រការ២៩ថ្មីនៃបទបញ្ជាផ្ទៃក្នុង សូមអង្គសភាមេត្តាពិនិត្យនិងអនុម័តលើខ្លឹមសារទាំងមូលនៃសេចក្តីព្រាងច្បាប់នេះជាមុនសិន ឯកឧត្តម ស កាពុន អញ្ជើញចុះ ។

**ឯកឧត្តម ស ភាពុន:** សូមថ្វាយបង្គំសម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា សូមគោរពសម្តេចអនុប្រធានទី១ សូមគោរពឯកឧត្តមអនុប្រធានទី២ សូមគោរពអង្គសភាទាំងមូល ហើយនិងសូមគោរពតំណាងរាជរដ្ឋាភិបាល ។ ចំពោះសេចក្តីព្រាងច្បាប់ពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ទូលព្រះបង្គំខ្ញុំបាទមានយោបល់ថា យោលទៅលើការជាក់ស្តែងប្រល័យពូជសាសន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលទូលព្រះបង្គំខ្ញុំបាទបានរស់នៅពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ មករា ឆ្នាំ១៩៧៩ គឺ៣ឆ្នាំ ៨ខែ ២០ថ្ងៃ យោលទៅលើមតិជាតិនៃប្រជាជនកម្ពុជាដែលបានទទួលរងគ្រោះដោយរបបប្រល័យពូជសាសន៍នេះ យោលទៅលើមតិអន្តរជាតិនិងយោងមាត្រា៦នៃអនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទូលព្រះបង្គំខ្ញុំបាទមានយោបល់ថាត្រូវយកសេចក្តីព្រាងច្បាប់នេះមកពិភាក្សានិងអនុម័ត សូមអរគុណ ។

**សម្តេចក្រុមព្រះ:** សូមអរគុណឯកឧត្តម សូមអញ្ជើញឯកឧត្តម សម រង្ស៊ី ។

**ឯកឧត្តម សម រង្ស៊ី:** សូមក្រាបថ្វាយបង្គំសម្តេចព្រះប្រធានរដ្ឋសភា សូមគោរពអង្គសភាទាំងមូល ហើយសូមគោរពតំណាងរាជរដ្ឋាភិបាល ក្នុងនាមគណបក្សសមរង្ស៊ី ទូលបង្គំខ្ញុំសូមគាំទ្រសេចក្តីព្រាងច្បាប់នេះដែលឆ្លុះបញ្ចាំងនូវកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ហើយម្សិលមិញនេះទូលបង្គំខ្ញុំបានទទួលការបញ្ជាក់ពីឯកឧត្តម សុខ អាន ជាតំណាងរាជរដ្ឋាភិបាល ក្នុងកិច្ចពិភាក្សាថ្ងៃនេះគឺថាសេចក្តីព្រាងច្បាប់នេះគឺឆ្លុះបញ្ចាំងទាំងស្រុងនៅកិច្ចព្រមព្រៀមរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ទោះគ្មានអត្ថបទជាភាសាអង់គ្លេសក៏ដោយ ប៉ុន្តែអ្វីដែលចែងជាខេមរភាសានេះគឺគ្មានឃ្លាតអ្វីគួរឲ្យកត់សម្គាល់ពីខ្លឹមសារនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ដូច្នេះទូលបង្គំខ្ញុំសូមគាំទ្រទាំងស្រុងនូវសេចក្តីព្រាងច្បាប់នេះ ។

**សម្តេចក្រុមព្រះ:** សូមអរគុណឯកឧត្តម សូមអញ្ជើញឯកឧត្តម ឃ្លោក ប៊ុតឌី ។

**ឯកឧត្តម ឃ្លោក ប៊ុតឌី:** សូមក្រាបបង្គំថ្វាយសម្តេចក្រុមព្រះ ព្រះប្រធាននៃរដ្ឋសភា សូមគោរពសម្តេចអនុប្រធានទី១ ឯកឧត្តមអនុប្រធានទី២ ព្រះអង្គម្ចាស់ និងឯកឧត្តម លោកជំទាវ សមាជិកសមាជិកានៃអង្គសភា ទូលបង្គំខ្ញុំបាទមិនខុសពីឯកឧត្តមតំណាងរាស្ត្រពីមុនហ្នឹងដែរ សូមក្នុងករណីនៃច្បាប់សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់ទោសឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ សូមធ្វើសេចក្តីគាំទ្រយ៉ាងពេញទំហឹងលើខ្លឹមសាររួមនៃច្បាប់នេះ ដោយទូលបង្គំខ្ញុំបាទជឿជាក់ថាមុខជាឯកឧត្តមតំណាងរាជរដ្ឋាភិបាលដែលបានខំប្រឹងប្រែងធ្វើច្បាប់នេះឡើងមុខជាលុះនិងបញ្ជាក់ថា ខ្លឹមសារនៃច្បាប់ទាំងអស់ប្រាកដជាស្របទៅតាមលទ្ធផលនៃការសម្រុះសម្រួលរវាងរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិពិតប្រាកដមែន គ្រង់ណេះទូលបង្គំសូមគាំទ្រ ហើយសូមអរគុណ ។

**សម្តេចក្រុមព្រះ:** អរគុណឯកឧត្តម សូមអញ្ជើញឯកឧត្តម ឈួរ លាងហួត ។

**ឯកឧត្តម (ឈួរ លាងហួត)**: ទូលបង្គំសូមថ្លែងអំណរគុណដល់សម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា ហើយទូលបង្គំសូមគោរពដល់អង្គសភាទាំងមូល ទូលបង្គំក៏ដូចជាវាគ្មិនមុនៗដែរគឺថា ក្រោយពីបានពិនិត្យតាមដានយ៉ាងល្អិតល្អន់នូវខ្លឹមសារសេចក្តីព្រាងច្បាប់នេះឃើញថា សេចក្តីព្រាងច្បាប់នេះមានលក្ខណៈគ្រប់គ្រាន់ដើម្បីដំណើរការជំនុំជម្រះបទល្មើសប្រល័យពូជសាសន៍នៅកម្ពុជាបានហើយក្នុងនោះដែរ ទូលបង្គំខ្ញុំមានសេចក្តីមិនមែនគ្រាន់តែសប្បាយរីករាយ រំភើបយ៉ាងធំឥតឧបមាដោយឃើញថាស្មារតីមាតុភូមិនិយមបាននិងកំពុងតែបញ្ជាក់នៅក្នុងពេលនេះ ។ យ៉ាងណាមិញ កន្លងម៉ោយើងឃើញហើយថា មតិមួយចំនួនជាពិសេសមតិរបស់ខ្មែរមួយចំនួនដែលមិនទុកចិត្តលើខ្មែរគ្នាឯង មិនទុកចិត្តលើខ្លួនឯង ហើយទាមទារឲ្យតុលាការអន្តរជាតិជំនុំជម្រះរឿងនេះ ហើយកន្លងម៉ោយើងដឹងហើយថា រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ទាមទារតវ៉ាយ៉ាងស៊ិតស្វាញ

ជាមួយនឹងអ្នកច្បាប់អន្តរជាតិ ហើយខ្ញុំជឿជាក់ថា ប្រហែលបន្តិចទៀតនេះឯកឧត្តមតំណាងរាជរដ្ឋាភិបាលនឹងឡើងជម្រាបជូនហើយ ។ ការតវ៉ានេះគឺត្រូវមតិជាតិនិងអន្តរជាតិខ្លះដែលខ្វះការពិចារណាទិតៀនយ៉ាងខ្លាំងមែនទែន ហើយខ្លះនិងមិនមែនគ្រាន់តែមិនជួយចូកជួយថែវទេ ថែមទាំងយកដើងរាទឹកទៀត ។ ហើយអ្វីដែលយើងទាំងអស់គ្នាដែលអ្នកនៅក្នុងស្រុកនោះថានៅក្នុងស្រុកចុះដែលខិតខំតស៊ូខាំមាត់សង្កត់ចិត្ត នេះដោយសារយើងគោរពនូវស្មារតីនៃរដ្ឋធម្មនុញ្ញ ហើយអ៊ីចឹងហើយបានគេតែងជេរពួកយើងខ្ញុំនៅក្នុងស្រុកថាអាខ្លួនខ្មែរក្បាលយួន អាហ្នឹងក៏គេជេរដែរ គេជេរអ៊ីចឹង គេថាស្អីគេយុបយិត គេថាត្រូវការកេរ្តិ៍ខ្មាស់គេតិះដៀល ប៉ុន្តែការពិតវាត្រូវជាការពិត ឯកឧត្តមលោកជំទាវទាំងអស់គ្នាបានចូលរួមសរសេររដ្ឋធម្មនុញ្ញហើយ ហើយចូលរួមរៀនរដ្ឋធម្មនុញ្ញសិក្ខាមិនដឹងប៉ុន្មានទេ ទូលបង្គំមើលឃើញដល់យូរៗខ្ចិលចូលរួមរៀនសូត្រសិក្ខាសាលាផង ពីព្រោះ ប៉ុន្តែអ៊ីដែលគេមិនបានចាប់អារម្មណ៍នោះគឺនៅក្នុងឃ្លាមួយនៃរដ្ឋធម្មនុញ្ញ ហើយដែលរដ្ឋធម្មនុញ្ញនេះមានតាំងតែពីសរសេរនៅឆ្នាំ១៩៨១ម្ល៉េះ សរសេរយ៉ាងណា? សរសេរថា ខ្ញុំបាទទូលបង្គំសូមបើកមើលបន្តិចចុះ ពីព្រោះយូរទៅភ្លេចដែរ សរសេរនៅក្នុងមាត្រា១ដែលថាប្រជាជនកម្ពុជាជាម្ចាស់វាសនានៃប្រទេសរបស់ខ្លួន ឃ្លានេះហើយដែលយើងខ្ញុំដែលជាអ្នកច្បាប់នៅក្នុងស្រុកតិចតួចដែលរស់នៅសេសសល់នេះខិតខំបញ្ចូលគំនិត ហើយឲ្យបងប្អូនយើងចងចាំនោះថាខ្មែរមិនលក់ខុត្តមគតិខ្លួនទេ ហើយមើលយើងសរសេរឃ្លាមុនដំបូងយើងជាឯករាជ្យ អធិបតេយ្យ បើយើងគ្រាន់តែឯករាជ្យអធិបតេយ្យលើដី យើងជាម្ចាស់ដី ប៉ុន្តែខួរក្បាលនោះខ្ញុំគេខួរក្បាលនោះឲ្យគេដឹកនាំ អានេះមិនមែនជាខ្មែរទេ ។ ខ្មែរជាម្ចាស់វាសនារបស់ខ្លួន ខ្មែរកំណត់ខ្លួនឯង គំនិតនេះហើយមិនមែនមានឥឡូវទេ មានតាំងពីយើងសរសេររដ្ឋធម្មនុញ្ញឯណោះ ហើយយើងទ្រាំអត់សង្កត់ចិត្តធ្វើការងារឲ្យបានសម្រេច ថ្ងៃហ្នឹងសម្រេចហើយសម្រេចធំ ពួកដែលធ្លាប់ប្រឆាំងឥឡូវគាំទ្រមួយរយភាគរយមិនទាន់បានពិភាក្សាផង ន៉ែ ដល់តែខ្លាចៗអ៊ីចឹងខ្លាចគាំទ្រមួយរយភាគរយ មិនបានទាំងមើលផងដើរសួរគេសួរឯង ឯកសារនៅណោះណោះ អ៊ីចឹងបានថាគំនិតនេះមិនជាស្រួលប៉ុន្មានទេ គំនិតល្អគឺថាខ្មែរម្ចាស់ការ ធ្វើអ្វីកំណត់ដោយវាសនាដោយខ្លួនឯង ហ្នឹងទើបជាខ្មែរ ។ ពេលនេះគឺថាជាលទ្ធផលមួយដែលបញ្ជាក់ថាយើងតស៊ូយូរលង់ណាស់ទម្រាំចេញ នេះហើយដោយសារស្នាដៃរបស់រាជរដ្ឋាភិបាល ជាពិសេសសម្តេចនាយករដ្ឋមន្ត្រី ហើយដែលក្នុងនោះមានសហការីមួយចំនួនដែលតស៊ូមតិ ។ ខ្ញុំសូមជម្រាបថាខ្ញុំនេះមិនមែននៅក្នុងរដ្ឋាភិបាលទេ ប៉ុន្តែប្រហែលជាដឹងថាខ្ញុំហ្នឹងជាអ្នកចេះច្បាប់តិចតួចដែរ ។ ពួកបរទេសអ្នកណាមោ៉ចេះតែតាមសួរ គ្រាន់តែគេហៅស៊ីបាយនោះមិនដឹងនេះទេ សិក្ខាសាលាហ្នឹងក៏មិនដឹងយកទៅណាដែរ គេតាមសួរគេចង់ដឹង ចង់ដឹងគំនិតយើងហ៎ គេមើលមិនឃើញខួរក្បាលយើង ពីព្រោះយើងជាម្ចាស់វាសនាប្រទេសយើង វាសនាមើលម៉េចឃើញ បើឯករាជ្យទឹកដីព្រំដែនគេមើលឃើញ សួរៗៗណាស់ សួរថាតើយើងកំណត់យ៉ាងម៉េច ក្នុងការជជែកពិភាក្សាអ្នកច្បាប់ធំៗ កុំនិយាយតូចតាចនោះ ម៉ោត្រឹមបើកសិក្ខាសាលានោះតូចតាចទេ អ្នកច្បាប់ធំៗក្នុងការពិភាក្សាគេគោរពសរសើរគ្នាយើងរមិរម៉ក់នៅក្នុងស្រុកហ្នឹង ដែលចេះអី ដែលចេះស្រឡាញ់ជាតិខ្លួន ចេះស្រឡាញ់អធិបតេយ្យរបស់ខ្លួន ចេះស្រឡាញ់រដ្ឋធម្មនុញ្ញរបស់ខ្លួន ចេះកំណត់វាសនាខ្លួនដោយខ្លួនឯង ហ៊ានតស៊ូមតិមិនព្រមចុះញ៉ម គេចេះគោរពសិទ្ធិគ្នា គឺអ៊ីចឹងបានច្បាប់ហ្នឹងឃើញទេ អ្នកដែលមិនដឹងចេះតែជេរយើងថាម៉េចចេះតែទុកយូរម្ល៉េះ ទុកយូរម៉េចបើនៅចរចាគ្នា ហើយរឿងអធិបតេយ្យ ជេរទៅ គេចង់យកប្រយោជន៍គេ យើងចង់យកប្រយោជន៍យើងដែរ ប្រយោជន៍យើងស្អី ការពារកន្លែងត្រង់ហ្នឹងការពារស្មារតីកំណត់វាសនាខ្លួនដោយខ្លួនឯង មិនឲ្យគេម៉ោកំណត់ទេ យើងដឹងហើយមានខ្មែរមួយចំនួននោះ រឿងអីតូចតាចសូមឲ្យតុលាការប៉ារីស អ្វីតុលាការណោះណោះ ខ្មែរឯងមិនព្រមឲ្យមើលទេ នេះហើយដែលថាគំនិតគេហៅថាគោងកន្ទុយគេ គោងកន្ទុយបរទេស ខ្មែរអត់អ៊ីចឹងទេ គ្មានគំនិតណីងទេ កំណត់ខ្លួនឯង នេះហើយគេហៅថាយើងជាម្ចាស់ ហើយគំនិតនេះយើងមានទាំងអស់គ្នាហើយសព្វថ្ងៃនេះគេតែង ម៉ោបង្រៀនស្អីប្រជាធិបតេយ្យ លិទ្ធិប្រជាធិបតេយ្យស្រឡាញ់ជាតិដល់យើង សុទ្ធតែស្អីៗ ទូលបង្គំជម្រាបតាមត្រង់នៅពេលនេះ មិនទៅចូលសិក្ខាសាលាពីព្រោះវាឈឺក្បាលពេក ចាស់ហើយឡើងឈាមផង តែគេពន្យល់ច្រើនពេក

ឡើងឈាមបានជាមិនចូល មិនសូវចូលទេ ហើយទូលបង្គំក៏បានរៀនដែរអារឿងប្រជាធិបតេយ្យហ្នឹង រៀនតាំងពីសាលាអើយ ម៉ោម៉្លេះ គ្រាន់តែមើលសៀវភៅ អស់រាប់អើមិនដល់ពាន់ទេក៏រាប់រយជិតពាន់ដែរ ហើយគ្រូទូលបង្គំបានសួរថាម៉េចប្រជាធិបតេយ្យ គ្មានអ្នកណាថាប្រាកដមួយទេ ឆ្លើយឯណាណោះ គាត់ថាប្រជាធិបតេយ្យអ្វី ប្រឡិមប្រឡុំបើថាអ្នកណាថាប្រជាធិបតេយ្យទៅមើល អត់ដឹងគ្រាន់តែម៉ោសួរពេលនេះមិនដឹងជាប្រជាធិបតេយ្យយ៉ាងម៉េចទេ ហើយអ្នកដែលថានេះ ព្រះអង្គក៏បាននិយាយហើយដែរថា ប្រទេសមួយចំនួននោះក៏កំពុងតែជជែកគ្នាពីរឿងប្រជាធិបតេយ្យដែរ នេះហើយបានថាយើងត្រូវហ៊ានកំណត់ខ្លួនយើងថាយើងនេះ ហើយជាប្រទេសមួយប្រជាធិបតេយ្យហើយគឺថាប្រជារាស្ត្រយើងនេះជាតំណាងប្រជាជន ហើយដែលកំពុងតែកំណត់វាសនាប្រទេស ដោយខ្លួនហើយ កំណត់ទី១ក្នុងអី ក្នុងការធ្វើច្បាប់ ទី២ដល់ទៅជំនុំជម្រះគឺខ្មែរធ្វើទៅដោយខ្លួនឯងទៀត ត្រង់ថាគេចូលរួមម៉េចៗ ក៏ដោយ ក៏យើងទាមទារបានមតិភាគច្រើនដែរ អាហ្នឹងក្នុងការចរចាណោះចេញជាមតិភាគច្រើនតាមមើលទៅកុំចាំ ម៉េចបើយើង នៅភាគច្រើនដែរ ប៉ុន្តែទោះបីជាយ៉ាងណាក៏នេះដែរៗ យើងខ្ញុំសូមជម្រាបថា កន្លងម៉ោយើងដល់មិនទទួលដាច់ខាតឲ្យតុលាការ អន្តរជាតិជំនុំជម្រះ ព្រោះយើងមានបទពិសោធន៍ហើយ អន្តរជាតិមិនមែនជួយយើងចប់ចុងចប់ដើមទេ គេជួយតែជំនុំជម្រះទេ រួចជំនុំជម្រះហើយយកទៅដាក់គុកឯណា អន្តរជាតិមានគុកណាដាក់ ដាក់គុកស្រុកណា មានស្រុកណាមានគុកដាក់ គ្មានគុកអន្តរជាតិទេ មានតុលាការអន្តរជាតិ មានដល់គុកអន្តរជាតិមិនដាក់ឯណា ខ្មែរនឹងដាក់គុកខ្លួនឯងគ្នាឯងដដែលហ្នឹងៗ យើងខ្ញុំមានពិសោធន៍ ច្បាស់ណាស់ កាលអ៊ុនតាក់ចូលម៉ោបោះឆ្នោត គេធ្វើច្បាប់អីហើយចាប់មនុស្សម៉ាគំនរយកកាលម៉ាហ៊ឹកបោះឆ្នោតណឹងទេ ចាប់ប៉ូលិស អ៊ុនតាក់ចាប់ដែរតើ ចាប់យកទៅ ស្រាប់តែថាហក់! អ៊ុនតាក់ចាប់ហើយភ័យប្រឡោតគោតតូង មិនដឹងយកប្រគល់ មនុស្សទៅណា ចាប់ហើយមិនដឹងយកទៅប្រគល់ទៅតុលាការណា រត់ម៉ោក្រសួងយុត្តិធម៌ កាលហ្នុងសពឯកឧត្តម ចែម ស្ងួន គាត់ថាទេខ្ញុំអត់ទទួលគាត់ទេ គាត់ចង់លេងជាមួយអាន៎ែអន្តរជាតិហើយ គាត់ថាទេខ្ញុំមិនដឹងទេ អ្នកឯងចាប់ អ្នកឯងទទួលខុសត្រូវ យកទៅកាត់ឯណា កាត់ទៅខ្ញុំមិនដឹងទេ អ្ហ៎ូ! អង្វរ ៗ ខ្លាច សន្ធតកាត់នេះទៅគាត់អាចសម្រួលការងារ ប៉ុន្តែឲ្យដឹងថាខ្មែរត្រូវធ្វើ មិនមែនអ្នកឯង នេះទេ ម៉ោចាប់ហើយម៉េចក៏មិនបញ្ជូនម៉ោ ចាប់យកទៅទុកអស់ ទុកតទៅទៀត អូ! ភ័យដែរ រត់យកម៉ោហ្នឹង អាហ្នឹងអ៊ីចឹងៗ រួចរឿងហ្នឹងអ៊ីចឹងទៀតដែរទារឲ្យតុលាការ រួចឥឡូវនេះបើតាមដែលខ្ញុំដឹង យើងមើលកាសែតយើងដឹងហើយ យើងបង្កើតតុលាការ អ៊ីចឹងហើយគេសួរន៎ែ តាមមើលដូចជាសួរសម្តេចនាយក ហ៊ានទៅចាប់ទេ ៗ បើកាលណាចេះទេឲ្យចាប់ តុលាការគ្រាន់តែចាប់ ហ្នឹងមិនហ៊ានទាំងទៅចាប់ផង អានេះហើយមិនខុសអីកាលពីជំនាន់អ៊ុនតាក់ទេ ក្អេងក្អាងតែនៅអីភ្នំពេញទេ ដល់ពេលទៅដល់រៀប ចូលទៅប៉ៃលិនខ្មែរក្រហមតូចមួយកាន់កាំភ្លើងអាកាដាក់ឬស្សីតែម៉ាដើម អ្ហ៎ូ! រទេះកង់អីឈប់ឡូដផ្លែ ថាអត់ ហ៊ានចូលទេ ចូលឯណា កាំភ្លើងមួយដើមតូចទេ តាមខ្ញុំដឹងអត់ហ៊ានចូលទេ នេះហើយយើងមានពិសោធន៍ណាស់ ប៉ុន្តែយើងអត់ និយាយ យើងដឹងថារឿងខ្លះយើងជាម្ចាស់ការបានកើត បើយើងចង់ឲ្យសម្រេចគឺយើងធ្វើខ្លួនយើង យើងសម្រេច យើងបានធ្វើបាន គេជួយបាន ប៉ុន្តែគេធ្វើកន្លែងខ្លះគេធ្វើមិនបានទេ ពីព្រោះគេមានអាណត្តិគេ គេមិនចេះស៊ីប្រហុក គេមិនចេះដេកព្រៃ គេមិនដឹងស្អីទេ គ្រប់សព្វទាំងអស់ ភាសានិយាយមិនត្រូវគ្នាផង ម្នាក់និយាយលិច ម្នាក់និយាយកើត ច្បាប់ក៏មិនត្រូវគ្នា អ្នកខ្លះចេះច្បាប់បានតែមួយ ជ្រុងយកម៉ោ ជំនាញការ ន៎ែវាអញ្ចេះ បានថាសព្វគ្រប់ហើយយើងបទពិសោធន៍ច្រើនណាស់រឿងអន្តរជាតិនេះ អ៊ីចឹងហើយ បានជាយើងខំតស៊ូមតិ ប៉ុន្តែយើងមិនមាត់ ថាធ្វើម៉េចឲ្យរឿងប្រល័យពូជសាសន៍នៅកម្ពុជាត្រូវតែកាត់ ប៉ុន្តែកាត់ហើយឲ្យផ្តល់ យុត្តិធម៌ ថាឲ្យធ្វើបានសម្រេចដល់ចប់ចុងចប់ដើម ជជែកគ្នាទៅ គឺថាគ្មានអីជាងខ្មែរកាត់ដោយខ្មែរទេ អ៊ីចឹងបានយើងខំតស៊ូមតិនេះ ថាថ្ងៃនេះសម្រេចហើយ ហើយត្រង់ថាច្បាប់អាម៉េចៗនោះ អានេះទុកឲ្យឯកឧត្តម សុខ អាន នឹងពន្យល់ថែមទៀត ប៉ុន្តែអ្វីដែល ខ្ញុំចូលរួមក្នុងខ្លឹមសាររួមនេះគឺថា ស្មារតីម្ចាស់ការ ស្មារតីម្ចាស់វាសនាប្រទេសជាតិ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញគឺបានសម្រេចហើយ សម្រេចនេះសូមទុកជាប្រវត្តិសាស្ត្រ ហើយសូមឲ្យបងប្អូនខ្មែរនៅថ្ងៃក្រោយណោះកុំលក់ខួរក្បាលឲ្យទៅគេ បើលក់យកលុយ

*លក់ទៅ ប៉ុន្តែកុំលក់ជាតិ លក់ខ្លួនទៅបម្រើគេទៅចុះ ប៉ុន្តែខួរក្បាលស្មារតីជាតិនោះណា៎ អាណឹងមានចែងនៅក្នុងរដ្ឋធម្មនុញ្ញហើយ ហើយចែងរដ្ឋធម្មនុញ្ញនេះចែងចារឹកគ្រប់រដ្ឋធម្មនុញ្ញទាំងអស់ តាំងពី៨១រហូតម៉ោដល់រដ្ឋធម្មនុញ្ញសព្វថ្ងៃនេះទៀត អានេះជាចរិត នេះទូលបង្គំសូមចូលរួមក្នុងខ្លឹមសាររួមប៉ុណ្ណេះ សូមអរព្រះគុណ ហើយមានការទាស់ខុសយ៉ាងណាសូមព្រះអង្គហើយអង្គរដ្ឋសភាទាំងមូលមេត្តាអនុគ្រោះដល់ខ្ញុំ ។*

**សម្តេចក្រុមព្រះ:** *ឯកឧត្តម ជាម ចន្ទនី ។*

**ឯកឧត្តម ជាម ចន្ទនី:** *ទូលបង្គំខ្ញុំបាទដោយក្រោយពីពិនិត្យលើខ្លឹមសាររួមនៃច្បាប់ ទូលបង្គំខ្ញុំបាទសូមមិនបញ្ចេញយោបល់ សូមអរគុណ ។*

**សម្តេចក្រុមព្រះ:** *សូមអរគុណឯកឧត្តម សូមអញ្ជើញឯកឧត្តម គាត ឈន់ ។*

**ឯកឧត្តម គាត ឈន់:** *ទូលព្រះបង្គំក្រាបថ្វាយបង្គំសម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភាជាទីគោរព សម្តេចអនុប្រធានទី១ ឯកឧត្តមអនុប្រធានទី២ និងសូមគោរពសភាទាំងមូល ទូលបង្គំសូមរាជានុញ្ញាតឡើងម៉ោនេះថ្វីដ្បិតតែខ្លួនឯងជាសមាជិករដ្ឋាភិបាល ហើយតំណាងរាជរដ្ឋាភិបាលនៅទីនេះនឹងការពារសេចក្តីព្រាងច្បាប់នេះហើយក៏ដោយ ទូលបង្គំសូមរាជានុញ្ញាតមានមតិក្នុងឋានៈជាតំណាងរាស្ត្រ ។ ថ្ងៃនេះសភាយើងកំពុងរៀបចំជាយន្តការមួយៗមិនមែនស្ថាប័នទេ សម្រាប់វិនិច្ឆ័យអតីតកាលៗ យើងទាំងអស់គ្នាច្រើនតែដឹងថា អតីតកាលមិនបាច់ព្យាករណ៍ទេ គឺយើងដឹងរួចហើយ នេះគឺជាការជាក់ស្តែង ក៏ប៉ុន្តែក្នុងប្រវត្តិសាស្ត្រ និយាយជារួមមកយើងពិបាកព្យាករណ៍អតីតកាលណាស់ (le passé est imprévisible) សូមនិយាយបារាំងផង (you can not predict the past) និយាយជាអង់គ្លេសទៅ ឃើញថាយើងពិបាកព្យាករណ៍អតីតកាល ។ សូម្បីតែក្នុងទំព័រប្រវត្តិសាស្ត្រជាច្រើនក៏មានការខ្វែងគ្នាដែរក្នុងការបកស្រាយនូវព្រឹត្តិការណ៍ទាំងឡាយ ប៉ុន្តែពេលនេះយើងត្រូវតែបង្កើតយន្តការមួយនេះដែលតាមសំណើរបស់រាជរដ្ឋាភិបាលដើម្បីនឹងវិនិច្ឆ័យអតីតកាល ។ ហើយអតីតកាលនេះមិនមែនអតីតកាលដែលពិបាកព្យាករណ៍ទេ ពីព្រោះទាំងអស់គ្នាសុទ្ធតែឈឺចាប់ខ្លោចផ្សា អ្នកដែលរស់រាល់ថ្ងៃនេះឈឺចាប់ខ្លោចផ្សាចំពោះអតីតកាលដែលមាន ដែលយើងប្រុងនឹងបង្កើតយន្តការឲ្យវិនិច្ឆ័យនេះ ពីព្រោះជារយៈកាលមួយដែលជាកលយុគដែលខ្លោចផ្សាបំផុតចំពោះប្រទេសកម្ពុជាយើង ។ ដូច្នោះបានជាមានការចាំបាច់បង្កើតនូវយន្តការសម្រាប់វិនិច្ឆ័យអតីតកាលនេះ ហើយមិនបាច់ទៅណាឆ្ងាយទេ ឲ្យតែជួបគ្នារាល់ថ្ងៃនេះនៅទីណាឋានណាក៏ដោយ ចង់នៅក្នុងភ្នំពេញឬមួយចង់នៅបរទេស ទៅជួបគ្នានៅសហរដ្ឋ អាមេរិកឬជួបគ្នានៅបារាំង ឬនៅអូស្ត្រាលី ឬនៅត្រង់ណា បើនិយាយទៅរៀបរាប់ដំបូងមិត្តភាពអីធម្មតា ដល់រួចម៉ោចូលទៅប្រវត្តិផ្ទាល់ខ្លួននិងការឈឺចាប់ផ្ទាល់ខ្លួន និយាយមិនចប់ទាល់តែម៉ាស្របក់ទាល់ថាហ្នឹងអីចឹងចាំនិយាយរឿងអីផ្សេង ពីព្រោះវាថាសណ្តោងសោកនាដកម្មដែលគ្របដណ្តប់ម៉ោលើប្រទេសកម្ពុជា ៧៥-៧៩នេះវាប៉ះទាំងអស់ ទាំងអស់គ្នាអ្នកដែលនៅរស់ រស់ហើយក៏សភាពយើងមិនធម្មតាដែរ ទាំងអស់គ្នាយើងនៅទ្រោម ទ្រោមជារូបកាយនោះម្យ៉ាង ប៉ុន្តែទ្រោមលើអារម្មណ៍នេះ អីចឹងហើយបានអារម្មណ៍យើងទ្រោម ហើយត្រង់ហ្នឹងហើយដែលទាមទារពីយើងនូវកម្លាំងចិត្ត កម្លាំងប្រាជ្ញា កម្លាំងស្មារតី កម្លាំងអារម្មណ៍ ខ័ន្ធទាំងប៉ុន្មានរបស់យើងនេះដើម្បីនឹងធ្វើម៉េចក្នុងការវិនិច្ឆ័យនេះឲ្យបានសត្យានុម័តិបំផុត សម្រាប់អ្វី? សម្រាប់ថាថ្ងៃក្រោយទៀតនៅលើទឹកដីនេះ ឬនៅលើទឹកដីដទៃ នៅលើទឹកដីនៃប្រទេសនេះ ឬលើទឹកដីនៅប្រទេសដទៃ កុំឲ្យមានកលយុគដែលពោរពេញទៅដោយការស្លាប់ ការពាត់ប្រាសនិរាសខ្លោចផ្សាទៀត ហើយដែលប៉ះសង្គម និគម សហគមន៍របស់មនុស្សច្រើនមហាច្រើន តួលេខអាចនឹងខ្វែងគ្នាថា៣លាននាក់ចំពោះអ្នកដែលចាកលោកទៅនេះ ឬមួយថា១លាន៧សែន ប៉ុន្តែប៉ុន្មានក៏ដោយ សូម្បីតែ១សែននាក់ឬ២ម៉ឺននាក់ក៏វាហួស ពីព្រោះវាមិនត្រូវឲ្យមានព្រឹត្តិការណ៍យ៉ាងនេះសោះ ។ ១៧ មេសា ១៩៧៥ សង្ឃឹមថាជាតិអាចនឹងវិលមកទទួលបានសន្តិភាព ស្រុះស្រួលផ្សះផ្សាជាតិឡើងវិញបានក្រោម កាលនោះក្រោមការដឹកនាំសម្តេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ ប៉ុន្តែមានការឆក់ប្លន់អំណាច*

ហើយបង្វែរប្រទេសដែលមានពន្លឺហើយនេះឲ្យចូលមិនគ្រាន់តែក្នុងភាពងងឹតស្ងប់ស្ងាត់សូន្យសុងទេ គឺក្នុងភាពមួយដែលអណ្តាតភ្លើងឆេះរោលថែមទៀត ។ ដូច្នោះយើងមានកាតព្វកិច្ចមួយនៅទីនេះ គឺកាតព្វកិច្ចបង្កើតឲ្យបាន ហើយបើតាមមើលទៅច្បាស់ជាមានភាពឯកច្ឆ័ន្ទ ពីព្រោះរាជរដ្ឋាភិបាលបានធ្វើការនេះក្រោមការដឹកនាំផ្ទាល់របស់សម្តេចនាយករដ្ឋមន្ត្រី ហើយនិងតាមរយៈមតិណែនាំពីស្ថាប័នជាន់ខ្ពស់ដទៃទៀតនារដ្ឋសភា មានសម្តេចប្រធានរដ្ឋសភា សម្តេចព្រះប្រធានរដ្ឋសភាជាដើម សម្តេចប្រធានព្រឹទ្ធសភាជាដើម ខ្ញុំបាទមិនហ៊ាននិយាយពី មិនហ៊ានវិនិច្ឆ័យពីការណែនាំដ៏ខ្ពង់ខ្ពស់បំផុតពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទេ នេះច្បាស់ចេញជាភាពជាឯកច្ឆ័ន្ទមួយដើម្បីអ្វី? ហើយនេះសូមលើកយកពាក្យរបស់ អេលី វាលហ្វែរុល (Elie Wiesel) ដែលជាជ័យលាភីណូបែលខាងសន្តិភាពមកដើម្បីនឹងគូសសង្កត់បញ្ជាក់ មិនមែនថាយើងអត់ពាក្យទេនិយាយខ្លួនយើង ម្នាក់ៗមានពាក្យនិយាយច្រើនណាស់ក្នុងរឿងនេះ គ្រួសារណាក៏ដោយ មនុស្សណាក៏ដោយ គ្រាន់តែប្រហែលជាក្មួយៗជំនាន់ក្រោយលោកមិនបានរស់នៅផ្ទាល់ ក៏ប៉ុន្តែអ្នកដែលដឹងក្តី ដែលរស់ហើយដឹងក្តី ពេលនោះគឺចងចាំរហូត ។ ពាក្យ អេលី វាលហ្វែរុល ជ័យលាភីណូបែលខាងសន្តិភាពគាត់មានប្រសាសន៍ថា «យើងធ្វើយ៉ាងណាកុំឲ្យឃាតករវាសម្លាប់យើងពីរដង ទីមួយវាសម្លាប់រូបកាយយើង ទីពីរវាសម្លាប់ការចងចាំរបស់យើង» ។ ហើយសុំនិយាយជាភាសាបារាំងទៅ *Il peux pas de l'assassats (?) tue deux fois, [pour la] première fois physiquement [votre?] physique-- et deuxiement [votre?] mémoire* **(មជ្ឈមណ្ឌលឯកសារកម្ពុជាសូមជូនការបកប្រែពីឃ្លាដើមដែលមានប្រសាសន៍ដោយលោក អេលី វាលហ្វែរុល មកជាភាសាអង់គ្លេសដែលមានន័យថា *you can not be murdered twice, the first time physically and to have your memory killed the second time*)** ដូច្នោះការបង្កើតជាយន្តការដើម្បីវិនិច្ឆ័យអតីតកាលដ៏ខ្មៅងងឹតសូន្យសុងឈឺខ្លោចផ្សាដែលមានមនុស្សមានជនជាតិ កម្ពុជាដែលមាននិគមដែលរស់នៅលើជាតិជនជាតិដែលនៅលើទឹកដីកម្ពុជានេះរាប់លាននាក់ យើងមានកាតព្វកិច្ចចំពោះការចងចាំដើម្បីនឹងឲ្យកើតជាកម្លាំងមួយកសាងអនាគតឲ្យភ្លឺស្វាង ឲ្យចៀសផុតពីការដែលកើតមានពី៧៥ដល់៧៩នេះ ។ និយាយយ៉ាងនេះយើងទាំងអស់គ្នាច្បាស់ជាមិនសូវយល់ខុសគ្នាប៉ុន្មានទេ ។ យើងដែលមានករណីកិច្ចចំពោះការចងចាំនេះគឺសម្រាប់យុត្តិធម៌ សម្រាប់គោរពបូជាវិញ្ញាណក្ខ័ន្ធអ្នកស្លូតត្រង់ទាំងលាននាក់ដែលបាត់ជីវិតទៅនេះគឺសម្រាប់យុត្តិធម៌ សម្រាប់ការចងចាំ ។ តែក្នុងអំពើជាក់ស្តែងក្នុងការដែលយើងកំពុងបង្កើននៅចលនាការពង្រឹងនូវសុខសន្តិភាព ពង្រឹងនូវឯកភាពជាតិ ការផ្សះផ្សាជាតិ ចលនាការកំណែទម្រង់និងអភិវឌ្ឍន៍ប្រទេសដែលកំពុងតែឈានឡើងនេះ បរិការទាំងឡាយនេះដែលយើងកំពុងតែធ្វើរៀបចំយន្តការនៅក្នុងបរិការនេះ ក៏យើងត្រូវគិតដល់នៅការចាំបាច់នៃប្រទេសក្នុងពេលបច្ចុប្បន្នដែរ ។ ការចាំបាច់រកយុត្តិធម៌ដូចទូលបង្គំខ្ញុំបាទបានទូលថ្វាយខាងលើហើយ ប៉ុន្តែការចាំបាច់ឲ្យត្រូវឲ្យមានតុល្យភាពរវាងជ្រុងត្រីកោណទាំងបី យុត្តិធម៌ ការពង្រឹងសន្តិភាពឯកភាពជាតិ ការផ្សះផ្សាជាតិនេះជាជ្រុងទីពីរ និងការចាំបាច់តម្រូវការបន្តកំណែទម្រង់និងអភិវឌ្ឍន៍ ។ និយាយនេះមិនមែនសម្រាប់សម្រាំងការងារ ស្នូលនៃយន្តការនេះទេ ក៏ប៉ុន្តែគ្រាន់តែការងារដែលយើងត្រូវឲ្យយន្តការនេះវិនិច្ឆ័យគឺស្ថិតនៅក្នុងបរិការថ្មីមួយនៃព្រះរាជាណាចក្រកម្ពុជាយើងដែលកំពុងតែឈានទៅមុខ និយាយជារួមយើងនៅប្រឈមនឹងការលំបាក យើងនៅជួបប្រទះនៅដុយស្រួយនៅឡើយ ។ ហេតុដូច្នេះហើយ ខ្ញុំបាទជឿជាក់ថា បង្កើតយន្តការនេះបានហើយដល់ការប្រព្រឹត្តទៅ ការរៀបចំយើងនឹងធ្វើកំណត់ទៅដល់ការប្រព្រឹត្តទៅ ការប្រតិបត្តិជាក់ស្តែងនោះនឹងត្រូវបានទទួលការគិតគូរអំពីការចាំបាច់ ពីព្រោះអ្វីក៏ដោយក្នុងដំណើរការយើងប្រចាំថ្ងៃគឺត្រូវថ្លឹងរហូតរវាងការចាំបាច់ តម្រូវការនិងអ្វីដែលយើងចង់បាន សូម្បីតែប្រជាធិបតេយ្យឬសេរីភាពយ៉ាងណានោះក៏ត្រូវស្ថិតនៅក្រោមការចាំបាច់ដែរ អម្បាញ់មិញឯកឧត្តម ឈួរ លាងហួតនិយាយអំពីប្រជាធិបតេយ្យ បើសិនជាប្រជាធិបតេយ្យធ្វើមិនស្រួលវាទៅជាអាណាធិបតេយ្យ ដូច្នោះវាត្រូវស្ថិតនៅក្នុងបរិការមួយដែលប្រជាធិបតេយ្យនេះត្រូវកសាងឡើង សេរីភាពនេះត្រូវកសាងឡើងក្នុងការចាំបាច់មួយដែលត្រូវការដោះស្រាយអ្វីនៅចំពោះមុខនេះដែរ គ្មានអ្វីមួយដែលជាដាច់ណាត់អាប់សូលូតទេ ។ សេរីភាពនិងការចាំបាច់ តែការចាំបាច់វាកំណត់សេរីភាពដែរហើយនៅ

ក្នុងប្រវត្តិមនុស្សតែងតែមានការប្រយុទ្ធរវាងការចាំបាច់ និងសេរីភាពនិងប្រជាធិបតេយ្យ ហើយប្រជាធិបតេយ្យយើងនេះនឹងរស់រាន មានជីវិតបានយូរលុះត្រាតែសុខសាន្តត្រាណស្ថិរភាព នយោបាយមានសន្តិភាពនេះម្យ៉ាង ម្យ៉ាងទៀតទាល់តែស្រទាប់មធ្យមយើង និងឡើងកាន់តែខ្ពស់ឡើង មិនមែនឡើងដោយសារបង្កើនប្រាក់ខែយកប្រាក់ខែពីរដ្ឋទេ ឡើងដោយសារការរីកចម្រើនប្រែងទូទាំង ប្រទេសឡើងជាស្រទាប់មួយដែលខ្លាំងហ្នឹងបាន ប្រជាធិបតេយ្យស្រទាប់កណ្តាលនោះ ស្រទាប់កណ្តាលមិនមែនអភិជនឬក៏អ្នកក្រីក្រ ទេគឺជាស្រទាប់កណ្តាលឲ្យធំបាន នឹងបានមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីនិងប្រជាធិបតេយ្យនឹងន ខ្ញុំមិនយកប្រទេសដទៃទៀតមៅ ប្រៀបធៀបទេ មានអ្នកខ្លះយល់សប្តិដែរ មានគ្នា៨ភាគរយក្នុងប្រទេសខ្លះដែលជាស្រទាប់ដែលគេហៅថាស្រទាប់កណ្តាលនោះ ដែល គេហៅថាជាគ្រឹះនៃប្រជាធិបតេយ្យនោះ ចង់ធ្វើការផ្លាស់ប្តូរហើយសំណង់ប្រជាធិបតេយ្យដែលជាសំណង់ស្រទាប់លើនេះវានៅ តែលតោល វាអត់គ្រឹះសេដ្ឋកិច្ចទ្រទ្រង់ វាគ្មានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចទ្រទ្រង់ ម្ល៉ោះហើយចលនាប្រជាធិបតេយ្យខ្លះធ្លាក់នៅក្នុង ថ្កុកឈាម ប៉ុន្តែប្រទេសខ្លះទៀតដល់មាន១៦-១៧ភាគរយធំថែមទៀតផង ដំណើរការបោះឆ្នោតប្រជាធិបតេយ្យអីបាន ប៉ុន្តែ ប្រជាធិបតេយ្យមានកម្រិតដែរ ។ ហើយទូលព្រះបង្គំយើងខ្ញុំសរុបមួយម៉ាត់ទៅគ្រាន់តែថា ដល់ពេលដំណើរការគិតគូរបរិការនៃ ការចាំបាច់ដើម្បីស្វែងរកយុត្តិធម៌ ដើម្បីនឹងរំងាប់នូវអ្វីដែលជាការឈឺចាប់ចំពោះអ្នករស់ ប៉ុន្តែដើម្បីនឹងបូជាប្រារព្ធដល់វិញ្ញាណក្ខ័ន្ធ អ្នកដែលបាត់បង់ជីវិតទៅដោយអយុត្តិធម៌បំផុត សូមអរព្រះគុណ សូមអរគុណ ។

**សម្តេចក្រុមព្រះ**: សូមអញ្ជើញឯកឧត្តម ឯក សំអុល ។

**ឯកឧត្តម ឯក សំអុល**: សូមថ្វាយបង្គំសម្តេចក្រុមព្រះ ព្រះប្រធាននៃរដ្ឋសភា សូមគោរពសម្តេចអនុប្រធានទី១ សូមគោរពឯកឧត្តម អនុប្រធានទី២ និងសូមគោរពអង្គសភាទាំងមូល ទូលព្រះបង្គំខ្ញុំបាទមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការដែលរដ្ឋសភា នីតិកាលទី២បានទទួលយកសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តី ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ថ្ងៃនេះជាថ្ងៃសុក្រ តាមច័ន្ទគតិគឺត្រូវថ្ងៃ៤កើត ខែបុស្ស ឆ្នាំរោង ពុទ្ធសករាជ២៥៤៣ ហើយក៏ជាថ្ងៃដែលគិតថាបរិយាកាសល្អជាទីបំផុតបើប្រៀបធៀបទៅនឹងការពិភាក្សាលើបណ្តា សេចក្តីព្រាងច្បាប់ទាំងឡាយកន្លងមកពុំដែលចាប់ផ្តើមឡើង ឯកឧត្តម សម រង្ស៊ី ប្រធានគណបក្សសមរង្ស៊ី ឡើងធ្វើការគាំទ្រ ។ ដូច្នេះបរិយាកាសថ្ងៃនេះល្អមែនទែន សុខស្រួលមែនទែន ហើយដែលទូលបង្គំខ្ញុំបាទគិតថាដំណើរការនៃការពិភាក្សានិងអនុម័តលើ សេចក្តីព្រាងច្បាប់នេះនឹងដំណើរការទៅបានលឿនជាងប្រក្រតីដែលអង្គសភាយើងធ្លាប់បានជួបប្រទះកន្លងមក ។ អានេះជាការកត់ សម្គាល់ ជាការចាប់អារម្មណ៍របស់ទូលព្រះបង្គំខ្ញុំបាទ ។ ទូលព្រះបង្គំខ្ញុំបាទគិតថា កាលដែលរដ្ឋសភាពិភាក្សានិងអនុម័តច្បាប់នេះ គឺមានសារៈសំខាន់និងមានលក្ខណៈជាប្រវត្តិសាស្ត្រសម្រាប់ព្រះរាជាណាចក្រកម្ពុជាទីពីរ ហើយក៏មានសារៈសំខាន់មានវិសាលភាព ទៅលើផ្ទៃរាបអន្តរជាតិទៀត ពីព្រោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍កន្លងមកនៅកម្ពុជានេះគឺជាការទន្ទឹងរង់ចាំជាច្រើនឆ្នាំកន្លង មកហើយ ពិសេសតាំងពីរដ្ឋសភានីតិកាលទី១ដែលមានសម្តេចក្រុមព្រះជានាយករដ្ឋមន្ត្រីទី១ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ បានលើកបញ្ហាត្រូវធ្វើសវនាការកាត់សេចក្តីអំពីឧក្រិដ្ឋកម្មនេះ ។ ដូច្នេះបើទូលព្រះបង្គំខ្ញុំបាទមិនច្រឡំទេគឺតាំងតែពីឆ្នាំ១៩៩៧ ដែលសម្តេចក្រុមព្រះជានាយករដ្ឋមន្ត្រីទី១ និងសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ ។ ពី៩៧ម៉ោងដល់ថ្ងៃ២៩ ធ្នូ ឆ្នាំ២០០០ ទើបសម្រេចបានជាសេចក្តីព្រាងច្បាប់មួយ ហើយដែលតាមស្តាប់បទអន្តរាគមន៍កន្លងមកនេះគឺជារួមសមាជិកសមាជិការដ្ឋសភា គាំទ្រនូវខ្លឹមសាររួមក៏ដូចដំណើរការទៅមុខទៀត ដូច្នេះទូលព្រះបង្គំខ្ញុំបាទសូមថ្វាយយោបល់និងលើកយោបល់ថាគួរតែអនុម័ត លើខ្លឹមសាររួមហើយព្រះអង្គ សូមអរព្រះគុណ សូមអរគុណ ។

**សម្តេចក្រុមព្រះ**: សូមអរគុណឯកឧត្តម ខ្ញុំសូមអង្គសភាទាំងមូលមេត្តាអនុម័តលើខ្លឹមសាររួមនៃសេចក្តីព្រាងច្បាប់នេះ ។

**លេខាធិការនៃអង្គប្រជុំ**: សូមគោរពទូលថ្វាយសម្តេចក្រុមព្រះ ព្រះប្រធាននៃរដ្ឋសភា សម្តេចអនុប្រធានទី១ ឯកឧត្តមអនុប្រធានទី២

អង្គសភាទាំងមូលមតិគាំទ្រលើច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ លើខ្លឹមសាររួមមាន៩៨លើ៩៨ ។

**សម្តេចក្រុមព្រះ**៖ សភាជាតិលោកបានអនុម័តខ្លឹមសាររួមនៃសេចក្តីព្រាងច្បាប់ ។ សូមអញ្ជើញឯកឧត្តមទេសរដ្ឋមន្ត្រី សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អញ្ជើញមកការពារច្បាប់នៅមុខអង្គសភា សូមអរគុណ ។

**ឯកឧត្តម សុខ អាន**៖ សូមក្រាបថ្វាយបង្គំសម្តេចព្រះប្រធានរដ្ឋសភា សូមគោរពសម្តេចអនុប្រធានទី១ ឯកឧត្តមអនុប្រធានទី២ ហើយសូមថ្វាយបង្គំគោរពអង្គសភាទាំងមូលជាទីគោរព ហើយក៏សូមស្វាគមន៍ឯកឧត្តមតំណាងស្ថានទូតដែលបានអញ្ជើញចូលរួមស្តាប់ការពិភាក្សានេះ ។ ទូលបង្គំខ្ញុំបាទ សុំជាបឋមមុននឹងធ្វើអត្ថាធិប្បាយជាសេចក្តីផ្តើមនៅលើសេចក្តីព្រាងច្បាប់ដ៏សំខាន់នេះ សូមព្រះរាជានុញ្ញាត សូមអនុញ្ញាត កត់សម្គាល់នូវចំណុចពីរ ទី១ទូលបង្គំខ្ញុំបាទនៅចងចាំថា នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ហើយថ្ងៃនេះ គឺជាថ្ងៃទី២៩ ខែធ្នូដែរ ឆ្នាំ២០០០ ។ កាលពីថ្ងៃ២៩ ខែធ្នូ ឆ្នាំ១៩៩៨នេះ ទូលបង្គំខ្ញុំបាទនៅចងចាំថាគឺជាថ្ងៃដែលថ្នាក់ដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមបានធ្វើដំណើរមកភ្នំពេញដើម្បីចុះចូលជាមួយរាជរដ្ឋាភិបាល ដូច្នេះថ្ងៃនេះក៏មានន័យនៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យដែរ ។ ចំណុចមួយទៀតដែលទូលបង្គំខ្ញុំបាទសូមធ្វើការកត់សម្គាល់ ដោយឯកឧត្តមសម រង្ស៊ី គាត់បានមានប្រសាសន៍ថា ម្សិលមិញបានសួរទូលបង្គំខ្ញុំបាទអំពីខ្លឹមសារនៃច្បាប់ថាតើមានការឃុបឃិតគ្នាជាមួយនឹងអត្ថបទរបស់អង្គការសហប្រជាជាតិឬទេបាទ ហើយបើកាលណាដូចគ្នាឯកឧត្តមគាំទ្រ ។ ទូលបង្គំខ្ញុំបាទក៏សូមកត់សម្គាល់នូវចំណុចនេះដែរ គឺអ្វីដែលទូលបង្គំបានឆ្លើយគឺថាបានជម្រាបជូនឯកឧត្តមថា ឯកឧត្តមជ្រាបហើយ នេះគឺជាការចរចា ។ ដូច្នេះរាល់ការចរចាមិនអាចភាគីម្ខាងយកជំហរដូចភាគីម្ខាងទៀតទេ បើដូចបេះបិទមួយរយភាគរយទៅនឹងជំហរម្ខាងទៀតនោះមិនជាការចរចាទេ នោះគឺជាការចម្លងតាម គឺជាការទទួលបញ្ជា ហើយការចរចាគឺមានន័យជាការចរចា ប៉ុន្តែអ្វីដែលគួរជាទីរីករាយគឺថាយើងបានឯកភាពគ្នាលើគោលការណ៍សំខាន់ៗ លើគោលការណ៍ធំៗ លើគោលការណ៍សំខាន់ៗដែលទូលបង្គំខ្ញុំបាទយល់ថាបទខុសឆ្គងនាមជាសេចក្តីផ្តើមរបស់ទូលបង្គំខ្ញុំបាទ នឹងឆ្លុះបញ្ចាំងជាក់ស្តែងនៅចំណុចទាំងនេះ ។ នៅក្នុងបទអត្ថាធិប្បាយនេះ ទូលបង្គំខ្ញុំបាទសូមលើកឡើងនូវចំណុចចំនួន៥៖ ចំណុចទី១គឺសូមទូលថ្វាយនិងជម្រាបជូនអង្គសភាដ៏ខ្ពង់ខ្ពស់ អំពីប្រវត្តិនៃតុលាការអន្តរជាតិ ឬក៏អ្វីដែលគេហៅថាតុលាការដែលកាត់សេចក្តីលើឧក្រិដ្ឋកម្ម ហើយតើតុលាការរបស់យើងនេះវាមានសារជាតិជាតុលាការអ្វី? ចំណុចទី២ ទូលបង្គំខ្ញុំបាទនិងលើកឡើងនូវទស្សនាទាន នូវគោលការណ៍សំខាន់ៗដែលជាមូលដ្ឋានគ្រឹះនូវសេចក្តីព្រាងច្បាប់ដ៏សំខាន់នេះហើយគោលការណ៍ចំណុចទី៣ គឺដំណើរការដែលចាប់ផ្តើមចាប់តាំងពីឆ្នាំ១៩៩៧ រហូតមកដល់ថ្ងៃនេះជាដំណើរការជាក់ស្តែងដែលយើងបានឈានមកដល់សេចក្តីព្រាងច្បាប់ជាក់ស្តែងរបស់យើងដែលអង្គសភាដ៏ខ្ពង់ខ្ពស់ពិភាក្សានៅថ្ងៃនេះ ។ ហើយចំណុចទី៤គឺការសម្រុះសម្រួលធំៗរវាងយើងនិងអង្គការសហប្រជាជាតិ *les grands compromis* បាទជាចំណុចសម្រុះសម្រួលគ្នាធំៗ ជាគោលការណ៍ធំៗដែលបង្កើតបាននូវសេចក្តីព្រាងច្បាប់នេះ ហើយចំណុចទី៥គឺជាខ្លឹមសារយ៉ាងសង្ខេបបំផុតនៃជំពូកនីមួយៗជាខ្លឹមសារសង្ខេបដោយយើងនឹងលើកឡើងជាជំពូកៗ ដូច្នេះទូលបង្គំខ្ញុំបាទនឹងសូមទូលថ្វាយនិងជម្រាបជូនអំពីខ្លឹមសារជាក់ស្តែងដោយខ្លីៗបំផុតនៃជំពូកនីមួយៗ ។ ទូលបង្គំខ្ញុំបាទសូមចាប់ផ្តើមនូវចំណុចទី១ដែលលើកឡើងនូវប្រវត្តិនៃតុលាការអន្តរជាតិផ្សេងៗដែលមាននៅលើសកលលោកទាំងមូលតាំងពីដើមរហូតមកដល់សព្វថ្ងៃនេះ ។ ទូលបង្គំខ្ញុំបាទក៏សូមបញ្ជាក់ដែរថា សញ្ញាណនៃរដ្ឋដែលគេហៅថាអេតា (Etat) នោះ ដឺស្តេត (the state) នោះ គឺបានចាប់កំណើតយូរយារណាស់មកហើយ ច្រើនរយឆ្នាំឬក៏រាប់ពាន់ឆ្នាំមកហើយ ហើយកំណាយថ្មីៗនេះគឺយើងមានមោទនភាពដែរនូវការស្រាវជ្រាវថ្មីៗនេះនៅក្នុងខេត្តតាកែវ គឺដែលគេស្រាវជ្រាវឃើញថាជាទីក្រុងទី១របស់កម្ពុជានោះគឺអ្នកស្រាវជ្រាវ គេពិនិត្យឃើញថានេះជារដ្ឋទីមួយនៅតំបន់អាស៊ី-អគ្នេយ៍ ។ អ៊ីចឹងទូលបង្គំក៏សូមចូលមកខ្លឹមសារនេះវិញគឺថានៅពេលដែលមានរដ្ឋហើយនោះ គេសញ្ញាណមួយ កិច្ចការមួយធំគឺការគោរពអធិបតេយ្យភាពជាតិរបស់រដ្ឋ គឺទ្រឹស្តីឯករាជ្យ

អធិបតេយ្យភាពជាតិ ហើយគោលការណ៍នោះគឺគោលការណ៍ធំបំផុតរបស់អង្គការសហប្រជាជាតិ ដែលធម្មនុញ្ញអង្គការសហប្រជាជាតិគឺលើកតម្កើង និងចាត់ទុកជាគោលការណ៍ដែលត្រូវគោរពជាដាច់ខាត ។ ដូច្នេះគឺការគោរពអធិបតេយ្យភាពជាតិ នៅក្នុងនោះមានន័យមួយយ៉ាងសំខាន់ចំពោះការរៀបចំតុលាការគឺថាតុលាការ ចៅក្រមរបស់ប្រទេសណាគេកាត់សេចក្តីនៅលើដែនដីនៃប្រទេសនោះ ហើយដូចជាគេលើកពីគោលការណ៍នៃដែនដីតាំងពី *Intégrité territorialité* ជាដើម ។ ដូច្នេះគឺប្រទេសនីមួយៗម្ចាស់ការកាត់សេចក្តីទៅលើប្រជាពលរដ្ឋរបស់គេដែលបានប្រព្រឹត្តខុសដែលបានធ្វើខុសពីច្បាប់រដ្ឋរបស់គេ ហើយដែលជាការអនុវត្តច្បាប់ ហើយដែលជាបន្តិចម្តងៗគឺកកើតឡើងនូវទ្រឹស្តីនៃនីតិរដ្ឋ ដែលសព្វថ្ងៃនេះយើងកំពុងតែខិតខំជំរុញលើកកម្ពស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងនេះដែរ ។ ដូច្នេះបើយើងនិយាយពីខ្លឹមសារនេះគឺថាតាំងពីមុនតាំងពីកកើតដែលជារដ្ឋម៉ោរហូតម៉ោមុនសម័យសង្គ្រាមលោកលើកទី២ គឺការគោរពអធិបតេយ្យភាពជាតិ គឺតុលាការជាតិកាត់ទោស តុលាការគឺកាត់ទោសប្រជាពលរដ្ឋនៅក្នុងប្រទេសរបស់ខ្លួន មិនមានបញ្ហាដែលលើកឡើងពីចៅក្រមប្រទេសមួយទៅកាត់សេចក្តីនៅប្រទេសមួយទេ ប៉ុន្តែការវិវត្តនៅក្នុងប្រវត្តិសាស្ត្របានធ្វើឲ្យសញ្ញាណនេះគឺទទួលនូវចំណុចដាក់ស្តែងថ្មីៗ ជាពិសេសគឺចាប់តាំងពីក្រោយសង្គ្រាមលោកលើកទី១ និងលើកទី២ ជាពិសេសលើកទី២ ។ កាលពីក្រោយសង្គ្រាមលោកលើកទី១ មុនសង្គ្រាមលោកលើកទី២ គឺមានការខិតខំដើម្បីបង្កើតឡើងនូវអ្វីដែលគេហៅថា អាយស៊ីស៊ីនោះ (International Criminal Court) គឺជាការរៀបចំជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិអចិន្ត្រៃយ៍ ប៉ុន្តែគេខិតខំតាំងពីមុនសង្គ្រាមលោកលើកទី២បានន័យថា ១៩៣៧ ឆ្នាំដាក់ស្តែងរហូតម៉ោដល់សព្វថ្ងៃនេះ ថ្មីៗនេះទើបស៊ីញ៉េបានទេនូវអ្វីដែលគេហៅថាអនុសញ្ញាដើម្បីប្រមូលផ្តុំគ្នា ប្រមូលផ្តុំប្រទេសដែលឯកភាពរៀបចំជាតុលាការឧក្រិដ្ឋកម្មអចិន្ត្រៃយ៍ ប៉ុន្តែតុលាការពុំទាន់រៀបបានទេបើគិតទៅតាំងពី១៩៣៧ម៉ោទល់សព្វថ្ងៃមិនទាន់រៀបចំចេញជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិអចិន្ត្រៃយ៍ទេ ព្រោះមានប្រទេសខ្លះនៅស្ទាក់ស្ទើរ គេមិនសូវដូចថាខិតខំរួមចំណែកនៅក្នុងការផាររហ្វឹងដែរ ដូច្នេះហើយក្រោយសង្គ្រាមលោកលើកទី២ នៅពេលដែលអាល្លឺម៉ង់និងជប៉ុនចាញ់សង្គ្រាមអ៊ីចឹង នៅពេលនោះមានការកកើតឡើងនូវតុលាការឧក្រិដ្ឋកម្មដើម្បីកាត់ទោសមេដឹកនាំអាល្លឺម៉ង់និងជប៉ុន ។ នៅប្រទេសអាល្លឺម៉ង់មានកកើតឡើងនូវតុលាការមួយដែលគេហៅថាតុលាការយោធាអន្តរជាតិ តុលាការយោធាអន្តរជាតិ ដែលជាភាសាអង់គ្លេសហៅថា International Military Tribunal បានកកើតនៅនូរ៉ាំប៊ែរប្រទេសអាល្លឺម៉ង់ ហើយការកកើតនោះ គឺតាំងពីសង្គ្រាមមិនទាន់ចប់រលត់ទាំងអស់នោះគឺគេបានរៀបចំ គេបានមានគំនិតបង្កើតតុលាការនេះហើយតាមរយៈកិច្ចព្រមព្រៀងនៅទីក្រុងឡុងថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥ ។ អ៊ីចឹងក្នុងឆ្នាំ៤៥-៤៦ គេបានរៀបចំបង្កើតតុលាការនេះដែលដាក់ឈ្មោះហៅថាជាតុលាការយោធានៅនូរ៉ាំប៊ែរ តុលាការនេះគេបានរៀបចំដោយប្រទេសឈ្នះសង្គ្រាមអ៊ីចឹងគេមិនដូចជាតុលាការរបស់យើងសុទ្ធសាធទេ ចំណុចនេះហើយដែលទូលបង្គំខ្ញុំបាទនិងធ្វើការគូសបញ្ជាក់ជាក្រោយ ។ ជាពិសេសប្រទេសសម្ព័ន្ធមិត្ត មានសហរដ្ឋអាមេរិក មានបារាំង មានអង់គ្លេស មានអតីតសូវៀត អ៊ីចឹងគេរៀបចំជាតុលាការនេះឡើងដើម្បីកាត់ទោសមេដឹកនាំហ្វាស៊ីសអាល្លឺម៉ង់ដែលជាអ្នកបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមធំជាងគេ អ៊ីចឹងនៅក្នុងការកាត់ក្តីតុលាការនូរ៉ាំប៊ែរ គេកាត់បាន ២៤នាក់ ។ នៅក្នុងនោះមានអ្នករួចខ្លួន ខ្លះមានអ្នកត្រូវប្រហារជីវិត មានអ្នកត្រូវជាប់គុកម៉ាជីវិត មានអ្នកត្រូវជាប់គុក១០ទៅ២០ឆ្នាំឧទាហរណ៍ ប៉ុន្តែតុលាការនេះអ្វីដែលទូលបង្គំចង់បញ្ជាក់គឺថាជាការរៀបចំដោយអ្នកច្បាប់របស់ប្រទេសឈ្នះដើម្បីកាត់ទោសអ្នកចាញ់ អ៊ីចឹងអ្នកចាញ់អត់មានអ្នកការពារខ្លួនទេ គឺជាតុលាការដែលដាក់ចេញពីខាងក្រៅដើម្បីកាត់ទោសមេដឹកនាំឧក្រិដ្ឋកម្មរបស់អាល្លឺម៉ង់ហ្វាស៊ីសដែលបានបង្កសង្គ្រាមលោកលើកទី២ ។ ហើយតុលាការមួយទៀត នៅក្នុងអំឡុងឆ្នាំក្រោយសង្គ្រាមលោកលើកទី២នេះ ជាពិសេសគឺថាពី៤៦មកដល់៤៩ បានន័យថាក្រោយនូរ៉ាំប៊ែរបន្តិច មានតុលាការមួយទៀតគេដាក់ឈ្មោះហៅថាតុលាការអន្តរជាតិសម្រាប់ចុងបូព៌ា តុលាការអន្តរជាតិសម្រាប់ចុងបូព៌ានេះគឺរៀបចំនៅទីក្រុងតូក្យូ ដើម្បីកាត់ទោសមេដឹកនាំជប៉ុនក្នុងឧក្រិដ្ឋកម្មសង្គ្រាម ។ នៅក្នុងនូរ៉ាំប៊ែរឆ្លងតាមតុលាការនូរ៉ាំប៊ែរ គឺបានកំណត់នូវទោសដែលគេហៅថាឧក្រិដ្ឋកម្ម

ប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មសង្គ្រាមជាពិសេសជាសញ្ញាណ និងទស្សនាទាន ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម គឺក៏កើតឡើងតាំងពីសម័យនោះមក ។ នៅជប៉ុន តុលាការយោធាអន្តរជាតិនៅជប៉ុនគឺរៀបចំកាត់សេចក្តីបាន២៨នាក់ អ្នកដែលត្រូវកាត់សេចក្តីនោះ ។ ហើយគេបានបង្កើតឡើងនូវសញ្ញាណឧក្រិដ្ឋកម្មនៃការទទួលខុសត្រូវជាបុគ្គលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ហើយនិងប្រល័យពូជសាសន៍តាមរយៈតុលាការនៅជប៉ុន ។ ប៉ុន្តែតុលាការនេះក៏ដូច្នោះដែរ រៀបចំឡើងដោយប្រទេសឈ្នះសង្គ្រាម មានតុលាការមួយទៀត ក្រោយពីនេះទៀតយូរអង្វែងមក គឺមានតុលាការនៅយូហ្គោស្លាវី ដែលគេហៅថាតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងរ៉ាន់ដា ។ អតីតតុលាការសម្រាប់យូហ្គោស្លាវីនេះ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនេះ គឺកើតឡើងនៅឆ្នាំ១៩៩៣ ហើយតាំងនៅទីក្រុងឡាអេ ដែលគេហៅថា ឌឺ ហេក មិនមែននៅយូហ្គោស្លាវីទេ ហើយក៏ជាការរៀបចំឡើងដោយអ្នកច្បាប់បរទេសដែរ ។ តុលាការនៅរ៉ាន់ដាគឺមានពីរផ្នែកមានផ្នែកតុលាការអន្តរជាតិ ហើយមិនមែនតាំងទីនៅក្នុងប្រទេសរ៉ាន់ដាទេ គឺនៅក្នុងប្រទេសតង់ហ្សានី ដើម្បីកាត់ទោសមេដឹកនាំរ៉ាន់ដា ហើយនៅក្នុងការកាត់ទោសនេះគឺគេអាចសន្និដ្ឋានថា ដូចដែលយើងបានឃើញរហូតមកដល់សព្វថ្ងៃគឺគេបានរៀបចំកាត់ទោស៤៥ករណីហើយ ជាមេដឹកនាំកម្រិតជាន់ខ្ពស់ ទន្ទឹមនឹងនេះមានតុលាការមួយទៀតដែលរ៉ាន់ដារៀបចំឡើងដោយខ្លួនឯង គេហៅថាតុលាការជាតិរ៉ាន់ដា គឺសម្រាប់កាត់ទោសអ្នកដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះដែរ ប៉ុន្តែថ្នាក់ក្រោម តែចំនួនច្រើនណាស់ ចំនួនអ្នកដែលត្រូវកាត់ទោសហើយត្រូវចាប់ដាក់ឃុំឃាំងនោះមានដល់ទៅ១២ម៉ឺននាក់ៗ ហើយដែលសព្វថ្ងៃនេះគឺថាការងារនេះគឺទទួលស្គាល់ថាលំបាកធ្វើដែរព្រោះត្រូវកាត់ទោសពីរដណ្តប់ម៉ឺននាក់ អ៊ីចឹងហើយមានការកែសម្រួលជាបន្តបន្ទាប់ ។ ឧទាហរណ៍ កែសម្រួលទៅជារូបភាពកាត់ទោសតាមលក្ខណៈប្រជាប្រិយនៅតាមភូមិ ការផ្តោលទោសរបស់ប្រជាពលរដ្ឋអីជាដើម ។

ចំណុចមួយដែរ ដែលយើងទទួលស្គាល់ថាជាតុលាការកាត់ទោសឧក្រិដ្ឋកម្មដែរគឺបានរៀបចំឡើងនៅកម្ពុជាឆ្នាំ១៩៧៩ ដើម្បីកាត់ទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់ខ្មែរក្រហមដែលនៅពេលនោះយើងបានកាត់ទោសមេដឹកនាំខ្មែរក្រហមពីរនាក់ ។ តុលាការមួយទៀតដែលទូលបង្គំយើងខ្ញុំបាទបានលើកឡើងអម្បាញ់មិញដែលគេហៅថា អាយស៊ីស៊ី នេះជា អ៊ិនធើណេសិនណលក្រែមមីណល ខត (International Criminal Court) នេះដែលគេខិតខំរៀបចំតាំងពីឆ្នាំ១៩៣៧ ដល់ឥឡូវនេះគេទើបតែឈានមកដល់ប្រមូលការឯកភាពបានពីប្រទេសចំនួនប្រហែលជាងហុកសិប ហើយគឺអាចថាទៅអនាគតគេនឹងខិតខំរៀបចំឲ្យទៅជាតុលាការអចិន្ត្រៃយ៍ បានន័យថាមិនចាំមានតុលាការពិសេសដូចជាតុលាការនូរ៉ាំប៊ែរ តុលាការនៅតូក្យូ មិនបាច់មានតុលាការពិសេសនៅរ៉ាន់ដា នៅអតីតយូហ្គោស្លាវីទៀតទេ ប្រសិនណាជាមានតុលាការអចិន្ត្រៃយ៍ តុលាការឧក្រិដ្ឋកម្មអចិន្ត្រៃយ៍នេះ ហើយគេសង្ឃឹមថាអាចនឹងមាននៅពេលអនាគត ហើយប្រហែលជាតាំងទីនៅទីក្រុងឡាអេ ។ នេះជាករណីជាប្រវត្តិដែលទូលបង្គំយើងខ្ញុំបានរៀបរាប់ជាសង្ខេបថាមានជាតុលាការ ដូចជាសម្រាប់កាត់ទោសឧក្រិដ្ឋកម្មនៃឧក្រិដ្ឋកម្មនោះ ឧក្រិដ្ឋកម្មដែលធ្ងន់ធ្ងរខ្លាំងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាបទប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាពជាដើម ដែលសញ្ញាណដែលទស្សនាទានទាំងនេះគឺចេញអំពីការងាររបស់តុលាការពិសេសអម្បាលម៉ានដែលទូលបង្គំខ្ញុំបាទបានលើកឡើង ប៉ុន្តែតុលាការទាំងនេះបើយើងប្រៀបធៀបនឹងអ្វីដែលយើងកំពុងធ្វើគឺមិនដូចគ្នាទេ ។ មួយផ្នែកដែលយើងរៀបរាប់គឺជាតុលាការដែលមានការរៀបចំពីខាងក្រៅដើម្បីកាត់ទោសអ្នកដែលប្រជាពលរដ្ឋ ឬក៏អ្នកដែលដឹកនាំប្រទេសនៅក្នុងប្រទេសមួយ ហើយបើយើងប្រៀបធៀបអ្វីដែលយើងកំពុងធ្វើទៅនឹងតុលាការទាំងនោះយើងឃើញថា យើងមានលក្ខណៈថ្មីមានលក្ខណៈជាលើកដំបូងគេនៅលើសកលលោក នៅលើឆាកអន្តរជាតិ ព្រោះជាតុលាការដែលរៀបចំឡើងមានការឯកភាពពីម្ចាស់ផ្ទះពីយើងផ្ទាល់ ថ្ងៃនេះរដ្ឋសភា បើសិនច្បាប់នេះត្រូវបានរដ្ឋសភាអនុម័តហើយមានឆ្លងតាមនីតិវិធីហូរហែរទៅ... ***(នៅមានត)***

# រូបថតក្របមុខ

*ផ្ញើជូនលោក ឆាំង យុ ជាទីរាប់អាន*

*ជាបឋម ខ្ញុំមានសេចក្តីរីករាយណាស់ដែលលោកជ្រើសយករូបថតដែលខ្ញុំថតមកប្រើប្រាស់នៅលើក្របមុខនៃទស្សនាវដ្តីស្វែងរកការពិត លេខនេះ ។ ខ្ញុំសូមស្ងើចសរសើរដោយស្មោះចំពោះកិច្ចការរបស់លោក និងសូមចូលរួមជួយជំរុញកិច្ចការនេះតាមតែខ្ញុំអាចធ្វើទៅបាន ។*

*ខ្ញុំសូមជម្រាបជូនជាលម្អិតអំពីរូបថតនេះ ។ ខ្ញុំបានថតរូបនេះនៅខែធ្នូ ឆ្នាំ១៩៧៨ គឺពីរសប្តាហ៍មុនពេលមានការវាយលុករបស់វៀតណាម ។ ពេលនោះក្រុមរបស់ខ្ញុំកំពុងស្ថិតនៅក្នុងតំបន់ក្រែកជិតព្រំប្រទល់កម្ពុជា-វៀតណាម គឺជិតផ្លូវជាតិលេខ៧ ដែលនៅពេលនោះត្រូវបានស្គាល់ជាទូទៅថាភូមិភាគបូព៌ា ។ សមមិត្ត ពីន ឈរនៅផ្នែកខាងក្រោយក្នុងរូបថត ។ សមមិត្ត ពីន មិនត្រឹមតែជាមេដឹកនាំនៅភូមិភាគបូព៌ាទេ ប៉ុន្តែថែមទាំងធ្វើការជាមួយនឹងកងសន្តិសុខដែលមានការិយាល័យនៅគុកទួលស្លែងទៀតផង ។ នៅផ្នែកខាងមុខនៃរូបថត មានយុទ្ធជនវ័យក្មេងៗដែលខ្ញុំសន្មតថាបានវាយប្រយុទ្ធគ្នានៅពេលដែលវៀតណាមចូលមកលុកលុយប្រទេសកម្ពុជាពីរសប្តាហ៍ក្រោយមកទៀត ។*

*ក្រុមខ្ញុំគឺជាអ្នកកាសែតលោកខាងលិចមុនដំបូងបង្អស់និងក្រោយបង្អស់ដែលបានឃើញប្រទេសកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងអំណាចរបស់ ប៉ុល ពត និងឃើញសមរភូមិពិតៗជាកន្លែងដែលកងទ័ពវៀតណាមនិងខ្មែរក្រហមបានវាយប្រយុទ្ធគ្នានៅរដូវប្រាំងនាពេលនោះ ។*

*ក្រុមខ្ញុំត្រូវបានឃ្លាំមើលយ៉ាងប្រុងប្រយ័ត្នជាទីបំផុត ។ ខ្ញុំបានឮសំឡេងគ្រាប់ផ្លោងពីចម្ងាយនៅម្តុំព្រំដែនកម្ពុជា-វៀតណាម ។ ខ្ញុំបានឃើញផ្សែងគ្រាប់កាំភ្លើងមីរដេដាសដែលត្រូវបានកម្ទាំងប្រដាប់អាវុធទាំងសងខាងផ្លោងដាក់គ្នាទៅវិញទៅមក ។ ក្រោយមកសមរភូមិប្រែជាស្ងាត់សូន្យឈឹង ។ ខ្ញុំឃើញមានមនុស្សពីរ-បីនាក់តែប៉ុណ្ណោះនៅតាមផ្លូវឬនៅសមរភូមិប្រយុទ្ធ ។*

*សមមិត្ត ពីន ចង់បង្ហាញថាខ្មែរក្រហមកំពុងតែកាន់កាប់តំបន់ក្រែក និងបម្រុងវាយបណ្តេញអ្នកឈ្លានពានវៀតណាម ។ សមមិត្ត ពីន និយាយថា បក្សបាន«កម្ចាត់»«ភ្នាក់ងារវៀតណាមដែលលួចជ្រៀតចូលមក» ។ នេះជាអ្វីដែលខ្ញុំយកធ្វើជាឯកសារយោងចំពោះការកាប់សម្លាប់ជាទ្រង់ទ្រាយធំទៅលើកម្មាភិបាលភូមិភាគបូព៌ា ។*

*វៀតណាមបានកាន់កាប់តំបន់ក្រែកពីរសប្តាហ៍បន្ទាប់មក ។ នៅពេលនោះខ្ញុំនៅជាមួយអ្នកកាសែតលោកខាងលិច៣នាក់គឺ ម៉េល ខូម, ខាដ វើល និង ឌីក ដូមែន ។ ជាច្រើនយប់ក្រោយមកទៀត ក្រុមខ្ញុំក៏បានទទួលការវាយប្រហារ(ដោយអាចកំបាំងពីសំណាក់ពួកខ្មែរក្រហម) នៅឯផ្ទះសំណាក់មួយស្ថិតនៅទីក្រុងភ្នំពេញ ហើយបណ្ឌិត ខាដ វើល ក៏ត្រូវបានធ្វើឃាត ។*

*មូលហេតុដែលខ្ញុំថតរូបមួយសន្លឹកនេះពីព្រោះទាហានទាំងអស់នៅក្នុងរូបថត មើលទៅហាក់ដូចជាតំណាងឲ្យកងកម្លាំងដែលព្យាយាមការពារប្រទេសទប់ទល់នឹងអ្វីដែលយើងដឹងជាទូទៅថាជាការឈ្លានពានទ្រង់ទ្រាយធំរបស់វៀតណាម ។ ចំពោះរូបខ្ញុំ ទាហានទាំងនេះមានវ័យក្មេងៗនិងមិនសូវមានអាវុធទំនើបធំដុំដើម្បីឲ្យខ្លួនអាចដេញកងទ័ពវៀតណាមឲ្យចេញពីប្រទេសបានឡើយ ។*

*នៅឆ្នាំក្រោយខ្ញុំសង្ឃឹមថានឹងបានមកលេងប្រទេសកម្ពុជាម្តងទៀត ។ ជួបគ្នាឆ្នាំក្រោយ ។ សូមជូនពរគ្រប់ប្រការ ។*

**អេលីហ្សាប៉ែត ប៉ែកឃ័រ** *(អ្នកនិពន្ធសៀវភៅ «នៅពេលដែលសង្គ្រាមបានរលត់ទៅ»)*

# ទស្សនាវដ្ដី ស្វែងរកការពិត ឆ្នាំ២០០០



១



២



៣





៥



៦



៧





៩



១០



១១



ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា

ទស្សនាវដ្ដីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number13, January 2001
Funded by the Royal Ministry of Foreign Affairs,Oslo, Norway, Section for the Human Rights and Humanitarian Assistance; the Canada Funds, Canadian Embassy,Phnom Penh; the Swedish International Development Cooperation Agency (Sida), Embassy of Sweden, Phnom Penh; and the Royal Netherlands Government, *The Hague*.